# ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ

## ភាគទី ៧

## សមុច្ចយសង្គហវិភាគ

រៀបរៀងដោយៈ ភិក្ខុ អគ្គចិត្តោ យ៉ុន យី

ព.ស.២៥៦៦

# មាតិកា

វត្ថុធម៌ ៧២ ប្រការ ....................................................០១
និយមន័យសមុច្ចយ....................................................០១
**១.អកុសលសង្គហមាន ៩ កង** ....................................................០២
អាសវៈ ៤ .................................................... ០៧
ធម៌លះបង់អាសវៈ ៤ ....................................................១០
ឱឃៈមាន ៤ ....................................................១០
ធម៌លះបង់ឱឃៈ ៤ ....................................................១១
យោគៈមាន ៤ ....................................................១២
ធម៌លះបង់យោគៈ ៤ .................................................... ១៣
គន្ថៈមាន ៤ .................................................... ១៣
ធម៌លះបង់គន្ថៈ ៤ ....................................................១៥
ភាពផ្សេងគ្នារវាងអភិជ្ឈានិងព្យាបាទដែលជាមនោទុច្ចរិតនិងគន្ថៈ ១៥
ឧបាទាន ៤....................................................១៦
ធម៌លះបង់ឧបាទាន ៤....................................................១៩
នីវរណៈ ៦....................................................១៩
ធម៌លះបង់នីវរណៈ ៦.................................................... ២២
កម្រិត ៣ របស់កិលេស....................................................២៤
ប្រៀបកិលេស ៣ កម្រិតជាមួយឈើគូស ....................................................២៥
អនុសយ ៧ ....................................................២៥

ការលះកិលេស ៣ ....................................................២៦
ធម៌លះបង់អនុសយ ...............................................២៦
សំយោជនៈមាន ១០ ...............................................២៦
ធម៌លះបង់សំយោជនៈ១០ ........................................ ៣១
សំសារវដ្តៈ ៣....................................................... ៣១
កិលេស ១០ យ៉ាង ................................................... ៣៥
កិលេសដោយពិស្តារ ១៥០០.......................................៣៧
តណ្ហា ១០៨ ............................................................ ៣៨
ធម៌លះកិលេស ១០ ................................................ ៣៨
សរុបអង្គធម៌ក្នុងអកុសលធម៌ ៩ កង ......................... ៣៨
តារាងអកុសលធម៌ ៩ កង .........................................៤០
**២.មិស្សកសង្គហៈ**...................................................៤១
ហេតុមាន ៦ .........................................................៤២
ឈានង្គមាន ៧ .................................................... ៤៣
ឈាន ព្រោះមាន ២ ន័យ ........................................ ៤៣
ឈានដុតបដិបក្ខធម៌...............................................៤៥
មគ្គង្គមាន ១២.......................................................៤៦
សម្មាទិដ្ឋិចែកជា ២..................................................៤៦
សម្មាសង្កប្បៈ ...................................................... ៤៧
កុសលវិតក្កៈ ៣ ប្រការ.............................................. ៤៧

សម្មាវាចា ........................................ ៤៧
វៀរចាកសម្តី ៤ យ៉ាង ........................................ ៤៧
សម្មាកម្មន្តៈ ........................................ ៤៨
វៀរចាកកាយកម្ម ៣ ........................................ ៤៨
សម្មាអាជីវៈ ........................................ ៤៨
វៀរចាកបាបធម៌ ៥ ........................................ ៤៨
អានេសនៈមាន ២១ ........................................ ៤៩
ជំនួញដែលគ្រហស្ថមិនត្រូវធ្វើមាន ៥ ........................................ ៥០
សម្មាវាយាម ........................................ ៥១
បធាន ៤ យ៉ាង ........................................ ៥១
ឥន្ទ្រិយ ២២ ........................................ ៥៣
ចែកឥន្ទ្រិយ ២២ ដោយភូមិ ........................................ ៥៧
ចែកឥន្ទ្រិយ ២២ ដោយកុសលតិកៈ ........................................ ៥៨
ចែកឥន្ទ្រិយ ២២ ដោយរូប និងនាម ........................................ ៥៨
ចែកឥន្ទ្រិយ ២២ ដោយហេតុ និងនហេតុ ........................................ ៥៨
ចែកឥន្ទ្រិយ ២២ ដោយសហេតុក និងអហេតុក ........................................ ៥៩
ចែកឥន្ទ្រិយ ២២ ដោយខន្ធ ........................................ ៦០
ចែកឥន្ទ្រិយ ២២ ដោយអាយតនៈ ........................................ ៦០
ចែកឥន្ទ្រិយ ២២ ដោយធាតុ ........................................ ៦១
ចែកឥន្ទ្រិយ ២២ ដោយភព ........................................ ៦១

ចែកឥន្ទ្រិយ ២២ ដោយកំណើត ៤ ........................................ ៦១
ពួកកាមសុគតិឱបបាតិកៈ ........................................ ៦២
ពួកទុគ្គតិគព្ភសេយ្យកៈ ........................................ ៦២
ពួកសុគតិគព្ភសេយ្យកៈ ........................................ ៦៣
ពួកអសញ្ញសត្តព្រហ្ម ........................................ ៦៣
ពលៈ ៩ ........................................ ៦៥
អធិបតី ៤ ........................................ ៦៦
ភាពជាធំមាន ២ យ៉ាង ........................................ ៦៨
អាហារ ៤ ........................................ ៧០
វដ្តៈមាន ៣ យ៉ាង ........................................ ៧០
ភ័យក្នុងអាហារ ៤ យ៉ាង ........................................ ៧៥
**៣.ពោធិបក្ខិយសង្គហៈ** ........................................ ៧៦
សតិប្បដ្ឋាន ៤ ........................................ ៧៨
ហេតុ និងផលនៃសតិប្បដ្ឋាន ៤ ........................................ ៨០
អានិសង្សនៃការចម្រើនសតិប្បដ្ឋាន ........................................ ៨០
សតិប្បដ្ឋានសូត្រ (ឧទ្ទេសវារកថា) ........................................ ៨១
សតិប្បដ្ឋាន ៣ យ៉ាង ........................................ ៨៧
ពាក្យថា ភិក្ខុ ........................................ ៨៧
អានាបានបព្វៈ ........................................ ៨៨
តម្កល់សតិ អានាបានស្សតិមាន១៦ វត្ថុ ........................................ ៩០

វិធីចម្រើនតាមវិសុទ្ធិមគ្គ ៨ យ៉ាង ........................................ ៩៦
ឥរិយាបថបព្វៈ ........................................ ៩៦
សម្បជញ្ញបព្វៈ ........................................ ៩៩
សម្បជញ្ញៈមាន ៤ យ៉ាង ........................................ ១០០
បដិកូលមនសិការបព្វៈ ........................................ ១០៧
អាការៈ ៣២ ប្រការ ........................................ ១០៧
ធាតុមនសិការបព្វៈ ........................................ ១០៩
មហាភូតរូបព្រោះហេតុ ៥ យ៉ាង ........................................ ១១២
បរិញ្ញា ៣ ........................................ ១១៥
នវសីវថិកាបព្វៈ ........................................ ១១៦
វេទនានុបស្សនាសតិប្បដ្ឋាន ........................................ ១១៨
ទ្រង់សម្ដែងវេទនា ៩ យ៉ាង ........................................ ១២៣
វេទនា ៥ យ៉ាង ........................................ ១២៧
ចិត្តានុបស្សនាសតិប្បដ្ឋាន ........................................ ១៣០
អង្គធម៌របស់ចិត្តានុបស្សនាសតិប្បដ្ឋាន ........................................ ១៣២
ធម្មានុបស្សនាសតិប្បដ្ឋាន ........................................ ១៣៥
នីវរណបព្វៈ ........................................ ១៣៥
ធម៌លះបង់កាមឆន្ទៈ ៦ ប្រការ ........................................ ១៤១
ធម៌សម្រាប់លះបង់ព្យាបាទ ........................................ ១៤២
ធម៌សម្រាប់លះបង់ថីនមិទ្ធៈ ........................................ ១៤៣

ធម៌សម្រាប់លះបង់ឧទ្ធច្ចកុក្កុច្ចៈមាន ៦ ប្រការ ...................... ១៤៤
ធម៌សម្រាប់លះវិចិកិច្ឆាមាន ៦ ប្រការ ................................ ១៤៤
ខន្ធបញ្ញៈ ............................................................ ១៤៥
អាយតនបញ្ញៈ ........................................................ ១៤៨
អាយតនៈដោយអត្ថ ១២ ........................................... ១៥១
អាយតនៈសព្វ ........................................................ ១៥២
អាយតនៈដោយបរិយាយ ..........................................១៥៣
អាយតនៈដោយសភាវៈ ............................................ ១៥៤
អាយតនៈដោយត្រៃលក្ខណ៍........................................១៥៧
ពោជ្ឈង្គៈ ៧ ..........................................................១៥៧
ហេតុនៃសតិសម្ពោជ្ឈង្គៈមាន ៤.................................. ១៥៨
ហេតុនៃធម្មវិចយសម្ពោជ្ឈង្គៈមាន ៧ .......................... ១៥៩
ហេតុនៃវីរិយសម្ពោជ្ឈង្គៈមាន ១១ ............................. ១៦០
ហេតុនៃបីតិសម្ពោជ្ឈង្គៈមាន ១១ .............................. ១៦១
ហេតុនៃបស្សទ្ធិសម្ពោជ្ឈង្គៈមាន ៧ ............................១៦២
ហេតុនៃសមាធិសម្ពោជ្ឈង្គៈមាន ១១ ..........................១៦៣
ហេតុនៃឧបេក្ខាសម្ពោជ្ឈង្គៈមាន ៥ ............................. ១៦៤
សច្ចបញ្ញៈ ............................................................ ១៦៥
ទុក្ខសច្ចៈ ............................................................ ១៦៦
សមុទយសច្ចៈ .........................................................១៧៤

ទុក្ខនិរោធសច្ចៈ ........ ១៨៤
មគ្គសច្ចៈ ........ ១៩៤
អង្គធម៌របស់សតិប្បដ្ឋាន ៤ ........ ២០៥
សតិប្បដ្ឋាន ៤ លះវិបល្លាស ៤ ប្រការ ........ ២០៥
សម្មប្បធាន ៤ ប្រការ ........ ២០៨
ឥទ្ធិបាទ ៤ ប្រការ ........ ២១០
ឥន្ទ្រិយ ៥ ប្រការ ........ ២១២
សទ្ធា ២ យ៉ាង ........ ២១៣
អង្គរបស់សោតាមាន ៤ ........ ២១៤
ពលៈមាន ៥ ប្រការ ........ ២១៥
ធម៌បដិបក្ខជាមួយពលៈ ៥ ប្រការ ........ ២១៦
ពោជ្ឈង្គៈមាន ៧ ........ ២១៦
មគ្គង្គៈ ........ ២១៩
សម្មាទិដ្ឋិមាន ៤ ប្រភេទ ........ ២១៩
សម្មាទិដ្ឋិមាន ៥ ប្រការ ........ ២២០
តារាងសរុបអង្គធម៌ពោធិបក្ខិយធម៌ ........ ២២៥
**៤.សព្វសង្គហៈ** ........ ២២៦
ខន្ធមាន ៥ យ៉ាង ........ ២២៦
និព្វានជាខន្ធវិមុត្តិព្រោះមិនមានប្រភេទផ្សេងគ្នា ........ ២២៩
ការបដិបត្តិក្នុងខន្ធ ........ ២២៩

ពិចារណាខន្ធដោយការប្រៀបធៀប ................................... ២៣០
ឧបាទានក្ខន្ធ........................................................................ ២៣០
អាយតនៈ១២ ...................................................................... ២៣១
អាយតនៈមានអត្ថ ៥ យ៉ាង..................................................២៣២
អង្គធម៌របស់អាយតនៈ.........................................................២៣៣
ធាតុ ១៨ ............................................................................. ២៣៦
កិច្ចបដិបត្តិក្នុងធាតុ ........................................................... ២៣៨
អរិយសច្ចៈ ៤ ..................................................................... ២៣៩
ឧបមាអរិយៈ ៤...................................................................២៤០
ទុក្ខសច្ចៈ ...........................................................................២៤២
ទុក្ខ ១២ កង .......................................................................២៤២
មរណៈមាន ៣ យ៉ាង ..........................................................២៤៥
កិច្ចបដិបត្តិក្នុងទុក្ខសច្ចៈ......................................................២៥០
សមុទយសច្ចៈ .....................................................................២៥២
សមុទយៈដោយសភាវៈ ៤ យ៉ាង ..........................................២៥២
ឧបមាទោសរបស់កាម១០ យ៉ាង ......................................... ២៥៣
និរោធសច្ចៈ.........................................................................២៥៤
ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ......................................២៥៥
ទុក្ខនិរោធគាមិនីបដិបទាដោយសភាវៈ ៤ យ៉ាង ....................២៥៦
អង្គធម៌មគ្គអង្គ ៨ ...............................................................២៥៨

អង្គធម៌របស់អរិយសច្ចៈ ៤ ..................................................២៥៨
ហេតុ និងផលជាដើមរបស់អរិយសច្ចៈ ៤..............................២៥៨
សុញ្ញតាក្នុងសច្ចៈ ...............................................................២៦០
អរិយសច្ចៈដោយចតុក្កៈ ..................................................... ២៦៣
អរិយសច្ចៈដោយអត្ថៈ.........................................................២៦៦
តារាងសព្វសង្គហៈ...............................................................២៦៩
អ្នកពិនិត្យ ............................................................................ ២៧០
ឯកសារពិគ្រោះ ................................................................... ២៧១

# បុព្វកថា

ខ្ញុំព្រះករុណាអាត្មាភាព ភិក្ខុអគ្គចិត្តោ **យ៉ុន យី** បានរៀបចំសៀវភៅនេះឡើង ដែលមានចំណងជើង **ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ** ដោយសារ ខ្ញុំព្រះករុណាអាត្មាភាពមានសេចក្តីជ្រះថ្លាក្រៃលែង បន្ទាប់ពីបានសិក្សាព្រះអភិធម្ម ដែលអាចយកមកអប់រំ ប្រតិបត្តិប្រចាំថ្ងៃ។ ដូច្នេះបានជាមានគំនិតចង់ផ្សព្វផ្សាយ ព្រះអភិធម្មទៅដល់ពុទ្ធបរិស័ទទាំងឡាយឱ្យបានយល់ដឹងមេរៀនរបស់ព្រះសម្ពុទ្ធ ឱ្យកាន់តែទូលំទូលាយដល់ពុទ្ធសានិកជន។

ក្នុងបរិច្ឆេទទី ៧ នេះ មានមេរៀនសំខាន់ច្រើនដែលគួរដល់ការសិក្សា ដោយសង្ខេបមានវត្ថុធម៌ ៧២ ប្រការគឺ ចិត្ត ១ ចេតសិក ៥២ និប្ផន្នរូប ១៨ និព្វាន ១ ដែលជាគោលសំខាន់ក្នុងសៀវភៅនេះ។

**វត្តមណីរតនារាម** ថ្ងៃសុក្រ ៩ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័កព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២២

**ភិក្ខុអគ្គចិត្តោ យ៉ុន យី**

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរព្រះគុណនិងអរគុណចំពោះ៖

១.ព្រះឧបជ្ឈាយ៍ ពោធិវង្សាវិមល **អ៊ុក ជុំ**

២.លោកម្ចាស់គ្រូព្រះភិក្ខុវជិរប្បញ្ញោ **សាន សុជា**

៣.ព្រមទាំងលោកគ្រូដទៃៗទៀត ដែលបានធ្លាប់ជួយបង្ហាត់បង្រៀនកន្លងមក។

៤.សូមអរគុណចំពោះញោម ប្រុស **ចេង យ៉ុន** និងញោមស្រី **ម៉េង ង៉ា** និងលោកយាយ **ចេង ចិន** ជា យាយរបស់ខ្ញុំយ៉ាងក្រៃលែង ដែលបានដឹកនាំខ្ញុំឱ្យបានបួសក្នុងព្រះពុទ្ធសាសនាដ៏ប្រសើរនេះ។

៥.ព្រមទាំងសូមអនុមោទនា ចំពោះទឹកចិត្តជ្រះថ្លារបស់ញាតិញោមទាំងឡាយដែលមានសទ្ធាជ្រះថ្លាឧបត្ថម្ភធម្មទានសៀវភៅនេះ។

ប្រសិនបើមានកំហុសឆ្គង ចំពោះអក្ខរាវិរុទ្ធក្នុងសៀវភៅនេះ ក្រែងពិនិត្យមិនបានអស់សេចក្ដី ឬយល់សេចក្ដីនៃពុទ្ធវចនៈមិនអស់ សូមអភ័យទោសនិងអត់ទោសអំពីសំណាក់វិញ្ញូជនទាំងឡាយផង។

# ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ

**Abhidhamma in Daily Life**

# បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ

## វត្ថុធម៌ ៧២ ប្រការ

**វត្ថុធម៌** សំដៅយកធម៌ដែលមានអង្គធម៌បរមត្ថរបស់ខ្លួនអាចប្រាកដដល់បញ្ញាបាន។

## វត្ថុធម៌ ៧២ ប្រការ

ក.**ចិត្ត១** ចិត្តមានលក្ខណៈម្យ៉ាង គឺ**អារម្មណវិជាននលក្ខណំ** មានការដឹងអារម្មណ៍ ជាលក្ខណៈ។

**ខ.ចេតសិក ៥២** មានសភាវៈរបស់ខ្លួនទាំង ៥២។

**គ.និប្ផន្នរូប ១៨** យកតែនិប្ផន្នរូបប៉ុណ្ណោះ ព្រោះសម្រេចពីសមុដ្ឋាន ៤ (កម្ម ចិត្ត ឧតុ អាហារ)។

**ឃ.**និព្វាន ១ គឺ **សន្តិលក្ខណំ** មានភាពស្ងប់ ជាលក្ខណៈ។

**សមុច្ចយ** (**សំ+ឧច្ចយ**) ការរួបរួមចូលជាមួយគ្នា ឬធម៌ដែលមានសភាពចូលគ្នាបាន។

## វចនត្ថៈ សមុច្ចយ

**សហ ឧច្ចីយន្តេ ឯត្ថាតិ** = **សមុច្ចយោ** (វា) **សម្បិណ្ឌេត្វា ឧច្ចីយន្តេ ឯតេនាតិ** = **សមុច្ចយោ** បរិច្ឆេទដែលឈ្មោះថា **សមុច្ចយ** ព្រោះជាបរិច្ឆេទដែលសម្តែងរួបរួមនូវបរមត្ថធម៌ទាំង ៤ ប្រការព្រមគ្នា ឬបរិច្ឆេទដែលឈ្មោះថា **សមុច្ចយ**

ព្រោះជាហេតុនៃការសម្តែងរួបរួមនូវបរមត្ថធម៌ ដែលមានសភាពចូលគ្នាឱ្យជាពួកៗ។

## សមុច្ចយសង្គហមាន ៤ មាតិកា

**១.អកុសលសង្គហៈ** សង្គ្រោះអកុសល ៩ កង

**២.មិស្សកសង្គហៈ** សង្គ្រោះមិស្សកធម៌មាន ៧

**៣.ពោធិបក្ខិយសង្គហៈ** សង្គ្រោះពោធិបក្ខិយធម៌ ៣៧

**៤.សព្វសង្គហៈ** សង្គ្រោះធម៌ទាំងពួងមាន ៥ ។

## ១.អកុសលសង្គហមាន ៩ កង

### ១.អាសវៈ ៤ (Taints)

១.**កាមាសវៈ** គ្រឿងដេកត្រាំ គឺកាម

The taint of sensual desire

២.**ភវាសវៈ** គ្រឿងដេកត្រាំ គឺភព

The taint of (attactment to) existence

៣.**ទិដ្ឋាសវៈ** គ្រឿងដេកត្រាំ គឺទិដ្ឋិ

The taint of wrong views

៤.**អវិជ្ជាសវៈ** គ្រឿងដេកត្រាំ គឺអវិជ្ជា។

The taint of ignorance

### ២.ឱឃៈ ៤

**Floods**

១.**កាមោឃៈ** អន្លង់ គឺកាម (The flood of sensual desire)

២. **ភវោឃៈ** អន្លង់ គឺភព (The flood of (attachment to) existence)

៣.**ទិដ្ឋោឃៈ** អន្លង់ គឺទិដ្ឋិ (The flood of wrong views)

៤.**អវិជ្ជោឃៈ** អន្លង់ គឺអវិជ្ជា។ (The flood of ignorance)

### ៣.យោគៈ ៤ (Bonds)

១.**កាមយោគ** គ្រឿងប្រកបគឺ កាម
The bond of sensual desire

២.**ភវយោគៈ** គ្រឿងប្រកបគឺ ភព
The bond of (attachment to) existence

៣.**ទិដ្ឋិយោគៈ** គ្រឿងប្រកបគឺ ទិដ្ឋិ
The bond of wrong views

៤.**អវិជ្ជាយោគៈ** គ្រឿងប្រកបគឺ អវិជ្ជា។
The bond of ignorance

### ៤.គន្ថៈ ៤ (Four Bodily knots)

១.**អភិជ្ឈាកាយគន្ថៈ** គ្រឿងចងកាយគឺ អភិជ្ឈា
The bodily knot of covetousness

២.**ព្យាបាទកាយគន្ថៈ** គ្រឿងចងកាយគឺ ព្យាបាទ
The bodily knot of ill will

៣.**សីលព្វតបរាមាសកាយគន្ថៈ** គ្រឿងចងកាយគឺ សីលព្វត-បរាមាសៈ
The bodily knot of adherence to rite and ceremonies

៤.**ឥទំសច្ចាភិនិវេសកាយគន្ថៈ** គ្រឿងចងកាយគឺ សេចក្តីប្រកាន់មាំថា វត្ថុនេះពិត។ The bodily knot of dogmatic belief.

### ៥.ឧបាទាន ៤ (Four Clingings)

១.**កាមុបាទាន** គ្រឿងប្រកាន់មាំក្នុងកាម

Clinging to sense pleasures
**២.ទិដ្ឋុបាទាន** គ្រឿងប្រកាន់មាំក្នុងទិដ្ឋិ
Clinging to wrong views
**៣.សីលព្វតុបាទាន** គ្រឿងប្រកាន់មាំក្នុងសីល និងវត្ត
Clinging to rites and ceremonies
**៤.អត្តវាទុបាទាន** គ្រឿងប្រកាន់មាំក្នុងវាទថាខ្លួន។
Clinging to a doctrine of self.

## ៦.នីវរណៈ ៦ (Six Hindrances)

**១.កាមឆន្ទៈ** សេចក្តីពេញចិត្តក្នុងកាម
The hindrance of sensual desire
**២.ព្យាបាទៈ** សេចក្តីប្រទូសរ៉ាយ
The hindrance of ill-will
**៣.ថីនមិទ្ធៈ** សេចក្តីងោកងក់ រួញរា
The hindrance of sloth and torpor
**៤.ឧទ្ធច្ចកុក្កុច្ចៈ** សេចក្តីរវើរវាយ ក្តៅក្រហាយ
The hindrance of restlessness and worry
**៥.វិចិកិច្ឆា** សេចក្តីសង្ស័យ
The hindrance of doubt
**៦.អវិជ្ជា** សេចក្តីមិនដឹង។ The hindrance of ignorance.

## ៧.អនុសយ ៧

## Seven Latent Despositions

**១.កាមរាគានុសយ** គ្រឿងដេកត្រាំគឺ កាម
The latent disposition to sensual lust
**២.ភវរាគានុសយ** គ្រឿងដេកត្រាំគឺ ភវរាគៈ
The latent disposition attachment to existence

**៣.បដិឃានុសយ** គ្រឿងដេកត្រាំគឺ បដិឃៈ

The latent disposition to aversion

**៤.មានានុសយ** គ្រឿងដេកត្រាំគឺ មានះ

The latent disposition to conceit

**៥.ទិដ្ឋានុសយ** គ្រឿងដេកត្រាំគឺ ទិដ្ឋិ

The latent disposition to wrong views

**៦.វិចិកិច្ឆានុសយ** គ្រឿងដេកត្រាំគឺ សង្ស័យ

The latent disposition to doubt.

**៧.អវិជ្ជានុសយ** គ្រឿងដេកត្រាំគឺ អវិជ្ជា។

The latent disposition to ignorance.

## ៨.សញ្ញោជន ១០ មាន ២ ន័យ

Ten Fetters enumerated in twofold.

### ១.សុត្តន្តន័យមាន ១០ គឺ

១.**សក្កាយទិដ្ឋិ** គ្រឿងចង គឺការប្រកាន់ខុសក្នុងកាយ

The fetter of wrong views

២.**វិចិកិច្ឆា** គ្រឿងចង គឺការសង្ស័យ

The fetter of doubt

៣.**សីលព្វតបរាមាស** គ្រឿងចង គឺការស្ទាបអង្អែលវត្តខុស

The fetter of adherence to rites and ceremonies

៤.**កាមឆន្ទៈ** គ្រឿងចង គឺការប្រាថ្នាក្នុងកាម

The fetter of sensual lust

៥.**ព្យាបាទៈ** គ្រឿងចង គឺការចងគំនុំ

The fetter of attachment to fine-material existence

៦.**រូបរាគៈ** គ្រឿងចង គឺការត្រេកអរក្នុងរូបភព

The fetter of attachment to immaterial existence

៧.**អរូបរាគៈ** គ្រឿងចង គឺការត្រេកអរក្នុងអរូបភព

The fetter of attachment to immaterial existence

៨.**មានះ** គ្រឿងចង គឺការលើកតម្កើងខ្លួន

The fetter of conceit

៩.**ឧទ្ធច្ចៈ** គ្រឿងចង គឺការរវើរវាយ

The fetter of restlessness

១០.**អវិជ្ជា** គ្រឿងចង គឺការវង្វេង ។

The fetter of ignorance.

## ២.អភិធម្មន័យមាន ១០ គឺ

១.**កាមរាគៈ** គ្រឿងចង គឺការត្រេកអរក្នុងកាម

២.**បដិឃៈ** គ្រឿងចង គឺការថ្នាំងថ្នាក់

៣.**មានះ** គ្រឿងចង គឺការលើកតម្កើងខ្លួន

៤.**ទិដ្ឋិ** គ្រឿងចង គឺការយល់ខុស

៥.**វិចិកិច្ឆា** គ្រឿងចង គឺការសង្ស័យ

៦.**សីលព្វតបរាមាសៈ** គ្រឿងចង គឺការស្ទាបអង្អែលវត្តខុស

៧.**ភវរាគៈ** គ្រឿងចង គឺការត្រេកអរក្នុងភព

៨.**ឥស្សា** គ្រឿងចង គឺការច្រណែន

៩.**មច្ឆរិយៈ** គ្រឿងចង គឺការកំណាញ់

១០.**អវិជ្ជា** គ្រឿងចង គឺការវង្វេង។

## ៩.កិលេស ១០

**The Ten Defilements**

**១.លោភកិលេស** គ្រឿងសៅហ្មងគឺ ជាប់ជំពាក់ Greed
**២.ទោសកិលេស** គ្រឿងសៅហ្មងគឺ ខឹងក្រោធ Hatred
**៣.មោហកិលេស** គ្រឿងសៅហ្មងគឺ វង្វេង Delusion
**៤.មានកិលេស** គ្រឿងសៅហ្មងគឺ លើកតម្កើង Conceit
**៥.ទិដ្ឋិកិលេស** គ្រឿងសៅហ្មងគឺ យល់ខុស Wrong views
**៦.វិចិកិច្ឆាកិលេស** គ្រឿងសៅហ្មងគឺ សង្ស័យ Doubt
**៧.ថីនកិលេស** គ្រឿងសៅហ្មងគឺ រួញរា Sloth
**៨.ឧទ្ធច្ចកិលេស** គ្រឿងសៅហ្មងគឺ រវើរវាយ Restlessness
**៩.អហិរិកកិលេស** គ្រឿងសៅហ្មងគឺមិនខ្មាសបាប Shamelessness
**១០.អនោត្តប្បកិលេស** គ្រឿងសៅហ្មងគឺ មិនតក់ស្លុតចំពោះបាប។ Fearlessness of wrongdoing.

## អធិប្បាយ

## ១.អាសវៈ ៤

**អាសវៈ** សំដៅយកគ្រឿងដេកត្រាំងដ៏យូរ ឧបមាដូចជាសុរាជាវត្ថុដែលត្រូវត្រាំយូរណាស់ ទើបបណ្តាលឱ្យអ្នកពិសាអាចស្រវឹងបាត់ស្មារតី អាចធ្វើអំពើដែលមិនគួរធ្វើបាន ដែលធ្វើឱ្យចិត្តស្រវឹងវង្វេង ភ្លេចស្មារតី ក្នុងអំណាច លោភៈខ្លះ ទិដ្ឋិខ្លះ មោហៈខ្លះជាហេតុឱ្យធ្វើទុច្ចរិតផ្សេងៗ។

## អាសវៈ កាត់បទជា ២ បទ

**អា + សវ = អាសវៈ អា** ប្រែថា វដ្តទុក្ខដ៏វែងឆ្ងាយមិនមានកំណត់។

**សវៈ** ប្រែថា ចម្រើនរុងរឿង រួមមក **អាសវៈ** ប្រែថា ធម៌ដែលធ្វើឱ្យវដ្ដទុក្ខដែលវែងឆ្ងាយមិនមានកំណត់នោះ ចម្រើនរុងរឿងមិនមានទីបំផុត។

អាសវៈនេះកាលរួម ២ បទចូលគ្នាហើយ កើតបាន ឬហូរទៅបានរហូតដល់ភវគ្គភូមិ ឬ គោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍។

**អាយតំ សំសារទុក្ខំ សវន្តិ បសវន្តិ ឋឡ្សន្តីតិ = អាសវា** ធម៌ទាំងឡាយណាធ្វើឱ្យវដ្ដៈដ៏យូរអង្វែងនោះ ចម្រើនរុងរឿង ធម៌ទាំងឡាយនោះ ឈ្មោះថា **អាសវៈ** (លោភៈ ទិដ្ឋិ មោហៈ)។

ធម្មតា **លោភ ទិដ្ឋិ មោហៈ** ទាំងនេះកើតឡើងដោយអាស្រ័យលោកិយធម៌ និងបញ្ញត្តិធម៌ ដែលសម្ដែងថា កើតបានរហូតដល់ ភវគ្គភូមិ ឬគោត្រភូនោះ មិនមានសេចក្ដីសម្ដែងពិសេសយ៉ាងណាទេ បានសេចក្ដីថា នេវសញ្ញានាសញ្ញាយតនភូមិក្ដី គោត្រភូញាណក្ដី ទាំងនេះរមែងជាលោកិយធម៌ ដូច្នេះទើបជាអារម្មណ៍របស់ **លោភ ទិដ្ឋិ មោហៈ**។ ដូចបរមត្ថទីបនីពោលថា៖

**ភវតោ អាភវគ្គា ធម្មតោ អាគោត្រភុម្ហា សវន្តិ អារម្មណករណវសេន បវត្តន្តីតិ = អាសវា** ធម៌ទាំងឡាយណា ហូរទៅដល់ ឬកើតបានដល់ ពោលដោយភូមិហើយ ដល់ភវគ្គភូមិ ពោលដោយធម៌ដល់គោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ ដូច្នេះទើបឈ្មោះថា **អាសវៈ**។

មែនពិត សូម្បីអកុសលចេតសិកដទៃៗ ដូចជា **អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ មានៈ** ក៏កើតបាន និងហូរទៅដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចធ្វើឱ្យជាអារម្មណ៍ដូចគ្នា តែព្រះពុទ្ធអង្គទ្រង់មិនបានចាត់អកុសលចេតសិកដទៃនោះៗ ជាអាសវៈ ទាំងនេះ ព្រោះ **លោភៈ ទិដ្ឋិ មោហៈ** ទាំង៣ នេះ មានសភាពទូលំទូលាយ និងប្រាកដច្បាស់ជាង អកុសលចេតសិកដទៃៗ ដូចពន្លឺដែលផ្សាយចេញពីដួងព្រះអាទិត្យ រមែងផ្សាយពន្លឺខ្លាំងជាងពន្លឺដទៃៗ ដូចជាពន្លឺដួងព្រះចន្ទ ឬដួងប្រទីប ដូច្នេះព្រះពុទ្ធអង្គទើបទ្រង់សម្តែង ធម៌ដែលជាគ្រឿងត្រាំ និងហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូចំពោះដែលប្រាកដច្បាស់ខ្លាំងបំផុត។

## អាសវៈមាន ៤ ប្រការ

**១.កាមាសវៈ** គ្រឿងដេកត្រាំ ឬហូរទៅក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ភវាសវៈ** គ្រឿងដេកត្រាំ ឬហូរទៅអាស្រ័យសេចក្តីត្រេកអរជាប់ ក្នុងអត្តភាពនៃខ្លួនក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤។

**៣.ទិដ្ឋាសវៈ** គ្រឿងដេកត្រាំ ឬហូរទៅអាស្រ័យសេចក្តីយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤។

**៤.អវិជ្ជាសវៈ** គ្រឿងដេកត្រាំ ឬហូរទៅអាស្រ័យសេចក្តីវង្វេង អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត១២។

## ធម៌លះបង់អាសវៈ ៤

- **កាមាសវៈ** លះដោយបញ្ញាក្នុងអនាគាមិមគ្គ
- **ភវាសវៈ** លះដោយអរហត្តមគ្គ
- **ទិដ្ឋាសវៈ** លះដោយសោតាបត្តិមគ្គ
- **អវិជ្ជាសវៈ** លះដោយអរហត្តមគ្គ។

## ២.ឱឃៈ ៤

ឱឃធម៌ សំដៅយកធម៌ដែលដូចជាអន្លង់ទឹក ព្រោះធម្មតាអន្លង់ទឹកកាលណាមានវត្ថុណាមួយ ឬសត្វណាមួយធ្លាក់ចូលក្នុងអន្លង់ទឹកហើយ ទឹកនោះតែង ក្ដួចពន្លិចពន្លង់បៀតបៀនវត្ថុឬសត្វនោះៗ ឱ្យលិចលង់មិនមានឱកាសនឹងងើប យ៉ាងណា **លោភៈ ទិដ្ឋិ មោហៈ** ក៏យ៉ាងនោះដែរ។

កាលសត្វទាំងឡាយត្រូវគ្របសង្កត់ដោយលោភ សេចក្ដីយល់ខុស និងសេចក្ដីល្ងង់នៅក្នុងវត្ថុដែលមិនមែនសារៈរមែងត្រូវអំណាចនៃអកុសលធម៌ទាំងនោះ ដឹកនាំឱ្យធ្វើទុច្ចរិតកម្មផ្សេងៗ នាំទៅកាន់អបាយភូមិ ជាភូមិខាងក្រោមហៅថា **ហេដ្ឋិមសង្សារ** រកឱកាសដើម្បីផុតចាកពីភូមិនោះលំបាកក្រៃលែង ឬមិនដូច្នោះ ក៏នឹងឱ្យជាប់ចិត្តនៅក្នុងការវិលវល់ កើតស្លាប់ក្នុងភូមិដែលមានសេចក្ដីសុខសប្បាយ ដែលជាសុគតិភូមិថ្នាក់កណ្ដាល ហៅថា **មជ្ឈិម-សង្សារ** ឬភូមិថ្នាក់ខ្ពស់ដែលហៅថា **ឧបរិមសង្សារ** នៅក្នុងភូមិផ្សេងៗ ដូចពោលមកនេះ សុទ្ធតែមិនផុតពីវដ្ដទុក្ខនោះឯង។

វចនត្ថៈថា **អវហនន្តីតិ ឱសីទាបេន្តីតិ = ឱឃា** ធម្ម ជាតិណារមែងធ្វើឱ្យសត្វលិចលង់ ធម្មជាតិនោះឈ្មោះថា **ឱឃៈ**។

## ឱឃៈមាន ៤ ប្រការ

**១.កាមោឃៈ** ធ្វើឱ្យសត្វលិចលង់ក្នុងកាមគុណារម្មណ៍ អង្គធម៌ បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ភវោឃៈ** ធ្វើឱ្យសត្វលិចលង់ដោយសេចក្តីត្រេកអរក្នុងរូបភព អរូបភព ឬរូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិក ក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៣.ទិដ្ឋោឃៈ** ធ្វើឱ្យសត្វលិចលង់ដោយសេចក្តីយល់ខុស អង្គធម៌ បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៤.អវិជ្ជោឃៈ** ធ្វើឱ្យសត្វលិចលង់ដោយសេចក្តីវង្វេង អង្គធម៌ បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២។

**ឱឃៈ** ទាំង ៤ នេះមានអង្គធម៌ត្រឹមតែ ៣ ប្រការប៉ុណ្ណោះ គឺ លោភចេតសិក ទិដ្ឋិចេតសិក មោហចេតសិក។

## ធម៌ដែលលះបង់ឱឃៈ ៤

**បញ្ញា** ក្នុងសោតាបត្តិមគ្គចិត្តលះ ទិដ្ឋោឃៈ

**បញ្ញា** ក្នុងអនាគាមិមគ្គចិត្តលះ កាមោឃៈ

**បញ្ញា** ក្នុងអរហត្តមគ្គចិត្តលះ ភវោឃៈនិង អវិជ្ជោឃៈ។

## ៣.យោគៈ ៤

**យោគធម៌** សំដៅយកគ្រឿងប្រកបដូចជាការស្អិត តែងប្រកបវត្ថុពីរផ្សេងគ្នា យ៉ាងណា **លោភៈ ទិដ្ឋិ មោហៈ** ប្រកបសត្វទាំងឡាយទុកស្អិតជាប់នៅនឹងវដ្តៈបាន។

វចនត្ថៈថា **វដ្ដស្មឹ សត្តេ យោជេន្តីតិ = យោគោ** ធម៌ទាំងឡាយណា ជាគ្រឿងប្រកបសត្វទុកឱ្យជាប់ក្នុងវដ្តទុក្ខ ឈ្មោះថា **យោគៈ**។

ឧបមាដូចគោដែលទឹមរទេះ កាលគោដើរទៅផ្លូវណា ក៏រមែងអូសរទេះជាប់តាមទៅជាមួយជានិច្ច សត្វទាំងឡាយដែលវិលវល់កើតស្លាប់នៅក្នុងសង្សារវដ្តទុក្ខក៏ដូចគ្នា រមែងវិលវល់ក្នុងវដ្តទុក្ខរួចផុតទៅមិនបាន ព្រោះត្រូវប្រកបទុក្ខដោយ **លោភៈ ទិដ្ឋិ មោហៈ** ប្រៀបដូចជាខ្សែទាមដែលចងគោជាប់ជាមួយរទេះ។ គោប្រៀបដូចសត្វទាំងឡាយ រទេះប្រៀបដូចភពផ្សេងៗ មានកាមភពជាដើម ខ្សែទាមដែលចងគោជាប់ជាមួយរទេះ គឺ **លោភៈ ទិដ្ឋិ មោហៈ** ជាយោគធម៌នោះឯង។

## យោគៈមាន ៤ ប្រការ

**១.កាមយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឱ្យជាប់ស្អិតក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ភវយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឱ្យជាប់ស្អិតក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន អង្គធម៌បានដល់លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៣.ទិដ្ឋិយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឱ្យជាប់ស្អិតក្នុងសេចក្ដីយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគត-សម្បយុត្តចិត្ត ៤។

**៤.អវិជ្ជាយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឱ្យជាប់ស្អិតក្នុងសេចក្ដីវង្វេង សេចក្ដីល្ងង់ អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២។

## ធម៌លះបង់យោគៈ៤

**បញ្ញា** ក្នុងសោតាបត្តិមគ្គចិត្តលះទិដ្ឋិយោគៈ

**បញ្ញា** ក្នុងអនាគាមិមគ្គចិត្តលះកាមយោគៈ

**បញ្ញា** ក្នុងអរហត្តមគ្គចិត្តលះភវយោគៈ និងអវិជ្ជាយោគៈ។

## ៤.គន្ថៈ

**គន្ថធម៌** គ្រឿងចងដោយអាការកៀវថ្លក់ ដែលប្រើក្នុងន័យនៃគន្ថៈ មិនមែនសំដៅយកការចងទុកធូរៗ ងាយរបូតស្រួលៗ នោះទេ គឺសំដៅយកការចាក់ស្រែះ ក្រងឆ្វាក់ទុកក្នុងលក្ខណៈកៀវថ្លក់ដូចច្រវាក់ដែលគ្មានកំណួច។

ធម្មតា ច្រវាក់ដែកនោះជាកងកៀវថ្លក់រណែងរណោងជាប់គ្នានិងគ្នាជាកម្រងយ៉ាងណា សភាវធម៌គឺ លោភៈ ទោសៈ និងទិដ្ឋិ

ទាំង៣ នេះ ក៏ជាគ្រឿងចាក់ស្រែះសត្វទុកក្នុងរវាងចុតិ និងបដិសន្ធិ ហើយបដិសន្ធិ និងចុតិ រណែងរណោងជាប់តគ្នា ជាកម្រងមិនងាយរបូតពីគ្នាបានក៏យ៉ាងនោះដែរ។

**កាយំ គន្ថេតីតិ** = **កាយគន្ថា វា កាយេន កាយំ គន្ថេតីតិ** = **កាយគន្ថា** ធម៌ទាំងឡាយណាចងគឺកៀវថ្កក់ទុកនូវនាមកាយ ធម៌ទាំងនោះឈ្មោះថា **កាយគន្ថៈ**។ ឬធម៌ទាំងឡាយណាចង គឺកៀវថ្កក់រវាងនាមកាយ រូបកាយក្នុងបច្ចុប្បន្នភព និងនាមកាយក្នុងអនាគតភពធម៌ទាំងនោះឈ្មោះថា **កាយគន្ថៈ**។

វចនត្ថៈតាមមូលដីកាថា៖ **គន្ថករណំ សន្ខលិកចក្កលិកានំ វិយ បដិពន្ធតាករណំ វា គន្ថនំ** = **គន្ថោ** ការដោតក្រង ឬចងព័ទ្ធឱ្យជាប់គ្នាដូចច្រវាក់នោះ ឈ្មោះថា **គន្ថៈ** ។

## គន្ថៈមាន ៤ ប្រការ

**១.អភិជ្ឈាកាយគន្ថៈ** ធម្មជាតិដែលចាក់ស្រែះដោតក្រងសត្វឆ្ងាក់នូវនាមកាយ និងរូបកាយក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ព្យាបាទកាយគន្ថៈ** ធម្មជាតិដែលចាក់ស្រែះដោតក្រងសត្វឆ្ងាក់នូវនាមកាយ និងរូបកាយដោយក្រោធខឹង អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសមូលចិត្ត ២។

**៣.សីលព្វតបរាមាសកាយគន្ថៈ** ធម្មជាតិដែលចាក់ស្រែះដោតក្រងសត្វឆ្ងាក់នូវនាមកាយ និងរូបកាយដោយស្ទាប

អង្ហែលសីលវត្ត អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្ត ចិត្ត ៤។

**៤.ឥទំសច្ចាភិនិវេសកាយគន្ថៈ** ធម្មជាតិដែលចាក់ស្រែះដោតក្រងសត្វឆ្ងាក់នូវនាមកាយ និងរូបកាយដោយប្រកាន់ខ្ជាប់ខុសថាត្រូវ អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្ត ចិត្ត ៤។

## ធម៌លះគន្ថៈ ៤

- **បញ្ញា** ក្នុងសោតាបត្តិមគ្គ លះសីលព្វតបរាមាសកាយគន្ថៈ និង ឥទំសច្ចាភិនិវេសកាយគន្ថៈ
- **បញ្ញា** ក្នុងអនាគាមិមគ្គ លះព្យាបាទកាយគន្ថៈ
- **បញ្ញា** ក្នុងអរហត្តមគ្គ លះអភិជ្ឈាកាយគន្ថៈ។

## ភាពផ្សេងគ្នារវាងអភិជ្ឈា និងព្យាបាទ ដែលជាមនោទុច្ចរិត និងគន្ថៈ

**១.អភិជ្ឈាមនោទុច្ចរិត** ជាសេចក្ដីលោភយ៉ាងគ្រោតគ្រោតមានភាពប្រាថ្នាចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ មកជាអារម្មណ៍របស់ខ្លួនៗ ដោយមិនត្រូវតាមធម៌។

**២.អភិជ្ឈាកាយគន្ថៈ** ជាសេចក្ដីលោភយ៉ាងគ្រោតគ្រោត និងយ៉ាងល្អិត ដែលទាក់ទងជាមួយនឹងសេចក្ដីចង់បាន និងសេចក្ដីពេញចិត្តក្នុងទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬរបស់ខ្លួនឯង ដោយត្រូវ

តាមធម៌ ឬមិនត្រូវតាមធម៌ក្តី សេចក្តីពេញចិត្តចង់បានទាំងអស់នេះ ជា **អភិជ្ឈាកាយគន្ថៈ** ទាំងអស់។

**៣.ព្យាបាទមនោទុច្ចរិត** ជាទោសៈយ៉ាងគ្រោតគ្រាត ដែលទាក់ទងនឹងសេចក្តីក្រោធ គិតប្រទូស្តអ្នកដទៃដោយបំណងឱ្យបានទទួលការបាត់បង់ផ្សេងៗ ឬគិតប្រទេចផ្តាសាឱ្យអ្នកដែលខ្លួនស្អប់ខ្ពើមនោះដល់នូវសេចក្តីវិនាស។

**៤.ព្យាបាទកាយគន្ថៈ** ជាទោសៈយ៉ាងគ្រោតគ្រាត និងល្អិត ដែលមានសភាពជាការមិនចូលចិត្ត មិនពេញចិត្ត ក្រោធ ស្អប់ កើតទុក្ខ ភ័យខ្លាច សោកសៅខូចចិត្ត រហូតដល់ការធ្វើទុច្ចរិតកម្មមានកាយទុច្ចរិតជាដើម។

## ៥.ឧបាទាន

**ឧបាទានធម៌** មានឧបមាដូចជា ពស់ដែលចាប់កញ្ចាញ់ចេក ឬកង្កែប រមែងខាំជាប់យ៉ាងណែនមិនព្រមលែង យ៉ាងណា **លោភៈ ទិដ្ឋិ** រមែងប្រកាន់មាំអារម្មណ៍មិនព្រមលែង។

**វចនត្ថថាៈ ឧបាទីយន្តីតិ = ឧបាទានានិ** ធម៌ទាំងឡាយណា រមែងប្រកាន់យកមាំក្នុងអារម្មណ៍ ធម៌ទាំងនោះឈ្មោះថា **ឧបាទាន**។ តាមបរមត្ថទីបនីដីកាៈ **ភុសំ អាទិយន្តិ អមុញ្ចនវសេន គណ្ហន្តីតិ = ឧបាទានានិ** ធម៌ទាំងឡាយណាដែលចាប់ប្រកាន់យ៉ាងខ្លាំងក្លា ធម៌ទាំងឡាយនោះ ឈ្មោះថា **ឧបាទាន** ។

តាមន័យបដិច្ចសមុប្បាទ ឧបាទានកើតឡើងបានអាស្រ័យតណ្ហាជាហេតុ ដូច្នោះតណ្ហាទើបជាការចង់បានក្នុងអារម្មណ៍ដែលមកមិនទាន់ដល់ ចំណែក **ឧបាទាន** ជាសេចក្ដីប្រកាន់មាំក្នុងអារម្មណ៍ដែលមកដល់ខ្លួនហើយ ដោយមិនព្រមលែង។

**តើតណ្ហា និងឧបាទានមួយណាប្រកាន់មាំជាង?**

**តណ្ហា** ជាសេចក្ដីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ ជួបលើកដំបូង។

**ឧបាទាន** ជាសេចក្ដីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ដែលបានជួបហើយនៅជាប់ក្នុងចិត្ត ឬន័យម្យ៉ាងទៀត

**តណ្ហា** ប្រៀបដូចជាដើមឈើដែលនៅតូច ឬទើបតែដាំថ្មីៗ រមែងដកបានងាយ ចំណែក **ឧបាទាន** ដូចជាឈើនោះដាំទុកធំហើយ ដកបានដោយលំបាក ព្រោះឫសកែវចាក់មាំហើយ **ឧបាទាន** ទើបជាការប្រកាន់មាំទុកក្នុងអារម្មណ៍យ៉ាងណែនជាងតណ្ហា។

## ឧបាទាន ៤

**១.កាមុបាទាន** សេចក្ដីប្រកាន់មាំក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ទិដ្ឋុបាទាន** សេចក្ដីប្រកាន់មាំក្នុងការយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៣.សីលព្វតុបាទាន** សេចក្តីប្រកាន់មាំក្នុងការប្រតិបត្តិខុសថារួចផុតទុក្ខ អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៤.អត្តវាទុបាទាន** សេចក្តីប្រកាន់ខុសក្នុងនាមរូបថាជាតួខ្លួន (សក្កាយទិដ្ឋិ) អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

## សរុបអង្គធម៌

១.**កាមុបាទាន** អង្គធម៌ លោភចេតសិក ក្នុងលោភចិត្ត ៨

| | | |
|---|---|---|
| ២.**សីលព្វតុបាទាន** | អង្គធម៌ | ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ |
| ៣.**ទិដ្ឋុបាទាន** | អង្គធម៌ | |
| ៤.**អត្តវាទុបាទាន** | អង្គធម៌ | |

ឈ្មោះថា **ខន្ធ** ប៉ុន្តែ មិនឈ្មោះថា **ឧបាទានក្ខន្ធ** បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦។

ឈ្មោះថា **ខន្ធ** ផង និងឈ្មោះថា **ឧបាទានក្ខន្ធ** ផង បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥២ រូប ២៨។

មិនឈ្មោះថា **ខន្ធ** ប៉ុន្តែ ឈ្មោះថា **ឧបាទានក្ខន្ធ** មិនមានអង្គធម៌ទេ។

មិនឈ្មោះថា **ខន្ធ**ផង មិនឈ្មោះថា **ឧបាទានក្ខន្ធ**ផង អង្គធម៌ បានដល់ ព្រះនិព្វាន។

បណ្តាឧបាទាន ៤ សក្កាយទិដ្ឋិ ចូលក្នុង អត្តវាទុបាទាន

**ឧច្ឆេទទិដ្ឋិ** } **ទិដ្ឋុបាទាន**
**សស្សតទិដ្ឋិ**

## ធម៌លះបង់ឧបាទាន ៤

**បញ្ញាក្នុងអរហត្តមគ្គ** លះកាមុបាទាន
**បញ្ញាក្នុងសោតាបត្តិមគ្គ** លះឧបាទាន ៣ ផ្សេងទៀត។

## កំណត់ចំណាំបន្ថែម

**កាមុបាទាន** ការប្រកាន់មាំក្នុងរូបភព ឬអរូបភពផង
**ទិដ្ឋុបាទាន** កម្មស្សកតាញាណ រមែងលះបានក្នុងខាងដើម
**អត្តវាទុបាទាន** វិបស្សនាញាណ រមែងលះបានក្នុងខាងដើម
**វិបស្សនាបញ្ញា** ជាហេតុនៃការលះឧបាទានទាំងពួង។

## ៦.នីវរណៈ

នីវរណធម៌ ជាគ្រឿងហាមឃាត់សេចក្តីល្អ ព្រោះធម្មតាបុគ្គលមិនត្រេកអរក្នុងការបំពេញទាន រក្សាសីល ចម្រើនភាវនាបាន ព្រោះតែនីវរណធម៌នេះ។ ធម្មតាបុគ្គលទាំងឡាយដែលមិនត្រេកអរក្នុងការបំពេញទាន រក្សាសីលជាដើម ព្រោះហេតុនៃនីវរណធម៌ បានដល់ លោភៈ ទោសៈ ថីនមិទ្ធៈ ឧទ្ធច្ចៈ កុក្កុច្ចៈ វិចិកិច្ឆា និងមោហៈ

ណាមួយ ឬច្រើនយ៉ាងនោះឯង គ្រាខ្លះខណៈកំពុងធ្វើកុសលនោះ កើតសេចក្តីស្ទាក់ស្ទើរចិត្ត ធុញទ្រាន់កើតសេចក្តីមិនពេញចិត្តក្នុងការធ្វើឡើងធ្វើឱ្យសទ្ធា សតិ និងបញ្ញាថយ ចុះទាំងនេះអាចជាអំណាចរបស់ថីនមិទ្ធៈ កើតឡើងរារាំងសេចក្តីល្អមានសទ្ធាជាដើម ឬដោយអំណាចកាមឆន្ទនីវរណៈ ព្យាបាទនីវរណៈយ៉ាងគ្រោតគ្រាតកើតឡើងដល់ឈានលាភីបុគ្គល ក៏ធ្វើឱ្យឈានដែលសម្រេចហើយសាបសូន្យ មិនអាចតាំងនៅក្នុងឈានសមាបត្តិបាន។

វចនត្ថថា៖ **ឈានាទិកំ និវារេន្តីតិ =នីវរណានិ** ធម៌ទាំងឡាយណាជារនាំងរារាំងសេចក្តីល្អ មានឈានជាដើម មិនឱ្យកើតឡើងធម៌ទាំងនោះឈ្មោះថា ***នីវរណៈ***។

## នីវរណៈមាន ៦ ប្រការ

**១.កាមឆន្ទៈ** ធម្មជាតិជាគ្រឿងរារាំងនូវសេចក្តីល្អ គឺពេញចិត្តក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិក ក្នុងលោភមូលចិត្ត ៨ ។

**២.ព្យាបាទៈ** ធម្មជាតិជាគ្រឿងរារាំង គឺសេចក្តីក្រោធ អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសមូលចិត្ត២។

**៣.ថីនមិទ្ធៈ** ធម្មជាតិជាគ្រឿងរារាំង គឺងោកងក់រួញរា អង្គធម៌បានដល់ ថីនមិទ្ធចេតសិកក្នុងអកុសលសសង្ខារិកចិត្ត ៥។

**៤.ឧទ្ធច្ចកុក្កុច្ចៈ** ធម្មជាតិជាគ្រឿងរារាំង គឺសេចក្ដីរវើរវាយ និងរំខានចិត្ត អង្គធម៌បានដល់ ឧទ្ធច្ចចេតសិកក្នុងអកុសលចិត្ត ១២ និងកុក្កុច្ចចេតសិកក្នុងទោសមូលចិត្ត ២។

**៥.វិចិកិច្ឆា** ធម្មជាតិជាគ្រឿងរារាំង គឺសេចក្ដីសង្ស័យស្ទាក់ស្ទើរក្នុងវត្ថុដែលគួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិក ក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១។

**៦.អវិជ្ជា** ធម្មជាតិជាគ្រឿងរារាំង គឺការវង្វេង អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២។

ក្នុងនីវរណធម៌ ៦ ប្រការមានអង្គធម៌ ៨ ប្រការគឺ លោភចេតសិក ទោសចេតសិក ថីនចេតសិក មិទ្ធចេតសិក ឧទ្ធច្ចចេតសិក កុក្កុច្ចចេតសិក វិចិកិច្ឆាចេតសិក និងមោហចេតសិក។

សម្រាប់ថីនចេតសិក និងមិទ្ធចេតសិកទាំង ២ នេះដែលចាត់ជានីវរណៈជាមួយគ្នាព្រោះជា **សហកទាចិ** គឺត្រូវកើតព្រមជាមួយអកុសលសសង្ខារិកចិត្តដូចគ្នា ពោលដោយកិច្ចរមែងធ្វើឱ្យចិត្ត និងចេតសិកថយចាកអារម្មណ៍ដូចគ្នា ជាហេតុនៃកោសជ្ជៈ គឺសេចក្ដីខ្ជិលច្រអូសដូចគ្នា និងកាលពោលដោយបដិបក្ខធម៌ មានវីរិយចេតសិកដែលជាបដិបក្ខធម៌ដូចគ្នា។

**ឧទ្ធច្ច** និង**កុក្កុច្ចចេតសិក** ចាត់ជានីវរណៈជាមួយគ្នា កាលពោលដោយកិច្ចគឺធ្វើឱ្យមិនស្ងប់ ពោលដោយបច្ច័យជាហេតុឱ្យដល់ព្យសនៈ ៥ ប្រការ ពោលដោយបដិបក្ខធម៌ ជាបដិបក្ខដល់

សោមនស្សវេទនា គឺសេចក្ដីសុខចិត្ត ជាហេតុឱ្យដល់អប្បនាភាវនា។

**នីវរណធម៌** ដែលជាគ្រឿងរារាំងឈានមានត្រឹម ៥ ប្រការគឺ

១.កាមឆន្ទៈ ២.ព្យាបាទៈ ៣.ថីនមិទ្ធៈ ៤.ឧទ្ធច្ចកុក្កុច្ចៈ ៥.វិចិកិច្ឆា។

ចំណែកអវិជ្ជានីវរណៈ មិនមែនជាគ្រឿងរារាំងឈានឡើយ ព្រោះឈានដោយច្រើនអាស្រ័យបញ្ញត្តារម្មណ៍ តែការចម្រើនវិបស្សនាកម្មដ្ឋានដើម្បីឱ្យកើតមគ្គផល និព្វាននោះ នឹងត្រូវអាស្រ័យបញ្ញា គឺសម្មាទិដ្ឋិជាប្រការសំខាន់ ទើបពោលថាអវិជ្ជានីវរណៈប៉ុណ្ណោះ ជាគ្រឿងរារាំងមគ្គ ផល និព្វាន យ៉ាងពិតប្រាកដ។

## ធម៌លះបង់នីវរណៈ ៦ ប្រការ

**១.បញ្ញា** ក្នុងសោតាបត្តិមគ្គលះ វិចិកិច្ឆា កុក្កុច្ចៈ(គ្រោតគ្រាត)

**២.បញ្ញា** ក្នុងអនាគាមិមគ្គលះ កាមឆន្ទៈ និងព្យាបាទៈ

**៣.បញ្ញា** ក្នុងអរហត្តមគ្គលះនីវរណធម៌ដែលនៅសល់។

**កាយានុគតធម៌** (ការងោកងក់ប្រចាំកាយរបស់មនុស្សម្នាក់ៗ) ១០ ប្រការគឺ

**១.សីត** សម្ពស្សត្រជាក់

**២.ឧណ្ហ** សម្ពស្សក្ដៅ

**៣.ជិឃច្ឆា** ឃ្លាន

**៤.បិបាស** ស្រេក

**៥.ឧច្ចារៈ** បន្ទោបង់លាមក

**៦.បស្សាវៈ** បន្ទោបង់មូត្រ

**៧.ថីនមិទ្ធៈ** ងងុយងោកងក់

**៨.ជរា** ចាស់

**៩.ព្យាធិ** ឈឺ

**១០.មរណៈ** សេចក្តីស្លាប់។

**ចំណាំៈ** ថីនមិទ្ធៈដែលជាការដេកលក់នោះ បុថុជ្ជន និង សេក្ខបុគ្គលថីនមិទ្ធៈ ដែលជាកិលេសនីវរណៈរមែងកើតឡើងបាន ចំណែកព្រះខីណាស្រព អ្នកអស់អាសវក្កិលេសហើយ ការដេកលក់ មិនបានប្រព្រឹត្តទៅជាមួយថីនមិទ្ធកិលេសឡើយ គង់មានតែការ ដេកលក់ដែលជាសេចក្តីចាំបាច់របស់ភវង្គកិច្ច គឺជាធម៌ប្រចាំកាយ ប៉ុណ្ណោះ។

## ៧.អនុសយមាន ៧
## (កិលេសដេកសម្ងំក្នុងចិត្ត)

**អនុស័យ** ជាឈ្មោះរបស់កិលេសដ៏យ៉ាងល្អិតម្យ៉ាងដែល ដេកសម្ងំនៅក្នុងសន្តាន។ ដរាបមិនទាន់សម្រេចជាព្រះអរហន្តទេ អនុស័យនៅមានជាប្រចាំរឿយៗ មិនបង្ហាញចេញឱ្យឃើញប្រាកដ វៀរលែងព្រះសម្មាសម្ពុទ្ធដែលទ្រង់ជ្រាប។

ធម្មតាអនុស័យកិលេស ជាធម្មជាតិដែលដេកសម្ងំនៅជា ប្រចាំក្នុងខន្ធសន្តាន មិនសម្តែងចេញមកប្រាកដតាមទ្វារណាមួយ

ឡើយ កាលមានអារម្មណ៍ផ្សេងៗ មកប៉ះខ្ទប់ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តហើយ អនុស័យកិលេសដែលស្ងប់នោះ ក៏នឹងប្រែសភាពជាបរិយុដ្ឋានកិលេស គឺកិលេសយ៉ាងកណ្តាលប្រាកដឡើង ក៏នឹងជាបច្ច័យដល់វីតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ប្រាកដជាការធ្វើតាមផ្លូវកាយ វាចាឡើងមក ទាំងបរិយុដ្ឋានកិលេស និងវីតិក្កមកិលេស ២ ប្រការនេះ មិនហៅថា អនុស័យកិលេសទេ តែបរិយុដ្ឋានកិលេស និងវីតិក្កមកិលេសកើតពីបរិយុដ្ឋានកិលេស ជាហេតុបច្ច័យឧបត្ថម្ភដល់គ្នានិងគ្នាយ៉ាងនេះឯង។

**វចនត្ថៈថា សន្តានេ អនុសេន្តីតិ = អនុសយា** ធម៌ទាំងឡាយណា រមែងដេកសំងំនៅជារឿយៗក្នុងសន្តាននៃនាមរូប ធម៌ទាំងនោះ ឈ្មោះថា **អនុសយ។**

ម្យ៉ាងទៀតថា **អនុរូបំ ការណំ លភិត្វា ឧប្បជ្ជន្តីតិ** = **អនុសយា** ធម៌ទាំងឡាយណា កាលបានហេតុសមគួរហើយ រមែងកើតឡើងបាន ធម៌ទាំងឡាយនោះ ឈ្មោះថា **អនុសយ ។**

## កម្រិត ៣របស់កិលេស

**១.ប្រព្រឹត្តល្មើស** កើតឡើងតាមផ្លូវកាយ និងវាចា

Surface level

**២.រួមរឹតចិត្ត** ប្រព្រឹត្តទៅជាជវនចិត្តប៉ុណ្ណោះ

Transgression level

**៣.អនុសយ** មិនទាន់កើតជាមួយជវនចិត្ត(សម្ងំ)។ Latent level.

## ប្រៀបកិលេស ៣ ការប្រៀបធៀបជាមួយឈើគូស

**១.អនុសយកិលេស** ដូចធាតុប្រេងដែលនៅត្រង់ក្បាលឈើគូស

**២.បរិយុដ្ឋានកិលេស** ដូចយកឈើគូសមកគូស ភ្លើងរមែងប្រាកដឡើង

**៣.វីតិក្កមកិលេស** ដូចយកភ្លើងទៅដុតរបស់ផ្សេងៗឱ្យឆេះ។

## អនុសយមាន ៧ ប្រការ

**១.កាមរាគានុសយ** ដេកសម្ងំ គឺសេចក្ដីពេញចិត្តក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ភវរាគានុសយ** ដេកសម្ងំ គឺសេចក្ដីពេញចិត្តក្នុងរូបភព អរូបភព រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្ត ៤។

**៣.បដិឃានុសយ** ដេកសម្ងំ គឺសេចក្ដីក្រោធ អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសចិត្ត ២។

**៤.មានានុសយ** ដេកសម្ងំ គឺសេចក្ដីលើកតម្កើងខ្លួន អង្គធម៌បានដល់ មានចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៥.ទិដ្ឋានុសយ** ដេកសម្ងំ គឺការយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៦.វិចិកិច្ឆា** ដេកសម្ងំ គឺសេចក្ដីសង្ស័យ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត១។

**៧.អវិជ្ជា** ដេកសម្ងំ គឺសេចក្តីវង្វេងមិនដឹងតាមពិត អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត១២។

## ការលះកិលេស ៣

**១.កុសលសីល** អាចលះ វីតិក្កមកិលេស

**២.កុសលសមាធិ** អាចលះ បរិយុដ្ឋានកិលេស

**៣.បញ្ញាក្នុងមគ្គ** អាចលះ អនុសយកិលេស។

## ធម៌លះអនុសយ

**១.បញ្ញា** ក្នុងសោតាបត្តិមគ្គលះទិដ្ឋិ និងវិចិកិច្ឆា

**២.បញ្ញា** ក្នុងអនាគាមិមគ្គលះកាមរាគៈ និងបដិឃៈ

**៣.បញ្ញា** ក្នុងអរហត្តមគ្គលះអនុសយនៅសល់។

## ៨.សំយោជនៈ (ក្នុងព្រះសូត្រ)

**សំយោជនធម៌** ជាគ្រឿងចងសត្វទាំងឡាយឱ្យជាប់នៅក្នុងវដ្តទុក្ខ ដូចជាខ្សែចងលាមសត្វទុកជាប់នឹងបង្គោលមិនឱ្យរបូត។

ធម្មតា ក្នុងសន្តានរបស់បុថុជ្ជនទាំងឡាយ រមែងមានធម្មជាតិម្យ៉ាង ប្រៀបដូចខ្សែ ១០ សរសៃ ដែលចងសត្វទុកមិនឱ្យរួចពីទុក្ខបាន គឺត្រូវវិលវល់ស្លាប់កើតក្នុងវដ្តទុក្ខ ខ្សែ ១០ សរសៃនោះ ក៏គឺសំយោជនៈនោះឯង បើខ្សែណាមួយតឹងហើយ សំយោជនៈកិលេសនោះក៏នឹងទាញសត្វនោះឱ្យកើតក្នុងភូមិ ដែលទាក់ទងជាមួយសំយោជនៈនោះៗបាន ដោយអាស្រ័យកម្មដែលសត្វទាំងនោះបានធ្វើទុក។

វចនត្ថៈថា **ពន្ធនាការកាមម្ហិ សំយោជនេន វជ្ឈា គីវាយ ពន្ធិតា សត្តា ន សក្កោន្តិ ច សព្វេ។** សត្វទាំងឡាយដែលត្រូវខ្សែ គឺសំយោជនៈចងទុកក្នុងកាមគុណ៥ ដែលប្រៀបបីដូចជាគុក ទើបមិនអាចនឹងគេចទៅឱ្យផុតបានឡើយ។

**១.កាមរាគសញ្ញោជន** ធម្មជាតិចងសត្វទុកក្នុងកាម-គុណារម្មណ៍អង្គធម៌បានដល់លោភចេតសិកក្នុងលោភមូលចិត្ត៨។

**២.រូបរាគសញ្ញោជន** ធម្មជាតិចងសត្វទុក ក្នុងរូបភព រូបឈាន អង្គធម៌បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៣.អរូបរាគសញ្ញោជន** ធម្មជាតិចងសត្វទុកក្នុងអរូបភព ឬអរូបឈាន អង្គធម៌បានដល់លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្ត-ចិត្ត ៤។

**៤.បដិឃសញ្ញោជន** ធម្មជាតិចងសត្វទុក គឺសេចក្ដីក្រោធ អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសមូលចិត្ត ២។

**៥.មានសញ្ញោជន** ធម្មជាតិចងសត្វទុកគឺលើកតម្កើងខ្លួន អង្គធម៌បានដល់ មានចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤។

**៦.ទិដ្ឋិសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៧.សីលព្វតបរាមាសសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការបដិបត្តិខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៨.វិចិកិច្ឆាសញ្ញោជន** ធម្មជាតិចងសត្វទុកដោយសេចក្ដីសង្ស័យក្នុងវត្ថុគួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១។

**៩.ឧទ្ធច្ចសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការរវើរវាយ អង្គធម៌បានដល់ ឧទ្ធច្ចចេតសិកក្នុងអកុសលចិត្ត ១២។

**១០.អវិជ្ជាសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការវង្វេង អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២។

## សំយោជនមាន ១០ យ៉ាង

(តាមន័យព្រះអភិធម្ម)

**១.កាមរាគសញ្ញោជន** ធម្មជាតិចងសត្វទុកក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ភវរាគសញ្ញោជន** ធម្មជាតិចងសត្វទុកក្នុងរូបភព អរូបភព រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៣.បដិឃសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការក្រោធ អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសមូលចិត្ត ២។

**៤.មានសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការលើកតម្កើងខ្លួន អង្គធម៌បានដល់ មានចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤។

**៥.ទិដ្ឋិសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៦.សីលព្វតបរាមាសសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការបដិបត្តិខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគត-សម្បយុត្តចិត្ត ៤។

**៧.វិចិកិច្ឆាសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការសង្ស័យក្នុងវត្ថុគួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១។

**៨.ឥស្សាសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការច្រណែន អង្គធម៌បានដល់ ឥស្សាចេតសិកក្នុងទោសមូលចិត្ត ២។

**៩.មច្ឆរិយសញ្ញោជន** ធម្មជាតិចងសត្វទុកដោយការកំណាញ់ហួងហែងក្នុងសម្បត្តិ អង្គធម៌បានដល់ មច្ឆរិយចេតសិកក្នុងទោសមូលចិត្ត ២។

**១០.អវិជ្ជាសញ្ញោជន** ធម្មជាតិចងសត្វទុកដោយអាការវង្វេងអង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២។

## សំយោជនទាំង ១០ នេះ កើតអាស្រ័យរូប និងចក្ខុ ជាហេតុ

១.កាលបើរូបារម្មណ៍ល្អ មកប៉ះខ្ទប់នឹងចក្ខុ **កាមរាគសំយោជនៈ** ក៏កើតឡើង។

២.កាលបើរូបារម្មណ៍មិនល្អ មកប៉ះខ្ទប់នឹងចក្ខុ បដិឃសំយោជន ក៏កើតឡើង។

៣.ប្រសិនបើមិនមានខ្លួន គឺអញទេ អ្នកដទៃមិនសមគួរដើម្បីបាននូវរូបារម្មណ៍ **មានសំយោជនៈ** ក៏កើតឡើង។

៤.ប្រសិនបើមានសេចក្ដីសង្ស័យថា រូបនុ៎ះ ជាសត្វ ឬបុគ្គលហ្ន៎ **វិចិកិច្ឆាសំយោជនៈ** ក៏កើតឡើង។

៥.កាលបើប្រកាន់រូបថាទៀង **ទិដ្ឋិសំយោជនៈ** ក៏កើតឡើង។

៦.កាលបើប្រាថ្នាភពថា អារម្មណ៍នេះ យើងបានដោយងាយ ក្នុងភពសម្បត្តិ គឺរមែងបានដោយងាយ អ្នកដទៃដែលបានឈាន ឬកើតជាព្រហ្ម **ភវរាគសំយោជនៈ** ក៏កើតឡើង។

៧.កាលបើបុគ្គលប្រកាន់ (**សីលព្វត**) ថាអញមានរូបារម្មណ៍ **សីលព្វតបរាមាសសំយោជនៈ** ក៏កើតឡើង។

៨.កាលបើសេចក្ដីរារាំង (ជំទាស់) កើតឡើងអ្នកដទៃមិនគប្បីបាននូវរូបារម្មណ៍ **ឥស្សាសំយោជនៈ** ក៏កើតឡើង។

៩.កាលបើសេចក្ដីកំណាញ់ ហួងហែងរូបារម្មណ៍ ដែលខ្លួនបានហើយមិនប្រាថ្នាឱ្យជាសាធារណៈដល់ជនដទៃ **មច្ឆរិយសំយោជនៈ** ក៏កើតឡើង។

១០.កាលបើមិនដឹងច្បាស់ ដោយអំណាចនៃការមិនដឹងច្បាស់ ក្នុងចក្ខុ និងរូបារម្មណ៍ **អវិជ្ជាសំយោជនៈ** ក៏កើតឡើង។

## ធម៌លះសំយោជនៈ

**បញ្ញាក្នុងសោតាបត្តិមគ្គលះ** ទិដ្ឋិសំយោជនៈ វិចិកិច្ឆា-សំយោជនៈ សីលព្វតបរាមាសសំយោជនៈ ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ

**បញ្ញាក្នុងអនាគាមិមគ្គលះ** កាមរាគសំយោជនៈ បដិឃ-សំយោជនៈ

**បញ្ញាក្នុងអរហត្តមគ្គលះ** សំយោជនៈដែលនៅសល់។

## សំសារវដ្ដ ៣

**១.ហេដ្ឋិមសំសារ** វដ្ដខាងក្រោម (អបាយភូមិ)

**២.មជ្ឈិមសំសារ** វដ្ដកណ្ដាល (មនុស្ស និងទេវតា)

**៣.ឧបរិមសំសារ** វដ្ដខ្ពស់ (ព្រហ្មលោក)។

## ការចែកសញ្ញោជន ១០

## (សុត្តន្តន័យ) ចែកជា ២ យ៉ាង

**១.ឱរម្ភាគិយសញ្ញោជនមាន ៥** គឺ កាមរាគៈ១ បដិឃៈ១ ទិដ្ឋិ១ សីលព្វតបរាមាស១ វិចិកិច្ឆា១ ដែលចងទាញសត្វទុកក្នុងភូមិខាងក្រោម គឺកាមភូមិ។

**២.ឧទ្ធម្ភាគិយសញ្ញោជនមាន ៥** គឺ រូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ដែលចងទាញសត្វទុកក្នុងភូមិខាងលើ គឺរូបភូមិ អរូបភូមិ។

ធម្មតាបុថុជ្ជនទាំងឡាយ ដែលមិនបានចម្រើនសមថភាវនាឱ្យចូលដល់ឈាន កាមរាគសំយោជនៈ រមែងតឹងឡើងជានិច្ច និងបើបានធ្វើទុច្ចរិតកម្មទុកច្រើន បដិឃសំយោជនៈយ៉ាងគ្រោតគ្រាត ទិដ្ឋិសំយោជនៈ និងវិចិកិច្ឆាសំយោជនៈទាំង ៣ យ៉ាងនេះ ក៏នឹងមានឱកាសតឹងឡើង នឹងនាំទៅកាន់អបាយភូមិបាន ។

ចំណែកសីលព្វតបរាមាសសំយោជនៈ នឹងមិនប្រាកដដល់បុគ្គលទូទៅ តែបើប្រាកដឡើងពេលណា ក៏អាចទាញទៅកាន់អបាយភូមិបានដូចគ្នា។

បើបុគ្គលនោះធ្វើសុចរិតកម្មជាចំណែកច្រើន បដិឃសំយោ-ជនយ៉ាងសាមញ្ញ (មិននាំទៅកាន់អបាយ) សក្កាយទិដ្ឋិសំយោជនៈមានឱកាសតឹងឡើងបាន នឹងនាំទៅកើតជាមនុស្ស ឬទេវតា ។

ចំណែកមិច្ឆាទិដ្ឋិ សីលព្វតបរាមាស វិចិកិច្ឆាសំយោជនៈទាំង ៣ នេះ មិនមានឱកាសតឹងឡើងបានក្នុងការធ្វើបុណ្យកុសល។

សម្រាប់បុថុជ្ជនដែលបានឈាន កាមរាគសំយោជនៈ បដិឃសំយោជនៈ និងសីលព្វតបរាមាស មិនមានឱកាសរឹតតឹងបានទេ។

**ឧទ្ធម្ភាគិយសំយោជនៈ** គឺរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និង អវិជ្ជាសំយោជនៈប៉ុណ្ណោះ ដែលមានឱកាសតឹងឡើង ស្រេចហើយតែរូបឈាន ឬអរូបជ្ឈានដែលខ្លួនបាន ដោយហេតុនេះ ឈានលាភីបុគ្គល កាលស្លាប់ពីកាមភូមិទើបទៅកើតក្នុងរូបភូមិ ឬអរូបភូមិតាមសមគួរដល់ឈាន តែបុថុជ្ជនដែលកើតជាព្រហ្មនេះ នៅមិនបានប្រហារកាមរាគៈ បដិឃៈ ឱ្យជាសមុច្ឆេទទេ ប្រហារដើម្បីការគ្របសង្កត់ដោយអំណាចរបស់ឈានប៉ុណ្ណោះ។ ដូច្នោះកាលព្រហ្មអង្គណាវិនាសចាកឈាន បន្ទាប់ពីស្លាប់ទៅនឹងទៅកើតព្រហ្មទៀតមិនបាន គឺត្រូវមកកើតក្នុងកាមភូមិជាមនុស្ស ឬក៏ជាទេវតាវិញ ដែលជាយ៉ាងនេះ ក៏ដោយអំណាចកាមរាគសំយោជនៈ បដិឃសំយោជនៈ ដែលមានចងនៅក្នុងខន្ធសន្តានរបស់ខ្លួនឯង ជាអ្នកទាញរឹតតឹងចុះមកដោយ **ឱរម្ភាគិយសំយោជនៈ**។

ចំណែកព្រះអរិយបុគ្គលដែលសម្រេចជាព្រះសោតាបន្ន ឬព្រះសកទាគាមិបុគ្គលនោះ ប្រហារទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ទាំង ៣ នេះ ដោយដាច់ជាសមុច្ឆេទហើយ ទើបផុតចាកការទាញទៅកាន់ **ហេដ្ឋិមសង្សារ** គឺអបាយភូមិ ៤ តែនៅមិនផុត **មជ្ឈិមសង្សារ** គឺមនុស្សភូមិ ទេវភូមិ និង **ឧបរិសង្សារ** គឺរូបភូមិ អរូបភូមិ ដែលជាភូមិថ្នាក់ខ្ពស់ ទាំងនេះព្រោះនៅមានសំយោជនៈដែលនៅសល់ ៧ ទៀត នៅក្នុងខន្ធសន្តាន កាលសម្រេចជាព្រះអនាគាមី ក៏នឹងប្រហារកាមរាគៈ បដិឃៈទាំង២នេះ បានដោយដាច់ជាសមុច្ឆេទ

២ ប្រការទៀត ជាការដាច់ចាកមជ្ឈិមសង្សារបានដាច់ជាសមុច្ឆេទ នោះ គឺព្រះអនាគាមីនឹងផុតចាកមនុស្សភូមិ និងទេវភូមិ តែនឹងទៅកើតក្នុងរូបភូមិ និងអរូបភូមិប៉ុណ្ណោះ ទាំងនេះព្រោះឧទ្ធម្ភាគិយសំយោជនៈនៅមាន កាលសម្រេចជាព្រះអរហន្ត ក៏នឹងផុតចាកឧបរិមសង្សារទៀត កាលបរិនិព្វានហើយ ក៏ផុតចាកសេចក្ដីវិលវល់កើតស្លាប់ហើយ មិនថាក្នុងសង្សារណាៗ ព្រោះកាត់ផ្ដាច់សរសៃនៃសំយោជនៈ ១០ ប្រការ។

បរមត្ថទីបនីដីកាសម្ដែងថា សំយោជនៈដែលត្រូវប្រហារដោយមគ្គខាងក្រោម ៣ ឈ្មោះថា **ឱរម្ភាគិយសំយោជនៈ** ចំណែកសំយោជនៈ ដែលត្រូវប្រហារដោយអរហត្តមគ្គនោះ ឈ្មោះថា **ឧទ្ធម្ភាគិយសំយោជនៈ**។

## ចែកសញ្ញោជន ១០ (អភិធម្មន័យ)
## ចែកជា ២ យ៉ាង

**១.ឱរម្ភាគិយមាន ៧ គឺ** កាមរាគៈ១ បដិឃៈ១ ទិដ្ឋិ១ សីលព្វតបរាមាស១ វិចិកិច្ឆា១ ឥស្សា១ មច្ឆរិយ១។

**២.ឧទ្ធម្ភាគិយមាន ៣គឺ** ភវរាគៈ១ មានៈ១ អវិជ្ជា ១។

## សង្គ្រោះអង្គធម៌តាមន័យទាំង ២
## តាមន័យព្រះសូត្រមានអង្គធម៌ ៧

១.លោភចេតសិក ២.ទោសចេតសិក ៣.មានចេតសិក
៤.ទិដ្ឋិចេតសិក ៥.វិចិកិច្ឆាចេតសិក ៦.ឧទ្ធច្ចចេតសិក
៧.មោហចេតសិក។

## តាមន័យព្រះអភិធម្មមានអង្គធម៌ ៨

១.លោភចេតសិក ២.ទោសចេតសិក ៣.មានចេតសិក
៤.ទិដ្ឋិចេតសិក ៥.វិចិកិច្ឆាចេតសិក ៦.ឥស្សាចេតសិក
៧.មច្ឆរិយចេតសិក ៨.មោហចេតសិក។

## ៩.កិលេស ១០ យ៉ាង

កិលេសធម៌ ជាគ្រឿងសៅហ្មង សភាវៈបៀតបៀនចិត្ត ដុតបំផ្លាញចិត្ត និងកាយ សេចក្ដីថា ចិត្ត ចេតសិក រូប ដែលកើតព្រមជាមួយកិលេសរមែងត្រូវក្ដៅក្រហាយទៅផងដែរ សូម្បីរូបដែលកើតពីអកុសលចិត្តក៏មានសភាពសៅហ្មងដែរ។ ធម្មតាចិត្តរបស់បុគ្គលដែលមិនបានប្រកបដោយកិលេស មានលោភៈ និងសេចក្ដីក្រោធជាដើម បុគ្គលនោះរមែងដឹងខ្លួនថាចិត្តខណៈនោះស្រឡះល្អសប្បាយចិត្តនិងសប្បាយកាយ មុខស្រស់ថ្លាមិនមានសេចក្ដីក្ដៅក្រហាយកាយ និងចិត្ត ថែមទាំងជាទីសប្បាយភ្នែក សប្បាយចិត្តដល់អ្នកដែលបានជួបទៀតផង តែបើក្នុងខណៈណាចិត្តរបស់បុគ្គលម្នាក់មានលោភៈ ឬសេចក្ដីក្រោធក្ដីធំក្នុងចិត្តហើយ រូបរាងកាយទឹកមុខក៏មិនស្រស់ថ្លា ដោយអំណាចរបស់កិលេស។ មានវចនត្ថៈថាៈ

**១.ចិត្តំ កិលិស្សន្តិ ទិពាធេន្តីតិ កិលេសា** ធម៌ទាំងឡាយឯណា រមែងបៀតបៀននូវចិត្ត ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **កិលេស**។

**២.ចិត្តំ កិលិស្សន្តិ ឧបតាបេន្តីតិ កិលេសា** ធម៌ទាំងឡាយឯណា រមែងញ៉ាំងចិត្តឱ្យក្តៅ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **កិលេស**។

**៣.កិលិស្សន្តិ សត្តា ឯតេហីតិ កិលេសា** សត្វទាំងឡាយដែលសៅហ្មង ដោយធម៌ទាំងឡាយនុ៎ះ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **កិលេស**។

**១.លោភកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការត្រេកអរពេញចិត្តក្នុងលោកិយធម៌ អង្គធម៌បានដល់ លោភចេតសិកក្នុងលោភចិត្ត៨។

**២.ទោសកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះសេចក្តីក្រោធ អង្គធម៌បានដល់ ទោសចេតសិកក្នុងទោសចិត្ត ២។

**៣.មោហកិលេស** គ្រឿងសៅហ្មងរោលរាលព្រោះសេចក្តីវង្វេង អង្គធម៌បានដល់មោហចេតសិកក្នុងអកុសលចិត្ត ១២។

**៤.មានកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការលើកតម្កើងខ្លួន វាយឫក អង្គធម៌បានដល់ មានចេតសិកក្នុងទិដ្ឋិគតវិប្ប-យុត្តចិត្ត ៤។

**៥.ទិដ្ឋិកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការយល់ខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុង ទិដ្ឋិគតសម្បយុត្តចិត្ត ៤។

**៦.វិចិកិច្ឆាកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះសេចក្តីសង្ស័យ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆា-សម្បយុត្តចិត្ត១។

**៧.ថីនកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការរាថយ អង្គធម៌បានដល់ ថីនចេតសិកក្នុងអកុសលសសង្ខារិកចិត្ត៥។

**៨.ឧទ្ធច្ចកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការរវើរវាយ អង្គធម៌បានដល់ ឧទ្ធច្ចចេតសិកក្នុងអកុសលចិត្ត ១២។

**៩.អហិរិកកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការមិនខ្មាសចំពោះទុច្ចរិត អង្គធម៌បានដល់ អហិរិកចេតសិកក្នុងអកុសលចិត្ត ១២។

**១០.អនោត្តប្បកិលេស** គ្រឿងសៅហ្មងរោលរាល ព្រោះការមិនតក់ស្លុតចំពោះទុច្ចរិត អង្គធម៌បានដល់ អនោត្តប្ប-ចេតសិកក្នុងអកុសលចិត្ត ១២ ។

## កិលេសដោយពិស្តារ ១៥០០

អារម្មណ៍ដែលជាហេតុឱ្យកើតកិលេស ១០ មាន១៥០ គឺ នាមធម៌ ៥៣ (ចិត្ត១ និងចេតសិក៥២) និប្ផន្នរូប ១៨ លក្ខណរូប ៤ រួម ៧៥ ក្នុងអជ្ឈត្តសន្តាន និងពហិទ្ធសន្តាន = ១៥០ គុណនឹងកិលេស ១០ = ១៥០០។

## តណ្ហា ១០៨

- ✓ អារម្មណ៍របស់តណ្ហាមាន ៦ (រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា) គុណនឹងតណ្ហា ៣ (កាមតណ្ហា ភវតណ្ហា វិភវតណ្ហា) = ១៨ ។
- ✓ តណ្ហា ១៨ គុណនឹង ២ (អជ្ឈត្តៈ និងពហិទ្ធៈ) = ៣៦
- ✓ តណ្ហា ៣៦ គុណនឹង ៣ កាល (បច្ចុប្បន្ន១ អតីត១ អនាគត១) = ១០៨ ។

## កិលេសទាំងឡាយចែកជា ៣ ថ្នាក់

១.**អនុសយកិលេស** ជាកិលេសល្អិតដែលដេកត្រាំជ្រកសម្ងំជាប្រចាំក្នុងខន្ធសន្ដាន ជាកិលេសលះមិនទាន់បាន។

២.**បរិយុដ្ឋានកិលេស** ជាកិលេសថ្នាក់កណ្ដាល ដែលកើតប្រាកដតាមផ្លូវចិត្ត។

៣.**វីតិក្កមកិលេស** ជាកិលេសថ្នាក់គ្រោតគ្រាតដែលសម្ដែងចេញតាមផ្លូវកាយ និងផ្លូវវាចា។

## ធម៌លះកិលេស ១០

**បញ្ញាក្នុងសោតបត្តិមគ្គចិត្តលះ** ទិដ្ឋិកិលេស និងវិចិកិច្ឆាកិលេស

**បញ្ញាក្នុងអនាគាមិមគ្គចិត្តលះ** ទោសកិលេស

**បញ្ញាក្នុងអរហត្តមគ្គចិត្តលះ** កិលេសដែលនៅសល់។

## សរុបអង្គធម៌ក្នុងអកុសលធម៌ ៩ កង

**លោភចេតសិក** ជាអង្គធម៌របស់អកុសលទាំង ៩ កង។
**ទិដ្ឋិចេតសិក** ជាអង្គធម៌របស់អកុសលទាំង ៨ កង (វៀរនីវរណៈ)។
**មោហចេតសិក** ជាអង្គធម៌របស់អកុសលទាំង ៧ កង (វៀរគន្ថៈ ឧបាទាន)។
**ទោសចេតសិក** ជាអង្គធម៌របស់អកុសលទាំង ៥ កង គឺ គន្ថៈ នីវរណៈ អនុស័យ សំយោជនៈ កិលេស។
**វិចិកិច្ឆាចេតសិក** ជាអង្គធម៌របស់អកុសលទាំង ៤ កង គឺនីវរណៈ អនុស័យ សំយោជនៈ កិលេស។
**ឧទ្ធច្ចចេតសិក** ជាអង្គធម៌របស់អកុសលទាំង៣កង គឺនីវរណៈ សំយោជនៈ កិលេស។
**មានចេតសិក** ជាអង្គធម៌របស់អកុសលទាំង៣កង គឺអនុសយ សំយោជនៈ កិលេស។
**ថីនចេតសិក** ជាអង្គធម៌របស់អកុសលទាំង ២ កង គឺនីវរណៈ កិលេស។
**មិទ្ធចេតសិក** ជាអង្គធម៌របស់អកុសល ១ កង គឺនីវរណៈ។
**កុក្កុច្ចចេតសិក** ជាអង្គធម៌របស់អកុសល ១ កង គឺនីវរណៈ ។
**ឥស្សាចេតសិក** ជាអង្គធម៌របស់អកុសល១ កង គឺសំយោជនៈ។
**មច្ឆរិយចេតសិក** ជាអង្គធម៌របស់អកុសល១ កង គឺសំយោជនៈ។
**អហិរិកចេតសិក** ជាអង្គធម៌របស់អកុសល១ កង គឺកិលេស។
**អនោត្តប្បចេតសិក** ជាអង្គធម៌របស់អកុសល១ កងគឺកិលេស។

## តារាងអកុសលធម៌ ៩ កង

| ឈ្មោះ | អា | ឱ | យោ | គ | ឧ | នី | អនុ | សំ | កិ | ឋាន |
|---|---|---|---|---|---|---|---|---|---|---|
| លោភ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ៩ |
| ទោស | | | | ✓ | | ✓ | ✓ | ✓ | ✓ | ៥ |
| មោហ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ៧ |
| អហិរិក | | | | | | | | | ✓ | ១ |
| អនោត្តប្ប | | | | | | | | | ✓ | ១ |
| ទិដ្ឋិ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ៨ |
| មានះ | | | | | | | ✓ | ✓ | ✓ | ៣ |
| ឥស្សា | | | | | | | | ✓ | | ១ |
| មច្ឆរិយះ | | | | | | | | ✓ | | ១ |
| កុក្កុច្ចះ | | | | | | ✓ | | | | ១ |
| ថីនះ | | | | | | ✓ | | | ✓ | ២ |
| មិទ្ធះ | | | | | | ✓ | | | | ១ |
| វិចិកិច្ឆា | | | | | | ✓ | ✓ | ✓ | ✓ | ៤ |
| ឧទ្ធច្ចះ | | | | | | ✓ | | ✓ | ✓ | ៣ |

(ចប់អកុសលសង្គហៈ)

# ២.មិស្សកសង្គហៈ

**Compendium of Mixed Categories**

**មិស្សកសង្គហៈ** ជាពួកដែលសង្គ្រោះធម៌ផ្សេងៗ ដោយភាពជាកុសល អកុសល និងអព្យាកត លាយឡំគ្នា។ មានវចនត្ថថាៈ

**កុសលាកុសលាព្យាកតា មិស្សកានំ ហេតុឆក្កាទីនំ សង្គហោតិ = មិស្សកសង្គហោ** ពួកធម៌ផ្សេងៗ មានហេតុ ៦ ជាដើម ដែលសង្គ្រោះច្រឡូកច្រឡំចូលគ្នា ទាំងកុសល អកុសល និងអព្យាកតបាននោះ ហៅថា **មិស្សកសង្គហ**។

**មានធម៌ ៧ ពួក មាន ៦៤ ប្រភេទគឺ**

- ហេតុ ៦
- ឈានង្គ ៧
- មគ្គង្គ ១២
- ឥន្ទ្រិយ ២២
- ពលៈ ៩
- អធិបតី ៤
- អាហារ ៤ ។

## ១.ហេតុ (Roots)

**ហេតុ** ជាធម៌ដែលធ្វើឱ្យផលកើតឡើង ធ្វើឱ្យផលនោះតាំងនៅ និងធ្វើឱ្យចម្រើនឡើង។ មានវចនត្ថៈថា៖

**ហិនោតិ បតិដ្ឋាតិ ផលមេត្ថាតិ = ហេតុ** ផលរមែងតាំងនៅក្នុងធម៌នុ៎ះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **ហេតុ**។

ធម៌ទាំងឡាយដែលមានឧបការៈអំពីហេតុ រមែងមានសភាពតាំងមាំក្នុងអារម្មណ៍ ដូចដើមឈើដែលមានឫសលូតលាស់ល្អផ្សាយទៅ។

## ហេតុមាន ៦ ប្រការ

**១.លោភហេតុ** សេចក្តីចង់បាន ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់លោភចេតសិកក្នុងលោភមូលចិត្ត ៨។

**២.ទោសហេតុ** ការខឹងក្រោធ ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់ទោសចេតសិកក្នុងទោសមូលចិត្ត ២។

**៣.មោហហេតុ** ការវង្វេង ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់មោហចេតសិកក្នុងអកុសលចិត្ត ១២។

**៤.អលោភហេតុ** ការមិនជាប់ជំពាក់ ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់ អលោភចេតសិកក្នុងសោភណចិត្ត ៥៩។

**៥.អទោសហេតុ** ការមិនក្រោធ ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់ អទោសចេតសិកក្នុងសោភណចិត្ត ៥៩ ។

**៦.អមោហហេតុ** ការមិនវង្វេង ជាហេតុនាំឱ្យនាមរូបកើតព្រមនឹងខ្លួនតាំងមាំ និងចម្រើនបានក្នុងអារម្មណ៍ អង្គធម៌បានដល់បញ្ញាចេតសិកក្នុងសោភណចិត្ត ៤៧ ។

**លោភហេតុ ទោសហេតុ មោហហេតុ** ជាហេតុប្រកបក្នុងអកុសលចិត្ត និងអកុសលចេតសិកទើបហៅថា អកុសលហេតុ។

**អលោភហេតុ អទោសហេតុ អមោហហេតុ** ជាហេតុប្រកបក្នុងសោភណចិត្ត ដែលជាកុសលចិត្តហៅថា កុសលហេតុ។

**អលោភហេតុ អទោសហេតុ អមោហហេតុ** ជាហេតុប្រកបក្នុងសោភណចិត្ត ដែលជាវិបាកចិត្ត និងកិរិយាចិត្តហៅថា អព្យាកតហេតុ។

## ២.ឈានង្គមាន ៧ (Jhana Factors)

**ឈាន** មានន័យ ២ គឺ

១.ជាធម្មជាតិដែលមានសភាពសម្លឹងអារម្មណ៍ មិនកំណត់ថា ការសម្លឹងអារម្មណ៍កម្មដ្ឋានអ្វីក្តី ជាលោកិយ ឬលោកុត្តរារម្មណ៍ បរមត្ថ ឬបញ្ញត្តិអារម្មណ៍ក្តី ការសម្លឹងទាំងនោះជាអារម្មណ៍របស់ឈានទាំងអស់។

២.**ឈាន** ប្រែថា **ដុត** គឺធ្វើឱ្យធម៌ដែលជាបដិបក្ខជាមួយខ្លួនមានកម្លាំងថយចុះទៅ ឬមិនឱ្យកើតឡើងបាន បានដល់អង្គឈាន

៦ ដែលប្រកបក្នុងមហគ្គតចិត្ត ចំណែកអង្គឈានដែលនៅក្នុងកាមចិត្តនោះ មានសភាពចូលទៅសម្លឹងអារម្មណ៍ច្រើនជាង និងដុតធម៌ដែលជាបដិបក្ខជាមួយនឹងខ្លួន។

**អារម្មណំ ឧបគន្ត្វា ចិន្តនសង្ខាតេន ឧបនិជ្ឈាយនដ្ឋេន យថារហំ បច្ចនីកធម្មជ្ឈាបនដ្ឋេន ច ឈានានិ** ធម្មជាតិទាំងឡាយ ឈ្មោះថា **ឈាន** ព្រោះមានអត្ថថា ចូលទៅសម្លឹង ពោលគឺ ចូលទៅគិត (សម្លឹងមើល) នូវអារម្មណ៍ និងព្រោះមានអត្ថថា ដុតនូវធម៌ដែលជាសត្រូវតាមសមគួរ ដូច្នេះ។

## ឈានង្គៈមាន ៧ ប្រការ

**១.វិតក្ក** (Initial application) សភាវៈលើកចិត្តឡើងកាន់អារម្មណ៍ អង្គធម៌បានដល់ វិតក្កចេតសិកក្នុងចិត្ត ៥៥។

**២.វិចារ** (Sustained applic) សភាវៈពិចារណាអារម្មណ៍ អង្គធម៌បានដល់ វិចារចេតសិកក្នុងចិត្ត ៦៦។

**៣.បីតិ** (Joy) ការឆ្អែតកាយ និងចិត្ត អង្គធម៌បានដល់ បីតិចេតសិកក្នុងចិត្ត ៥១។

**៤.ឯកគ្គតា** (One-pointedness of mind) ការតាំងចិត្តឱ្យស្ងប់ អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងចិត្ត ១១១។

**៥.សោមនស្ស** (Pleasant feeling) សោយអារម្មណ៍ជាសុខ អង្គធម៌បានដល់ វេទនាចេតសិកក្នុងសោមនស្សសហគតចិត្ត ៦២។

**៦.ទោមនស្ស** (Unpleasant feeling) សោយអារម្មណ៍ជាទុក្ខ អង្គធម៌បានដល់ វេទនាចេតសិកក្នុងទោសមូលចិត្ត ២។

**៧.ឧបេក្ខា** (Neutral feeling) សោយអារម្មណ៍ជាកណ្ដាល អង្គធម៌បានដល់ វេទនាចេតសិកក្នុងឧបេក្ខាសហគតចិត្ត ៤៧ (វៀរឧបេក្ខាវេទនាក្នុងទ្វិចតុវិញ្ញាណ ៨)។

## ឈានជុតបដិបក្ខធម៌

**១.វិតក្កៈ** បដិបក្ខនឹង ថីនមិទ្ធៈ

**២.វិចារៈ** បដិបក្ខនឹង វិចិកិច្ឆា

**៣.បីតិ** បដិបក្ខនឹង ព្យាបាទៈ

**៤.សោមនស្ស និង ឧបេក្ខា** បដិបក្ខនឹង ឧទ្ធច្ចៈ កុក្កុច្ចៈ ទោមនស្ស។

**៥.ឯកគ្គតា** បដិបក្ខនឹង កាមឆន្ទៈ។

## ចំណាំបន្ថែម

**ឯកគ្គតាចេតសិក** ដែលប្រកបក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ១០ មិនជាឈានង្គៈ និងឯកគ្គតាចេតសិកក្នុងអវីរិយចិត្ត ១៦ រមែងមិនដល់នូវសមាធិន្ទ្រិយ និងសមាធិពលៈ។

## ៣.មគ្គង្គមាន ១២

**មគ្គ** ប្រែថា ផ្លូវ គឺជាធម្មជាតិនាំទៅកាន់គោលដៅ។ ធម៌ដែលជាហេតុឱ្យដល់ទុគ្គតិភូមិ សុគតិភូមិ និព្វាន និងជាគន្លងឱ្យទៅ

កាន់ទុគ្គតិភូមិ សុគតិភូមិ និងព្រះនិព្វាន ឬន័យម្យ៉ាងទៀត ព្រោះជាធម៌ក្នុងចំណែកមួយរបស់មគ្គ ទើបហៅថា **អង្គមគ្គ។**

## មគ្គង្គមាន ១២ ប្រភេទ

**Twelve path factors**

**១.សម្មាទិដ្ឋិ** (Right View) ការយល់ត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ៧៩។

## សម្មាទិដ្ឋិចែកជា ២ គឺ

១.**លោកិយសម្មាទិដ្ឋិ** (mundane-right view) គឺយល់ថាការធ្វើទានមានផល មាតាបិតាមានគុណជាដើម។

២.**លោកុត្តរសម្មាទិដ្ឋិ** (supramundane-right view) គឺយល់ច្បាស់ពីអរិយសច្ចៈ៤ សម្រេចមគ្គផល មានព្រះនិព្វានជាអារម្មណ៍។

## តើសម្មាទិដ្ឋិមានអ្វីទំនុកបម្រុងឱ្យកើត?

មានធម៌៥ គឺ

១.**សីល** ការរក្សាសីល

២.**សុត្តៈ** ការស្តាប់ព្រះធម៌

៣.**សាកច្ឆា** សន្ទនាព្រះធម៌

៤.**សមថៈ** ចម្រើនសមថភាវនា

៥.**វិបស្សនា** ចម្រើនបញ្ញា ។

២.**សម្មាសង្កប្បៈ** (Right Intention or Thought) ការត្រិះរិះត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ វិតក្កចេតសិកក្នុងកាមសោភណចិត្ត២៤ បឋមជ្ឈានចិត្ត ១១។

**កុសលវិតក្កៈ ៣ ប្រការ**

**១.នេក្ខម្មសង្កប្ប** ត្រិះរិះចេញចាកកាម គឺកាយនេក្ខម្ម និងចិត្តនេក្ខម្ម អលោភជាសមុដ្ឋាន។

**២.អព្យាបាទសង្កប្ប** ត្រិះរិះក្នុងការមិនព្យាបាទ ដោយមេត្តា គឺអទោសៈ។

**៣.អវិហិំសាសង្កប្បៈ** ត្រិះរិះក្នុងការមិនបៀតបៀន ដោយមុទិតា និងឧបេក្ខា គឺអមោហៈ។

**៣.សម្មាវាចា** (Right Speech) សម្ដីត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ សម្មាវាចាចេតសិក ក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨។

**វៀរចាកសម្ដី ៤ យ៉ាងគឺ**

១.**មុសាវាទា វេរមណី** វៀរចាកពាក្យកុហក

២.**បិសុណាវាចា វេរមណី** វៀរចាកពាក្យញុះញង់

៣.**ផរុសវាចា វេរមណី** វៀរចាកការនិយាយពាក្យទ្រគោះបោះបោក

៤.**សម្ផប្បលាបា វេរមណី** វៀរចាកការនិយាយពាក្យឥតប្រយោជន៍។ វាចាល្អ ៥ យ៉ាងគឺ ត្រូវកាល ពាក្យពិត ពាក្យល្អទន់ភ្លន់ ពាក្យមានប្រយោជន៍ ពាក្យប្រកបដោយមេត្តា។

**៤.សម្មាកម្មន្ត** (Right Action) ការងារត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ សម្មាកម្មន្តចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨។

## វៀរចាកកាយកម្ម ៣ គឺ

១.**បាណាតិបាតា វេរមណី** វៀរចាកការសម្លាប់សត្វ

២.**អទិន្នាទានា វេរមណី** វៀរចាកការលួចទ្រព្យគេ

៣.**កាមេសុមិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តិខុសក្នុងកាម។

**៥.សម្មាអាជីវ** (Right Livelihood) ការចិញ្ចឹមជីវិតត្រូវជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ សម្មាអាជីវចេតសិកក្នុងមហាកុសលចិត្ត ៨ និងលោកុត្តរចិត្ត ៨។

## វៀរចាកបាបធម៌ ៥ គឺ

**១.កុហនា** = ការកុហក

**២.លបនា** = ការនិយាយរាក់ទាក់

**៣.នេមិត្តិកតា** = ការធ្វើនិមិត្តផ្សេងៗដោយកាយ ឬវាចា

**៤.និប្បេសិកតា** = ប្រើសម្តីដូចខ្មោស គឺនិយាយទាក់កោសយកលាភផ្សេង ៗ

**៥.លាភេន លាភំ និជិគីសនតា** ការយកលាភទៅទាក់លាភ។

**អានេសនៈ ២១**

**១.វេឡុទាន** ការឱ្យឫស្សី

២.**បត្តទាន** ការឱ្យស្លឹកឈើ

៣.**បុប្ផទាន** ការឱ្យផ្កាឈើ

៤.**ផលទាន** ការឱ្យផ្លែឈើ

៥.**ទន្តកដ្ឋទាន** ការឱ្យឈើស្ទន់

៦.**មុខោទកទាន** ការឱ្យទឹកលុបមុខ

៧.**សិនានទាន** ការឱ្យវត្ថុសម្រាប់កក់ងូត

៨.**ចុណ្ណទាន** ការឱ្យគ្រឿងលម្អិតសម្រាប់លាប

៩.**មត្តិកទាន** ការឱ្យដីស្អិត

១០.**ចាដុកម្យតា** ការប្រព្រឹត្តិបន្ទាបកាយ វាចា

១១.**មុគ្គសូបតា** ការពោលពាក្យពិតខ្លះ មិនពិតខ្លះ

១២.**បារិភដ្យតា** ការផ្គាប់ផ្គន់ត្រកូល

១៣.**ជង្ឃបេសនិកំ** ការបម្រើត្រកូលដោយកម្លាំងស្មង

១៤.**វេជ្ជកម្ម** ការធ្វើពេទ្យមើលជម្ងឺ

១៥.**ទូតកម្មំ** ការធ្វើជាទូត

១៦.**បហិណគមនំ** ការទទួលបម្រើត្រកូលឱ្យគេប្រើទៅមក

១៧.**បិណ្ឌប្បដិបិណ្ឌកំ** ការឱ្យអាហារបិណ្ឌបាតដល់ត្រកូល ហើយស្វែងរកបរិភោគដោយខ្លួន

១៨.**ទានូបទានំ** ការឱ្យទៅវិញទៅមក

១៩.**វត្ថុវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូមើលជ័យភូមិ

២០.**នក្ខត្តវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូទាយនក្ខត្តឫក្ស

២១.**អង្គវិជ្ជា** ការរៀនវិជ្ជាធ្វើគ្រូទាយលក្ខណៈរូបកាយ។

ពាក្យថា **អនេសនៈ** គឺការស្វែងរកដោយមិនគួរសម លាភដែលបព្វជិតមិនគួរស្វែរក ព្រោះជាអំពើសៅហ្មង ជាការចិញ្ចឹមជីវិតខុសរបស់អ្នកបួស។

## ជំនួញដែលគ្រហស្ថមិនត្រូវធ្វើមាន ៥

**១.សត្ថវណិជ្ជា** ជួញគ្រឿងសាស្ត្រាវុធ

**២.សត្តវណិជ្ជា** ជួញមនុស្ស

**៣.មំសវណិជ្ជា** ជួញសាច់

**៤.មជ្ជវណិជ្ជា** ជួញគ្រឿងស្រវឹង

**៥.វិសវណិជ្ជា** ជួញថ្នាំពិស ថ្នាំពុល។

## សាច់បរិសុទ្ធ ៣ យ៉ាងគឺ

១.**មិនបានឃើញ** មិនបានឃើញគេសម្លាប់មកដើម្បីខ្លួន

២.**មិនបានឮ** គឺមិនបានឮសំឡេងគេសម្លាប់ដើម្បីខ្លួន

៣.**មិនបានរង្កៀស** គឺមិនមានសេចក្តីសង្ស័យថា គេសម្លាប់មកដើម្បីខ្លួនបរិភោគ។

**៦.សម្មាវាយាម** (Right Effort) ការព្យាយាមត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ វីរិយចេតសិក ក្នុងសោភណចិត្ត ៥៩ ឬ ៩១។

**បធាន ៤ យ៉ាង**

**១.សំវរប្បធាន** ព្យាយាមមិនឱ្យបាបកើតឡើងក្នុងសន្តាន

**២.បហានប្បធាន** ព្យាយាមលះបាបដែលកើតឡើងហើយ

**៣.ភាវនាបធាន** ព្យាយាមញុំាងកុសលឱ្យកើតឡើងក្នុងសន្តាន

**៤.អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឱ្យសាបសូន្យ។

**៧.សម្មាសតិ** (Right Mindfulness) ការរលឹកត្រូវ ជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ សតិចេតសិក ក្នុងសោភណចិត្ត ៥៩ (សតិប្បដ្ឋាន៤)។

**៨.សម្មាសមាធិ** (Right Concentration) ការតម្កល់ចិត្តនឹងត្រូវជាផ្លូវទៅកាន់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ ឯកគ្គតា-ចេតសិក ក្នុងសោភណចិត្ត ៥៩ ឬ៩១។

**៩.មិច្ឆាទិដ្ឋិ** (Wrong View) ការយល់ខុស ជាផ្លូវទៅកាន់ទុគ្គតិភូមិ អង្គធម៌បានដល់ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤។

**១០.មិច្ឆាសង្កប្បៈ** (Wrong Intention) ការត្រិះរិះខុស ជាផ្លូវទៅកាន់ទុគ្គតិភូមិ អង្គធម៌បានដល់ វិតក្កចេតសិកក្នុងអកុសលចិត្ត ១២។

**១១.មិច្ឆាវាយាមៈ** (Wrong Effort) ការព្យាយាមខុស ជាផ្លូវទៅកាន់ទុគ្គតិភូមិ អង្គធម៌បានដល់ វីរិយចេតសិកក្នុងអកុសលចិត្ត ១២។

**១២.មិច្ឆាសមាធិ** (Wrong Concentration) ការតម្កល់ចិត្តនឹងខុស ជាផ្លូវទៅកាន់ទុគ្គតិភូមិ អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងអកុសលចិត្ត ១១ (វៀរវិចិកិច្ឆា១)។

## អដ្ឋមគ្គ ៨ នាំទៅកាន់សុគតិ និងនិព្វាន

១.សម្មាទិដ្ឋិ ២.សម្មាសង្កប្បៈ ៣.សម្មាវាចា ៤.សម្មាកម្មន្តៈ ៥.សម្មាអាជីវៈ ៦.សម្មាវាយាមៈ ៧.សម្មាសតិ ៨.សម្មាសមាធិ។

## អដ្ឋមគ្គដែលជាផ្លូវទៅកាន់ទុគ្គតិភូមិ

១.មិច្ឆាទិដ្ឋិ ២.មិច្ឆាសង្កប្បៈ ៣.មិច្ឆាវាយាម ៤.មិច្ឆាសមាធិ។

ក្នុងមគ្គង្គមានអង្គធម៌ ៩ គឺ បញ្ញា វិតក្កៈ សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ វីរិយៈ សតិ ឯកគ្គតា និងទិដ្ឋិ។

ក្នុងព្រះសូត្រ ព្រះពុទ្ធសម្ដែងអង្គមគ្គមាន ១៦ ប្រការ ក្រៅពីអង្គមគ្គ ១២ ប្រការ នៅមានមគ្គ ៤ ប្រការគឺ៖

មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាសតិ។ តែបើសង្គ្រោះអង្គធម៌បរមត្ថមិនមានដោយចំពោះ បានតែសង្គ្រោះចូលក្នុងអកុសលចិត្តុប្បាទ ដែលទាក់ទងដោយវចីទុច្ចរិត កាយទុច្ចរិត ការចិញ្ចឹមជីវិតខុស និងការរលឹកដល់វត្ថុដែលមិនល្អផ្សេងៗ ឬមិនដូច្នោះ មិច្ឆាសតិសំដៅយកការរលឹកអារម្មណ៍ដទៃដែលក្រៅពីសតិប្បដ្ឋាន។

## ចំណាំបន្ថែម

អហេតុកចិត្ត ១៨ និងឯកគ្គតាចេតសិកដែលនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្តរមែងមិនបានមគ្គង្គ គឺមិនបានចាត់ជាអង្គមគ្គទាំងនេះ ព្រោះអហេតុកចិត្ត ១៨ មិនមានសម្បយុត្តហេតុឡើយ កាលមិនមានហេតុប្រកបហើយ ក៏មិនជាហេតុជាផ្លូវឱ្យដល់សុគតិ និងព្រះនិព្វានបានឡើយ។

ចំណែកឯកគ្គតាចេតសិក ដែលនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្តដែលមិនរាប់ជាអង្គមគ្គ ព្រោះហេតុថា វិចិកិច្ឆាសម្បយុត្តចិត្តនោះសូម្បីប្រកបដោយមោហៈក៏ពិត តែមានត្រឹមតែហេតុមួយ ទើបមានកម្លាំងមិនច្រើន ថែមទាំងមានការមិនជឿជាក់ក្នុងចិត្តប្រកបទៀត ធ្វើឱ្យកម្លាំងដែលមានមិនច្រើននោះ ត្រូវថយចុះទៀត ព្រោះមានអារម្មណ៍បាចសាចទើបមិនដល់នូវភាពជាសមាធិក្នុងមគ្គ។

## ៤.ឥន្ទ្រិយ ២២

វចនត្ថថាៈ **ឥន្ទដ្ឋំ ករោន្តីតិ = ឥន្ទ្រិយានិ** ធម៌ដែលធ្វើភាពជាធំ ។

**ឥន្ទដ្ឋំ ការេន្តីតិ = ឥន្ទ្រិយានិ** ធម៌ញ៉ាំងធម៌ដទៃធ្វើភាពជាធំ។

### ឈ្មោះថា ជាធំក្នុងទីនេះតើដូចម្តេច?

គឺការមានអំណាចញ៉ាំងធម៌ដទៃៗ ឱ្យប្រព្រឹត្តទៅស្របតាមខ្លួនក្នុងកិច្ចនោះៗ និងកាលបើខ្លួនខ្លាំងក្លា ធម៌ទាំងនោះក៏ខ្លាំងក្លាក្លាម កាលបើខ្លួនទន់ខ្សោយ ធម៌នោះក៏ខ្សោយតាម។

ភាពជាអ្នកគ្រប់គ្រងរបស់សភាវធម៌ ដែលជាឥន្ទ្រិយនោះ រមែងជាអ្នកគ្រប់គ្រងចំពោះធម៌ដែលកើតរួមជាមួយខ្លួន និងធ្វើកិច្ចតាមនាទីរបស់ខ្លួនប៉ុណ្ណោះ សេចក្តីថា ធម៌ដែលកើតព្រមគ្នានោះ អាចមានកិច្ចនាទីដែលត្រូវធ្វើច្រើនយ៉ាង តែភាពជាអ្នកគ្រប់គ្រងនោះ រមែងគ្រប់គ្រងបានចំពោះការងារតាមនាទីរបស់ខ្លួនប៉ុណ្ណោះ មិនឈានទៅក្នុងកិច្ចនាទីរបស់អ្នកដទៃ ដូច្នោះក្នុងកិច្ចការងារម្យ៉ាង ដែលមានកិច្ចនាទីត្រូវធ្វើច្រើនយ៉ាង ទើបត្រូវមានឥន្ទ្រិយច្រើនដូចមានអ្នកគ្រប់គ្រងច្រើននាក់ដូចជារដ្ឋបាល មានកិច្ចនាទីដែលត្រូវគ្រប់គ្រងប្រទេសតាមនយោបាយ ដែលថ្លែងប្រកាសទុកដល់ប្រជាជន ក៏បែងចែកការងារក្រសួងផ្សេងៗ ក្រសួងនីមួយៗ មានរដ្ឋមន្ត្រីជាអ្នកគ្រប់គ្រងការងារក្នុងនាទីដែលទទួលខុសត្រូវរបស់ខ្លួន ធម៌ដែលជាឥន្ទ្រិយក៏មានឧបមាដូចមន្ត្រីនោះឯង។

## ឥន្ទ្រិយមាន ២២ គឺ

## Twenty-two faculties

**១.ចក្ខុន្ទ្រិយ** (The eye faculty) ធម្មជាតិគ្រប់គ្រងក្នុងការឃើញ អង្គធម៌បានដល់ ចក្ខុបសាទរូប។

**២.សោតិន្ទ្រិយ** (The ear faculty) ធម្មជាតិគ្រប់គ្រងក្នុងការឮ អង្គធម៌បានដល់ សោតបសាទរូប។

**៣.ឃានិន្ទ្រិយ** (The nose faculty) ធម្មជាតិគ្រប់គ្រងក្នុងការដឹងក្លិន អង្គធម៌បានដល់ ឃានបសាទរូប។

**៤.ជិវ្ហិន្ទ្រិយ** (The tongue faculty) ធម្មជាតិគ្រប់គ្រងក្នុងការដឹងរស អង្គធម៌បានដល់ ជិវ្ហាបសាទរូប។

**៥.កាយិន្ទ្រិយ** (The body faculty) ធម្មជាតិគ្រប់គ្រងក្នុងកាយ អង្គធម៌បានដល់ កាយបសាទរូប។

**៦.ឥត្ថិន្ទ្រិយ** (The femininity faculty) ធម្មជាតិគ្រប់គ្រងក្នុងភាពជាស្រី អង្គធម៌បានដល់ ឥត្ថីភាវរូប។

**៧.បុរិសិន្ទ្រិយ** (The masculinity faculty) ធម្មជាតិគ្រប់គ្រងក្នុងភាពជាប្រុស អង្គធម៌បានដល់ បុរិសភាវរូប។

**៨.ជីវិតិន្ទ្រិយ** (The life faculty) ធម្មជាតិគ្រប់គ្រងក្នុងការរក្សានាមរូប អង្គធម៌បានដល់ ជីវិតរូប និងជីវិតិន្ទ្រិយចេតសិក។

**៩.មនិន្ទ្រិយ** (The mind faculty) ធម្មជាតិគ្រប់គ្រងក្នុងការទទួលអារម្មណ៍ អង្គធម៌បានដល់ ចិត្តទាំងអស់។

**១០.សុខិន្ទ្រិយ** (The pleasure faculty) physical pleasure ធម្មជាតិគ្រប់គ្រងក្នុងការសោយសុខ អង្គធម៌បានដល់ វេទនាក្នុងសុខកាយវិញ្ញាណ។

**១១.ទុក្ខិន្ទ្រិយ** (The pain faculty) physical pain ធម្មជាតិគ្រប់គ្រងក្នុងការសោយទុក្ខ អង្គធម៌បានដល់ វេទនាក្នុងទុក្ខកាយវិញ្ញាណ។

**១២.សោមនស្សិន្ទ្រិយ** (The joy faculty)mental joy ធម្មជាតិគ្រប់គ្រងក្នុងសុខតាមផ្លូវចិត្ត អង្គធម៌បានដល់ វេទនាក្នុងចិត្ត ៦២។

**១៣.ទោមនស្សិន្ទ្រិយ** (The displeasure faculty) mental pain ធម្មជាតិគ្រប់គ្រងក្នុងទុក្ខផ្លូវចិត្ត អង្គធម៌បានដល់ វេទនាចេតសិកក្នុងទោសមូលចិត្ត ២។

**១៤.ឧបេក្ខិន្ទ្រិយ** (The equanimity faculty) ធម្មជាតិគ្រប់គ្រងក្នុងឧបេក្ខា អង្គធម៌បានដល់ វេទនាចេតសិកក្នុងឧបេក្ខាចិត្ត ៥៥។

**១៥.សទ្ធិន្ទ្រិយ** (The faith faculty) ធម្មជាតិគ្រប់គ្រងក្នុងការជឿ អង្គធម៌បានដល់សទ្ធាចេតសិកក្នុងសោភណចិត្ត ៥៩។

**១៦.វីរិយិន្ទ្រិយ** (The effort faculty) ធម្មជាតិគ្រប់គ្រងក្នុងការព្យាយាម អង្គធម៌បានដល់ វីរិយចេតសិកក្នុងចិត្ត ១០៥។

**១៧.សតិន្ទ្រិយ** (The mindfulness faculty) ធម្មជាតិគ្រប់គ្រងក្នុងការរលឹកត្រូវ អង្គធម៌បានដល់ សតិចេតសិកក្នុងសោភណចិត្ត ៥៩។

**១៨.សមាធិន្ទ្រិយ** (The concentration faculty) ធម្មជាតិគ្រប់គ្រងក្នុងការធ្វើចិត្តឱ្យតាំងមាំ អង្គធម៌បានដល់ ឯកគ្គតា-ចេតសិកក្នុងចិត្ត ១០៤។

**១៩.បញ្ញិន្ទ្រិយ** (The wisdom faculty) ធម្មជាតិគ្រប់គ្រងក្នុងការដឹងច្បាស់ អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងចិត្ត ៧៩។

**២០.អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** (The faculty, "I will know what has not been known by me before") ធម្មជាតិគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ ៤ ដែលខ្លួនមិនធ្លាប់ដឹង អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងសោតាបត្តិមគ្គចិត្ត ១។

**២១.អញ្ញិន្ទ្រិយ** (The faculty, "which knowns within the limit of those known by the first path") ធម្មជាតិគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ ៤ ដែលខ្លួនធ្លាប់ដឹង អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមគ្គចិត្តខាងលើ ៣ និងផលចិត្តខាងក្រោម ៣។

**២២.អញ្ញាតាវិន្ទ្រិយ** (The faculty, "of one who has final knowledge) ធម្មជាតិគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ ៤ ស្រេចបាច់ហើយ អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងអរហត្តផលចិត្ត ១។

## ចែកឥន្ទ្រិយ ២២ ដោយភូមិ

**ឥន្ទ្រិយ ១០** គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ មាននៅក្នុងកាមធម៌ឬហៅថា កាមឥន្ទ្រិយ។

**ឥន្ទ្រិយ ៨** គឺ ជីវិតិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ មាននៅក្នុងកាមធម៌ផង រូបធម៌ផង អរូបធម៌ផង។

**ឥន្ទ្រិយ ១** គឺ សោមនស្សិន្ទ្រិយ មានក្នុងកាមភពផង រូបភពផង លោកុត្តរធម៌ផង។

**ឥន្ទ្រិយ ៣** គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ មាននៅក្នុងលោកុត្តរធម៌។

## ចែកឥន្ទ្រិយ ២២ ដោយកុសលតិកៈ

ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ជាអព្យាកតតែម្យ៉ាង។ ទោមនស្សិន្ទ្រិយ ជាអកុសលតែម្យ៉ាង។

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ជាកុសលតែម្យ៉ាង។

- សទ្ធិន្ទ្រិយ សតិន្ទ្រិយ បញ្ញិន្ទ្រិយ អញ្ញិន្ទ្រិយ ជាកុសលក៏មាន ជាអព្យាកតក៏មាន។
- ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតក៏មាន។

## ចែកឥន្ទ្រិយ២២ ដោយរូប និងនាម

**ឥន្ទ្រិយ ៧ ជារូបគឺ** ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ។

**ឥន្ទ្រិយ ១៤ គឺ** មនិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិ-ន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ជានាម។ ជីវិតិន្ទ្រិយជារូបផង ជានាមផង។

## ចែកឥន្ទ្រិយ ២២ ដោយហេតុ និងនហេតុ

**ឥន្ទ្រិយ ១៨** គឺ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតន្ទ្រិយ មនិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ ជានហេតុ។

**ឥន្ទ្រិយ ៤** គឺ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ជាហេតុ។

## ចែកឥន្ទ្រិយ ២២ ដោយសហេតុក និងអហេតុក

**ឥន្ទ្រិយ ៧ គឺ** ទោមនស្សិន្ទ្រិយ សទ្ធិន្ទ្រិយ សតិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ជាសហេតុក។

**ឥន្ទ្រិយ ៩ គឺ** ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ជាអហេតុក។

**ឥន្ទ្រិយ ៦ គឺ** ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ វិរិយិន្ទ្រិយ សមាធិន្ទ្រិយ ជាសហេតុកផង អហេតុកផង។

## ចែកឥន្ទ្រិយ ២២ ដោយខន្ធ

**ឥន្ទ្រិយ ៧ គឺ** ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជារូបខន្ធ។

**ឥន្ទ្រិយ ៥ គឺ** សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជាវេទនាខន្ធ។

**ឥន្ទ្រិយ ៨ គឺ** សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ  អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ជាសង្ខារខន្ធ។

**ឥន្ទ្រិយ១ គឺ** មនិន្ទ្រិយ ជាវិញ្ញាណក្ខន្ធ។

**ឥន្ទ្រិយ ១ គឺ** ជីវិតិន្ទ្រិយ ជារូបក្ខន្ធផង ជាសង្ខារក្ខន្ធផង។

## ចែកឥន្ទ្រិយ២២ ដោយអាយតនៈ

**ឥន្ទ្រិយ ៥** គឺ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជាអាយតនៈ៥។

**ឥន្ទ្រិយ ១**គឺ មនិន្ទ្រិយ ជាមនាយតនៈ។

**ឥន្ទ្រិយ ១៦** គឺ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ វេទនិន្ទ្រិយ ៥ និងសង្ខារក្ខិន្ទ្រិយ ៨ ជាធម្មាយតនៈ។

## ចែកឥន្ទ្រិយ ២២ ដោយធាតុ

**ឥន្ទ្រិយ ៥ គឺ** ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជាធាតុ ៥។

**ឥន្ទ្រិយ ១ គឺ** មនិន្ទ្រិយ ជាវិញ្ញាណធាតុ ៧។

**ឥន្ទ្រិយ ១៦ គឺ** ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ វេទនិន្ទ្រិយ ៥ និងសង្ខារក្ខិន្ទ្រិយ ៨ ជាធម្មធាតុ។

## ចែកឥន្ទ្រិយ២២ ដោយភព ៣

**ឥន្ទ្រិយ ៨** គឺ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ មានក្នុងកាមភព។

**ឥន្ទ្រិយ ២ គឺ** ចក្ខុន្ទ្រិយ សោតិន្ទ្រិយ មានក្នុងកាមភពផង រូបភពផង ។

**ឥន្ទ្រិយ ១២ គឺ** ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ និងសង្ខារក្ខិន្ទ្រិយ ៨ មានក្នុងកាមភពផង រូបភពផង អរូបភពផង។

## ចែកឥន្ទ្រិយ២២ ដោយកំណើត ៤

## ខណៈបដិសន្ធិ

**ទុគ្គតិសំសេទជ:** មានយ៉ាងច្រើន ៩ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ (ឬបុរិសិន្ទ្រិយ) ជីវិតិន្ទ្រិយ មនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ។

**សុគតិសំសេទជ:** មានយ៉ាងច្រើន ១៤ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិ(ឬបុរិសិន្ទ្រិយ) ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ (ឬឧបេក្ខិន្ទ្រិយ) សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ។

**មានយ៉ាងតិច ៩** គឺ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ (ឬឧបេក្ខិន្ទ្រិយ) សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ និងសមាធិន្ទ្រិយ ។

## កាមទុគ្គតិឱបបាតិក:

**មានយ៉ាងច្រើន ៩** ដូចគ្នានឹងទុគ្គតិសំសេទជៈ។

**មានយ៉ាងតិច ៦** គឺ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជីវិតិន្ទ្រិយ មនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ។

## ពួកកាមសុគតិឱបបាតិក

**មានយ៉ាងច្រើន ១៤** គឺ ដូចគ្នានឹងកាមសុគតិសំសេទជៈ។

**មានយ៉ាងតិច ១៣** វៀរបញ្ញិន្ទ្រិយ។

មនុស្សដើមកប្បមិនមានភាវិន្ទ្រិយ។

## ពួកទុគ្គតិគព្ភសេយ្យក

**មានយ៉ាងច្រើន ៥** គឺកាយិន្ទ្រិយ ឥត្ថិន្ទ្រិយ (ឬបុរិសិន្ទ្រិយ) ជីវិតិន្ទ្រិយ មនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ។

**មានយ៉ាងតិច ៤** (វៀរភាវិន្ទ្រិយ)។

## ពួកសុគតិគព្ភសេយ្យកៈ

**មានយ៉ាងច្រើន ១០ គឺ** កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ (ឬបុរិសិន្ទ្រិយ) ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ (ឬឧបេក្ខិន្ទ្រិយ) សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ។

មានយ៉ាងតិច ៨ វៀរបញ្ញិន្ទ្រិយ និងភាវិន្ទ្រិយ។

**ពួកឱបបាតិករូបព្រហ្ម** មាន ១០ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ជីវិតិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ (ឬឧបេក្ខិន្ទ្រិយ) សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ។

## ពួកអសញ្ញសត្តព្រហ្ម

**មានឥន្ទ្រិយ ១** គឺ ជីវិតិន្ទ្រិយ ។

## ពួកឱបបាតិកអរូបព្រហ្ម

**មានឥន្ទ្រិយ ៨ គឺ** ជីវិតិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ។

## ៥.ពលៈ ៩

**ពលៈ** គឺកម្លាំង បានដល់ ការមិនញាប់ញ័រ។ វចនត្ថៈថា៖

**អកម្បនដ្ឋេន** = **ពលំ** ឈ្មោះថា **ពល** ព្រោះអត្ថថា មិនញាប់ញ័រ។ ឬ **ពលីយន្តិ ឧប្បន្នេ បដិបក្ខ ធម្មេ សហន្តិ មទ្ទន្តីតិ** = **ពលានិ** ពួកធម៌ណាវមែង មានកម្លាំងគ្របសង្កត់នូវបដិបក្ខធម៌ដែលកើតឡើងហើយ និងមានសេចក្តីអត់ធន់ គឺថាញាំញីនូវបដិបក្ខធម៌ទាំងនោះ ដូច្នោះពួកធម៌នោះឈ្មោះថា **ពលៈ**។

ធម្មតាអ្នកដែលជាមេទ័ពនាយពលទាំងឡាយ រមែងមិនញាប់ញ័រក្នុងនាទីរបស់ខ្លួនយ៉ាងណា អង្គធម៌ ៩ ប្រការមានសទ្ធាជាដើម ក៏មិនញាប់ញ័រក្នុងនាទីរបស់ខ្លួនឯង ក៏យ៉ាងនោះដែរ។

**ដូចមានសាធកបាលីថា៖**

**អសទ្ធិយេ កោសជ្ជេ ច មុដ្ឋស្សច្චេ ច ឧទ្ធច្ចេ**
**អវិជ្ជាយ អហិរិកេ នោត្តប្បេ ច ន កម្បរេ។**
**តស្មា សទ្ធាទយោ សត្ត កុសលាទី ពលានិ ច**
**យុត្តេស្វេវ អកម្បេន អបុញ្ញាបិ តំ នាមិកា។**

អង្គធម៌ ៧ ប្រការ មានសទ្ធាជាដើម ដែលជាកុសល និងអព្យាកតៈទាំងនេះ ឈ្មោះថា **ពលៈ** ព្រោះហេតុមិនញាប់ញ័រ ក្នុងអកុសលធម៌តាមលំដាប់ គឺ**សទ្ធា** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុឱ្យកើតការមិនមានសទ្ធា **វីរិយៈ** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុឱ្យកើតការខ្ជិល **សតិ** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុឱ្យកើតការភ្លេចសតិ **សមាធិ** រមែងមិនញាប់ញ័រក្នុងការរវើរវាយ **បញ្ញា** រមែងមិនញាប់ញ័រដល់ការមិនដឹងធម៌តាមសេចក្តីពិត **ហិរិ** រមែងមិនញាប់ញ័រដល់ការមិនខ្មាសក្នុងបាបទុច្ចរិត សូម្បីក្នុងផ្នែកអកុសលធម៌ក៏មាន **អហិរិកៈ អនោត្តប្បៈ** ដែលប្រកបជាមួយអកុសលចិត្តទាំងនោះក៏បាន ឈ្មោះថា **ពលៈ** ព្រោះមិនមានសេចក្តីញាប់ញ័រក្នុងអកុសលធម៌ដូចគ្នាជាមួយខ្លួន តែមិន

បានរារាំងទម្លាយដោយការប្រការណាឡើយ គង់មានតែការមិនញាប់ញ័រ ព្រោះជាធម៌ដូចគ្នាជាមួយខ្លួន។

រួមសេចក្តីមកថា ធម៌ដែលជាកម្លាំងធ្វើឱ្យសម្បយុត្តធម៌ដែលកើតរួមគ្នាជាមួយខ្លួនមានភាពរឹងមាំ រហូតអាចធ្វើសេចក្តីល្អបាន ឬអាក្រក់ឱ្យសម្រេចបាន ធម៌នោះ ឈ្មោះថា **ពលៈ** ទើបមានទាំងកុសលពលៈ និងអកុសលពលៈ។

## ពលៈមាន ៩ ប្រការ

### Nine Strength or power

**១.សទ្ធាពលៈ** (The power of faith) ធម្មជាតិមិនញាប់ញ័រក្នុងការជឿ បានដល់សទ្ធាចេតសិកក្នុងសោភណចិត្ត៥៩។

**២.វីរិយពលៈ** (The power of effort) ធម្មជាតិមិនញាប់ញ័រក្នុងសេចក្តីព្យាយាម បានដល់ វីរិយចេតសិកក្នុងវីរិយចិត្ត១០៥។

**៣.សតិពលៈ** (The power of mindfulness) ធម្មជាតិមិនញាប់ញ័រក្នុងការរលឹកដោយប្រពៃ បានដល់ សតិចេតសិកក្នុងសោភណចិត្ត ៩១។

**៤.សមាធិពលៈ** (The power of concentration) ធម្មជាតិមិនញាប់ញ័រក្នុងការតម្កល់ចិត្ត បានដល់ ឯកគ្គតាចេតសិកក្នុងចិត្ត ១០៤។

**៥.បញ្ញាពលៈ** (The power of wisdom) ធម្មជាតិមិនញាប់ញ័រក្នុងការដឹងតាមពិត បានដល់ បញ្ញាចេតសិកក្នុងចិត្ត ៤៧។

**៦.ហិរិពលៈ** (The power of shame) ធម្មជាតិមិនញាប់ញ័រក្នុងការខ្មាសបាប បានដល់ ហិរិចេតសិកក្នុងសោភណចិត្ត ៥៩។

**៧.ឱត្តប្បពលៈ** (The power of fear) ធម្មជាតិមិនញាប់ញ័រក្នុងការតក់ស្លុតចំពោះបាប បានដល់ ឱត្តប្បចេតសិកក្នុងសោភណចិត្ត ៥៩។

**៨.អហិរិកពលៈ** (The power of shamelessness) ធម្មជាតិមិនញាប់ញ័រក្នុងការមិនខ្មាសបាប បានដល់ អហិរិកចេតសិកក្នុងអកុសលចិត្ត ១២។

**៩.អនោត្តប្បពលៈ** (The power of fearlessness) ធម្មជាតិមិនញាប់ញ័រក្នុងការមិនតក់ស្លុតចំពោះបាប បានដល់ អនោត្តប្ប-ចេតសិកក្នុងអកុសលចិត្ត ១២។

ពលៈ ៩ ប្រការនេះ **អហិរិក អនោត្តប្បៈ** ជាពលៈផ្នែកអកុសលតែម្យ៉ាង។

**សទ្ធា សតិ បញ្ញា ហិរិ ឱត្តប្បៈ** ជាពលៈក្នុងផ្នែកកុសលតែម្យ៉ាង **វិរិយ សមាធិ** ជាពលៈមានទាំងផ្នែកកុសល និងអកុសលលាយគ្នា ដោយហេតុនេះ ទើបចាត់ពួកពលៈនេះទុកក្នុងមិស្សកសង្គហៈ។

## ៦.អធិបតី ៤

**អធិបតី** សភាវធម៌ដែលទ្រទ្រង់សភាពជាធំក្រៃលែងជាងធម៌ដទៃកើតឡើងព្រមជាមួយខ្លួន។ មានវចនត្ថៈថា៖

**អធិកោ បតិ= អធិបតិ** ធម៌ជាធំក្រៃលែង និងមានអំណាចលើស ធម៌នោះ ឈ្មោះថា អធិបតី។

**អធិមានំ បតិ= អធិបតិ** ធម៌ជាធំជាងធម៌ដែលជាប់ ទាក់ទងនឹងខ្លួន ធម៌នោះឈ្មោះថា អធិបតី។

**យេ អត្តាធីន វត្តីនំ បត្តិយាធិបតី មតា ឆន្ទ វន្តស្ស កិន្នាម ន សិជ្ឈតីតិ អធិនា។** ធម៌ជាធំលើសជាងសហជាតធម៌នោះ ឈ្មោះថា អធិបតី ព្រោះជាបុញ្ញាភិសង្ខារ សភាវៈណានឹងមិនជាផលសម្រេចដល់បុគ្គលជាអ្នកមានឆន្ទៈមិនមាន។

ក្នុងកិច្ចការងារណាមួយ កាលមានសេចក្តីពេញចិត្ត មានសេចក្តីព្យាយាម មានចិត្តផ្តោតចំពោះការងារ និងមានការឆ្លៀវឆ្លាតការងារនោះរមែងសម្រេចបាន ដូចសម្តែងក្នុងធម្មាវតារបូរាណដីកា

**ឆន្ទវតោ កឹ នាម ន សិជ្ឈតិ** កាលមានឆន្ទៈហើយ វត្ថុដែលនឹងមិនសម្រេចមិនមាន។

**វីរិយវតោ កឹ នាម ន សិជ្ឈតិ** កាលមានវីរិយៈហើយ វត្ថុណាកាលមិនសម្រេចមិនមាន។

**ចិត្តវតោ កឹ នាម ន សិជ្ឈតិ** កាលមានចិត្តផ្តោតហើយ វត្ថុណាដែលនឹងមិនសម្រេចមិនមាន។

**បញ្ញាវតោ កឹ នាម ន សិជ្ឈតិ** កាលមានបញ្ញាហើយ វត្ថុណាដែលនឹងមិនសម្រេចមិនមាន។

## ភាពជាធំគ្រប់គ្រងសភាវធម៌មាន ២ ប្រការ

១.ជាធំជាអ្នកគ្រប់គ្រងដោយសភាពជាឥន្ទ្រិយ
២.ជាធំជាអ្នកគ្រប់គ្រងដោយសភាពជាអធិបតី ។

ភាពជាធំដោយភាពជាឥន្ទ្រិយនោះ មិនមែនជាការធំក្រៃលែងទេ គឺកាលខណៈកើតឡើងនោះ រមែងកើតព្រមៗ គ្នា បានច្រើនឥន្ទ្រិយ ដោយមិនទាស់គ្នា ព្រោះធម៌ដែលជាឥន្ទ្រិយនោះរមែងជាធំគ្រប់គ្រងចំពោះឥន្ទ្រិយរបស់ខ្លួន មិនជំទាស់គ្នាជាមួយឥន្ទ្រិយណា ព្រោះធ្វើការផ្សេងគ្នា។

ចំណែកភាពជាធំដោយភាពជាអធិបតីនោះ មានភាពជាធំក្រៃលែងជាងធម៌ដែលកើតព្រមជាមួយនឹងខ្លួន ដូច្នោះកាលកើតឡើងនោះ រមែងកើតជាអធិបតីបានត្រឹមតែមួយ ដូចជាក្នុងខណៈដែលឆន្ទៈជាអធិបតី គឺមានការពេញចិត្តយ៉ាងខ្លាំង វិរិយៈ ចិត្ត និងបញ្ញា ក៏បណ្តោយតាមឆន្ទៈក្នុងអារម្មណ៍នោះៗ ឬបើកាលវិរិយៈជាអធិបតី គឺមានសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា កើតឡើងហើយ ឆន្ទៈ ចិត្ត និងបញ្ញា ក៏បណ្តោយតាមវិរិយៈក្នុងអារម្មណ៍នោះៗ ឬបើចិត្តជាអធិបតី គឺសេចក្តីតាំងចិត្តមាំកើតហើយ ឆន្ទៈ វិរិយៈ និងបញ្ញា ក៏បណ្តោយតាមចិត្តក្នុងអារម្មណ៍នោះៗ និងកាលបើបញ្ញាជាអធិបតីកើតហើយ ឆន្ទៈ វិរិយៈ និងចិត្ត ក៏បណ្តោយតាមបញ្ញាក្នុងអារម្មណ៍នោះៗ។

# អធិបតីមាន ៤ ប្រការ

## Four predominants

**១.ឆន្ទាធិបតិ** (Predominance of desire) សភាវៈជាធំក្នុងការពេញចិត្ត បានដល់ ឆន្ទចេតសិកក្នុងទ្វិហេតុកជវនចិត្ត ១៨ តិហេតុកជវនចិត្ត ៣៤។

**២.វីរិយាធិបតិ** (Predominance of effort) សភាវៈជាធំក្នុងការព្យាយាម បានដល់ វីរិយចេតសិកក្នុងទ្វិហេតុកជវនចិត្ត ១៨ តិហេតុកជវនចិត្ត ៣៤។

**៣.ចិត្តាធិបតិ** (Predominance of consciousness) សភាវៈជាធំក្នុងការយកចិត្តទុកដាក់ បានដល់ទ្វិហេតុកជវនចិត្ត ១៨ តិហេតុ-កជវនចិត្ត ៣៤។

**៤.វិមំសាធិបតិ** (Predominance of wisdom) (Investigation) សភាវៈជាធំក្នុងការដឹងតាមសេចក្តីពិត បានដល់ បញ្ញាចេតសិកក្នុងតិហេតុកជវនចិត្ត៣៤។

<u>**ចំណាំ**</u> ជវនដែលជាអធិបតី ហៅថា សាធិបតីជវន បានដល់ជវនចិត្ត ៥២ ដួង គឺ **ទ្វិហេតុកជវនចិត្ត១៨** (លោភមូលចិត្ត៨ ទោសមូល ២ មហាកុសលញាណវិប្បយុត្ត៤ និងមហាកិរិយាញាណវិប្បយុត្តចិត្ត៤)។

**តិហេតុកជវនចិត្ត ៣៤** (មហាកុសលញាណសម្បយុត្តចិត្ត ៤ និងមហាកិរិយាញាណសម្បយុត្តចិត្ត ៤ មហគ្គតកុសលចិត្ត ៩ មហគ្គត-កិរិយាចិត្ត ៩ និងលោកុត្តរចិត្ត ៨)។

## ៧.អាហារ ៤

**អាហារ** ប្រែថា **នាំមក** គឺអាហារ ជាធម៌ដែលឧបត្ថម្ភនាំឱ្យផលធម៌កើតឡើង ។ មានវចនត្ថថាៈ **អាហរន្តីតិ= អាហារា** ធម៌ពួកណា រមែងនាំមកនូវធម៌ដែលជាផលរបស់ខ្លួនៗ។

**អាហារ** ជាហេតុឧបត្ថម្ភគាំទ្រឱ្យផលកើតឡើង និងជួយគាំទ្រតាំងនៅបាន ចម្រើនឡើងបានហាក់ដូចជាអាហារ ជាអ្នកនាំ ឬអ្នកចាត់ចែងការងារផ្សេងៗ ព្រោះធម្មតាកិច្ចការណា នឹងចាត់តាំងឡើងបានរក្សាទុកឱ្យគង់វង្សតាំងនៅបាន និងឱ្យចម្រើនរុងរឿងឡើងបាននោះ ត្រូវអាស្រ័យអ្នកចាត់ការ ឬអ្នកនាំជាសំខាន់ បើខ្វះអ្នកនាំ ឬអ្នកចាត់ការហើយ កិច្ចការនោះ និងតាំងនៅ នឹងចម្រើនឡើងមិនបាន សេចក្តីនេះយ៉ាងណា អ្នកនៅក្នុងកាមភូមិក៏យ៉ាងនោះ។

### អាហារមានអត្ថ ២ យ៉ាង

ធម៌នាំសម្បយុត្តធម៌ទៅក្រៃលែង = **អាហរន្តិ អតិវេកេន ហរន្តិ បវត្តេន្តីតិ = អាហារា។**

**អាហរន្តិ សុដ្ឋុ ហរន្តិ វហន្តិ ឯតេហីតិ = អាហារា** ធម៌ធ្វើឱ្យបច្ច័យ និងបច្ចយុប្បន្ននាំខ្លួន និងនាទីរបស់បច្ច័យ និងបច្ចយុប្បន្នប្រព្រឹត្តទៅបានដោយល្អ។

### វដ្តមាន ៣ យ៉ាង

១.**កិលេសវដ្តៈ** ការវិលវល់ គឺកិលេស

២.**កម្មវដ្ដ:** ការវិលវល់ គឺកម្ម

៣.**វិបាកវដ្ដ:** ការវិលវល់ គឺផលរបស់កម្ម។

**អាហារក្នុងទីនេះដូចម្ដេច?ហើយធ្វើឱ្យកើតអ្វី?**

**កពលិង្ការាហារ** ធ្វើឱ្យកើតរូបកលាបដែលមានឱជាជាទី ៨។

**ផស្សាហារ** ឱ្យកើតវេទនា។

**មនោសញ្ចេតនាហារ** ឱ្យកើតភព ៣។

**វិញ្ញាណាហារ** ឱ្យកើតនាមរូប ដែលកើតក្នុងបដិសន្ធិកាល (សេចក្ដីនេះ ដែលពោលជាប់ទាក់ទិននឹងផលដែលប្រាកដច្បាស់)។

## អាហារមាន ៤ ប្រការ

**Four Nutriments**

១.**កពលិង្ការាហារ** (Edible food) សភាវៈញុំាងអាហារជរូបឱ្យកើត អង្គធម៌បានដល់ ឱជានៅក្នុងអាហារផ្សេងៗ គឺអាហារជរូប។

២.**ផស្សាហារ** (Contact) សភាវៈញុំាងវេទនាឱ្យកើត អង្គធម៌បានដល់ផស្សចេតសិកក្នុងចិត្តទាំងអស់។

៣.**មនោសញ្ចេតនាហារ** (Volition) សភាវៈញុំាងវិបាកវិញ្ញាណ មានបដិសន្ធិវិញ្ញាណជាដើមឱ្យកើត អង្គធម៌បានដល់ចេតនាចេតសិកក្នុងចិត្តទាំងអស់។

៤.**វិញ្ញាណាហារ** (Consciousness) សភាវៈញុំាងចេតសិកនិងកម្មជរូបឱ្យកើត អង្គធម៌បានដល់ ចិត្តទាំងអស់។

# អធិប្បាយ

**កវលិង្ការាហារ** នាំមកនូវរូបដែលជាឱជា មានបាយទឹក នំទឹកដោះជាដើម ធ្វើឱ្យកើតអាហារសុទ្ធដ្ឋកកលាបឡើងខាងក្រោយក្នុង សន្តានរបស់សត្វទាំងឡាយ ពោលគឺសត្វទាំងឡាយកើតឡើងបានដោយអំណាចរបស់អកុសល និងកាមាវចរកុសលធម៌ហើយ សត្វនោះនឹងមានជីវិតរស់នៅបាន និងចម្រើនលូតលាស់ឡើងបានក៏ត្រូវអាស្រ័យឱជាដែលនៅក្នុងអាហារផ្សេងៗ ជាអ្នកនាំអាហារជ្ជរូបកើតឡើងសត្វទាំងឡាយនោះ កាលអាហារជ្ជរូបកើតឡើងហើយក៏ធ្វើឱ្យសត្វនោះមានជីវិតនៅបាន។

**ផស្សចេតសិក** ឈ្មោះថា **អាហារ** ព្រោះជាអ្នកនាំមកនូវវេទនាផ្សេងៗ មានសុខខ្លះ ទុក្ខខ្លះ មិនសុខ មិនទុក្ខខ្លះ។ ធម្មតាសត្វទាំងឡាយដែលមានការដឹងខ្លួនថា សប្បាយ មិនសប្បាយ ឬព្រងើយៗ ដែលជាសភាពរបស់វេទនាទាំងនេះ នឹងប្រាកដឡើងបានក៏ត្រូវអាស្រ័យការប៉ះខ្ទប់គ្នារវាងអារម្មណ៍ ទ្វារ និងចិត្តការប៉ះខ្ទប់រវាងសភាវធម៌ ៣ ប្រការនេះ ហៅថា ផស្សៈ បើមិនមានផស្សៈគឺការប៉ះខ្ទប់របស់ចិត្ត និងអារម្មណ៍ត្រង់ទ្វារនេះហើយ ការដឹងខ្លួនផ្សេងៗ នឹងប្រាកដឡើងមិនបាន និងកាលសត្វទាំងឡាយខ្វះការដឹងខ្លួននេះហើយ សេចក្តីលោភពេញចិត្តក្នុងអារម្មណ៍ផ្សេងៗ ដែលជាហេតុនៃការចម្រើនធំធាត់របស់សត្វទាំងឡាយក៏មិនបានដូចគ្នា។

**ចេតនាចេតសិក** ឈ្មោះថា **អាហារ** ព្រោះជាអ្នកនាំឱ្យវិបាកចិត្តមានបដិសន្ធិវិញ្ញាណ និងបញ្ចវិញ្ញាណជាដើមកើតឡើង ទាំងនេះព្រោះធម្មតាសត្វទាំងឡាយក្នុងលោកនេះ វៀរតែព្រះអរហន្តចេញ កាលស្លាប់ក៏រមែងកើតឡើងថ្មីជាប់តគ្នាភ្លាម និងតមកក៏បានឃើញ ការឮ ដឹងក្លិន ដឹងរស ដឹងសម្ផស្សប្រាកដឡើង តមកចិត្តដែលដឹងអារម្មណ៍ទាំងនេះ ជាវិបាកវិញ្ញាណទាំងនេះ ហើយធម៌ដែលជាហេតុនៃវិបាកវិញ្ញាណទាំងនេះ ក៏បានដល់ចេតនា ដែលមានសភាពចាត់ចែងការធ្វើផ្សេងៗ ដែលទាក់ទងដោយ កាយ វាចា ចិត្ត បើមិនមានចេតនាជាអ្នកចាត់ចែងទេ សត្វទាំងឡាយកាលស្លាប់ហើយ ក៏មិនមានការកើត ការឃើញជាដើម ចេតនាដែលជាអ្នកនាំមកឱ្យសត្វទាំងឡាយមាន ២ ប្រភេទគឺ

ចេតនាដែលប្រកបក្នុងអកុសល និងលោកិយកុសលនោះ រមែងជាអ្នកនាំឱ្យវិបាកវិញ្ញាណកើតឡើងដោយត្រង់។

ចំណែកចេតនាដែលប្រកបជាមួយចិត្តដទៃ ដែលក្រៅពីអកុសល និងលោកិយកុសលនោះ ជាអ្នកនាំសម្បយុត្តខន្ធជាមួយគ្នាកើតឡើងប៉ុណ្ណោះ។

**វិញ្ញាណាហារ** គឺចិត្តទាំងអស់ ឈ្មោះថា **អាហារ** ព្រោះនាំឱ្យចេតសិក និងកម្មជរូបកើតឡើង។ ធម្មតានាមខន្ធ ៤ គឺចិត្ត និងចេតសិក រមែងមានការកើតព្រមគ្នា រលត់ព្រមគ្នា មានអារម្មណ៍និងវត្ថុអាស្រ័យជាមួយគ្នា តែចិត្តនោះរមែងជាប្រធានក្នុងធម៌ទាំងពួង

ទើបជាអ្នកនាំចេតសិក និងកម្មជរូប ពោលគឺក្នុងបដិសន្ធិកាល បដិសន្ធិវិញ្ញាណ ជាអ្នកនាំឱ្យចេតសិក និងកម្មជរូបកើតឡើង។ ចំណែកបវត្តិកាល បវត្តិវិញ្ញាណជាអ្នកនាំឱ្យចេតសិក និងចិត្តជរូប កើតឡើង មិនបាននាំឱ្យកម្មជរូបកើតឡើងបានឡើយ ទាំងនេះ ព្រោះកម្មជរូបមិនមែនរូប ដែលកើតពីសមុដ្ឋានរបស់ចិត្ត តែជារូប ដែលកើតពីសមុដ្ឋានរបស់កម្ម យ៉ាងណាក្តី កម្មជរូបដែលកើតក្នុង បវត្តិកាល និងកម្មជរូបរបស់អសញ្ញសត្តព្រហ្មទាំងនេះ សូម្បីមិន បានកើតឡើងអាស្រ័យចិត្តក្នុងបច្ចុប្បន្ននេះក្តី តែងកើតឡើងពីអតីត កម្ម ហៅថា **កម្មវិញ្ញាណ** គឺអកុសលចិត្ត និងលោកិយកុសលចិត្តក្នុង ភពមុនៗ។

**សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយរស់នៅបាន ព្រោះអាហារ។

## សរុបសេចក្តី អាហារ

**១.កពឡិង្ការាហារ** នាំមកនូវអាហារជ្ជសុទ្ធដ្ឋកកលាប ឱ្យកើត ក្នុងសន្តានរបស់សត្វទាំងឡាយ។

**២.ផស្សាហារ** នាំមកនូវវេទនា គឺសុខខ្លះ ទុក្ខខ្លះ ឧបេក្ខាខ្លះ។

**៣.មនោសញ្ចេតនាហារ** នាំមកនូវបដិសន្ធិវិញ្ញាណ ការកើតជា មនុស្ស ទេវតា ព្រហ្ម អបាយសត្វ និងបវត្តិវិញ្ញាណ គឺការឃើញជា ដើម។

**៤.វិញ្ញាណាហារ** នាំមកនូវចេតសិក ចិត្តជរូប និងកម្មជរូប។

# ភ័យក្នុងអាហារ ៤

១.**កវលិង្ការាហារ** ភ័យគឺការប្រាថ្នា (ចំណង់)

២.**ផស្សាហារ** ភ័យ គឺការជាប់ជំពាក់

៣.**មនោសញ្ចេតនាហារ** ភ័យគឺការប្រមូលមក

៤.**វិញ្ញាណាហារ** ភ័យ គឺការធ្លាក់ចុះពោះ (ការកាន់យកកំណើត)។

## សួរថាព្រោះហេតុអ្វី?

ព្រោះសត្វទាំងឡាយសាងភ័យ គឺសេចក្តីប្រាថ្នាក្នុង **កវលិង្ការាហារ** ត្រូវប្រឈមមុខចំពោះការងារជាដើម ធ្វើការងារ មានការរាប់ដោយម្រាមដៃជាដើម ដើម្បីត្រូវការអាហារ រមែងចូលដល់ទុក្ខមិនមែនតិច។ ហើយបុគ្គលចំពូកខ្លះ សូម្បីនឹងបួសក្នុងព្រះពុទ្ធសាសនានេះ ក៏ស្វែងរកអាហារ ដោយការស្វែងរកដោយមិនសមគួរ មានវេជ្ជកម្មជាដើម នឹងជាអ្នកត្រូវរិះគន់តិះដៀលក្នុងបច្ចុប្បន្ននេះ។

ជនទាំងឡាយអ្នកមានអស្សាទៈក្នុងផស្សៈ សូម្បីបានជួបប្រទះនឹងផស្សៈ ក៏នឹងបៀតបៀនរបស់ទាំងឡាយ មានប្រពន្ធជាដើម របស់អ្នកដទៃដែលគេរក្សា។ អ្នកម្ចាស់ទ្រព្យនឹងចាប់គេ ព្រមដោយរបស់កាប់ឱ្យដាច់ជាកំណាត់ៗ ចោលត្រង់គំនរសម្រាម ឬប្រគល់ខ្លួនដល់ព្រះរាជា។ តពីនោះព្រះរាជាត្រាស់បញ្ជាឱ្យពួកគេធ្វើការងារផ្សេងៗ ដាក់ទោស និងបែកធ្លាយរាងកាយទៅ ពួកគេទទួលភ័យក្នុងទុគ្គតិ។

ភ័យក្នុងភព ៣ ដែលមានកុសល និងអកុសលកម្មនោះ ជាមូលដ្ឋាន នឹងមានមកទាំងអស់ ព្រោះការប្រមូលមកនូវកម្ម។ ព្រោះហេតុនោះការប្រមូលក្នុងមនោសញ្ចេតនាហារនោះឯងជាភ័យ។

ចំណែកបដិសន្ធិវិញ្ញាណ ក៏នឹងទទួលយកបដិសន្ធិនាមរូបនោះឯង កើតឡើងក្នុងទីកាន់យកកំណើត កាលបដិសន្ធិវិញ្ញាណនោះកើតឡើងហើយ ភ័យគ្រប់យ៉ាងក៏បានកើតឡើងដូចគ្នា ព្រោះមានបដិសន្ធិជាមូលដ្ឋាន។ (សម្មាទិដ្ឋិសូត្រ បិ.២០ និងអដ្ឋកថា)

(ចប់មិស្សកសង្គហៈ)

# ពោធិបក្ខិយសង្គហៈ

មានធម៌ ៣៧ ប្រភេទគឺ

១.សតិប្បដ្ឋាន ៤
២.សម្មប្បធាន ៤
៣.ឥទ្ធិបាទ ៤
៤.ឥន្ទ្រិយ ៥
៥.ពលៈ ៥
៦.ពោជ្ឈង្គៈ ៧
៧.មគ្គ ៨ ។

**ពោធិ** គឺជាធម៌ត្រាស់ដឹងនូវអរិយសច្ច ឬញាណក្នុងមគ្គទាំង ៤ ហៅថា **ពោធិ**។ **ពោធិ** អង្គធម៌បានដល់ បញ្ញាក្នុងមគ្គចិត្ត ៤។

**បក្ខិយ** ប្រែថា ជាពួក គឺជាពួកមគ្គញាណ។

**សង្ខេប:** ប្រែថា ដោយសង្ខេប ឬរួបរួម។

**ពោធិបក្ខិយសង្គហ** សំដៅដល់ការរួបរួមធម៌ដែលជាពួកនៃមគ្គញាណ។

**ពោធិយា បក្ខេ ភវាតិ = ពោធិបក្ខិយា** ធម៌ដែលកើតក្នុងមគ្គញាណ ៤ ឈ្មោះថា **ពោធិបក្ខិយ** បានដល់ ពោធិបក្ខិយធម៌ ៣៧។

មហានិទ្ទេសសម្តែងថា: **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយ-សម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ។** ប្រែថា ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គៈ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គ ៤ លោកហៅថា **ពោធិ។** (បិដក ៦៤ ទំព័រ ១៧៥)

## ពោធិមានអត្ថ ២ យ៉ាង

**ចត្តារិ សច្ចានិ ពុជ្ឈតីតិ = ពោធិ** ធម៌ត្រាស់ដឹងនូវអរិយសច្ចៈ ៤ ។

**ពុជ្ឈន្តិ តានិ តំ សមង្គិនោ ឯតាយាតិ= ពោធិ** ធម៌ធ្វើអ្នកដល់ព្រមនោះឱ្យត្រាស់ដឹង ។

**ពោធិបក្ខិយ** បានដល់ ធម៌ដែលមានក្នុងផ្នែកនៃធម៌ត្រាស់ដឹងនូវអរិយសច្ចៈ ៤ រាប់បញ្ចូលក្នុងសិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា។

# ១.សតិប្បដ្ឋាន ៤

**សតិ ឯវ បដ្ឋានំ** = **សតិប្បដ្ឋានំ** ធម៌ដែលជាធំតាំងមាំ។

**សតិយា បដ្ឋានំ** = **សតិប្បដ្ឋានំ** ទីតាំងរបស់សតិ។

## ពាក្យថា សតិប្បដ្ឋាន

**សតិ** ប្រែថា រលឹកបាន សេចក្តីថា រលឹកគុណធម៌ និងមិនមែនគុណដែលបានធ្វើហើយ ឬកំពុងធ្វើ ឬរលឹកដល់ពុទ្ធគុណ ធម្មគុណ សង្ឃគុណ រហូតដល់ការមានសតិ រលឹកដល់បច្ចុប្បន្នរបស់នាមរូបដោយមិនភ្លេច ខណៈនោះរមែងរារាំងកិលេសនីវរណៈឱ្យចិត្តតាំងនៅក្នុងសោភណចិត្ត បរមត្ថទីបនីដីកាសម្តែងថា៖

**សរតីតិ សតិ អត្តនា កតានិ កត្តព្វានិ ច កល្យាណកម្មានិ វា ពុទ្ធគុណាទីនិ វា អប្បមជ្ជនវសេន ឧបគច្ឆតីតិ។ សតិ** គឺការរលឹកបាន ក្នុងសេចក្តីល្អ ដែលខ្លួនបានធ្វើទៅហើយ ឬកំពុងធ្វើតទៅក្តី ឬព្រះពុទ្ធគុណជាដើមក្តី ដោយមិនភ្លេច។

**បដ្ឋាន** ប្រែថា ទីតាំង សេចក្តីថា ទីតាំងរបស់ធម៌ មានសតិជាដើម គឺនាមរូបជាអារម្មណ៍ ដែលជាទីកំណត់ដឹងដោយសតិសម្បជញ្ញក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីឱ្យដល់នូវសេចក្តីបរិសុទ្ធផុតចាកកិលេសទាំងឡាយ ដូចក្នុងមហាវារសូត្រថា **បដ្ឋាតីតិ** = **បដ្ឋានំ** ប្រែថា ទីតាំងរបស់ធម៌ គឺអារម្មណ៍ ឈ្មោះថា **បដ្ឋាន**។

**យោគីបុគ្គលលះចោលមិនបានមាន ៣ យ៉ាងគឺៈ**

១- **ឧបនិស្សយ** ត្រូវនៅក្នុងសំណាក់អាចារ្យជាអ្នកអង់អាច ។

២- **អារក្ខ** ត្រូវរក្សាឥន្ទ្រីយ៍ ៦ ឲ្យបរិបូណ៌ ។

៣-**ឧបនិពន្ធ** ត្រូវចងចិត្តទុកក្នុងសតិប្បដ្ឋាន ៤។

**យោគីបុគ្គលគួរវៀរដូចតទៅនេះគឺៈ**

១-**កម្មារាមតា** រវល់នឹងការងារផ្សេង ៗ ។

២-**និទ្ទារាមតា** រវល់តែដេក គឺដេកច្រើន ព្យាយាមប្រតិបត្តិធម៌តិច។

៣-**ភស្សារាមតា** រវល់តែនិយាយគ្នា តិរច្ឆានកថា ជជែកគ្នា គយគន់រកតែគូកននិយាយ គូកនជជែក មិនតាំងចិត្តកំណត់។

៤-**សង្គណិការាមតា** ពេញចិត្តតែក្នុងការច្របូកច្របល់ដោយពួកគណៈ មិនពេញចិត្តនៅក្នុងទីស្ងាត់ ។

៥-**អគុត្តទ្វារតា** មិនសង្រួមឥន្ទ្រីយ៍ទាំង ៦ ឱ្យបរិបូណ៌។

៦-**ភោជនេ អមត្តញ្ញុតា** មិនដឹងប្រមាណក្នុងភោជន (នៅអស់៤-៥ម៉ាត់ទៀតនឹងឆ្អែតត្រូវឈប់ នេះទើបហៅថា ដឹងប្រមាណ។

៧-**យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** ចិត្តទៅកាន់អារម្មណ៍ណាមិនកំណត់ដឹងនូវចិត្តក្នុងអារម្មណ៍នោះ ឬចិត្តរបូតទៅដោយអាការយ៉ាងណា មិនបានកំណត់ដឹងដោយអាការយ៉ាងនោះ។

# ហេតុ និងផលនៃសតិប្បដ្ឋាន

**ហេតុ** គឺជាផ្លូវមួយដែលនឹងនាំទៅកាន់ព្រះនិព្វាន។

**ផល** គឺអ្នកចម្រើនក្នុងផ្លូវសតិប្បដ្ឋាននេះនឹងបានទទួលផលពិសេស ៧ ប្រការគឺ

១.បរិសុទ្ធចាកកិលេស

២.ផុតចាកសេចក្តីសោកសៅ

៣.ផុតចាកសេចក្តីខ្សឹកខ្សួល

៤.ផុតចាកសេចក្តីទុក្ខកាយ

៥.ផុតចាកសេចក្តីទុក្ខចិត្ត

៦.ញ៉ាំងឱ្យបានអរិយមគ្គ

៧.ធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ចំពោះមុខក្នុងភពនេះ។

# អានិសង្សនៃការចម្រើនសតិប្បដ្ឋាន

ចម្រើនរយៈពេល ៧ ឆ្នាំ រមែងមានផល ២ គឺ ជាព្រះអរហន្ត ក្នុងបច្ចុប្បន្នជាតិ១ ឬនៅឧបាទិនឹងសម្រេច ជាព្រះអនាគាមី ១ ឬ ៦,៥,៤,៣,២,១,ឆ្នាំ ឬ ៧ ខែ,៦,៥,៤,៣,២,១,ខែ ៧ ថ្ងៃ។

## ព្រះតម្រាស់មុនបរិនិព្វានថា៖

ម្នាលអានន្ទ បុគ្គលណាទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈគោរព រាប់អានបូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ម្នាលភិក្ខុ

ទាំងឡាយ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយនឹងប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង។

**អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ។ អយំ តថាគតស្ស បច្ឆិមា វាចា។** គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត។

## សតិប្បដ្ឋានសូត្រ

**ឯវម្មេ សុតំ។** សូត្រនេះឈ្មោះ សតិប្បដ្ឋានសូត្រដែលខ្ញុំអានន្ទបានស្តាប់មកយ៉ាងនេះថា

**ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសទម្មំ នាម កុរូនំ និគមោ។** សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកម្មាសទម្មនិគម របស់អ្នកដែនកុរុ។

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ។** ក្នុងទីនោះឯង ទ្រង់ត្រាស់ហៅ ភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ"

**ភគវន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ។** ភិក្ខុទាំងឡាយនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស។

**ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា។** ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន។ (បិ.១៧ ទំ.២៤៤)

**កតមេ ចត្តារោ** ? សតិប្បដ្ឋានទាំង ៤ គឺអ្វីខ្លះ?

**ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។** ពិចារណានូវវេទនាក្នុងវេទនា ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។** ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។** ពិចារណានូវធម៌ក្នុងធម៌ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**ឧទ្ទេសវារកថា និដ្ឋិតា**

(ឧទ្ទេសវារកថា ចប់)

## អដ្ឋកថាអធិប្បាយឧទ្ទេសវារកថា

ពាក្យថា **កម្ចាត់បង់** មានន័យថា នាំចេញដោយការកម្ចាត់ចោលជាខណៈៗ ឬដោយការគ្របសង្កត់។ ពាក្យថា **ក្នុងលោក** គឺ

ក្នុងកាយនោះឯង។ ពិតហើយ **កាយនេះ** ទ្រង់ត្រាស់ថា **លោក** ព្រោះអត្ថថា ទ្រុឌទ្រោម ។

ពាក្យថា **ទុក្ខទោមនស្សានំ អត្ថង្គមាយ** (ដើម្បីរម្ងាប់នូវទុក្ខទាំងឡាយ) អធិប្បាយថា ដើម្បីរំលត់នូវទុក្ខទាំង ២ យ៉ាងនេះគឺទុក្ខផ្លូវកាយ១ ទោមនស្សផ្លូវចិត្ត១ ដូចជាទុក្ខរបស់ព្រះតិស្សត្ថេរជាដើម និងទោមនស្សរបស់សក្កទេវរាជជាដើម។

## ព្រះថេរៈគប់បំបាក់ជើង

តំណាលមកថា ក្នុងក្រុងសាវត្ថី បុត្ររបស់កុដុម្ពីឈ្មោះ តិស្ស លះបង់នូវទ្រព្យសម្បត្តិ ៤០ កោដិ ចេញបួសនៅតែម្នាក់ឯងក្នុងព្រៃមិនមានផ្ទះ។ ភរិយារបស់ប្អូនប្រុសលោកបានបញ្ជូនចោរ ៥០០ នាក់ ទៅសម្លាប់លោកចោល ពួកចោរបានឡោមព័ទ្ធ ព្រះថេរៈសួរថា ឧបាសកនាំគ្នាមកធ្វើអ្វី? ចោរប្រាប់ថា ពួកខ្ញុំនឹងសម្លាប់លោកឯងហ្នឹងណ៎ា។ ព្រះថេរៈសុំអង្វរថា ឧបាសកទាំងឡាយ ចូរកាន់យកខ្លួនអាត្មាភាពទុកជាគ្រឿងធានា ហើយឱ្យជីវិតដល់អាត្មាមួយយប់នេះចុះ។

ពួកចោរសួរថា សមណៈ នរណានឹងជាអ្នកប្រាកដប្រជាឱ្យលោកនៅក្នុងទីនេះ?

ព្រះថេរៈ ក៏ចាប់ដុំថ្មមួយដុំធំ គប់ឆ្អឹងស្មងជើងទាំងពីរឱ្យបាក់រួចពោលថា ឧបាសកអើយ មនុស្សដែលត្រូវគេចាប់យកជាធ្នូរ (ម្នាក់

នេះ) សមគួរឬទេ? ពួកចោរនាំគ្នាចៀសចេញទៅ បង្កាត់ភ្លើង ដេក នៅត្រង់ខាងដើមផ្លូវចង្រ្កមរបស់លោក។

កាលព្រះថេរៈគ្របសង្កត់វេទនាទុកហើយ ពិចារណាសីល ព្រោះអាស្រ័យសីលដ៏បរិសុទ្ធិ បីតិ និងបាមោជ្ជៈ ទើបកើតឡើង លំដាប់តអំពីនោះ លោកក៏ចម្រើនវិបស្សនា បំពេញសមណធម៌ រហូតពេញមួយយប់ គ្រប់យាមទាំង ៣ លុះអរុណរះឡើង ក៏បាន សម្រេចព្រះអរហត្ត បានបន្លឺឧទានថាៈ

**យើងគប់ជើងទាំង ២ ជាការទប់ស្កាត់ចំពោះចោរទាំងឡាយ យើងអៀនខ្មាសចំពោះសេចក្តីស្លាប់ ទាំងដែលនៅមានរាគៈ យើង គិតយ៉ាងនេះហើយ ក៏ឃើញច្បាស់តាមសេចក្តីពិត ដល់ពេលអរុណ រះ យើងក៏បើកនូវរនាំង ដល់នូវការអស់កិលេសពុំមានសេសសល់។**

## ទេវតាធ្លាក់នរក

សូម្បី សុព្រហ្មទេវបុត្រ មានទេពអប្សរមួយពាន់ជាបរិវារ សោយសួគ៌សម្បត្តិ បណ្តានាងទេពអប្សរមួយពាន់នោះ ទេពអប្សរ ៥០០ អង្គ កំពុងបេះផ្កាអំពីដើម ក៏ចុតិហើយធ្លាក់ក្នុងនរក។ សុព្រហ្ម ទេវបុត្រ រំពឹងគិតថាដូចម្តេចហ្ន៎ ទេពអប្សរបេះផ្កាទាំងនេះ ទើបមាន ការយឺតយូរម៉្លេះ ទ្រង់បានដឹងថាពួកនាងចុតិកើតក្នុងនរក ហើយ ទ្រង់ពិចារណាឃើញថា អាយុរបស់យើងតើប៉ុន្មានហើយហ្ន៎ ស្រាប់ តែទ្រង់ជ្រាប ព្រះជន្មាយុរបស់ព្រះអង្គ ក៏នឹងត្រូវអស់ដូចគ្នា ក៏ទ្រង់ ឃើញថា ព្រះអង្គនឹងកើតក្នុងនរកនោះឯង ទើបរន្ធត់ភ័យ ទ្រង់

ទោមនស្សយ៉ាងខ្លាំងក្លា ទ្រង់ត្រិះរិះថា ព្រះសាស្តានឹងទ្រង់បន្ទោបង់ទោមនស្សរបស់យើងនេះបាន អ្នកដទៃកម្ចាត់មិនបាន ហើយបានទ្រង់នាំទេពអប្សរ ៥០០ ដ៏សេសគាល់ព្រះមានព្រះភាគជាម្ចាស់ទូលសួរបញ្ហាថា៖

ចិត្តនេះតក់ស្លុតជានិច្ច ចិត្តនេះរន្ធត់ជានិច្ច ទាំងក្នុងកិច្ចដែលមិនទាន់កើត ទាំងក្នុងកិច្ចដែលកើតឡើងហើយ បើសេចក្តីមិនរន្ធត់តក់ស្លុតមាន ខ្ញុំព្រះអង្គសូមទូលសួរ សូមព្រះអង្គសម្តែងប្រាប់នូវការមិនតក់ស្លុតរន្ធត់នោះដល់ខ្ញុំព្រះអង្គ។ (អដ្ឋ.សតិ.ទំ.១០៤)

## ទ្រង់បានត្រាស់ប្រាប់ដល់សុព្រហ្មទេវបុត្រថា៖

ក្រៅអំពីអង្គធម៌ដែលជាគ្រឿងត្រាស់ដឹង តបៈជាគ្រឿងដុតនូវបាប ក្រៅអំពីការសង្រួមឥន្ទ្រិយ ក្រៅអំពីការលះបង់សង្ខតធម៌ទាំងពួង បានដល់ ព្រះនិញ្វាន តថាគតរកមើលមិនឃើញនូវសួស្តីរបស់សត្វទាំងឡាយឡើយ។

បទថា **និញ្វានស្ស សច្ឆិកិរិយាយ** ដើម្បីធ្វើឱ្យជាក់ច្បាស់នូវនិញ្វាន សេចក្តីថា ធ្វើឱ្យជាក់ច្បាស់នូវ **អមតធម៌** ដែលបាននាមថា **ព្រះនិញ្វាន** ព្រោះវៀរចាកតណ្ហាជាគ្រឿងរួបរឹត។

## មគ្គនេះនឹងនាំឧបទ្វវៈទាំង ៤ ចេញគឺ

សេចក្តីសោក ដែលជាវត្ថុដុតរោល១ សេចក្តីសោកខ្សឹកខ្សួលរំជួលចិត្តដែលជាការពណ៌នាផ្លូវវាចា១ សេចក្តីទុក្ខដែលជាការមិនសប្បាយផ្លូវកាយ១ ទោមនស្សដែលមិនជាការស្រស់ស្រាយផ្លូវចិត្ត

១ និងនាំគុណវិសេស ៣ យ៉ាងមកឱ្យ គឺវិសុទ្ធិសេចក្ដីបរិសុទ្ធិ១ ញាយធម៌ដែលគួរដឹង១ និព្វានការរលត់ (កិលេស)១។

## សតិប្បដ្ឋាន ៣ យ៉ាង

១.អារម្មណ៍របស់សតិ

២.ការដែលព្រះសាស្ដាទ្រង់មិនសោមនស្ស និងទោមនស្ស ក្នុងកាលសាវ័កទាំងឡាយបដិបត្តិក្នុងសតិប្បដ្ឋាន។

៣.សតិ ព្រោះអត្ថថា រលឹក ។

ពាក្យថា **មគ្គ** ព្រោះអត្ថថា ជាគ្រឿងទៅកាន់និព្វាន អ្នកមានសេចក្ដីត្រូវការនិព្វាន នឹងត្រូវធ្វើដំណើរទៅ។

## ពាក្យថា ភិក្ខុ

ពាក្យថា **ភិក្ខុ** ជាពាក្យសម្ដែងដល់បុគ្គលអ្នកញ៉ាំងវត្តបដិបត្តិឱ្យដល់ព្រម។ ម្យ៉ាងទៀត ទេវតា និងមនុស្សដទៃ ក៏ញ៉ាំងវត្តបដិបត្តិឱ្យដល់ព្រមដូចគ្នា។ ប៉ុន្តែព្រះអង្គត្រាស់ហៅថា **ភិក្ខុ** ព្រោះជាអ្នកប្រសើរ សម្ដែងដល់ភិក្ខុភាវៈដោយវត្តបដិបត្តិ។(អដ្ឋ.សតិ.ទំ.១១៧)

**អភិជ្ឈា** និង**ទោមនស្ស** មិនមែនព្រះយោគាវចរនោះ លះបង់បានក្នុងអារម្មណ៍ ត្រឹមកាយនេះប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបង់បានដូចគ្នា។ ឧបាទានក្ខន្ធ ៥ ក៏លោកហៅថា **លោក**។ លោក គឺកាយនេះឯង។

## អភិជ្ឈា គឺអ្វី?

គឺការត្រេកត្រអាល ការត្រេកត្រអាលខ្លាំងក្លា ការត្រេកអរតាមសេចក្តីភ្លើតភ្លើន ការត្រេកត្រអាលខ្លាំងនៃចិត្ត។

## ទោមនស្ស គឺអ្វី?

គឺការមិនត្រេកអរផ្លូវចិត្ត សេចក្តីទុក្ខផ្លូវចិត្ត ការមិនត្រេកអរទុក្ខវេទនាកើតពីមនោសម្ផស្ស។

ក្នុងទីនេះ **កាមឆន្ទៈ** ចូលនឹងសព្ទថា **អភិជ្ឈា, ព្យាបាទ** ចូលនឹងសព្ទថា **ទោមនស្ស**។

**អាតាបី** មានសេចក្តីព្យាយាម ទ្រង់ត្រាស់ដល់សម្មាវាយាម ដោយ **អាតប្បៈ** សេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ទ្រង់ត្រាស់ដល់កម្មដ្ឋាន ដែលឱ្យសម្រេចនូវប្រយោជន៍ទូទៅ ឬឧបាយជាគ្រឿងរក្សាកម្មដ្ឋាន ដោយសតិសម្បជញ្ញៈ ឬត្រាស់ដល់សមថៈ ដែលបានមកដោយអំណាចនៃកាយានុបស្សនា ត្រាស់សម្បជញ្ញៈ ត្រាស់ដល់ផលនៃភាវនា ដោយកម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្ស។

## ១.អានាបានបព្វៈ

ពាក្យថា **បព្វៈ** នេះ ប្រែថា សន្លាក់ ថ្នាំង ថ្នាក់ សង្កាត់ កំណត់ បែប ឬផ្នែក ( តាមគួរដល់លំនាំសេចក្តី) តែក្នុងទីនេះ សំដៅយកត្រង់ពាក្យថា សង្កាត់ ឬ កំណត់ ។ តើពិចារណាដូចម្តេច?

- ❖ ពិចារណាកាយខាងក្នុង និងខាងក្រៅ

- ❖ ពិចារណាធម៌ប្រជុំកើតឡើងក្នុងកាយ
- ❖ ពិចារណាធម៌សូន្យក្នុងកាយ និងប្រជុំកើតឡើង ហើយសូន្យទៅវិញក្នុងកាយ
- ❖ មានស្មារតីផ្ចង់ឡើង ចំពោះកាយមានមែន តែមិនមែនសត្វជាដើម
- ❖ ភិក្ខុមិនអាស្រ័យតណ្ហា និងទិដ្ឋិ
- ❖ មិនក្រៀកប្រកាន់អ្វីតិចតួចក្នុងលោកគ្រប់ឥរិយាបថទាំង ៤
- ❖ អានាបានស្សតិមានអានិសង្សច្រើន។

**អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ** ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើន បានធ្វើឱ្យរឿយៗ ហើយ រមែងញ៉ាំងសតិប្បដ្ឋានទាំង ៤ ឱ្យពេញបរិបូណ៌បាន។

- ❖ អាចញ៉ាំងវិជ្ជា និងពោជ្ឈង្គឱ្យបរិបូណ៌។

**ចម្រើនដូចម្ដេច?**

**ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់ម្លប់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឱ្យត្រង់តម្កល់សតិមានមុខឆ្ពោះទៅរកកម្មដ្ឋាន។

**អដ្ឋកថា សមន្តប្បាសាទិកា តតិយបារាជិកវណ្ណនា ពន្យល់ថា៖**

ត្រង់ពាក្យថា **អង្គុយពែនភ្នែន** បានដល់ ការអង្គុយបត់ជើងទាំងពីរ ដោយជុំវិញ គឺអង្គុយពែនភ្នែន។ ត្រង់ពាក្យថា **អាភុជិត្វា** ប្រែថា បត់ចូល។ ត្រង់ពាក្យថា **កាយឱ្យត្រង់** មានសេចក្តីថា តាំងរាងកាយចំណែកខាងលើឱ្យត្រង់ គឺឱ្យឆ្អឹងខ្នង ១៨ កំណាត់ទល់ទីបំផុត ចំពោះទីបំផុត។ ពិតប្រាកដណាស់ កាលអង្គុយបែបអាការៈយ៉ាងនេះ ស្បែកសាច់ និងសរសៃ រមែងមិនកោង។ ពេលនោះវេទនាទាំងឡាយដែលកើតមានក្នុងខណៈៗ ព្រោះការកោងនៃស្បែកសាច់ និងសរសៃទាំងឡាយនោះជាបច្ច័យ រមែងមិនកើតឡើងបាន។ កាលវេទនាទាំងនោះមិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ កម្មដ្ឋានតាំងនៅស៊ប់ល្អ រមែងដល់នូវសេចក្តីចម្រើន។ ពាក្យថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** មានសេចក្តីថា តាំងសតិចំពោះមុខឆ្ពោះទៅរកកម្មដ្ឋាន។

**ព្រះសារីបុត្រ សម្តែងក្នុងបដិសម្ភិទាមគ្គថា**

ពាក្យថា **តាំងសតិ** ឱ្យមុខឆ្ពោះទៅរកកម្មដ្ឋាន។ ពាក្យថា **បរិ** អត្ថថា កំណត់ ពាក្យថា **មុខ** ជាគ្រឿងចេញទៅ **សតិ** ប្រុងប្រយ័ត្ន។

**តម្កល់សតិថា៖**

**ភិក្ខុ នាសិកគ្គេ វា មុខនិមិត្តេ វា សតឹ ឧបដ្ឋបេត្វា និសិន្នោ ហោតិ។** ភិក្ខុតម្កល់នូវសតិត្រង់ច្រមុះ ឬត្រឹមរឹមបបូរមាត់ខាងលើ ហើយអង្គុយ។

**សោ សតោវ អស្សសតិ សតោវ បស្សសតិ។** ភិក្ខុនោះ មានសតិដកដង្ហើមចូល មានសតិដកដង្ហើមចេញ។

**១.ទីឃំ វា អស្សសន្តោ ទីឃំ អស្សាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សាមីតិ បជានាតិ** កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង។

**២.រស្សំ វា អស្សសន្តោ រស្សំ អស្សាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សាមីតិ បជានាតិ** កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចេញខ្លី។

**៣.សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុងក្នុងខណៈដកដង្ហើមចេញ។

**៤.បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវកាយសង្ខារគឺ ខ្យល់ដ៏គ្រោតគ្រាត ល្អិតនិង

ស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មានឹងរម្ងាប់នូវកាយសង្ខារគឺ ខ្យល់ដង្ហើមគ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈដកដង្ហើមចេញ។

(ចប់កាយានុបស្សនាសតិប្បដ្ឋាន)

**៥.បីតិបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ។

**៦.សុខបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ។

**៧.ចិត្តសង្ខារបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវចិត្តសង្ខារក្នុងខណៈកំពុងដកដង្ហើមចេញ។

**៨.បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ ឱ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ។

(ចប់វេទនានុបស្សនាសតិប្បដ្ឋាន)

**៩.ចិត្តបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ឱ្យដឹងច្បាស់ឱ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចេញ។

**១០.អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឱ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឱ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចេញ។

**១១.សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងតាំងចិត្តឱ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុ

សិក្សាថា អាត្មាអញនឹងតាំងចិត្តឱ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចេញ។

**១២.វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងញុំាងចិត្តឱ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងញុំាងចិត្តឱ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចេញ។

(ចប់ចិត្តានុបស្សនាសតិប្បដ្ឋាន)

**១៣.អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចេញ។

**១៤.វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈគ្រប់ខណៈដកដង្ហើមចេញ ។

**១៥.និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មា

អញនឹងជាប់តាមមើលនូវនិរោធ ក្នុងខណៈកំពុងដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធ ក្នុងខណៈកំពុងដកដង្ហើមចេញ។

**១៦.បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចេញ។

(ចប់ធម្មានុបស្សនាសតិប្បដ្ឋាន)

**តើអានាបានស្សតិមានវត្ថុ ១៦ ដូចម្តេច?**

**អានាបានស្សតិមានវត្ថុ ១៦ គឺ**

- **កាយានុបស្សនា** មាន ៤ (១-៤)
- **វេទនានុបស្សនា** មាន ៤ (៥-៨)
- **ចិត្តានុបស្សនា** មាន ៤ (៩-១២)
- **ធម្មានុបស្សនា** មាន ៤ (១៣-១៦)។

ភិក្ខុចម្រើនឈានកម្មដ្ឋាន កំណត់នាមរូបថា អង្គឈានទាំងឡាយនេះ អាស្រ័យអ្វី អាស្រ័យវត្ថុរូប **ករជកាយ** ឈ្មោះថា វត្ថុរូប អង្គឈានជានាមរូប ករជកាយជារូបធម៌ កាលនឹងគិតរកបច្ច័យនៃនាមរូបនោះ ក៏ឃើញបច្ចយាការ មានអវិជ្ជាជាដើម ទើបឆ្លងនូវសេចក្តីសង្ស័យបានថា នេះត្រឹមតែបច្ច័យ និងធម៌អាស្រ័យបច្ច័យ

កើតឡើង មិនមែនសត្វ ឬបុគ្គល ទើបកំណត់នូវត្រៃលក្ខណ៍ ព្រមទាំងបច្ច័យ ចម្រើនវិបស្សនា សម្រេចអរហត្តតាមលំដាប់ នេះជាផ្លូវនៃការផុតចាកទុក្ខរបស់ភិក្ខុមួយរូប។

## វិធីចម្រើនតាមវិសុទ្ធិមគ្គ ៨ យ៉ាង

**១.គណនា** ការរាប់

**២.អនុពន្ធនា** ការជាប់តាមខ្យល់

**៣.ផុសនា** ការប៉ះ បានសេចក្ដីថា ខ្យល់ប៉ះត្រង់ណា ឱ្យតាំងសតិទុកត្រង់នោះ

**៤.ឋបនា** ការឈប់ គឺធ្វើចិត្តឱ្យជាអប្បនាសមាធិ

**៥.សល្លក្ខណា** ការកំណត់ សំដៅដល់ការពិចារណា

**៦.វិវដ្ដនា** ការវិលត្រឡប់ សំដៅដល់ការបានមគ្គ

**៧.បារិសុទ្ធិ** សេចក្ដីបរិសុទ្ធិ សំដៅដល់ការបានផល

**៨.បដិបស្សនា** ការសម្លឹងមើលខាងក្រោយ សំដៅដល់ការពិចារណាខាងក្រោយ អំពីការបានមគ្គផលរួចហើយ ដូចពិចារណាមើលមគ្គផល និព្វាន និងកិលេសណាខ្លះដែលបានលះហើយ កិលេសណាខ្លះដែលនៅសល់។

## ២.ឥរិយាបថបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ**

**បជានាតិ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នប្បជានាតិ។** ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ (ក្នុងសាសនានេះ) ទោះដើរក្តី ដឹងច្បាស់ថា អញដើរ ទោះឈរក្តី ដឹងច្បាស់ថា អញឈរ ទោះអង្គុយ ដឹងច្បាស់ថាអង្គុយ ទោះដេកដឹងច្បាស់ថា អញដេក ទោះកាយរបស់ភិក្ខុនោះតម្កល់នៅដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយនោះដោយអាការយ៉ាងនោះៗ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ។** ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកនេះ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ។** ម្នាលភិក្ខុទាំងឡាយ បែបនេះហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ។

## ឥរិយាបថបព្វៈ មាន ៤ យ៉ាង

- **គច្ឆន្តោ** ដើរ ១
- **ឋិតោ** ឈរ ១
- **និសិន្នោ** អង្គុយ ១
- **សយានោ** ដេក ១ ។

# អដ្ឋកថាសតិប្បដ្ឋានសូត្រ

ក្នុងឥរិយាបថទាំងនោះ គប្បីជ្រាបថា សត្វតិរច្ឆាន ដូចជាឆ្កែស្រុក ឬឆ្កែចចកជាដើម កាលដើរក៏ដឹងខ្លួនថាដើរ ពិតមែន តែក្នុងឥរិយាបថនោះ ទ្រង់មិនបានត្រាស់សំដៅយកការដឹងក្នុងទីនេះទេ ព្រោះការដឹងដូច្នោះ មិនអាចលះបង់សេចក្ដីប្រកាន់ថាសត្វបាន ដកចេញនូវការយើញថាជាសត្វមិនបាន មិនមែនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ។ ចំណែកការដឹងរបស់ភិក្ខុ (អ្នកចម្រើនកាយានុបស្សនាសតិប្បដ្ឋាន) រមែងលះបង់នូវការឃើញថាជាសត្វ ដកនូវការប្រកាន់ថាជាសត្វបាន ជាកម្មដ្ឋាន និងជាសតិប្បដ្ឋានភាវនា។ ពាក្យដែលទ្រង់ត្រាស់សំដៅដល់ការឃើញច្បាស់យ៉ាងនេះថា **នរណាដើរ ការដើររបស់អ្នកណា ដើរបានព្រោះអ្វី**។

**នរណាដើរ** មានន័យថា មិនមែនសត្វ ឬបុគ្គលណាៗ ដើរឡើយ។ ពាក្យថា **ការដើររបស់នរណា** មានន័យថា មិនមែនការដើររបស់សត្វ ឬបុគ្គលណាៗ ឡើយ។ **ដើរបានព្រោះអ្វី** ដើរបានព្រោះការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត។ ភិក្ខុនោះរមែងដឹងច្បាស់យ៉ាងនេះថា គឺចិត្តកើតឡើងថា យើងនឹងដើរ ចិត្តនោះ ក៏ធ្វើឱ្យកើតវាយោធាតុ វាយោធាតុក៏ធ្វើឱ្យកើតវិញ្ញត្តិ គឺការកម្រើកកាយ ការនាំសកលកាយឈានទៅខាងមុខ ដោយការកម្រើកនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ហៅថា ដើរ។ ឥរិយាបថដទៃ មានការឈរជាដើម ក៏មានន័យដូចគ្នា។(អដ្ឋ.ទំ.៤០)

**ព្រះបុរាណាចារ្យពោលថា៖**

**នាវា មាលុតវេគេន ជិយាវេគេន តេជនំ យថា យាតិ តថា កាយោ យាតិ វាតាហតោ អយំ យន្តំ សុតវេ សេនេវ ចិត្តសុត្តវសេនិទំ បយុត្តំ កាយយន្តម្បិ យាតិ ឋាតិ និសីទតិ កោ នាម ឯត្ថ សោ សត្តោ យោ វិនា ហេតុប្បច្ចយេ អត្តនោ អានុភាវេន តិដ្ឋេ វា យទិ វា វជេ។** ទូកស្ទុះទៅដោយកម្លាំងខ្យល់ គ្រាប់ព្រួញស្ទុះទៅដោយកម្លាំងខ្សែធ្នូ យ៉ាងណា កាយនេះត្រូវខ្យល់នាំទៅ ទើបដើរទៅបាន ក៏ដូច្នោះ សូម្បីសរីរយន្ត គឺកាយនេះត្រូវបច្ច័យប្រកបហើយ ដើរ ឈរ និងអង្គុយបាន ដោយអំណាចខ្សែគឺចិត្ត ដូចជាគ្រឿងយន្តវិលទៅដោយអំណាចខ្សែទាញ ដូច្នោះ ក្នុងលោកនេះ សត្វណាៗ វៀរហេតុបច្ច័យចេញហើយ ឈរបាន ដើរបាន ដោយអានុភាពរបស់ខ្លួន សត្វនោះ ឈ្មោះអ្វីទៅ។

## ៣.សម្បជានបព្វៈ

គឺបច្ចេកទេសពិចារណា អំពីការដឹងអារម្មណ៍នៃគ្រប់ចលនារបស់រាងកាយ។ អ្នកបដិបត្តិធម៌ត្រូវដឹងគ្រប់អារម្មណ៍ នៃចលនារបស់គាត់ ឧទាហរណ៍៖

- ❑ ពេលដើរទៅមុខ ក៏ដឹងខ្លួន
- ❑ ពេលថយក្រោយក៏ដឹងខ្លួន

- ពេលលាដៃ លាជើងក៏ដឹង
- បន្ទោបង់លាមក ក៏ដឹងខ្លួន

## មានសម្បជញ្ញដូចជា

- ដើរទៅមុខថយក្រោយ ក្រឡេកមើលទិស ផ្សេងៗ
- បត់ដៃនិងជើង
- ទ្រទ្រង់សង្ឃាដី និងបាត្រ ចីវរ
- ក្នុងការបរិភោគមានផឹកស៊ី ជាដើម
- ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ និងឥរិយាបថទាំង ៤ និង ភ្ញាក់ និយាយ ស្ងៀម។

## សម្បជញ្ញមាន ៤ យ៉ាង

១.**សាត្ថកសម្បជញ្ញ** ការត្រិះរិះរំពឹងដល់សេចក្ដីវិនាស សេចក្ដីចម្រើន ហើយគេចចេញ ពីវិនាសប្រព្រឹត្តតែរឿងដែលចម្រើន។

សាត្ថកសម្បជញ្ញនោះ គឺការចម្រើនដោយធម៌ កាលបានឃើញនូវព្រះចេតិយ បានឃើញព្រះស្រីមហាពោធិ៍ ឃើញព្រះសង្ឃ ឃើញព្រះថេរៈ និងឃើញអសុភជាដើម។ គឺថាភិក្ខុនោះ ញុំាងបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតឡើង សូម្បីការឃើញព្រះចេតិយ ឬការឃើញព្រះស្រីមហាពោធិ៍ ញុំាងបីតិមានព្រះសង្ឃជាអារម្មណ៍ ឱ្យកើតឡើងព្រោះឃើញព្រះសង្ឃ ពិចារណាបីតិនោះឯងជារបស់អស់ទៅ រមែងសម្រេចព្រះអរហត្ត ឃើញព្រះថេរៈ

ទាំងឡាយ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈទាំងឡាយ ឃើញអសុភ ក៏ញុំាងឈានឱ្យកើតឡើងក្នុងអសុភនោះ ពិចារណាអសុភនោះជារបស់សូន្យទៅ រមែងសម្រេចអរហត្ត ព្រោះហេតុនោះការឃើញវត្ថុនោះ មានប្រយោជន៍ ។

២.**សប្បាយសម្បជញ្ញ** ពិចារណារឭកដល់រឿងដែលសប្បាយ ៤ យ៉ាង។

បើមនុស្សទាំងឡាយប្រជុំគ្នា ១០ យោជន៍ ១២ យោជន៍ សមគួរដល់សម្បត្តិរបស់ខ្លួន ដូចជារូបគំនូរ នាំគ្នាដើរទៅកាន់ទីនោះ លោភៈរមែងកើតឡើងដល់ភិក្ខុនោះ ព្រោះអារម្មណ៍ដែលគួរប្រាថ្នា បដិឃៈ រមែងកើតឡើង ព្រោះអារម្មណ៍មិនជាទីប្រាថ្នា មោហៈរមែងកើតឡើង ព្រោះមិនពិចារណា រមែងត្រូវអាបត្តិព្រោះកាយសគ្គៈក៏មាន រមែងជាអន្តរាយដល់ជីវិត និងព្រហ្មចារ្យក៏មាន។ តាមហេតុផលដូចពោលមកនេះ ទីនោះជាទីអសប្បាយ បើមិនមានអន្តរាយដូចដែលពោលមកហើយជាសប្បាយ។ ក្នុងការឃើញមហាពោធិ៍ក៏ដូចគ្នា។

**៣.គោចរសម្បជញ្ញៈ** យល់ដឹងក្នុងកម្មដ្ឋានទាំងឡាយដែលជាទីសប្បាយនៃចិត្តរហូតដល់វិបស្សនា ដល់ការលះកិលេស។

**ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅតែមិននាំមក រូបខ្លះមិននាំទៅតែនាំមក រូបខ្លះមិននាំទៅ ទាំងមិននាំមក រូបខ្លះនាំទៅផង នាំមកផង។**

ភិក្ខុណាជម្រះចិត្តចាកធម៌ ដែលជាគ្រឿងរារាំង ដោយការចង្ក្រម និងដោយការអង្គុយក្នុងពេលថ្ងៃ ក្នុងបឋមយាមក្នុងពេលជិតកណ្ដាលយប់ ក៏បដិបត្តិយ៉ាងនោះ សិងក្នុងមជ្ឈិមឈាម ភ្ញាក់ក្នុងបច្ឆិមយាមញ៉ាំងកាលឱ្យកន្លងទៅ ដោយការអង្គុយ និងការចង្ក្រម ធ្វើវត្តនៅលានព្រះចេតិយ និងលានព្រះស្រីមហាពោធិ៍ ស្រោចទឹកនៅព្រះស្រីមហាពោធិ៍ តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ និងប្រព្រឹត្តសមាទានខន្ធកវត្តគ្រប់យ៉ាង មានអាចារិយវត្ត និងឧបជ្ឈាយ៍វត្តជាដើម ភិក្ខុនោះធ្វើសរីរៈបរិកម្មហើយ ចូលទៅកាន់សេនាសនៈ ឱ្យរាងកាយមានការទទួលភាពកក់ក្ដៅ ហើយប្រកបរឿយៗនូវកម្មដ្ឋាន កាលដល់ពេលភិក្ខាចារ គ្រងចីវរ និងយកបាត្រ កំណត់កម្មដ្ឋានជាគោល ហើយចេញចាកអាសនៈ ប្រកបចិត្តក្នុងកម្មដ្ឋានយ៉ាងនោះ ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចម្រើនពុទ្ធានុស្សតិកម្មដ្ឋាន ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចម្រើនកម្មដ្ឋានដទៃ ផ្អាកកម្មដ្ឋាននោះចុះ ដូចជាការដាក់ចុះនូវរបស់កាន់ទុកត្រង់ជើងជណ្ដើរ កាន់យកបីតិ មានព្រះពុទ្ធជាអារម្មណ៍ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចេតិយធំធ្វើប្រទក្សិណ ៣ ជុំហើយថ្វាយបង្គំទិសទាំង ៤។

**នាំទៅ មិននាំមក** មានន័យថា ភិក្ខុ និងសាមណេរទាំងឡាយ សួរថា លោកដ៏ចម្រើនមនុស្សទាំងឡាយនោះត្រូវជាអ្វីនឹងលោក ភិក្ខុអង្គនោះពោលថា លោកសួរព្រោះឃើញអ្វី ភិក្ខុនិងសាមណេរទាំងនោះពោលថា ឃើញពួកគេស្រឡាញ់លោកខ្លាំង

ណាស់។ ភិក្ខុនោះក៏សរសើរ អ្នកស្រុកនោះថា អ្នកដ៏មានអាយុទាំងឡាយកិច្ចណា ដែលមាតាបិតាធ្វើបាន ដោយលំបាកកិច្ចនោះពួកគេធ្វើដល់យើង សូម្បីចីវររបស់ពួកយើង ក៏ជារបស់គេ ពេលមានភ័យក៏ឱ្យយើងផុតភ័យ ពេលឃ្លានក៏ឱ្យឆ្អែត អ្នកដែលជាឧបការដល់យើងដូច្នេះ មិនមានឡើយ។

**មិននាំទៅ តែនាំមក** មានន័យថា ភិក្ខុធ្វើវត្តបដិបត្តិដូចដែលពោលហើយ ភ្លើងធាតុរំលាយអាហារថ្មីអស់ទៅ ក៏ដុតសាច់ក្រពះញើសក៏ហូរជោកខ្លួន កម្មដ្ឋានមិនឡើងកាន់វិថី ភិក្ខុនោះគ្រងចីវរកាន់បាត្រ ថ្វាយបង្គំព្រះចេតិយយ៉ាងរហ័ស ចូលទៅកាន់ស្រុកដើម្បីយាគូ តាំងពីព្រលឹម ភិក្ខុទើបតែឆាន់យាគូបាន ២-៣ មាត់តែជោធាតុកើតពីកម្ម ក៏ឈប់ដុតសាច់ក្រពះ បែរមកដុតអាហារថ្មីភិក្ខុនោះក៏បានរលត់សេចក្តីស្រេកឃ្លាន ដូចស្រោចទឹក១០០ ក្អម ក៏ឆាន់យាគូ ផ្តើមការកំណត់កម្មដ្ឋានជាគោល លាងបាត្រ និងខ្ពុរមាត់ហើយ ចម្រើនកម្មដ្ឋានរឿយៗ ទៅ ក្នុងចន្លោះពេលដែលមិនទាន់បានឆាន់ភត្តាហារ និមន្តទៅបិណ្ឌបាតកន្លែងដែលមិនទាន់បានទៅឆាន់អាហារដោយការកំណត់កម្មដ្ឋាននោះជាគោល បន្ទាប់ពីនោះមក ក៏បានកាន់យកកម្មដ្ឋានដែលបានកំណត់ហើយនោះនិមន្តមកវិញ។

**មិននាំទៅ ទាំងមិននាំមក** មានសេចក្តីថា ភិក្ខុទាំងឡាយឆាន់ យាគូហើយ ផ្តើមចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ក្នុង

ព្រះពុទ្ធសាសនានេះរាប់មិនអស់ នៅកោះសីហឡទ្វីប ក្នុងរោងឆាន់របស់អ្នកស្រុកនោះៗ មិនមានអាសនៈណាមួយ ដែលភិក្ខុឆាន់យាគូហើយ មិនបានសម្រេចអរហត្តឡើយ។

ចំណែកភិក្ខុមានសេចក្តីប្រមាទ លះបង់នូវធុរៈទម្លាយវត្តដែលគប្បីធ្វើ មានចិត្តក្រាស់ដោយចេតោខីលធម៌ ៥ យ៉ាង (ធម៌ឱ្យវិនាស គឺសេចក្តីសង្ស័យ ១.ក្នុងព្រះពុទ្ធ ២.ក្នុងព្រះធម៌ ៣.ក្នុងព្រះសង្ឃ ៤.ក្នុងសិក្ខា ៥.សេចក្តីក្រោធក្នុងសព្រហ្មចារី) មិនខ្វល់ក្នុងកម្មដ្ឋាន ចូលទៅកាន់ស្រុកបិណ្ឌបាត ដើរស្និទ្ធស្នាលជាមួយគ្រហស្ថបរិភោគរួមជាមួយគ្រហស្ថ ដែលមិនសមគួរ ជាអ្នកចេញទៅទទេ។

**នាំទៅផង ទាំងនាំមកផង** គឺទៅក៏ចម្រើនកម្មដ្ឋាន ពេលត្រឡប់មក ក៏ចម្រើនកម្មដ្ឋាន។

កុលបុត្តទាំងឡាយ ដែលប្រាថ្នាប្រយោជន៍ បួសក្នុងព្រះសាសនានេះហើយ ១០ រូបខ្លះ ២០ រូបខ្លះ ១០០ រូបខ្លះ ក៏ធ្វើកតិកាគ្នាថា អាវុសោទាំងឡាយយើងបួស មិនមែនគេចម្ចាស់បំណុល មិនមែនបួសព្រោះគេចភ័យ មិនមែនបួសដើម្បីអាជីព តែដើម្បីផុតទុក្ខទើបបួសក្នុងព្រះសាសនានេះ ព្រោះដូច្នេះ បើកិលេសកើតឡើងក្នុងខណៈដើរ បើកិលេសកើតឡើងក្នុងខណៈឈរ បើកិលេសកើតឡើងក្នុងខណៈអង្គុយ បើកិលេសកើតឡើងក្នុងខណៈដេក ចូរគ្រប សង្កត់ក្នុងខណៈនោះៗចុះ។ ភិក្ខុទាំងឡាយកាលព្រមព្រៀងគ្នាយ៉ាងនេះហើយ ពេលចូលស្រុកដើម្បីភិក្ខាចារ ក៏មនសិការកម្មដ្ឋាន

រឿយៗ ទៅ។ ភិក្ខុនោះមិនឈានជើងដោយចិត្តប្រាសចាកកម្មដ្ឋានឡើយ សូម្បីឈានទៅមុខ ឬឈានថយក្រោយ។ ចម្រើនវិបស្សនាចុះកាន់អរិយភូមិ បើមិនអាចយ៉ាងនោះ ក៏អាចគ្របសង្កត់កិលេសនោះបាន នេះឈ្មោះថា **ទាំងនាំទៅ និងនាំមក**។

**៤.អសម្មោហសម្បជញ្ញៈ** ការពិចារណាយល់ច្បាស់ដោយមិនភ្លេចភ្លាំងស្រពិចស្រពិលសតិ។

បុថុជ្ជនអន្ធពាល កាលដើរទៅជាដើម ក៏វង្វេងគិតថា ខ្លួនដើរទៅ ការដើរទៅនោះ ខ្លួនធ្វើឱ្យកើតឡើង អញដើរទៅ ការដើរទៅអញធ្វើឱ្យកើត យ៉ាងណា ភិក្ខុក្នុងសាសនានេះ មិនវង្វេងដូច្នោះទេ កាលចិត្តគិតថា អញនឹងដើរទៅ វាយោធាតុក៏កើតពីចិត្ត ញ៉ាំងវិញ្ញត្តិឱ្យកើតឡើង រមែងកើតឡើងដោយចិត្តនោះឯង។ កាលរាងឆ្អឹងនោះឈានទៅយ៉ាងណា កាលបើជើងម្ខាងលើកឡើង ធាតុ ២ គឺ បឋវីធាតុ តេជោធាតុ មានកម្លាំងខ្លាំងឡើង។ ក្នុងខណៈដែលដាក់ជើងចុះ មានកម្លាំងខ្សោយចុះ ធាតុ ២ គឺវាយោធាតុ តេជោធាតុ មានកម្លាំងខ្សោយចុះ ធាតុ ២ ក្រៅនេះមានកម្លាំងខ្លាំងឡើង។

ក្នុងការដើរទៅមុខជាដើមនោះ នរណាមួយឈានទៅ ឬការឈានទៅរបស់អ្នកណា ដោយបរមត្ថ ធាតុទាំងឡាយប៉ុណ្ណោះដើរ ធាតុទាំងឡាយប៉ុណ្ណោះឈរ ធាតុទាំងឡាយប៉ុណ្ណោះអង្គុយ ធាតុទាំងឡាយប៉ុណ្ណោះដេក ក្នុងចំណែកនៃឥរិយាបថនោះៗ ចិត្តដួងដទៃកើតឡើង ចិត្តដួងដទៃរលត់ទៅ ព្រមជាមួយរូប ប្រព្រឹត្តទៅដូច

ជាក្រសែទឹកហូរដែលមិនដាច់ ដូច្នេះឈ្មោះថា **អសម្មោហសម្បជញ្ញ**។

## ស្មារតីដឹងវិថីចិត្តសម្រេចដឹងអារម្មណ៍

១.**ភវង្គចិត្ត** ញ៉ាំងភវង្គកិច្ច ជាអង្គនៃឧបបត្តិភព ឱ្យសម្រេចឡើង។

២.**កិរិយាមនោធាតុ** រំពឹងដល់អារម្មណ៍បន្ទាប់ពីភវង្គចិត្តនោះ ញ៉ាំង អាវជ្ជនចិត្តឱ្យកើតឡើង។

៣.**ចក្ខុវិញ្ញាណ** ញ៉ាំងទស្សនកិច្ចឱ្យសម្រេច បន្ទាប់ពីកិរិយាមនោធាតុនោះរលត់ទៅ។

៤.**វិបាកមនោធាតុ** ញ៉ាំងសម្បដិច្ឆន្នកិច្ច (កិច្ចទទួលអារម្មណ៍) ឱ្យ សម្រេចបន្ទាប់ពីចក្ខុវិញ្ញាណរលត់ទៅ។

៥.**វិបាកមនោវិញ្ញាណធាតុ** ញ៉ាំងសន្តីរណកិច្ច (កិច្ចគឺការពិចារណាអារម្មណ៍) ឱ្យសម្រេចកើតឡើង។

៦.**កិរិយាមនោវិញ្ញាណធាតុ** ញ៉ាំងវោដ្ឋព្វនកិច្ច (កិច្ចគឺការកំណត់អារម្មណ៍តាមបញ្ចទ្វារ) ឱ្យសម្រេចកើតឡើង។

៧.**ជវនចិត្ត** រមែងស្ទុះទៅ ៧ ខណៈបន្ទាប់អំពីកិរិយាមនោវិញ្ញាណធាតុរលត់ទៅ។

សូម្បីការដើរ ការឈរ ការអង្គុយ ការដេក ការនិយាយ ការស្ងៀមនោះ ក៏គប្បីមានការដឹងខ្លួនដោយ **អសម្មោហសម្បជញ្ញ**។

ព្រះមហាសិវត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា ភិក្ខុណាដើរ ឬចង្រ្កម ក្រោយមកឈរស្ងៀម កាលពិចារណាឃើញនាមរូប ដែលប្រព្រឹត្តទៅក្នុងវេលាចង្រ្កម រលត់ទៅក្នុងខណៈនៅស្ងៀមនោះឯង ឈ្មោះថា ធ្វើសេចក្ដីដឹងខ្លួនក្នុងការដើរ។

## ៤.បដិក្កូលមនសិការបព្វៈ

មានស្មារតីពិចារណានូវអាការ ៣២ ប្រការ ដោយសភាពមិនស្អាតជារបស់បដិកូល គ្រប់ឥរិយាបថទាំង ៤។

**កាយគតាសតិកម្មដ្ឋាន ដោយឧគ្គហកោសល្យ ៧ គឺ ដោយវាចា ដោយចិត្ត ដោយពណ៌ ដោយសណ្ឋាន ដោយទិស ដោយឱកាស** (ទីអាស្រ័យ) **ដោយបរិច្ឆេទ** (ការប្រកាសទីបំផុត)។

## អាការ ៣២ ប្រការ

**១.កេសា** សក់មានសណ្ឋានដូចផ្លែផ្កាំ មានចំនួន ៩ លាន

**២.លោមា** រោមមានពណ៌លឿង មាន ៩ កោដិ

**៣.នខា** ក្រចកមានពណ៌ដូចស្រកាត្រី មាន ២០

**៤.ទន្តា** ធ្មេញមានច្រើនពណ៌ ឬប្រាកដដូចគ្រាប់ឃ្លោក មាន ៣២

**៥.តចោ** ស្បែកមានច្រើនពណ៌ មានសជាដើម

**៦.មំសំ** សាច់មានពណ៌ដូចផ្កាចារ មាន ៩០០ ដុំ

**៧.នហារូ** សរសៃមានពណ៌សទាំងអស់មាន៩០០ សរសៃ

**៨.អដ្ឋិ** ឆ្អឹងមានពណ៌ស មាន ៣០០កំណាត់

**៩.អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹងមានពណ៌ស

**១០.វក្កំ** តម្រងបស្សាវៈមានពណ៌ក្រហមមាន ២ ដុំ

**១១.ហទយំ** បេះដូងពណ៌ក្រហម

**១២.យកនំ** ថ្លើមពណ៌ក្រហមព្រឿងៗ

**១៣.កិលោមកំ** វាវមានពណ៌ស ដូចសំពត់ទុកូលពស្រ្ត

**១៤.បិហកំ** ក្រពះមានពណ៌ខៀវដូចផ្កាជ្រៃ

**១៥.បប្ផាសំ** សួតមានពណ៌ក្រហម

**១៦.អន្តំ** ពោះវៀនធំមានពណ៌សដូចដុំស្ករស

**១៧.អន្តគុណំ** ពោះវៀនតូចមានពណ៌ដូចដើមកុមុទ

**១៨.ឧទរិយំ** អាហារថ្មីមានពណ៌ច្រើន

១៩.**ករីសំ** អាហារចាស់

២០.**មត្ថលុង្គំ** ខួរក្បាលមានពណ៌ដូចផ្សិតក្បាលពស់

២១.**បិត្តំ** ប្រមាត់មានពណ៌ដូចប្រេងល្ងដែលខាប់មាន ២ គឺ

**ក.ពទ្ធបិត្ត១**

**ខ.អពទ្ធបិត្ត១**

២២.**សេម្ហំ** ស្លេស្មដូចស្លឹកខ្ទឹងក្រាស់

២៣.**បុព្វោ** ខ្ទុះមានពណ៌ដូចស្លឹកឈើទុំ

២៤.**លោហិតំ** ឈាមមាន ២ គឺ

១.**សន្និចិតលោហិត** លោហិតកក

២.**សំសរណលោហិត** លោហិតរាវ

២៥.**សេទោ** ញើសមានពណ៌ដូចប្រេងល្ង

២៦.**មេទោ** ខ្លាញ់ខាប់ពណ៌ដូចទឹករមៀត

**២៧.អស្សុ** ទឹកភ្នែកពណ៌ដូចប្រេងល្ង

**២៨.វសា** ខ្លាញ់រាវ ពណ៌ដូចប្រេងដូង

២៩.**ខេឡោ** ទឹកមាត់មានពណ៌ដូចពពុះទឹក

៣០.**សង្ឃាណិកា** ទឹកសម្បោរមានពណ៌ដូចខ្ទិះត្នោតខ្ចី

៣១.**លសិកា** ទឹករំអិលមានពណ៌ដូចផ្កាកណ្ណិកា

៣២.**មុត្តំ** ទឹកមូត្រមានពណ៌ដូចសណ្តែកជ្រក់។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ។ ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ។** ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**កាយគតាសតិ** បានដល់ សម្លឹងកាយខ្លះ មានកាយជាអារម្មណ៍ខ្លះ។ កាលពោលថា **សម្លឹងកាយ** គឺពោលដល់សមថៈ។ កាលពោលថា មានកាយជាអារម្មណ៍ គឺពោលដល់វិបស្សនា ទីនេះពោលដល់សមថៈ និងវិបស្សនា។

## ៥.ធាតុមនសិការបព្វៈ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថា ឋិតំ យថា បណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ**

**បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ។** ម្នាល ភិក្ខុទាំងឡាយ នៅមានទៀត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលស្ថិតនៅយ៉ាងណា ដែលតម្កល់នៅយ៉ាងណា ថាជាធាតុដូច្នេះថា មាននៅក្នុងកាយនេះ ធាតុដី ទឹក ភ្លើង ខ្យល់។

**សេយ្យថាបិ ភិក្ខវេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា ចាតុម្មហាបថេ វិលសោ បដិវិភជិត្វា និសិន្នោ អស្ស។** ម្នាលភិក្ខុទាំងឡាយ យ៉ាងដូចម្តេចមិញ នាយពិឃាតគោ ដែលប៉ិនប្រសប់ក្តី កូនសិស្សអ្នកពិឃាតគោក្តី គប្បីសម្លាប់នូវមេគោហើយរំលែកជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំមានមុំ ៤។

**ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថា បណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ។** ម្នាលភិក្ខុទាំងឡាយ យ៉ាងដូច្នោះដែរ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលស្ថិតនៅយ៉ាងណា ដែលតម្កល់នៅយ៉ាងណា ដោយថាជាធាតុដូច្នេះថា មាននៅក្នុងកាយនេះ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់។

# អដ្ឋកថា

កាលអ្នកពិឃាតគោ នៅចិញ្ចឹមគោនៅឡើយក្តី នាំគោទៅកាន់ទីពិឃាតក្តី នាំគោទៅចងទុកក្នុងទីពិឃាតក្តី កំពុងសម្លាប់គោក្តី សម្លឹងមើលគោដែលស្លាប់ហើយក្តី ការសម្គាល់ថាគោនៅមាននៅឡើយ ដរាបណាគេមិនទាន់ពន្លះសាច់គោទៅជាចំណែកៗ តែពេលគេពន្លះសាច់គោទៅជាចំណែកៗហើយ ការសម្គាល់ថាជាគោក៏អស់ទៅ គេក៏ត្រឡប់ជាសម្គាល់ថាសាច់គោវិញ គេមិនបានគិតថា យើងលក់គោនោះទេ មនុស្សអ្នកទិញក៏គិតថា យើងទិញសាច់គោ មនុស្សទាំងឡាយនេះជួញដូរសាច់គោ សេចក្តីប្រៀបធៀបនេះយ៉ាងណា ភិក្ខុនេះក៏ដូច្នេះដូចគ្នា កាលបុថុជ្ជនល្ងង់ខ្លៅ គ្រហស្ថក្តី បព្វជិតក្តី មានការសម្គាល់ថាសត្វ ឬបុគ្គល នៅមានជានិច្ច កាលដែលនៅមិនទាន់បានពិចារណានូវកាយនេះ តាមអាការដែលវាតាំងនៅ ដែលចែកចេញជាចំណែកៗ នៃពួកធាតុ តែកាលបើលោកពិចារណាជាធាតុហើយ ការសម្គាល់ថាជាសត្វក៏អស់ទៅ ចិត្តក៏តាំងនៅដោយល្អ ក្នុងការប្រាកដនៃធាតុនោះ។

ព្រះយោគាវចរ ប្រៀបដូចអ្នកពិឃាតគោ ការសម្គាល់ថា **សត្វ** ដូចជា ការសម្គាល់ថា **គោ** ឥរិយាបថទាំង ៤ ប្រៀបដូចជាផ្លូវបែកជា ៤ ការពិចារណាជាធាតុ ប្រៀបដូចអ្នកពិឃាតគោ ពន្លះសាច់ចេញជាចំណែកៗ។

# មហាភូតរូប ព្រោះហេតុ ៥ យ៉ាង

១.**ព្រោះប្រាកដជារបស់ធំ** រូបទាំងឡាយនេះ ប្រាកដជារបស់ធំទាំងក្នុងសន្តាននៃរូបដែលមិនមានចិត្តគ្រប់គ្រង ទាំងក្នុងសន្តាននៃរូបដែលមានចិត្តគ្រប់គ្រង បណ្តាសន្តានទាំង ២ នោះ ក្នុងសន្តាននៃរូបដែលមិនមានចិត្តគ្រប់គ្រង ដូចជាចក្រវាល ផែនដីជាដើម ក្នុងសន្តានដែលមានចិត្តគ្រប់គ្រង ប្រាកដជារបស់ធំ ដូចជាត្រីអណ្តើកជាដើម។

២.**ដូចជាអ្នកលេងកល** ដែលដូចជាយក្សប្រុស និងយក្សស្រី នោះ មហាភូតរូបនេះ ព្រោះសម្តែងនូវវត្ថុដែលមិនមែនជាកែវមណី ឱ្យទៅជាកែវមណី សម្តែងដុំដីដែលមិនមែនជាមាស ឱ្យទៅជាមាស យ៉ាងណាខ្លួនឯង មិនមែនជាយក្ស មិនមែនជាបក្សី ក៏សម្តែងឱ្យជាយក្ស ឱ្យទៅជាបក្សី យ៉ាងណា សម្តែងសេចក្តីឧបមេយ្យនេះ ក៏ដូចគ្នា មហាភូតរូប ខ្លួនឯងមិនមែនជាពណ៌ខៀវ មិនមែនជាពណ៌លឿង ក៏សម្តែងឧបាទាយរូបឱ្យប្រាកដជាពណ៌លឿង មិនមែនជាពណ៌ក្រហម ក៏សម្តែងឧបាទាយរូបប្រាកដជាពណ៌ក្រហម មិនមែនជាពណ៌ស សម្តែងឱ្យប្រាកដជាពណ៌ស។ ម្យ៉ាងទៀត ឧបមាដូចជាយក្សប្រុសជាដើម ចាប់បុគ្គលណាបានហើយ មហាភូតរូបនោះ ក៏ចូលទៅក្នុងខ្លួនបុគ្គលទាំងនោះ ចង់រកវាក៏មិនឃើញ ឬនៅខាងក្រៅក៏មិនជួបនឹងថា វាមិនពួននៅក្នុងបុគ្គលនោះក៏មិនមែន សេចក្តីនេះយ៉ាងណា សូម្បីមហាភូតរូបនេះ ក៏ដូច្នោះដូចគ្នា នឹងចូលទៅរកវា

ខាងក្នុងនៃគ្នា និងគ្នា ក៏មិនជួបនឹងរកមើលនៅខាងក្រៅក៏មិនឃើញ មហាភូតរូបនេះ ជាធម្មជាតិបិតនៅខាងឋានៈ ដែលសាមញ្ញជនគិតមិនដល់។

ម្យ៉ាងទៀត មហាភូតរូបនេះ ឧបមាដូចជាយក្សស្រី បិទបាំងភាវៈខ្លួនឯងដែលគួរឱ្យខ្លាច ទុកដោយពណ៌សម្បុរ សណ្ឋានរាងរៅភាពឆើតឆាយ ដែលគួរឱ្យពេញចិត្ត បោកបញ្ឆោតសត្វទាំងឡាយយ៉ាងណា មហាភូតរូបនេះ ក៏ដូច្នោះ បិទបាំងលក្ខណៈរបស់ខ្លួន ទៅតាមសភាពដែលវាជារបស់គ្រោតគ្រាតជាដើម ទុកដោយពណ៌សម្បុរ ដែលគួរឱ្យពេញចិត្ត ដោយទ្រង់ទ្រាយអង្គាវយវៈ តូចធំដែលគួរពេញចិត្ត និងការលើកដៃជើង ការកម្រើកម្រាមដៃ ការប៉ប្រិចភ្នែកដែលគួរឱ្យពេញចិត្ត នៅក្នុងសរីរៈរបស់ស្ត្រី និងបុរសជាដើម ទុកហើយលួងលោមបុគ្គលល្ងង់ខ្លៅមិនឱ្យឃើញសភាវៈរបស់ខ្លួនឡើយ ដូច្នេះរូបនេះទើបឈ្មោះថា **មហាភូត**។

៣.**ព្រោះត្រូវថែទាំច្រើន** គឺត្រូវថែរក្សាដោយបច្ច័យច្រើន មហាភូតរូបនេះ ដោយអត្ថថា ត្រូវបរិភោគដើម្បីឱ្យរស់ ដោយអាហារជាគ្រឿងឧបត្ថម្ភជាដើម យ៉ាងច្រើន ព្រោះត្រូវទំនុកបម្រុងរៀងរាល់ថ្ងៃ ម្យ៉ាងទៀត មហាភូតរូបនេះ ព្រោះត្រូវទំនុកបម្រុងថែរក្សាបានដោយលំបាក។

៤.**មានការប្រែប្រួលច្រើន** គឺរូបនេះមានការប្រែប្រួលច្រើនពិតហើយរូបនេះជារូបដែលមានចិត្តគ្រប់គ្រងក៏មាន ជារូបដែលមិន

មានចិត្តគ្រប់គ្រងក៏មាន រមែងមានការប្រែប្រួលច្រើន រមែងប្រាកដ ក្នុងពេលវិនាស ឯរូបដែលមានចិត្តគ្រប់គ្រងរមែងប្រាកដការប្រែប្រួល ក្នុងពេលដែលធាតុកម្រើក។

៥.**ដោយហេតុជារបស់ធំ** មានប្រាកដ ព្រោះត្រូវកំណត់ដោយការព្យាយាមធំ **មហាភូត** ព្រោះជាវត្ថុធំមានប្រាកដ។

**លក្ខណៈបឋវី ២ យ៉ាង**
- ១.**កក្ខឡបឋវី** មានភាពរឹង
- ២.**អថទុបឋវី** មានភាពទន់

**លក្ខណៈអាបោ ២ យ៉ាង**
- ១.**បគ្ឃរណអាបោ** មានភាពហូរជ្រាប
- ២.**អពន្ធនអាបោ** មានការកកពូនផ្តុំ

**លក្ខណៈតេជោ ២ យ៉ាង**
- ១.**ឧណ្ហតេជោ** មានចំហាយក្តៅ
- ២.**សីតតេជោ** មានចំហាយត្រជាក់

**លក្ខណៈវាយោ ២ យ៉ាង**
- ១.**វិត្ថម្ភនវាយោ** មានភាពតឹង
- ២.**សមុទីរណវាយោ** មានភាពកម្រើក

## ពិចារណាធាតុទាំង ៤ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់

១-**ពាហិរធាតុ** ធាតុខាងក្រៅគឺ ដី ទឹក ភ្លើង ខ្យល់ខាងក្រៅ ដូចដែលយើងធ្លាប់ស្គាល់មកហើយនោះ ។

២-**អជ្ឈត្តិកធាតុ** ធាតុខាងក្នុងគឺ ដី ទឹក ភ្លើង ខ្យល់ក្នុងរូបកាយយើងនេះឯង។

## បរិញ្ញា ៣

១.**ញាតបរិញ្ញា** គឺកំណត់ដឹងធាតុខាងក្នុង ខាងក្រៅ ដូចជាបឋវីធាតុនេះ ជា**លក្ខណះ**របស់បឋវីធាតុ នេះជា**កិច្ច** នេះជា**បច្ចុប្បដ្ឋាន** (អាការប្រាកដ) នេះ**បទដ្ឋាន** (ហេតុជិត) របស់បឋវីធាតុ។

២.**តីរណបរិញ្ញា** ពិចារណាធ្វើឱ្យវត្ថុដែលខ្លួនដឹងហើយដោយអាការៈ ៤០ ថា មិនទៀង ជាទុក្ខ ជារោគ ជាកូនសរចាក់ដោត ជាវត្ថុអាក្រក់ ជាអាពាធ ជារបស់កន្ទៀត ជារបស់វិនាស ជារបស់ចង្រៃ ជារបស់ ឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់បែកធ្លាយ ជារបស់មិនស្ថិតស្ថេរ ជារបស់ពឹងមិនបាន ជារបស់សង្ឃឹមមិនបាន ជារបស់ទទេ ជារបស់សោះសូន្យ ជារបស់មិនមែនខ្លួនប្រកបដោយទោស ប្រែប្រួល គ្មានខ្លឹមសារ ជាឫសគល់នៃសេចក្តីលំបាក ជាឃាតកជារបស់ព្រាត់ប្រាស ប្រកបដោយអាសវៈជាសង្ខតៈ ជាមារ ជារបស់មានជាតិជាធម្មតា ជរាជាធម្មតា ព្យាធិជាធម្មតា

មរណៈជាធម្មតា សោកជាធម្មតា ខ្សឹកខ្សួលជាធម្មតា ចង្អៀតចង្អល់ជាធម្មតា ជាវត្ថុមានសេចក្ដីសៅហ្មងជាធម្មតា។

៣.**បហានបរិញ្ញា** កំណត់ដឹងឆន្ទរាគៈដោយអរហត្តមគ្គ (គម្ពីរវិសុទ្ធិមគ្គដោយអំណាចលះបង់វិបល្លាស)។

## ភូមិរបស់បរិញ្ញា

ភូមិរបស់ញាតបរិញ្ញា ចាប់តាំងពីសង្ខារបរិច្ឆេទ (កំណត់សង្ខារ គឺនាមរូប) ទៅរហូត **បច្ចយបរិគ្គហៈ** (កំណត់បច្ច័យរបស់នាមរូប) ។

ភូមិរបស់តីរណបរិញ្ញា ចាប់តាំងពីកលាបសម្មសនញាណរហូតដល់ **ឧទយព្វយានុបស្សនា** (ឃើញទាំងការកើតនិងការរលត់) ភូមិរបស់បហានបរិញ្ញា ចាប់តាំងពីភង្គានុបស្សនា (ឃើញការរលត់) ឃើញកាន់តែច្បាស់រហូតដល់អនុបស្សនា៧ ។

## ត្រៃលក្ខណ៍លះធម៌ ៣

- **អនិច្ចតា** លះបង់និច្ចសញ្ញា
- **ទុក្ខតា** លះបង់សុខសញ្ញា
- **អនត្តា** លះបង់អត្តសញ្ញា ។

## ៦.នវសីវថិកាបព្វៈ

## បច្ចេកទេសពិចារណាសាកសព៩ បែបប្លែកៗគ្នាក្នុងព្រៃស្មសាន

១.សាកសពដែលគេចោលកណ្ដាលវាលក្នុងព្រៃស្មសានច្រើនថ្ងៃ។

២.សាកសពដែលគេចោលកណ្តាលវាល ក្នុងព្រៃស្មសានដែលសត្វ
ដណ្តើមហែកចឹកស៊ី។
៣.សាកសពដែលគេចោលកណ្តាលវាល ក្នុងព្រៃស្មសានច្រើនខែ
សល់តែស្បែក និងឆ្អឹង។
៤.សាកសពសល់តែគ្រោងឆ្អឹង សល់សាច់ និងឈាមខ្លះ។
៥.សាកសពនៅមានតែឆ្អឹង មានតែសរសៃជាគ្រឿងចង។
៦.សាកសពនៅសល់តែឆ្អឹងរាត់រាយរប៉ាត់រប៉ាយលើផែនដី។
៧.សាកសពនៅសល់តែរាងឆ្អឹងទទេ មានសម្បុរដូចជាសម្បុរនៃ
ស័ង្ខ ( ខ្យង)។
៨.សាកសពដែលគេចោលច្រើនឆ្នាំសល់តែគ្រោងឆ្អឹង គរជាពំនូក។
៩.សាកសពដែលគេចោលច្រើនឆ្នាំ នៅសល់តែពុកផុយជាកម្ទេច
តូចធំ។

## អដ្ឋកថា

ភិក្ខុបើញាណបង្អោននូវកាយរបស់ខ្លួននេះ ទៅប្រៀបនឹងសាកសព ប្រៀបយ៉ាងណា ប្រៀបថាកាយនេះនឹងមានសភាពយ៉ាងនោះជាធម្មតា គង់ជាដូច្នោះ នឹងកន្លងផុតនូវសភាពបែបនោះមិនបានឡើយ។ លោកអធិប្បាយថា កាយនេះដែលនៅឈរ ដើរបានជាដើម ក៏ព្រោះមានធម៌ ៣ ប្រការ គឺ**អាយុ ១ ភ្លើងធាតុ១ និង វិញ្ញាណ១** កាលបើធម៌៣ នេះប្រាសទៅហើយ កាយនេះនឹងមានសភាពបែបនោះ ជាធម្មតា គឺគង់មានសភាពរលួយស្អុយដូចគ្នា ត្រូវ

តែដូច្នោះឯង គឺនឹងទៅជាប្រភេទសាកសពហើមប៉ោងជាដើម យ៉ាងនោះដូចគ្នា មិនកន្លងសភាពបែបនោះបានឡើយ គឺមិនកន្លងភាពជាសាកសពហើមប៉ោងបានឡើយ។

**កាយានុបស្សនាមាន ១៤ បព្វៈគឺ** អានាបានបព្វៈ១ ឥរិយាបថបព្វៈ១ សម្បជញ្ញបព្វៈ១ បដិកូលមនសិការបព្វៈ១ ធាតុមនសិការបព្វៈ១ នវសីវថិកាបព្វៈ៩ = ១៤ បព្វៈ។

## ២.វេទនានុបស្សនាសតិប្បដ្ឋាន

**វេទនានុបស្សនា** មកពីពាក្យថា **វេទនា** + **អនុបស្សនា** = **វេទនានុបស្សនា**។ **វេទនា** ប្រែថាការទទួលអារម្មណ៍ ការសោយ ឬរងអារម្មណ៍ ឬការទទួលដឹងអារម្មណ៍។

**អនុបស្សនា** ប្រែថា ការពិនិត្យពិចារណារឿយ ៗ ។ រួមសេចក្ដីមក វេទនានុបស្សនា មានន័យថា ការពិនិត្យ ពិសោធន៍ពិចារណារឿយៗនូវវេទនាទាំងឡាយ ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងសង្កត់ធ្ងន់ទៅលើកាយវេទនាយ៉ាងនេះ ក៏ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ថា ចិត្ត និងកាយមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់រហូតទាល់តែអ្វីៗ ដែលកើតឡើងនៅក្នុងចិត្ត តែងតែបញ្ចេញខ្លួនវា មកជាវេទនានៅលើកាយទ្រង់ត្រាស់នឹងពួកភិក្ខុទាំងឡាយថាៈ

**វេទនា សមោសរណា សព្វេ ធម្មា។**

ពួកធម៌ទាំងអស់ មានវេទនាជាទីប្រជុំចុះ។

ក្នុងបដិច្ចសមុប្បាទ (ធម៌ដែលកើតមានឡើង ដោយសារបច្ច័យ) ព្រះពុទ្ធទ្រង់បានសម្តែងថាៈ **សឡាយតនបច្ចយា ផស្សោ** អាយតនៈទាំង ៦ ជាបច្ច័យនាំឱ្យកើតសម្ផស្ស។

**ផស្សបច្ចយា វេទនា** សម្ផស្ស ( ការប៉ះ ) ជាបច្ច័យនាំឲ្យកើតវេទនា **វេទនាបច្ចយា តណ្ហា** វេទនាជាបច្ច័យនាំឲ្យកើតតណ្ហា។ ការពន្យល់ពាក្យថា **វេទនា** តាមរយៈសុតមយបញ្ញា មិនលំបាកទេ ប៉ុន្តែគេមិនអាចយល់ពីអត្ថន័យជ្រាលជ្រៅ នៃពាក្យវេទនានេះបានឡើយ លុះត្រាតែគេពិសោធផ្ទាល់តាមរយៈភាវនាមយបញ្ញា ទើបគេទទួលស្គាល់យល់ពីអាថ៌កំបាំងនៃពាក្យនេះ យ៉ាងពិតប្រាកដ។

ពាក្យថា **សាមិស** បានសេចក្តីថា ប្រកបដោយការជាប់ចិត្ត ឬ ឧបាទាន។ តាមន័យដើមគឺ **ស + អាមិស** ដែលមានសាច់។ ពាក្យថា **អាមិស** ប្រែថា វត្ថុដែលចិត្តជាប់ជំពាក់ឬ ប្រាថ្នា បានដល់បញ្ចកាមគុណគឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ បានដល់បច្ច័យ ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ។ ហេតុកើតនៃវេទនាមាន ៥ អវិជ្ជា តណ្ហា ឧបាទាន កម្ម និងអាហារ។

**កថញ្ច ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ?

**ឥធ ភិក្ខវេ ភិក្ខុ សុខំ វេទនំ វេទយមានោ សុខំ វេទនំ វេទយាមីតិ បជានាតិ ទុក្ខំ  វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ  បជានាតិ អទុក្ខមសុខំ វេទនំ វេទយមានោ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ  ភិក្ខុក្នុងសាសនានេះ  ទោះសោយនូវវេទនាជាសុខដឹងច្បាស់ថា “អញសោយវេទនាជាសុខ” ទោះសោយវេទនាជាទុក្ខដឹងច្បាស់ថា  “អញសោយវេទនាជាទុក្ខ”  ទោះសោយវេទនាឥតទុក្ខ ឥតសុខ ដឹងច្បាស់ថា “អញសោយវេទនាឥតទុក្ខ ឥតសុខ” ។

**សាមិសំ វា សុខំ វេទនំ វេទិយមានោ សាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទយមានោ និរាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ ។**

ទោះសោយនូវវេទនាជាសុខដែលប្រកបដោយអាមិស  ដឹងច្បាស់ថា អញសោយវេទនាជាសុខដែលប្រកបដោយអាមិស ទោះសោយនូវវេទនាជាសុខដែលឥតអាមិស ដឹងច្បាស់ថា អញសោយវេទនាជាសុខដែលឥតអាមិស។

**សាមិសំ វា ទុក្ខំ វេទនំ វេទយមានោ សាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ ។**

ទោះសោយនូវវេទនាជាទុក្ខ ដែលប្រកបដោយអាមិស ដឹងច្បាស់ថា អញសោយវេទនាជាទុក្ខដែលប្រកបដោយអាមិស ទោះសោយវេទនាជាទុក្ខដែលឥតអាមិស ដឹងច្បាស់ថា អញសោយវេទនាជាទុក្ខដែលឥតអាមិស។

**សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ  វេទយាមីតិ បជានាតិ ។**

ទោះសោយនូវវេទនា ឥតទុក្ខ ឥតសុខ ដែលប្រកបដោយអាមិសដឹងច្បាស់ថា "អញសោយវេទនាឥតទុក្ខ ឥតសុខដែលប្រកបដោយអាមិស" ទោះសោយវេទនា ឥតទុក្ខ ឥតសុខ ដែលឥតអាមិស ដឹងច្បាស់ថា អញសោយនូវវេទនាឥតទុក្ខ ឥតសុខ ដែលឥតអាមិស។

**ឥតិ អជ្ឈត្តំ វា វេទនាសុ វេទនានុបស្សី វិហរតិ ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ អជ្ឈត្ត ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ សមុទយ-**

**ធម្មានុបស្សី វា វេទនាសុ វិហរតិ វយធម្មានុបស្សី វា វេទនាសុ វិហរតិ សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ អត្ថិ វេទនាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនា ទាំងឡាយជាខាងក្រៅ (របស់អ្នកដទៃ)ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងវេទនាទាំងឡាយផងពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យក្នុងវេទនាទាំងឡាយផង ។

ម៉្យាងទៀត ស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា គ្រាន់តែជាវេទនាទាំងឡាយ (មិនមែនសត្វមិនមែនបុគ្គលមិនមែនស្ត្រី មិនមែនបុរសជាដើម) ល្មមតែកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវំ ខោ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗនូវវេទនាទាំងឡាយ។

(វេទនានុបស្សនាសតិបដ្ឋាន ចប់)

**ក្នុងមហាសតិបដ្ឋានសូត្រ ព្រះពុទ្ធទ្រង់សម្ដែង៩ យ៉ាងប៉ុណ្ណោះ**

១- **សុខវេទនា** វេទនាជាសុខ

២- **ទុក្ខវេទនា** វេទនាជាទុក្ខ

៣- **អទុក្ខមសុខវេទនា** វេទនាមិនជាទុក្ខ មិនជាសុខ

៤-**សាមិសសុខវេទនា** វេទនាជាសុខប្រកប ដោយការជំពាក់ចិត្ត

៥- **សាមិសទុក្ខវេទនា** វេទនាជាទុក្ខប្រកប ដោយការជំពាក់ចិត្ត

៦-**និរាមិសសុខវេទនា** វេទនាជាសុខដោយគ្មាន ការជំពាក់ចិត្ត

៧- **និរាមិសទុក្ខវេទនា** វេទនាជាទុក្ខ គ្មានការជំពាក់ចិត្ត

៨-**សាមិសអទុក្ខមសុខវេទនា** វេទនាមិនមែនទុក្ខ មិនមែនសុខ ប្រកបដោយការជំពាក់ចិត្ត

៩-**និរាមិសអទុក្ខមសុខវេទនា** វេទនាមិនមែនទុក្ខ មិនមែនសុខ ដោយគ្មានការជំពាក់ចិត្ត ។

**ចែកជា២ ធំគឺ វេទនាប្រកបដោយអាមិស និងឥតមានអាមិស។**

កាលទទួលសុខវេទនាប្រកបដោយអាមិសក្តី (សោមនស្សវេទនា ដែលប្រកបដោយកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ គឺ ទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហៅថា សាមិសសុខ) ក៏ដឹង

ច្បាស់ថាអាត្មាអញទទួលសុខវេទនាប្រកបដោយអាមិស កាលទទួលសុខវេទនាដែលឥតអាមិសៈក្តី (អាស្រ័យនេក្ខម្មៈ តាមដីកា នេក្ខម្មៈ បានដល់ កុសលប្រព្រឹត្តទៅក្នុងទ្វារ ៦) ក៏ដឹងច្បាស់ថាអាត្មាអញទទួលសុខវេទនាឥតអាមិសៈ កាលទទួលទុក្ខវេទនាប្រកបដោយ អាមិសៈ (គឺទោមនស្សប្រកបដោយកាមគុណ ៥ តាមទ្វារ ៦) ក៏ដឹងច្បាស់ថាអាត្មាអញទទួលទុក្ខវេទនាប្រកបដោយអាមិសៈ កាលទទួលទុក្ខវេទនាឥតអាមិសៈ (គឺទោមនស្សដែលអាស្រ័យនេក្ខម្មៈ) ក៏ដឹងច្បាស់ថាអាត្មាអញទទួលទុក្ខវេទនាឥតអាមិសៈ កាលទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសៈ (គឺឧបេក្ខាវេទនាប្រកបដោយកាមគុណ ៥ តាមទ្វារ៦) ក៏ដឹងច្បាស់ថាអាត្មាអញទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសៈ កាលទទួលអទុក្ខមសុខវេទនាឥត អាមិសៈ (គឺឧបេក្ខាដែលអាស្រ័យនេក្ខម្មៈ) ក៏ដឹងច្បាស់ថាអាត្មាអញទទួលអទុក្ខមសុខវេទនាឥតអាមិសៈ។

## អដ្ឋកថា សឡាយតនវិភង្គសូត្រ

**សោមនស្សដែលអាស្រ័យផ្ទះ** បានដល់ សោមនស្សដែលអាស្រ័យកាមគុណប្រព្រឹត្តទៅក្នុងទ្វារ ៦ គឺក្នុងវេទនាទាំងឡាយនោះសោមនស្សដែលអាស្រ័យផ្ទះ ៦ យ៉ាង តើដូចម្តេច កាលបុគ្គលពិចារណាឃើញរូប ដែលគប្បីដឹងច្បាស់ដោយភ្នែក រូបគួរជាទីស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត គួររីករាយ ជារបស់ប្រចាំលោក ដោយការបានផ្ទាល់ ឬការតាមត្រិះរិះដល់រូបដែលធ្លាប់បានមកក្នុង

កាលមុន ដែលកន្លងហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ទើបកើតសោមនស្សឡើង។

**សោមនស្សមិនអាស្រ័យផ្ទះ** បានដល់ សោមនស្សដែលកើតឡើងដល់អ្នកដែលមានសោមនស្សថា យើងបានឈ្វេងយល់ក្នុងវិបស្សនាហើយ ជាអ្នកមានសេចក្តីត្រេកអរ ក្នុងការផ្តើមចម្រើននូវវិបស្សនា ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចំ ជាដើម ក្នុងអារម្មណ៍ជាទីពេញចិត្ត ដែលមកកាន់ទ្វារ ៦ យ៉ាងនេះជាដើមថា សោមនស្សដែលអាស្រ័យការចេញចាកផ្ទះទាំង ៦ យ៉ាងដូចម្តេច កាលបុគ្គលដឹងរូបទាំងឡាយថា មិនទៀង មានការប្រែប្រួល បែកធ្លាយ រលត់ ហើយឃើញនូវរូបនោះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតថា រូបទាំងឡាយសូម្បីក្នុងអតីត និងបច្ចុប្បន្ន រូបទាំងឡាយនោះទាំងអស់មិនទៀង ទ្រាំនៅមិនបាន មានសេចក្តីប្រែប្រួលជាធម្មតា ទើបកើតសោមនស្សឡើង ដូច្នោះបុគ្គលគប្បីសេពនូវសោមនស្សអាស្រ័យការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការត្រិះរិះដល់ និងដោយអំណាចឈានជាដើម។

**ទោមនស្សអាស្រ័យផ្ទះ** បានដល់ ទោមនស្សអាស្រ័យកាមគុណដែលកើតដល់អ្នកត្រិះរិះថា យើងមិនបានសោយ នឹងមិនបានសោយនូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៦ កាលបុគ្គលពិចារណាឃើញ ការមិនបានចំពោះនូវរូបដែលគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត ក្នុងលោកដែលដឹងច្បាស់ដោយភ្នែក ឬកាលតាមរលឹកដល់រូប

ដែលមិនធ្លាប់បាន កាលបើកន្លងទៅហើយ រលត់ហើយ ប្រែប្រួលទៅហើយ ក៏កើតនូវទោមនស្សឡើង។

**ទោមនស្សអាស្រ័យការចេញចាកផ្ទះ** បានដល់ទោមនស្សដែលកើតដល់អ្នកដែលមិនអាចញ៉ាំងចិត្តឱ្យសម្រេចក្នុងធម៌ គឺអរិយផល តាមសេចក្ដីប្រាថ្នាបាន ពោលគឺរួចផុតដ៏កំពូល ហើយក៏ផ្ដើមចម្រើនវិបស្សនាតាមអំណាចត្រៃលក្ខណ៍ មានអនិច្ចំជាដើម ដើម្បីសម្រេចនូវអរិយផលនោះ លោកកើតទុក្ខថា យើងមិនអាចញ៉ាំងចិត្តឱ្យកាន់វិបស្សនាអស់ថ្ងៃ អស់ខែ អស់ឆ្នាំ ហើយសម្រេចអរិយភូមិក្នុងរូបដែលគួរស្រឡាញ់ មកកាន់គន្លងទ្វារ ៦។

**ឧបេក្ខាដែលអាស្រ័យផ្ទះ** បានដល់ ឧបេក្ខាដែលអាស្រ័យកាមគុណ ដែលជាប់ជំពាក់ ដែលប្រកៀកកើតឡើងក្នុងកាមគុណនោះឯង ប្រព្រឹត្តទៅកន្លងរូបមិនបាន ដូចមេឃ្មុំជាប់ជំពាក់ក្នុងទឹកអំពៅ ក្នុងអារម្មណ៍គួរជាទីស្រឡាញ់ ដែលមកកាន់គន្លងទ្វារទាំង ៦ ឧបេក្ខាអាស្រ័យផ្ទះក៏កើតឡើងដល់បុគ្គលល្ងង់ បុគ្គលវង្វេង បុគ្គលមានកិលេសក្រាស់ បុគ្គលគិតតែយកឈ្នះមិនមានព្រំដែន យកតែឈ្នះមិនមានផល មានប្រក្រតីមិនឃើញទោស មិនបានទទួលការសិក្សា ជាអន្ធបុថុជ្ជនឧបេក្ខាបែបនេះជាឧបេក្ខាកន្លងរូបមិនបាន។

**ឧបេក្ខាដែលអាស្រ័យចេញចាកផ្ទះ** បានដល់ ឧបេក្ខាដែលប្រកបព្រមដោយវិបស្សនាញាណ កើតដល់បុគ្គលដែលមិនរីករាយក្នុងអារម្មណ៍ ដែលគួររីករាយមិនប្រទូសរ៉ាយក្នុងអារម្មណ៍ដែលមិន

ជាទីពេញចិត្ត មិនវង្វេងព្រោះពិចារណាអារម្មណ៍ មានអារម្មណ៍ជាទីស្រឡាញ់ជាដើម ដែលមកកាន់គន្លងទ្វារទាំង ៦ លោករមែងដឹងច្បាស់ក្នុងវេទនាទាំងឡាយនោះ ឧបេក្ខាអាស្រ័យការចេញចាកផ្ទះ គឺឧបេក្ខាដែលដឹងច្បាស់នូវការមិនទៀង ការប្រែប្រួល ការវិនាស ការរលត់របស់រូប ហើយឃើញរូបទាំងឡាយដោយបញ្ញាដ៏ប្រពៃតាមពិតថា រូបទាំងឡាយ សូម្បីក្នុងអតីត បច្ចុប្បន្ន រូបទាំងឡាយនោះ សុទ្ធតែមិនទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលជាធម្មតា។

ព្រះសារីបុត្តត្ថេរពោលនឹងព្រះមហាកោដ្ឋិកត្ថេរថា ម្នាលអាវុសោ ព្រោះហេតុដែលធម្មជាតិនោះឯង សោយរសនៃអារម្មណ៍រមែងដឹងថាជាសុខ ជាទុក្ខ ព្រោះហេតុនោះឈ្មោះថា វេទនា។

វេទនាកាលពោលដោយសភាវៈ គឺមានតែម្យ៉ាងដោយលក្ខណៈ គឺសោយអារម្មណ៍ ពោលដោយជាតិមាន ៣ គឺ កុសល អកុសល និងអព្យាកត ។

## វេទនា ៥ យ៉ាង

១.**សុខ** សម្បយុត្តជាមួយកាយវិញ្ញាណជាកុសលវិបាក។

២.**ទុក្ខ** សម្បយុត្តជាមួយកាយវិញ្ញាណជាអកុសលវិបាក។

៣.**សោមនស្ស** សម្បយុត្តជាមួយចិត្ត ៦២ បានដល់

### កាមសោមនស្ស ១៨ គឺ

| | |
|---|---|
| អកុសលចិត្ត ៤ | អហេតុកកិរិយាចិត្ត ១ |
| អហេតុកកុសលវិបាកចិត្ត១ | កាមសោភណចិត្ត ១២។ |

## ឈានសោមនស្ស ៤៤

**រូបាវចរចិត្ត ១២** (វៀរបញ្ចមជ្ឈាន)

**លោកុត្តរចិត្ត ៣២** (វៀរបញ្ចមជ្ឈាន)។

៤.**ទោមនស្ស** សម្បយុត្តជាមួយអកុសល ២។

៥.**ឧបេក្ខា** សម្បយុត្តជាមួយចិត្ត ៥៥។

## លក្ខណៈនៃវេទនា ៥

១.**សុខវេទនា** មានការសោយផោដ្ឋព្វៈ គួរជាទីប្រាថ្នា ជាលក្ខណៈ មានការធ្វើសម្បយុត្តធម៌ឱ្យចម្រើន ជាកិច្ច មានសេចក្ដីសប្បាយកាយជាអាការប្រាកដ មានកាយបសាទជាហេតុជិត។

២.**ទុក្ខវេទនា** មានការសោយផោដ្ឋព្វៈ មិនជាទីប្រាថ្នាជាលក្ខណៈ មានការធ្វើឱ្យសម្បយុត្តធម៌ខ្សោយចុះជាកិច្ច មានការមិនសប្បាយកាយជាអាការប្រាកដ មានកាយបសាទជាហេតុជិត។

៣.**សោមនស្សវេទនា** មានការសោយអារម្មណ៍ ជាទីគាប់ចិត្តជាលក្ខណៈ មានការប្រសព្វនឹងអារម្មណ៍ជាទីប្រាថ្នា ជាកិច្ច មានការមិនសប្បាយចិត្ត ជាអាការប្រាកដ មានបស្សទ្ធិ ជាហេតុជិត។

៤.**ទោមនស្សវេទនា** មានការសោយអារម្មណ៍ មិនជាទីគាប់ចិត្ត ជាលក្ខណៈ មានការប្រសព្វនឹងអាការមិនជាទីគាប់ចិត្ត ជាកិច្ច មានការសប្បាយចិត្តជាអាការប្រាកដ មានហទយវត្ថុជាហេតុជិត។

៥.**ឧបេក្ខាវេទនា** មានការសោយអារម្មណ៍ ជាកណ្ដាល ជាលក្ខណៈ មានការរក្សាសម្បយុត្តធម៌មិនឱ្យចម្រើនឡើង មិន

ឱ្យសៅហ្មង ជាកិច្ច មានភាពស្ងប់ជាអាការប្រាកដ មានចិត្តដែលមិនប្រកបដោយបីតិ ជាហេតុជិត។

## អដ្ឋកថា

**សុខវេទនា** មានន័យថា ភិក្ខុកំពុងសោយនូវវេទនាដែលជាសុខ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី ក៏ដឹងច្បាស់ថា យើងសោយនូវសុខវេទនា។ សូម្បីទារកនៅក្មេងខ្ចី ក៏មានការសោយនូវសុខវេទនាដែរ នៅពេលបៅដោះ មានការដឹងច្បាស់នូវការសោយសុខវេទនាក៏ពិត តែថាសុខវេទនាជាដើមនេះ ទ្រង់មិនបានត្រាស់សំដៅការដឹងដូច្នោះទេ។ ព្រោះការដឹងដូច្នោះ មិនអាចលះបង់ការឃើញថា ជាសត្វបាន មិនអាចដកនូវការសម្គាល់ថា ជាសត្វបាន មិនមែនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ ចំណែកការដឹងច្បាស់របស់ភិក្ខុនេះ លះបង់ការឃើញថាជាសត្វបាន ទាំងជាកម្មដ្ឋាន ទាំងសតិប្បដ្ឋានភាវនា។ ពាក្យទាំងនេះទ្រង់ត្រាស់ដល់ការសោយសុខវេទនា ប្រកបដោយការដឹងខ្លួន យ៉ាងនេះថា **នរណាសោយ ការសោយរបស់នរណា សោយបានព្រោះអ្វី**។

ពាក្យថា **នរណាសោយ** គឺមិនមែនសត្វ ឬបុគ្គលណាៗសោយឡើយ។ ពាក្យថា **សោយបានព្រោះអ្វី** ឆ្លើយថា ព្រោះវេទនារបស់ភិក្ខុនោះ មានវត្ថុជាអារម្មណ៍តែម្យ៉ាង ហេតុនោះ ព្រោះវត្ថុឱ្យជាទីតាំងនៃវេទនា មានសុខវេទនាជាដើមនោះៗ ឱ្យជាអារម្មណ៍។

ពាក្យថា **យើងសោយនូវវេទនា** គ្រាន់តែជាសម្មតិវោហារប៉ុណ្ណោះ ព្រោះកាន់យកការប្រព្រឹត្តិទៅនៃវេទនានោះ។

## វេទនាជាអរូបកម្មដ្ឋាន

ព្រះមានព្រះភាគ ទ្រង់បានត្រាស់រូបកម្មដ្ឋានហើយ ទ្រង់ត្រាស់ដល់អរូបកម្មដ្ឋាន ទ្រង់ត្រាស់ដល់ការកើតឡើងនៃវេទនាទាំងឡាយ ព្រោះកម្មដ្ឋានរមែងប្រាកដច្បាស់ ដោយអំណាចវេទនា ទើបទ្រង់ត្រាស់នូវអរូបកម្មដ្ឋានដោយអំណាចវេទនា ព្រោះថា បើដោយអំណាចផស្សៈ ឬដោយអំណាចចិត្ត កម្មដ្ឋានមិនអាចប្រាកដច្បាស់បានឡើយ ប្រាកដដូចនៅក្នុងទីងងឹត។ ក្នុងសក្កបញ្ហាសូត្រ កម្មដ្ឋានមាន ២ គឺ រូបកម្មដ្ឋាន ១ អរូបកម្មដ្ឋាន១។

## ៣.ចិត្តានុបស្សនា

**កថញ្ច ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្ត ?

**១.ឥធ ភិក្ខវេ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។

**២.សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ។**

ទោះចិត្តប្រកបដោយទោសៈ ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ។

**៣.សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តប្រកបដោយមោហៈ ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ។

**៤.សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តរួញរា ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ដឹងច្បាស់ថា ចិត្តរាយមាយ។

**៥.មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តដល់នូវភាវៈជាធំ ដឹងច្បាស់ថា “ចិត្តដល់នូវភាវៈជាធំ” ទោះចិត្តមិនដល់នូវភាវៈជាធំ ដឹងច្បាស់ថា “ចិត្តមិនដល់នូវភាវៈជាធំ”។

**៦.សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង។

**៧.សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ។**

ទោះចិត្តតម្កល់នៅមាំ ដឹងច្បាស់ថា “ចិត្តតម្កល់នៅមាំ” ទោះចិត្តមិនតម្កល់នៅមាំ ដឹងច្បាស់ថា “ចិត្តមិនតម្កល់នៅមាំ” ។

**៨.វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ។**

ទោះចិត្តផុតស្រឡះ ដឹងច្បាស់ថា “ចិត្តផុតស្រឡះ” ទោះចិត្តមិនផុតស្រឡះ ដឹងច្បាស់ថា “ចិត្តមិនផុតស្រឡះ”។

## អង្គធម៌របស់ចិត្តានុបស្សនាសតិប្បដ្ឋាន

| | |
|---|---|
| ១.**សរាគំ** | អង្គធម៌ លោភមូលចិត្ត ៨ |
| ២.**វីតរាគំ** | អង្គធម៌ លោកិយមហាកុសល និងអព្យាកត |
| ៣.**សទោសំ** | អង្គធម៌ ទោសមូលចិត្ត ២ |
| ៤.**វីតទោសំ** | អង្គធម៌ មហាកុសល និងអព្យាកត |
| ៥.**សមោហំ** | អង្គធម៌ មោហមូលចិត្ត ២ |
| ៦.**វីតមោហំ** | អង្គធម៌ មហាកុសល និងអព្យាកត |

៧.**សង្ខិត្តំ** អង្គធម៌ ថីនមិទ្ធៈ

៨.**វិក្ខិត្តំ** អង្គធម៌ ឧទ្ធច្ចៈ

៩.**មហគ្គតំ** អង្គធម៌ រូប និងអរូប

១០.**អមហគ្គតំ** អង្គធម៌ កាមាវចរ

១១.**សឧត្តរំ** អង្គធម៌ រូបាវចរ

១២.**អនុត្តរំ** អង្គធម៌ អរូបាវចរ

១៣.**សមាហិតំ** អង្គធម៌ ឧបចារៈ និងអប្បនា

១៤.**អសមាហិតំ** អង្គធម៌ មិនមានទាំងឧបចារ និងអប្បនា

១៥.**វិមុត្តំ** អង្គធម៌ តទង្គប្បហាន និងវិក្ខម្ភនប្បហាន

១៦.**អវិមុត្តំ** អង្គធម៌ មិនមានទាំង តទង្គប្បហាន និងវិក្ខម្ភន-ប្បហាន។

ព្រះជិនស្រីទ្រង់ត្រាស់ថា ៖

**យោ សហស្សំ សហស្សេន**

**សង្គាមេ មានុសេ ជិនេ**

**ឯកញ្ច ជេយ្យមត្តានំ**

**សវេ សង្គាមជុត្តមោ ។**

សូម្បីបុគ្គលអាចយកជ័យជម្នះ លើមនុស្សបានរាប់ពាន់នាក់

ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏មិនប្រសើរជាងការឈ្នះ

លើខ្លួនឯងតែម្នាក់ឡើយ បុគ្គលអ្នកឈ្នះខ្លួនឯងឈ្មោះថា

ជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត។

**ឥតិ អជ្ឈត្តំ វា ចិត្តេ ចិត្តានុបស្សី វិហរតិ ពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ វយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ អត្ថិ ចិត្តន្តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តខាងក្រៅ (របស់អ្នកដទៃ) ផង ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងចិត្តផង ពិចារណានូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្តផង ម៉្យាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា គ្រាន់តែជាចិត្ត (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវំ ខោ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត ។

## ៤.ធម្មានុបស្សនា

**ធម្មានុបស្សនា** គឺការពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ ទាំងឡាយមាន ៦ បព្វៈ ឬ បែប។

| | |
|---|---|
| ១.នីវរណធម៌ | ៥ |
| ២.ឧបាទានក្ខន្ធ | ៥ |
| ៣.អាយតនៈ | ១២ |
| ៤.ពោជ្ឈង្គ | ៧ |
| ៥.សច្ចៈ | ៤ ។ |

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណា ឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ?

## ១-នីវរណបព្វ

**ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ នីវរណៈ ៥។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចភិក្ខុ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ នីវរណៈ ៥?

**ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈ មាននៅក្នុងខ្លួន ដឹងច្បាស់ថា កាមច្ឆន្ទៈមានក្នុងខ្លួនរបស់អញ ទោះ កាមឆន្ទៈមិនមាននៅក្នុងខ្លួនរបស់អញ ក៏ដឹងច្បាស់ថាកាមឆន្ទៈមិន មានក្នុងសន្តានចិត្តរបស់អាត្មាអញ ម្យ៉ាងទៀត កិរិយាកើតឡើងនៃ កាមឆន្ទៈ ដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវ ហេតុនោះផង កិរិយាលះបង់នូវកាមឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុ ឯណាក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើត តទៅទៀតនៃកាមឆន្ទៈ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ**

**មេ អជ្ឈត្តំ  ព្យាបាទោតិ បជានាតិ យថា ច អនុប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច  បជានាតិ ។**

ទោះព្យាបាទមាននៅក្នុងខ្លួន ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងខ្លួនរបស់អញ  ទោះព្យាបាទមិនមាននៅក្នុងខ្លួន  ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងខ្លួនរបស់អញ ម៉្យាងទៀត កិរិយាកើតឡើងនៃព្យាបាទដែលមិនទាន់កើតឡើង  ដោយហេតុឯណាក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវព្យាបាទ ដែលកើតឡើង ហើយដោយហេតុឯណា  ក៏ដឹងច្បាស់នូវហេតុនោះផង  កិរិយាមិនកើតតទៅទៀតនៃព្យាបាទ ដែលលះបង់បានហើយ ដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ។**

ទោះថីនមិទ្ធៈមាននៅក្នុងខ្លួន ដឹងច្បាស់ថា “ ថីនមិទ្ធៈមាននៅក្នុងខ្លួនរបស់អញ ទោះថីនមិទ្ធៈមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនរបស់អញ ម្យ៉ាងទៀត កិរិយាកើតឡើងនៃថីនមិទ្ធៈដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវថីនមិទ្ធៈ ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃថីនមិទ្ធៈ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង។

**សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ យថា ច អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ។**

ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួន ដឹងច្បាស់ថា “ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួនរបស់អញ ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួនរបស់អញ ម្យ៉ាងទៀត កិរិយាកើតឡើងនៃឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ

ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃឧទ្ធច្ចកុក្កុច្ចៈ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង។

**សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ។**

ទោះវិចិកិច្ឆាមាននៅក្នុងខ្លួន ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងខ្លួនរបស់អញ ទោះវិចិកិច្ឆាមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងខ្លួនរបស់អញ ម្យ៉ាងទៀត កិរិយាកើតឡើងនៃវិចិកិច្ឆាដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆា ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា**

**វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុប្បដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយខាងក្រៅ (របស់អ្នកដទៃ) ផង ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុង ទាំងខាងក្រៅផង ពិចារណាឃើញរឿយៗនូវធម៌ដែលប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា គ្រាន់តែជាធម៌ទាំងឡាយ (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ។ មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ។**

ម្នាលភិក្ខុទាំងឡាយយ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈ៥។

## ១-នីវរណបព្វៈ

**ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌គឺនីវរណៈ៥**

**១-កាមច្ឆន្ទៈ** សេចក្ដីប្រាថ្នាក្នុងកាម

**២-ព្យាបាទៈ** ការញ៉ាំងប្រយោជន៍ និងសេចក្ដីសុខរបស់អ្នកដទៃឲ្យវិនាស

**៣-ថីនមិទ្ធៈ** សេចក្ដីខ្ជិលច្រអូស ឬ រួញរា

**៤-ឧទ្ធច្ចកុក្កុច្ចៈ** សេចក្ដីរាយមាយ ក្ដៅក្រហាយ

**៥-វិចិកិច្ឆា** សេចក្ដីសង្ស័យ ។

## ភិក្ខុក្នុងសាសនានេះពិចារណាថា

១-ទោះ **កាមច្ឆន្ទៈ** មាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **កាមច្ឆន្ទៈ** មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **កាមច្ឆន្ទៈ** មិនមាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ។ ទោះ **កាមច្ឆន្ទៈ** ដែលមិនទាន់កើតឡើងហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ។

ហេតុឱ្យកើតកាមឆន្ទៈគឺ អយោនិសោមនសិការក្នុងសុភនិមិត្ត។

## ធម៌លះបង់កាមឆន្ទៈ ៦ ប្រការ

១.ការកាន់យកនូវអសុភនិមិត្តជាអារម្មណ៍
២.ការប្រកបរឿយៗ នូវអសុភភាវនា
៣.ការរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ
៤.ការដឹងប្រមាណក្នុងភោជន
៥.ការមានកល្យាណមិត្ត
៦.និយាយតែរឿងដែលជាទីសប្បាយ។

២-ទោះ **ព្យាបាទៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ព្យាបាទៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **ព្យាបាទៈ** មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា**ព្យាបាទៈ** មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។
ហេតុនាំឱ្យកើតព្យាបាទគឺ អយោនិសោមនសិការក្នុងបដិឃនិមិត្ត។

## ធម៌សម្រាប់លះបង់ព្យាបាទ ៦ ប្រការ

១.ការកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍
២.ការប្រកបរឿយៗ នូវមេត្តាភាវនា
៣.ការពិចារណាដល់សត្វដែលមានកម្មជារបស់ខ្លួន
៤.ច្រើនដោយការពិចារណា
៥.ការមាននូវកល្យាណមិត្ត
៦.ការនិយាយក្នុងរឿងជាទីសប្បាយ។

៣-ទោះ **ថីនមិទ្ធៈ**មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ថីនមិទ្ធៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **ថីនមិទ្ធៈ** មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ថីនមិទ្ធៈ** មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។

ហេតុកើតឡើងនៃថីនមិទ្ធគឺ អយោនិសោមនសិការក្នុងអរតិធម៌

## ហេតុនៃការលះបង់ព្រោះ

១.**អារព្ភធាតុ** សេចក្តីព្យាយាម

២.**និក្កមធាតុ** កន្លងនូវការខ្ជិល

**៣.បរក្កមធាតុ** ការបោះពួយទៅមុខ។

## ធម៌សម្រាប់លះបង់ថីនមិទ្ធមាន ៦

១.ការកំណត់ដឹងភោជនដែលលើស

២.ការផ្លាស់ប្តូរឥរិយាបថ

៣.ការធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា

៤.ការនៅក្នុងទីស្រឡះ

៥.ការមានកល្យាណមិត្ត

៦.ការនិយាយរឿងជាទីសប្បាយ។

៤- ទោះ **ឧទ្ធច្ចកុក្កុច្ចៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ឧទ្ធច្ចកុក្កុច្ចៈ** មាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ។ ទោះ **ឧទ្ធច្ចកុក្កុច្ចៈ** មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ឧទ្ធច្ចកុក្កុច្ចៈ**មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។

- **ហេតុកើតនៃឧទ្ធច្ចកុក្កុច្ចៈគឺ** អយោនិសោមនសិការក្នុងការមិនស្ងប់នៃចិត្ត។
- **ហេតុលះបង់** គឺព្រោះដើម្បីសមាធិចិត្ត។

## ធម៌សម្រាប់លះបង់ឧទ្ធច្ចកុក្កុច្ចមាន ៦

១.ការស្តាប់ច្រើន

២.ការសាកសួរ

៣.ការជំនាញក្នុងវិន័យ

៤.សេពគប់អ្នកដែលមានការចម្រើន

៥.មានកល្យាណមិត្ត

៦.និយាយរឿងជាទីសប្បាយ។

៥- ទោះ **វិចិកិច្ឆា** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **វិចិកិច្ឆា** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **វិចិកិច្ឆា** មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **វិចិកិច្ឆា** មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។

- **ហេតុកើតនៃវិចិកិច្ឆា** គឺ អយោនិសោមនសិការក្នុងការងឿងឆ្ងល់
- **ហេតុលះបង់** គឺពិចារណាធម៌ដែលមានទោសនិងមិនទោស គួរសេព ឬមិនគួរសេពជាដើម។

## ធម៌សម្រាប់លះបង់វិចិកិច្ឆាមាន ៦

១.ការស្តាប់ច្រើន

២.ការសាកសួរ
៣.ការជំនាញក្នុងវិន័យ
៤.សម្បូណ៌ដោយសទ្ធា
៥.មានកល្យាណមិត្ត
៦.និយាយរឿងជាទីសប្បាយ។

**២-ខន្ធបព្វៈ**

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុក្នុងសាសនានេះពិចារណាឃើញរឿយៗ នូវធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ៥ ។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ**?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ៥?

**ឥធ ភិក្ខវេ ភិក្ខុ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ**

**អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ដឹងច្បាស់ដូច្នេះថា) រូបមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតនៃរូបមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់នៃរូបមានប្រមាណប៉ុណ្ណេះ វេទនាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតនៃវេទនាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់នៃវេទនាមានប្រមាណប៉ុណ្ណេះ សញ្ញាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតនៃសញ្ញាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់នៃសញ្ញាមានប្រមាណប៉ុណ្ណេះ សង្ខារមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតនៃសង្ខារមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់នៃសង្ខារមានប្រមាណប៉ុណ្ណេះ វិញ្ញាណមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតនៃវិញ្ញាណមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់នៃវិញ្ញាណមានប្រមាណប៉ុណ្ណេះ។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ។** ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយគឺឧបាទានក្ខន្ធ៥។

**អត្ថធម៌របស់ខន្ធ ៥**

| | |
|---|---|
| ១-**រូបក្ខន្ធ** | បានដល់ រូប ២៨ |
| ២-**វេទនាខន្ធ** | បានដល់ វេទនាចេតសិក |
| ៣-**សញ្ញាខន្ធ** | បានដល់ សញ្ញាចេតសិក |
| ៤-**សង្ខារក្ខន្ធ** | បានដល់ ចេតសិក ៥០ |
| ៥-**វិញ្ញាណក្ខន្ធ** | បានដល់ ចិត្ត ៨៩ ឬ១២១។ |

**ភិក្ខុក្នុងសាសនានេះ**

១-ដឹងច្បាស់ថាៈ **រូប** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃរូបមានប្រមាណប៉ុណ្ណេះ និងធម៌ដែលជាដែនរលត់ (វិនាស ) នៃរូបមានប្រមាណប៉ុណ្ណេះ ។

២-ដឹងច្បាស់ថាៈ **វេទនា** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណេះ និងធម៌ដែលជាដែនរលត់នៃវេទនា មានប្រមាណប៉ុណ្ណេះ ។

៣-ដឹងច្បាស់ថាៈ **សញ្ញា** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញា មានប្រមាណប៉ុណ្ណេះនិងធម៌ដែលជាដែនរលត់នៃសញ្ញា មានប្រមាណប៉ុណ្ណេះ ។

៤-ដឹងច្បាស់ថា: **សង្ខារ** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារ មានប្រមាណប៉ុណ្ណេះ និងធម៌ដែលជាដែនរលត់នៃសង្ខារមានប្រមាណប៉ុណ្ណេះ ។

៥-ដឹងច្បាស់ថា: **វិញ្ញាណ** មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ និងធម៌ដែលជាដែនរលត់នៃវិញ្ញាណមានប្រមាណប៉ុណ្ណេះ។

## អដ្ឋកថា

ពាក្យថា **ឧបាទានក្ខន្ធ ៥** គឺគំនរឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ អធិប្បាយថា គំនរធម៌ គឺប្រជុំធម៌ដែលជាបច្ច័យនៃឧបាទាន។

សេចក្ដីពិស្ដារមានក្នុងវិសុទ្ធិមគ្គ មាន **ឧទយព្វយានុបស្សនា** ជាដើមដើម្បីលះឧបាទានក្ខន្ធ។

## ៣-អាយតនបព្វៈ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ (ក្នុងសាសនានេះ) ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ**?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ?

**ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ តញ្ច បជានាតិ យថា ច អនុប្បន្នស្ស សញ្ញោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សញ្ញោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវចក្ខុផង ដឹងច្បាស់នូវរូបារម្មណ៍ទាំងឡាយផង ម៉្យាងទៀត សញ្ញោជនៈឯណាដែលអាស្រ័យនូវចក្ខុ និងរូបារម្មណ៍ទាំងពីរនោះ ហើយកើតឡើងក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង កិរិយាកើតឡើងនៃសញ្ញោជនៈដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវសញ្ញោជនៈដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃសញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង។

**សោតញ្ច បជានាតិ សទ្ទេ ច បជានាតិ**.................

ដឹងច្បាស់នូវសោតផងដឹងច្បាស់នូវសទ្ទារម្មណ៍ទាំងឡាយផង...

**ឃានញ្ច បជានាតិ គន្ធេ ច បជានាតិ**............

ដឹងច្បាស់នូវឃានផង ដឹងច្បាស់នូវគន្ធារម្មណ៍ទាំងឡាយ ផង......

**ជិវ្ហញ្ច បជានាតិ រសេ ច បជានាតិ**............

ដឹងច្បាស់នូវជិវ្ហាផង ដឹងច្បាស់នូវរសារម្មណ៍ទាំងឡាយ ផង.................

**កាយញ្ច បជានាតិ ផោដ្ឋព្វេ ច បជានាតិ**.........

ដឹងច្បាស់នូវកាយផង ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ ទាំងឡាយផង..................

**មនញ្ច បជានាតិ ធម្មេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ តញ្ច បជានាតិ ។ល។ យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ។**

ដឹងច្បាស់នូវមនោផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយ ផង ម៉្យាងទៀត សញ្ញោជនៈ ឯណាដែលអាស្រ័យនូវមនោ និង ធម្មារម្មណ៍ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈ នោះផង ។ល។ កិរិយាមិនកើត តទៅទៀតនៃសញ្ញោជនៈដែល លះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះ ផង។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចផង។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ។

## អាយតនៈដោយអត្ថ ១២ គឺ

១.**ចក្ខតីតិ ចក្ខុំ** ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា រមែងឃើញ

២.**រូបយតីតិ រូបំ** ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងឱ្យប្រាកដ

៣.**សុណាតីតិ សោតំ** ឈ្មោះថា **សោត** ព្រោះអត្ថថា បានឮ

៤.**សប្បតីតិ សទ្ទោ** ឈ្មោះថា **សទ្ទ** ព្រោះអត្ថថា ចេញទៅ គឺបន្លឺឡើង

៥.**ឃាយតីតិ ឃានំ** ឈ្មោះថា **ឃាន** ព្រោះអត្ថថា ស្រូបក្លិន

៦.**គន្ធយតីតិ គន្ធោ** ឈ្មោះថា **គន្ធ** ព្រោះអត្ថថា ភាយក្លិន

៧.**ជីវិតំ អាហាយតីតិ ជិវ្ហា** ឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា នាំមកនូវជីវិត

៨.**រសន្តិ តំ សត្តាតិ រសោ** ឈ្មោះថា **រស** ព្រោះអត្ថថា រីករាយ

៩.**កុច្ឆិតានំ សាសវធម្មានំ អាយោតិ កាយោ** ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាអណ្ដូងកើតនៃធម៌ មានអាសវៈដែលបណ្ឌិតខ្ពើមរអើម ពាក្យថា **អាយោ** គឺទីកើត

១០.**ផុស្សិយតីតិ ផោដ្ឋព្វំ** ឈ្មោះថា **ផោដ្ឋព្វ** ព្រោះអត្ថថា ដោយកាយរមែងប៉ះពាល់

១១.**មនុយតីតិ មនោ** ឈ្មោះថា **មនៈ** ព្រោះអត្ថថា ដឹង

១២.**អត្តនោ លក្ខណំ ធារយតីតិ ធម្មា** ឈ្មោះថា **ធម្មៈ** ព្រោះអត្ថថាទ្រទ្រង់នូវលក្ខណៈរបស់ខ្លួន។

## អាយតនស័ព្ទ




## អធិប្បាយ

១.**ព្រោះជាទីបន្តគ្នា** ចិត្តនិងចេតសិកទាំងឡាយរមែងបន្តគ្នា គឺព្យាយាមទៅតាមកិច្ចរបស់ខ្លួន មានការសោយអារម្មណ៍ ក្នុងទ្វារ

និងអារម្មណ៍នោះៗ មានចក្ខុ និងរូបជាដើម ទើបប្រែថា ជាទីបន្តនៃចិត្ត និងចេតសិកទាំងឡាយ។

២.**ព្រោះពង្រីកអាយៈទាំងឡាយ** គឺទ្វារ និងអារម្មណ៍ទាំងឡាយ រមែងផ្សាយគឺពង្រីកធម៌ទាំងឡាយនោះ ដែលជា **អាយៈ** (អ្នកមក) គឺចិត្ត និងចេតសិក។

៣.**ព្រោះនាំអាយតៈទៅ** គឺទ្វារ និងអារម្មណ៍ទាំងឡាយនោះ មិនទាន់ត្រឡប់ (គឺមិនទាន់រលត់) ត្រឹមណា ក៏រមែងនាំទៅគឺនាំសង្សារទុក្ខដែលប្រព្រឹត្តទៅក្នុងសង្សារ ដែលមានទីបំផុតខាងដើម និងខាងចុងមិនប្រាកដ ជា**អាយតៈ** គឺអូសបន្លាយដ៏វែងឆ្ងាយ ឱ្យប្រព្រឹត្តទៅជាដរាប ព្រោះហេតុនៃទ្វារ និងអារម្មណ៍ទាំងឡាយនោះ ទើបឈ្មោះថា **អាយតនៈ** ប្រែថា **នាំអាយតៈ** គឺសង្សារទុក្ខឱ្យអូសបន្លាយទៅ។

## ដោយបរិយាយ
## អាយតនៈដោយអត្ថ ៥ យ៉ាង

១.**ជាទីអាស្រ័យ** គឺចិត្ត និងចេតសិកទាំងឡាយ អាស្រ័យទ្វារ និងអារម្មណ៍ទាំងឡាយ។

២.**ជាអណ្តូងកើត** គឺចិត្ត និងចេតសិកទាំងឡាយ នៅពេញក្នុងចក្ខុជាដើម ព្រោះអាស្រ័យចក្ខុជាដើមនោះ (ជាទ្វារ) និងព្រោះមានរូបជាដើមជាអារម្មណ៍។

៣.**ជាទីប្រជុំចុះ** គឺទ្វារ និងអារម្មណ៍បានឈ្មោះថា ជាទីប្រជុំចុះនៃចិត្ត និងចេតសិកទាំងឡាយនោះ ព្រោះប្រជុំគ្នាក្នុងទ្វារ និងអារម្មណ៍នោះៗ ដោយជាវត្ថុ ជាទ្វារ និងអារម្មណ៍។

៤.**ជាទីឱ្យកំណើត** គឺទ្វារ និងអារម្មណ៍ ជាទីឱ្យកំណើតនៃចិត្ត និងចេតសិកទាំងឡាយនោះ ព្រោះកើតឡើងតែក្នុងចក្ខុទ្វារជាដើមនោះតែប៉ុណ្ណោះ។

៥.**ជាហេតុ** គឺទ្វារ និងអារម្មណ៍ ជាហេតុនៃចិត្ត និងចេតសិកទាំងឡាយនោះ ព្រោះកាលបើទ្វារ និងអារម្មណ៍ទាំងឡាយនោះ មិនមាន (ចិត្តចេតសិក) ក៏មិនមាន។

## ដោយសង្ខេប:

១.**ចក្ខុបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់នឹងរូបារម្មណ៍ ជាលក្ខណៈ មានការទាញស្រូបនូវរូបារម្មណ៍ ជាកិច្ច ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃចក្ខុវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹង ឃើញជាហេតុ ជាហេតុជិត។

២.**សោតបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់នឹងសទ្ទារម្មណ៍ ជាលក្ខណៈ មានការទាញស្រូបនូវសទ្ទារម្មណ៍ជាកិច្ច ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃសោតវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹងឮសំឡេងជាហេតុ ជាហេតុជិត។

៣.**ឃានបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់នឹងគន្ធារម្មណ៍ ជាលក្ខណៈ មានការទាញស្រូបនូវគន្ធារម្មណ៍ជាកិច្ច ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃឃានវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹងធុំក្លិនជាហេតុ ជាហេតុជិត។

៤.**ជិវ្ហាបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់នឹងរសារម្មណ៍ ជាលក្ខណៈ មានការទាញស្រូបនូវរសារម្មណ៍ជាកិច្ច ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃជិវ្ហាវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹងលិទ្ធភ្លក្សជាហេតុ ជាហេតុជិត។

៥.**កាយបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់នឹងផោដ្ឋព្វៈ ជាលក្ខណៈ មានការទាញស្រូបនូវផោដ្ឋព្វារម្មណ៍ ជាកិច្ច ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃកាយវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹងប៉ះពាល់ជាហេតុ ជាហេតុជិត។

៦.**រូបារម្មណ៍** មានការប៉ះខ្ទប់នឹងចក្ខុបសាទ ជាលក្ខណៈ ធ្វើជាអារម្មណ៍របស់ចក្ខុវិញ្ញាណ ជាកិច្ច មានភាពជាទីគោចររបស់ចក្ខុវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត។

៧.**សទ្ទារម្មណ៍** មានការប៉ះខ្ទប់នឹងសោតបសាទ ជាលក្ខណៈ ធ្វើជាអារម្មណ៍របស់សោតវិញ្ញាណ ជាកិច្ច មានភាពជាទីគោចររបស់សោតវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ២ គឺចិត្ត និងឧតុ ជាហេតុជិត។

៨.**គន្ធារម្មណ៍** មានការប៉ះខ្ទប់នឹងឃានបសាទ ជាលក្ខណៈ ធ្វើជាអារម្មណ៍របស់ឃានវិញ្ញាណ ជាកិច្ច មានភាពជាទីគោចររបស់ឃានវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត។

៩.**រសារម្មណ៍** មានការប៉ះខ្ទប់នឹងជិវ្ហាបសាទ ជាលក្ខណៈ ធ្វើជាអារម្មណ៍របស់ជិវ្ហាវិញ្ញាណ ជាកិច្ច មានភាពជាទីគោចររបស់ជិវ្ហាវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត។

១០.**ផោដ្ឋព្វារម្មណ៍** មាន ៣ យ៉ាង គឺ**បឋវីផោដ្ឋព្វារម្មណ៍** (រឹងទន់) **តេជោផោដ្ឋព្វារម្មណ៍** (ក្តៅ ត្រជាក់) **វាយោផោដ្ឋព្វារម្មណ៍** (កម្រើកតឹង ញ័រ) មានការប៉ះខ្ទប់នឹងកាយបសាទ ជាលក្ខណៈ ធ្វើជាអារម្មណ៍របស់កាយវិញ្ញាណ ជាកិច្ច មានភាពជាទីគោចររបស់កាយវិញ្ញាណ ជាអាការប្រាកដ មានមហាភូតរូប៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត។

១១.**ធម្មាយតនៈ** បានដល់ ចេតសិក សុខុមរូប និព្វាន បញ្ញត្តិ។

១២.**មនាយតនៈ** បានដល់ ភវង្គមន ប៉ុណ្ណោះជាឧប្បត្តិទ្វារ។

## អាយតនៈ ដោយត្រៃលក្ខណ៍

**ចក្ខុមិនទៀង** ដោយហេតុ ៤ គឺ មានការកើតឡើង និងវិនាសទៅវិញក្នុងទីបំផុត១ ដោយការប្រែប្រួលទៅ១ ដោយការកើតឡើងជាខណៈៗ ១ ដោយបដិសេធនូវការទៀង១។

**ចក្ខុជាទុក្ខ** ដោយហេតុ ៤គឺព្រោះជារបស់បៀតបៀនរឿយៗ១ ព្រោះជារបស់ទ្រាំបានដោយលំបាក១ ជាវត្ថុដែលជាទីតាំងនៃទុក្ខ១ ព្រោះបដិសេធនឹងសេចក្តីសុខ១ ។

**ចក្ខុជាអនត្តា** ដោយហេតុ ៤ គឺ ជារបស់សូន្យ១ ជារបស់មិនមានម្ចាស់ ១ ជាវត្ថុដែលធ្វើតាមការពេញចិត្តមិនបាន ១ បដិសេធចំពោះអត្តា ១។

សួរថា លក្ខណៈទាំងឡាយនេះ រមែងមិនប្រាកដ ព្រោះមិនមនសិការអ្វីមិនចាក់ធ្លុះអ្វី និងការរលត់មានអ្វីបិទបាំង?

ឆ្លើយថា **អនិច្ចលក្ខណៈ** ព្រោះសន្តតិបិទបាំង

**ទុក្ខលក្ខណៈ** ព្រោះឥរិយាបថទាំងឡាយបិទបាំង

អនត្តលក្ខណៈ ព្រោះឃនសញ្ញាបិទបាំង។

## ៤-ពោជ្ឈង្គបព្វៈ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុពោ-ជ្ឈង្គេសុ។** ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ (ក្នុងសាសនានេះ) ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គៈ៧។

១-ទោះបី **សតិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **សតិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះបី **សតិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **សតិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃសតិសម្ពោជ្ឈង្គៈមាន ៤

១.សតិសម្បជញ្ញៈ

២.ការវៀរចាកបុគ្គលដែលគ្មានសតិ

៣.ការសេពគប់បុគ្គលដែលមានសតិតាំងមាំ

៤.បង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ។

**សតិសម្ពោជ្ឈង្គៈ** រមែងកើតឡើងដោយសតិសម្បជញ្ញៈ ដោយការវៀរចាកបុគ្គលដែលគ្មានសតិ ប្រៀបដូចជាសត្វក្អែកដែលគ្មានអាហារ ហើយសេពគប់រកបុគ្គលដែលគ្មានសតិតាំងមាំ ដូចជាព្រះតិស្សត្ថេរ និងព្រះអភយត្ថេរជាដើម។ ជាអ្នកមានចិត្តបង្អោនទៅដើម្បីសតិក្នុងឥរិយាបថទាំងឡាយមាន ឈរ អង្គុយជាដើម។ ភិក្ខុ

រមែងដឹងច្បាស់ថា សតិសម្ពោជ្ឈង្គនោះ កើតដោយហេតុ ៤ ប្រការ យ៉ាងនេះរមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ។

២-ទោះបី **ធម្មវិចយសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **ធម្មវិចយសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះបី **ធម្មវិចយសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **ធម្មវិចយសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃធម្មវិចយសម្ពោជ្ឈង្គៈ មាន ៧

១.ការសាកសួរ
២.ការធ្វើវត្ថុឱ្យបរិសុទ្ធ
៣.ការធ្វើឱ្យឥន្ទ្រិយស្មើគ្នា
៤.ការវៀរចាកបុគ្គលដែលគ្មានបញ្ញា
៥.គប់រកបុគ្គលដែលមានបញ្ញា
៦.ពិចារណាដោយបញ្ញាដែលជ្រាលជ្រៅ
៧.ការបង្អោនចិត្តក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយធម៌ដែលជាចំណែកធម៌ខ្មៅ និងធម៌សការធ្វើឱ្យច្រើននូវយោនិសោមនសិការ ក្នុងធម៌ទាំងឡាយនោះ នេះជាអាហារដើម្បីឱ្យកើតឡើង ឬជាហេតុធ្វើនូវភិយ្យោភាព ការចម្រើនបរិបូរណ៍ពេញលេញនៃ **ធម្មវិចយសម្ពោជ្ឈង្គៈ** ដែលកើតឡើងហើយ។

៣-ទោះបី **វីរិយសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **វីរិយសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះបី **វីរិយសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **វីរិយសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃវីរិយសម្ពោជ្ឈង្គ មាន ១១

១.ការពិចារណាឃើញភ័យក្នុងអបាយ

២.ការឃើញអានិសង្ស

៣.ការពិចារណាដល់បដិបទា

៤.ការគោរពកោតក្រែងក្នុងបិណ្ឌបាត

៥.ពិចារណាឃើញនូវអរិយទ្រព្យថាជាទ្រព្យមត៌កធំ

៦.ពិចារណាការឃើញព្រះសាស្តាជាធំ

៧.ការពិចារណាការមានជាតិជាធំ

៨.ការមានសព្រហ្មចារីជាធំ

៩.វៀរចាកបុគ្គលខ្ជិលច្រអូស

១០.គប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម

១១.បង្អោនទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយ **អារម្ភធាតុ** (ធាតុគឺសេចក្តីព្យាយាម) **និក្កមធាតុ បរក្កមធាតុ** (ធាតុ គឺសេចក្តីព្យាយាមឆ្ពោះទៅមុខ) មានហើយ ការធ្វើឱ្យចម្រើននូវយោនិសោមនសិការៈក្នុងធាតុទាំង ៣

នោះជាអាហារដើម្បីកើតឡើងនៃវីរិយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬប្រព្រឹត្តទៅដើម្បីភិយ្យោភាព ការចម្រើនបរិបូរណ៍ពេញលេញនៃ**វីរិយសម្ពោជ្ឈង្គៈ** ដែលកើតហើយ។

៤-ទោះ **បីតិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **បីតិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **បីតិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **បីតិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃបីតិសម្ពោជ្ឈង្គ មាន ១១

១.**ពុទ្ធានុស្សតិ** រឭកគុណព្រះពុទ្ធ
២.**ធម្មានុស្សតិ** រឭកគុណព្រះធម៌
៣.**សង្ឃានុស្សតិ** រឭកគុណព្រះសង្ឃ
៤.**សីលានុស្សតិ** រឭកដល់សីល
៥.**ចាគានុស្សតិ** រឭកដល់ការបរិច្ចាគ
៦.**ទេវតានុស្សតិ** រឭកធម៌នាំឱ្យកើតទេវតា
៧.**ឧបសមានុស្សតិ** រឭកដល់សេចក្តីស្ងប់
៨.វៀរចាកបុគ្គលសៅហ្មង
៩.គប់រកបុគ្គលអ្នកបរិសុទ្ធ
១០.ពិចារណាសេចក្តីព្រះសូត្រ ដែលជាទីជ្រះថ្លា
១១.បង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ មាន ហើយ ការធ្វើឱ្យចម្រើននូវយោនិសោមនសិការ ក្នុងធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ នេះជាអាហារដើម្បីកើតឡើងនៃបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញនៃបីតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ។ បីតិនោះ ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ។ មនសិការញ៉ាំងបីតិនោះ ឱ្យកើតឡើង ឈ្មោះថា **យោនិសោមនសិការ**។

៥-ទោះ **បស្សទ្ធិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **បស្សទ្ធិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **បស្សទ្ធិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **បស្សទ្ធិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃបស្សទ្ធិសម្ពោជ្ឈង្គ មាន ៧

១.សេពភោជនដែលប្រណីត

២.សេពរដូវជាទីសប្បាយ

៣.សេពឥរិយាបថជាទីសប្បាយ

៤.ប្រកបភាពជាកណ្តាល

៥.វៀរបុគ្គលអ្នកមិនស្ងប់កាយ

៦.សេពបុគ្គលដែលមានកាយស្ងប់

៧.បង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយ **កាយបស្សទ្ធិ** សេចក្តីស្ងប់កាយ **ចិត្តបស្សទ្ធិ** សេចក្តីស្ងប់ចិត្ត ការធ្វើឱ្យចម្រើននូវយោនិសោមនសិការក្នុងការស្ងប់កាយ និងការស្ងប់ចិត្តនោះ នេះជាអាហារដើម្បីកើតឡើងនៃ **បស្សទ្ធិសម្ពោជ្ឈង្គៈ** ដែលនៅមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញនៃ**បស្សទ្ធិសម្ពោជ្ឈង្គ** ដែលកើតឡើងហើយ។

៦-ទោះ **សមាធិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **សមាធិសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **សមាធិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **សមាធិសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ។

## ហេតុនៃសមាធិសម្ពោជ្ឈង្គ មាន ១១

១.ធ្វើវត្ថុខាងក្នុង និងខាងក្រៅឱ្យស្អាតរៀបរយ

២.ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា

៣.ឆ្លាតក្នុងនិមិត្ត

៤.ផ្គងចិត្តក្នុងសម័យដែលគួរផ្គង

៥.គ្របសង្កត់ចិត្តក្នុងសម័យគួរគ្របសង្កត់

៦.ធ្វើចិត្តឱ្យរីករាយក្នុងសម័យដែលគួរ

៧.ព្រងើយក្នុងសម័យដែលគួរព្រងើយ

៨.វៀរចាកបុគ្គលដែលមានចិត្តមិនជាសមាធិ

៩.គប់រកបុគ្គលដែលមានចិត្តជាសមាធិ

១០.ពិចារណានូវវិមោក្ខ

១១.បង្អោនចិត្តទៅក្នុងសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយ **សមថនិមិត្ត អព្យគ្គនិមិត្ត** (មិនរាយមាយ) មានហើយការធ្វើឱ្យចម្រើននូវយោនិសោមនសិការក្នុងនិមិត្តទាំង ២ នោះ នេះជាអាហារដើម្បីការកើតឡើងនៃសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញនៃ**សមាធិសម្ពោជ្ឈង្គ**ដែលកើតឡើងហើយ។

៧-ទោះ **ឧបេក្ខាសម្ពោជ្ឈង្គៈ** មាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា **ឧបេក្ខាសម្ពោជ្ឈង្គ** មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ។ ទោះ **ឧបេក្ខាសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា **ឧបេក្ខាសម្ពោជ្ឈង្គៈ** មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ ។

## ហេតុនៃឧបេក្ខាសម្ពោជ្ឈង្គមាន ៥

១.ធ្វើចិត្តឱ្យជាកណ្តាលចំពោះសត្វ

២.ធ្វើចិត្តឱ្យជាកណ្តាលចំពោះសង្ខារ

៣.ធ្វើចិត្តឱ្យជាកណ្តាលចំពោះសត្វ និងសង្ខារ

៤.វៀរបុគ្គលអ្នកប្រកាន់សត្វនិងសង្ខារ

៥.បង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃ**ឧបេក្ខាសម្ពោជ្ឈង្គៈ** មានហើយ ការធ្វើឱ្យចម្រើននូវយោនិសោមនសិការ ក្នុងធម៌ដែលជាទីតាំងនៃ **ឧបេក្ខាសម្ពោជ្ឈង្គៈ** នេះជាអាហារដើម្បីកើតឡើងនៃ **ឧបេក្ខាសម្ពោជ្ឈង្គៈ** ដែលមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញនៃ **ឧបេក្ខាសម្ពោជ្ឈង្គៈ** ដែលកើតឡើងហើយ។

## ៥.សច្ចបព្វៈ

១-ដឹងច្បាស់ពិតប្រាកដថា នេះជាទុក្ខ

២-ដឹងច្បាស់ពិតប្រាកដថានេះជាហេតុឲ្យកើតទុក្ខ

៣-ដឹងច្បាស់ពិតប្រាកដថានេះជាការរំលត់ទុក្ខ

៤-ដឹងច្បាស់ពិតប្រាកដថានេះជា **ទុក្ខនិរោធគាមិនីបដិបទា** (មាគ៌ាឆ្ពោះទៅរកការរំលត់ទុក្ខ)។

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចៈ ៤។

**កថញ្ច ភក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចៈ ៤ ?

**ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ(ក្នុងសាសនានេះ) ដឹងច្បាស់តាមពិតដូច្នេះថានេះទុក្ខ ដឹងច្បាស់តាមពិត ដូច្នេះថា នេះធម៌ជាដែនកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតដូច្នេះថា នេះធម៌ជាទីរលត់នៃទុក្ខ ដឹងច្បាស់តាមពិតដូច្នេះថា នេះដំណើរទៅកាន់ធម៌ជាទីរលត់ទៅនៃទុក្ខ។

## ១.ទុក្ខសច្ចៈ

**កតមា ច ភិក្ខវេ ជាតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា កំណើត?

**យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ ចាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ ជាតិ ។**

កិរិយាកើតឯណា កិរិយាកើតព្រមឯណា កិរិយាយាងចុះកាន់គភ៌ឯណា កិរិយាប្រព្រឹត្តទៅមិនដាច់ឯណាកិរិយាកើតប្រាកដនៃខន្ធទាំងឡាយឯណា កិរិយាបានចំពោះនូវអាយតនៈទាំងឡាយ

ណា នៃសត្វទាំងឡាយនោះៗ ក្នុងពួកសត្វនោះៗ ម្នាលភិក្ខុទាំងឡាយតថាគតចាត់ឲ្យឈ្មោះថា កំណើត ។

**កតមា ច ភិក្ខវេ ជរា?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ជរា (សេចក្ដីចាស់)?

**យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិតចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ភិក្ខវេ ជរា។**

**ជរា** គឺសេចក្ដីចាស់គ្រាំគ្រា ឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយារ ការថយចុះនៃអាយុ ការទ្រុឌទ្រោមឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយនេះតថាគតហៅថា ជរា។

**កតមញ្ច ភិក្ខវេ មរណំ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា សេចក្ដីស្លាប់?

**យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុមរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ ភិក្ខវេ មរណំ។**

កិរិយាឃ្លាតទៅឯណា ភាពនៃកិរិយាឃ្លាតទៅឯណា កិរិយាបែកធ្លាយទៅឯណា កិរិយាបាត់បង់ទៅឯណា សេចក្ដីស្លាប់ដោយមច្ចុឯណា កិរិយាធ្វើនូវមរណកាលឯណា កិរិយាបែកធ្លាយនៃខន្ធទាំងឡាយឯណា កិរិយាដាក់ចុះនូវអត្តភាពឯណា កិរិយាផ្ដាច់បង់នូវ ជីវិតិន្ទ្រិយឯណា នៃសត្វទាំងឡាយនោះៗ ចាកពួកសត្វនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សេចក្ដីស្លាប់ ។

**កតមោ ច ភិក្ខវេ សោកោ?**

ម្នាលភិក្ខុទាំងឡាយ ដូម្ដេចហៅថា សេចក្ដីសោក?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកា សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អយំ វុច្ចតិ ភិក្ខវេ សោកោ។**

ម្នាលភិក្ខុទាំងឡាយ **សោកៈ** គឺសេចក្ដីស្ដាយស្រណោះឯណា សេចក្ដីស្រងេះស្រងោចឯណា សេចក្ដីរីងស្ងួតចិត្ត សេចក្ដីក្រៀមក្រំក្នុងចិត្តណារបស់សត្វដែលប្រកបដោយសេចក្ដីវិនាសណាមួយ (ឬ) ដែលសេចក្ដីទុក្ខណាមួយ ពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយនេះ តថាគតហៅថា **សោកៈ**។

**កតមោ ច ភិក្ខវេ បរិទេវោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា "សេចក្ដីខ្សឹកខ្សួល"?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា**

**បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ អយំ វុច្ចតិ ភិក្ខវេ បរិទេវោ។** ម្នាលភិក្ខុទាំងឡាយសភាវៈទួញរក (បិយជនមានកូនជាដើម) សភាវៈទួញរៀបរាប់ (សរសើរគុណ) កិរិយាយំអណ្តឺតអណ្តក កិរិយាយំបម្រះនទៀលណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ (ឬ) សេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយនេះតថាគតហៅថា **បរិទេវៈ**។

## កតមញ្ច ភិក្ខវេ ទុក្ខំ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីលំបាកកាយ"?

**យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកកាយ សេចក្តីមិនសប្បាយ សេចក្តីលំបាកដែលកើតពីកាយសម្ផស្ស ការទទួលរងសេចក្តីមិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា **ទុក្ខ** ។

## កតមញ្ច ភិក្ខវេ ទោមនស្សំ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា សេចក្តីអាក់អន់ចិត្ត?

**យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សំ។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកក្នុងចិត្តឯណាសេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតពីមនោសម្ផស្ស ការ

ទទួលអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទោមនស្ស។**

**កតមញ្ច ភិក្ខវេ ឧបាយាសោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា សេចក្ដីខ្លោចផ្សាចិត្ត?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ភិក្ខវេ ឧបាយាសោ។** ម្នាលភិក្ខុទាំងឡាយ សេចក្ដីតានតឹងក្នុងចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ភាវៈនៃសេចក្ដីតានតឹងក្នុងចិត្ត ភាវៈនៃសេចក្ដីចង្អៀតចង្អល់ចិត្តណា របស់សត្វដែលប្រកបដោយសេចក្ដីវិនាសណាមួយ ឬសេចក្ដីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតពោលថា **ឧបាយាស។**

**កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា កិរិយាជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ជាទុក្ខ?

**ឥធ ភិក្ខវេ យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកកាមា អយោគក្ខេមកាមា តេសំ សង្គតិ សមាគមោ សមោធានំ មិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ។**

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មានដល់បុគ្គលណា ក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវអំពើដែលមិនក្សេមចាកយោគៈ ចំពោះបុគ្គលនោះ កិរិយាបានជួបជុំគ្នា ការនៅប្រទាក់ប្រទាំគ្នា នឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយនេះតថាគតហៅថា កិរិយាជួបប្រសព្វដោយសត្វ និងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ជាទុក្ខ។

**កតមោ ច ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយជាទីស្រឡាញ់ជាទុក្ខ?

**ឥធ ភិក្ខវេ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស ហោន្តិ អត្ថកាមា ហិតកាមា ផាសុកកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា មិត្តា វា អមច្ចា វា ញាតិសាលោហិតា វា តេសំ អសង្គតិ អសមាគមោ អសមោធានំ អមិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ។**

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ទាំងឡាយឯណា ក្នុងលោកនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ពុំនោះសោត ជនទាំងឡាយឯណា ដែលមានប្រាថ្នានូវកម្មដែលចម្រើន មានប្រាថ្នានូវកម្មជាប្រយោជន៍ មានប្រាថ្នានូវកម្មដែលជាទីសប្បាយ មានប្រាថ្នានូវកម្មដែលក្សេមចាកយោគៈទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី កិរិយាមិនបានដើររួមគ្នាឯណា កិរិយាមិនបានមកជួបគ្នាឯណា កិរិយាមិនបានប្រជុំគ្នាឯណា ភាពជាអ្នកមិនច្រឡូកច្រឡំគ្នាឯណា ដោយអារម្មណ៍ទាំងឡាយនោះៗ ដោយជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយជាទីស្រឡាញ់ជាទុក្ខ។

**កតមោ ច ភិក្ខវេ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ជាទុក្ខ?

**ជាតិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យាតិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ។**

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងឡាយដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎

សូមឲ្យយើងទាំងឡាយកុំគប្បីជាអ្នកមានកំណើតជាធម្មតា ពុំនោះសោតកំណើត កុំគប្បីជាអ្នកមកដល់យើងទាំងឡាយ ហើយហេតុនោះក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្ដីប្រាថ្នាមែនពិត នេះម្យ៉ាងឈ្មោះថា ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះជាទុក្ខ។

**ជរាធម្មានំ ភិក្ខវេ សត្តានំ** ម្នាលភិក្ខុទាំងឡាយ (សេចក្ដីប្រាថ្នាកើតឡើង)ដល់សត្វទាំងឡាយដែលមានសេចក្ដីចាស់ ជាធម្មតា។

**ព្យាធិធម្មានំ ភិក្ខវេ សត្តានំ** ម្នាលភិក្ខុទាំងឡាយ (សេចក្ដីប្រាថ្នាកើតឡើង) ដល់សត្វទាំងឡាយដែលមានសេចក្ដីឈឺចាប់ ជាធម្មតា។

**មរណធម្មានំ ភិក្ខវេ សត្តានំ** ម្នាលភិក្ខុទាំងឡាយ (សេចក្ដីប្រាថ្នាកើតឡើង) ដល់សត្វទាំងឡាយដែលមានសេចក្ដីស្លាប់ ជាធម្មតា។

**សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា អស្សាម ន ច វត នោ សោកបរិទេវ-ទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ។** ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រាថ្នាកើតឡើងដល់សត្វទាំងឡាយ ដែលមានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួលលំបាកកាយ សេចក្ដីអាក់អន់ចិត្ត និងសេចក្ដីខ្លោចផ្សាចិត្តជាធម្មតាយ៉ាងនេះថា អើហ្ន៎! សូមឲ្យយើង

ទាំងឡាយកុំគប្បីជាអ្នកមានសេចក្តីសោក សេចក្តីខ្សឹកខ្សួលលំបាកកាយ សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តជាធម្មតា ពុំនោះសោត សេចក្តីសោក សេចក្តីខ្សឹកខ្សួលលំបាកកាយ សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តទាំងឡាយ កុំគប្បីមកដល់យើងទាំងឡាយឡើយហើយហេតុនោះក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្តីប្រាថ្នាមែនពិត នេះម្យ៉ាងឈ្មោះថា ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ជាទុក្ខ។

**កតមេ ច ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចដែលហៅថា ដោយបង្រួមមកឧបាទានក្ខន្ធទាំងឡាយ ៥ ជាទុក្ខ?

**សេយ្យថីទំ? រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធោ ទុក្ខា។** ឧបាទានក្ខន្ធទាំង ៥ នេះដូចម្តេច? រូបចាត់ជាឧបាទានក្ខន្ធ ១ វេទនាចាត់ជាឧបាទានក្ខន្ធ ១ សញ្ញាចាត់ជាឧបាទានក្ខន្ធ ១ សង្ខារចាត់ជាឧបាទានក្ខន្ធ ១ វិញ្ញាណចាត់ជាឧបាទានក្ខន្ធ ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះតថាគតចាត់ឲ្យឈ្មោះថា ដោយបង្រួមមកឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ។**

ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខអរិយសច្ចៈ។

## ២.សមុទយសច្ច

**កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ទុក្ខសមុទយអរិយសច្ចៈ?

**យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី។**

តណ្ហាឯណា ដែលមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតីកើតរលត់ព្រម ដោយនន្ទិរាគៈត្រេកអរចំពោះក្នុងភពនោះៗឬក្នុងអារម្មណ៍នោះៗ។

**សេយ្យថីទំ? កាមតណ្ហា ភវតណ្ហា វិភវតណ្ហា។**

តណ្ហានេះដូចម្ដេច? កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាមគុណ ១ ភវតណ្ហាសេចក្ដីប្រាថ្នាក្នុងរូបភព និងអរូបភពដែលប្រកបដោយសស្សតទិដ្ឋិ ១ វិភវតណ្ហា សេចក្ដីប្រាថ្នាដែលប្រកបដោយឧច្ឆេទទិដ្ឋិ ១។

**សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ?** ម្នាលភិក្ខុទាំងឡាយ តណ្ហានោះឯង កាលដែលកើតឡើង តើកើតឡើងក្នុងទីណា? កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា?

**យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** អារម្មណ៍ឯណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែល

កើតឡើងរមែងកើតឡើងក្នុងអារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងអារម្មណ៍នោះ។

**កិញ្ចិ លោកេ បិយរូបំ សាតរូបំ?**

អារម្មណ៍អ្វីសោតក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ?

**ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។**

ចក្ខុបសាទក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើងក្នុងចក្ខុបសាទនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងចក្ខុបសាទនោះ។

**សោតំ លោកេ** .... សោតបសាទ ក្នុងលោក ....

**ឃានំ លោកេ** .... ឃានបសាទ ក្នុងលោក ....

**ជិវ្ហា លោកេ** .... ជិវ្ហាបសាទ ក្នុងលោក ....

**កាយោ លោកេ** .... កាយបសាទ ក្នុងលោក ....

**មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** មនោក្នុងលោកដែលមានសភាព

គួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានោះ កាលដែលកើតឡើងរមែងកើតឡើងក្នុងមនោនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងមនោនោះ។

**រូបា លោកេ** .... រូបារម្មណ៍ ទាំងឡាយ ក្នុងលោក ....

**សទ្ទា លោកេ** .... សទ្ទារម្មណ៍ ទាំងឡាយ ក្នុងលោក ....

**គន្ធា លោកេ** .... គន្ធារម្មណ៍ ទាំងឡាយ ក្នុងលោក ....

**រសា លោកេ** .... រសារម្មណ៍ ទាំងឡាយ ក្នុងលោក ....

**ផោដ្ឋព្វា លោកេ** .... ផោដ្ឋព្វារម្មណ៍ ទាំងឡាយ ក្នុងលោក ....

**ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** ធម្មារម្មណ៍ទាំងឡាយក្នុងលោកដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលកើតឡើង រមែងកើតឡើងក្នុងធម្មារម្មណ៍ទាំងឡាយនោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុងធម្មារម្មណ៍ទាំងឡាយនោះ។

**ចក្ខុវិញ្ញាណំ លោកេ** .... ចក្ខុវិញ្ញាណ ក្នុងលោក ....

**សោតវិញ្ញាណំ លោកេ** .... សោតវិញ្ញាណ ក្នុងលោក ....

**ឃានវិញ្ញាណំ លោកេ** .... ឃានវិញ្ញាណ ក្នុងលោក ....

**ជិវ្ហាវិញ្ញាណំ លោកេ** .... ជិវ្ហាវិញ្ញាណ ក្នុងលោក ....

**កាយវិញ្ញាណំ លោកេ** .... កាយវិញ្ញាណ ក្នុងលោក ....

**មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងមនោវិញ្ញាណនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងមនោវិញ្ញាណនោះ។

**ចក្ខុសម្ផស្សោ លោកេ** .... ចក្ខុសម្ផស្ស ក្នុងលោក ....

**សោតសម្ផស្សោ លោកេ** .... សោតសម្ផស្ស ក្នុងលោក ....

**ឃានសម្ផស្សោ លោកេ** .... ឃានសម្ផស្ស ក្នុងលោក ....

**ជិវ្ហាសម្ផស្សោ លោកេ** .... ជិវ្ហាសម្ផស្ស ក្នុងលោក ....

**កាយសម្ផស្សោ លោកេ** .... កាយសម្ផស្ស ក្នុងលោក ....

**មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងមនោសម្ផស្សនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងមនោសម្ផស្សនោះ។

**ចក្ខុសម្ផស្សជា វេទនា លោកេ** ....

វេទនាដែលកើតអំពីចក្ខុសម្ផស្ស ក្នុងលោក ....

**សោតសម្ផស្សជា វេទនា លោកេ** ....

វេទនាដែលកើតអំពីសោតសម្ផស្ស ក្នុងលោក ....

**ឃានសម្ផស្សជា វេទនា លោកេ** ....

វេទនាដែលកើតអំពីឃានសម្ផស្ស ក្នុងលោក ....

**ជិវ្ហាសម្ផស្សជា វេទនា លោកេ** ....

វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ក្នុងលោក ....

**កាយសម្ផស្សជា វេទនា លោកេ** ....

វេទនាដែលកើតអំពីកាយសម្ផស្ស ក្នុងលោក ....

**មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ។** វេទនាដែលកើតអំពីមនោសម្ផស្ស ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើងក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនោះ កាលដែលជាប់នៅក៏រមែងជាប់ នៅក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនោះ។

**រូបសញ្ញា លោកេ** ....

សេចក្តីសម្គាល់នូវរូបារម្មណ៍ ក្នុងលោក ....

**សទ្ទសញ្ញា លោកេ** ....

សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ ក្នុងលោក ....

**គន្ធសញ្ញា លោកេ** ....

សេចក្តីសម្គាល់នូវគន្ធារម្មណ៍ ក្នុងលោក ....

**រសសញ្ញា លោកេ** ....

សេចក្តីសម្គាល់នូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វសញ្ញា លោកេ...**

សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មសញ្ញា លោកេ បិយរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវីសមានា និវីសតិ ។** សេចក្តីសម្គាល់នូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុង សេចក្តីសម្គាល់នូវធម្មារណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុង សេចក្តីសម្គាល់នូវធម្មារម្មណ៍នោះ ។

**រូបសញ្ចេតនា លោកេ...**

ការសន្សំនូវរូបារម្មណ៍ ក្នុងលោក...

**សទ្ទសញ្ចេតនា លោកេ...**

ការសន្សំនូវសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធសញ្ចេតនា លោកេ**

ការសន្សំនូវគន្ធារម្មណ៍ ក្នុងលោក...

**រសសញ្ចេតនា លោកេ...**

ការសន្សំនូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វសញ្ចេតនា លោកេ...**

ការសន្សំនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។** ការគិតសន្សំនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងសេចក្តីចុះចិត្ត ក្នុងធម្មារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសេចក្តីចុះចិត្តក្នុងធម្មារម្មណ៍នោះ។

**រូបតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងរូបារម្មណ៍ ក្នុងលោក...

**សទ្ទតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងគន្ធារម្មណ៍ ក្នុងលោក...

**រសតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងរសារម្មណ៍ ក្នុងលោក ...

**ផោដ្ឋព្វតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។** សេចក្តីចំណង់ក្នុងធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងសេចក្តីចំណង់ ក្នុងធម្មារម្មណ៍នោះកាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសេចក្តីចំណង់ក្នុងធម្មារម្មណ៍នោះ ។

**រូបវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរូបារម្មណ៍ ក្នុងលោក ...

**សទ្ទវិតក្កោ លោកេ...**

សភាពត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធវិតក្កោ លោកេ...**

សភាពត្រិះរិះនូវគន្ធារម្មណ៍ ក្នុងលោក...

**រសវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វវិតក្កោ លោកេ...**

សភាពត្រិះរិះនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។** សភាពត្រិះរិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើង ក្នុងសភាពត្រិះរិះធម្មារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ ។

**រូបវិចារោ លោកេ...**

សភាពពិចារណានូវរូបារម្មណ៍ ក្នុងលោក...

**សទ្ទវិចារោ លោកេ...**

សភាពពិចារណានូវសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធវិចារោ លោកេ...**

សភាពពិចារណានូវគន្ធារម្មណ៍ ក្នុងលោក...

**រសវិចារោ លោកេ...**

សភាពពិចារណានូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វវិចារោ លោកេ...**

សភាពពិចារណានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក....

**ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

សភាពពិចារណានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងសភាពពិចារណានូវធម្មារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុង សភាពពិចារណានូវធម្មារម្មណ៍នោះ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ** ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខសមុទយអរិយសច្ចៈ។

## ៣.ទុក្ខនិរោធសច្ចៈ

### កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា **ទុក្ខនិរោធអរិយសច្ចៈ**?

**យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ។** កិរិយារលត់ទៅ នៃតណ្ហានោះ មិនមានសេសសល់ដោយអរិយមគ្គ ឯណា កិរិយាលះបង់នូវតណ្ហានោះឯណា កិរិយារលាស់ចេញចាកតណ្ហានោះឯណា កិរិយារួចចាកតណ្ហានោះឯណា សេចក្ដីមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារលត់ទៅនៃតណ្ហាជាដើមនោះហៅថា**ទុក្ខនិរោធអរិយសច្ចៈ**។

**សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហីយមានា បហីយតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ?** ម្នាលភិក្ខុទាំងឡាយ តណ្ហានោះសោតកាលដែលលោកលះបង់ តើលះបង់ក្នុងទីណា? កាលដែលរលត់ទៅវិញ តើរលត់ទៅក្នុងទីណា?

**យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។** អារម្មណ៍ឯណាក្នុងលោកដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាល

ដែលលោកលះបង់ រមែងលះបង់ក្នុងអារម្មណ៍នោះ កាលដែល រលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងអារម្មណ៍នោះ ។

**កិញ្ច លោកេ បិយរូបំ សាតរូបំ ?**

អារម្មណ៍អ្វីសោតក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ?

**ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។** ចក្ខុបសាទក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់រមែងលះបង់ក្នុងចក្ខុបសាទនោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុង ចក្ខុបសាទនោះ។

**សោតំ លោកេ...**សោត ក្នុងលោក...

**ឃានំ លោកេ...**ឃាន ក្នុងលោក...

**ជិវ្ហា លោកេ...**ជិវ្ហា ក្នុងលោក...

**កាយោ លោកេ...**កាយ ក្នុងលោក...

**មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។** មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែល

លោកលះបង់ រមែងលះបង់ក្នុងមនោនោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងមនោនោះ។

**រូបា លោកេ**...រូបារម្មណ៍ទាំងឡាយ ក្នុងលោក...

**សទ្ទា លោកេ**...សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក...

**គន្ធា លោកេ**...គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក...

**រសា លោកេ**...រសារម្មណ៍ទាំងឡាយ ក្នុងលោក...

**ផោដ្ឋព្វា លោកេ**...ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក...

**ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។** ធម្មារម្មណ៍ទាំងឡាយក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងធម្មារម្មណ៍ទាំងឡាយនោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅវិញក្នុងធម្មារម្មណ៍ទាំងឡាយនោះ ។

**ចក្ខុវិញ្ញាណំ លោកេ**...ចក្ខុវិញ្ញាណក្នុងលោក...

**សោតវិញ្ញាណំ លោកេ**...សោតវិញ្ញាណក្នុងលោក...

**ឃានវិញ្ញាណំ លោកេ**...ឃានវិញ្ញាណក្នុងលោក...

**ជិវ្ហាវិញ្ញាណំ លោកេ**...ជិវ្ហាវិញ្ញាណក្នុងលោក...

**កាយវិញ្ញាណំ លោកេ...** កាយវិញ្ញាណក្នុងលោក...

**មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។**

មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងមនោវិញ្ញាណនោះ កាលរលត់ទៅ ក៏រលត់ទៅក្នុងមនោវិញ្ញាណនោះ។

**ចក្ខុសម្ផស្សោ លោកេ...**ចក្ខុសម្ផស្សក្នុងលោក...

**សោតសម្ផស្សោ លោកេ...**សោតសម្ផស្សក្នុងលោក...

**ឃានសម្ផស្សោ លោកេ...**ឃានសម្ផស្សក្នុងលោក...

**ជិវ្ហាសម្ផស្សោ លោកេ...**ជិវ្ហាសម្ផស្សក្នុងលោក...

**កាយសម្ផស្សោ លោកេ...**កាយសម្ផស្សក្នុងលោក...

**មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។**

មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងមនោសម្ផស្សនោះ ។

**ចក្ខុសម្ផស្សជា វេទនា លោកេ...**វេទនាកើតពីចក្ខុសម្ផស្សក្នុងលោក.

**សោតសម្ផស្សជា វេទនា លោកេ...**វេទនាកើតពីសោតសម្ផស្សក្នុងលោក...

**ឃានសម្ផស្សជា វេទនា លោកេ...**វេទនាកើតពីឃានសម្ផស្សក្នុងលោក...

**ជិវ្ហាសម្ផស្សជា វេទនា លោកេ...**វេទនាកើតពីជិវ្ហាសម្ផស្សក្នុងលោក...

**កាយសម្ផស្សជា វេទនា លោកេ...**វេទនាកើតពីកាយសម្ផស្សក្នុងលោក...

**មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។**

វេទនាកើតពីមនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងមនោសម្ផស្សនោះ កាលដែលរលត់ទៅ ក៏រលត់ក្នុងមនោសម្ផស្សនោះ។

**រូបសញ្ញា លោកេ...**

សេចក្តីសំគាល់នូវរូបារម្មណ៍ក្នុងលោក...

**សទ្ទសញ្ញា លោកេ...**

សេចក្តីសំគាល់នូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធសញ្ញា លោកេ...**

សេចក្តីសំគាល់នូវគន្ធារម្មណ៍ក្នុងលោក...

**រសសញ្ញា លោកេ...**

សេចក្តីសំគាល់នូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វសញ្ញា លោកេ...**

សេចក្តីសំគាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។** សេចក្តីសំគាល់នូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសេចក្តីសំគាល់នូវធម្មារម្មណ៍ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសេចក្តីសំគាល់នូវធម្មារម្មណ៍នោះ។

**រូបសញ្ចេតនា លោកេ...**

ការគិតសន្សំនូវរូបារម្មណ៍ក្នុងលោក...

**សទ្ទសញ្ចេតនា លោកេ...**

ការគិតសន្សំនូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធសញ្ចេតនា លោកេ...**

ការគិតសន្សំនូវគន្ធារម្មណ៍ក្នុងលោក...

**រសសញ្ចេតនា លោកេ...**

ការគិតសន្សំនូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វសញ្ចេតនា លោកេ...**

ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និវុជ្ឈមានា និរុជ្ឈតិ។** សេចក្តីចុះចិត្តក្នុងធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសេចក្តីចុះចិត្តក្នុងធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសេចក្តីចុះចិត្តក្នុងធម្មារម្មណ៍នោះ។

**រូបតណ្ហា លោកេ...**

សេចក្តីប្រាថ្នានូវរូបារម្មណ៍ក្នុងលោក...

**សទ្ទតណ្ហា លោកេ...**

សេចក្ដីប្រាថ្នានូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធតណ្ហា លោកេ...**

សេចក្ដីប្រាថ្នានូវគន្ធារម្មណ៍ក្នុងលោក

**រសតណ្ហា លោកេ...**

សេចក្ដីប្រាថ្នានូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វតណ្ហា លោកេ...**

សេចក្ដីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។**

សេចក្ដីប្រាថ្នានូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសេចក្ដីប្រាថ្នានូវធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសេចក្ដីប្រាថ្នានូវធម្មារម្មណ៍នោះ។

**រូបវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរូបារម្មណ៍ក្នុងលោក...

**សទ្ទវិតក្កោ លោកេ...**

សភាពត្រិះរិះនូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធវិតក្កោ លោកេ...**

សភាពត្រិះរិះនូវគន្ធារម្មណ៍ក្នុងលោក...

**រសវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វវិតក្កោ លោកេ...**

សភាពត្រិះរិះនូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។**

សភាពត្រិះរិះនូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ។

**រូបវិចារោ លោកេ...**

សភាពពិចារណានូវរូបារម្មណ៍ក្នុងលោក...

**សទ្ទវិចារោ លោកេ...**

សភាពពិចារណានូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធវិចារោ លោកេ...**

សភាពពិចារណានូវគន្ធារម្មណ៍ក្នុងលោក...

**រសវិចារោ លោកេ...**

សភាពពិចារណានូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វវិចារោ លោកេ...**

សភាពពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ។**

សភាពពិចារណានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងភាពពិចារណានូវធម្មារម្មណ៍នោះ កាល

ដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសភាពពិចារណានូវធម្មារម្មណ៍នោះ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ។**

ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធអរិយសច្ចៈ។

## ៤.មគ្គសច្ចៈ

**កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ?** ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ**?

**អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ។** នេះឯងគឺ តួអរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ។

**សេយ្យថីទំ? សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ។** អរិយមគ្គ នេះដូចម្តេច? ប្រាជ្ញាយល់ឃើញដោយប្រពៃ ១ សេចក្តីត្រិះរិះដោយប្រពៃ ១ ពោលពាក្យដោយប្រពៃ១ ការងារប្រព្រឹត្តទៅដោយប្រពៃ ១ កិរិយាចិញ្ចឹមជីវិតដោយប្រពៃ១ សេចក្តីព្យាយាមដោយប្រពៃ ១ សេចក្តីរឭកឃើញដោយប្រពៃ១ សេចក្តីតម្កល់ចិត្តដោយប្រពៃ ១។

**កតមា ច ភិក្ខវេ សម្មាទិដ្ឋិ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ប្រាជ្ញាយល់ឃើញដោយប្រពៃ ?

**យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតិ ភិក្ខវេ សម្មាទិដ្ឋិ។** ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដឹងច្បាស់ក្នុងកងទុក្ខណាប្រាជ្ញាដឹងច្បាស់ក្នុងធម៌ ជាដែនកើតនៃទុក្ខណា ប្រាជ្ញាដឹងច្បាស់ក្នុងធម៌ជាទីរលត់ទៅនៃទុក្ខឯណា ប្រាជ្ញាដឹងច្បាស់ក្នុងដំណើរដែលទៅកាន់ធម៌ជាទីរំលត់ទៅនៃទុក្ខឯណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ប្រាជ្ញាយល់ឃើញដោយប្រពៃ។

**កតមោ ច ភិក្ខវេ សម្មាសង្កប្បោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា សេចក្ដីត្រិះរិះដោយប្រពៃ?

**នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ។** សេចក្ដីត្រិះរិះដើម្បីចេញចាកកាម ១ សេចក្ដីត្រិះរិះដើម្បីមិនព្យាបាទ១ សេចក្ដីត្រិះរិះដើម្បីមិនបៀតបៀន ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សេចក្ដីត្រិះរិះដោយប្រពៃ។

**កតមា ច ភិក្ខវេ សម្មាវាចា?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ពោលពាក្យសំដីដោយប្រពៃ?

**មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា។**

ចេតនាវៀរចាកពោលនូវពាក្យមិនពិត១ ចេតនាវៀរចាកសំដីញុះញង់ស៊កសៀត១ ចេតនាវៀរចាកសំដីទ្រគោះខ្ទីខ្ទា ១ ចេតនាវៀរចាកសំដីរោយរាយឥតប្រយោជន៍១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ពោលពាក្យសំដីដោយប្រពៃ ។

**កតមោ ច ភិក្ខវេ សម្មាកម្មន្តោ?** ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចដែលហៅថា ការងារប្រព្រឹត្តទៅដោយប្រពៃ?

**បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ។**

ចេតនាវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះឆាប់ ១ ចេតនាវៀរចាកកិរិយាកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ១ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ការងារប្រព្រឹត្តទៅដោយប្រពៃ ។

**កតមោ ច ភិក្ខវេ សម្មាអាជីវោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចដែលហៅថា កិរិយាចិញ្ចឹមជីវិតដោយប្រពៃ ?

**ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ។** ម្នាលភិក្ខុទាំងឡាយ

អរិយសាវកក្នុងសាសនានេះ លះបង់នូវកិរិយាចិញ្ចឹមជីវិតខុស ហើយសម្រេចនូវការចិញ្ចឹមជីវិត ដោយព្យាយាមជាគ្រឿងរស់នៅ ដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា កិរិយាចិញ្ចឹមជីវិតដោយប្រពៃ ។

**កតមោ ច ភិក្ខវេ សម្មាវាយាមោ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចដែលហៅថា សេចក្ដីព្យាយាមដោយប្រពៃ?

**ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោ-សាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ  អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុកតាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុក តាំងព្យាយាមមាំដើម្បីលះបង់នូវធម៌ទាំង

ទ្បាយជាអកុសលដ៏លាមកដែលកើតហើយ។ ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំង ធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឲ្យកើតឡើង។ ញ៉ាំង ឆន្ទៈឲ្យកើតប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ស្ថិតស្ថេរកុំឲ្យភ្លេចភ្លាំងទៅវិញ ឲ្យបានចម្រើនធំទូលាយពេញ បរិបូរណ៍ក្រៃលែងឡើង។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សេចក្តីព្យាយាមដោយប្រពៃ ។

## កតមា ច ភិក្ខវេ សម្មាសតិ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា សេចក្តីរឭកត្រូវ ?

**ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោ-មនស្សំ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញ រឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវ កិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតី ជាគ្រឿងកំណត់ បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។ ពិចារណាឃើញ

រឿយៗ នូវវេទនាក្នុងវេទនា ទាំងឡាយមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក។ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។ ម្នាលភិក្ខុទាំងឡាយនេះតថាគតហៅថា សេចក្តីរឭកឃើញដោយប្រពៃ។

**កតមោ ច ភិក្ខវេ សម្មាសមាធិ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា សេចក្តីតម្កល់ចិត្តនឹងត្រូវ?

**ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ។ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខម សុខំ ឧបេក្ខាសតិ បារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ។** ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា

សម្មាសមាធិ។ ភិក្ខុក្នុងសាសនានេះស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលចូលទៅកាន់បឋមជ្ឈាន ប្រកប ដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ លុះភិក្ខុចូលទៅជិតរម្ងាប់វិតក្កៈ និងវិចារៈរួចហើយ ក៏ចូលទៅកាន់ទុតិយជ្ឈាន ដែលកើតមានក្នុងសន្តានជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈ និងវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ។បេ។ ចូលកាន់តតិយជ្ឈានសម្រេចសម្រាន្តនៅ ដោយឥរិយាបថ ៤ ចូលទៅកាន់ចតុត្ថជ្ឈានមានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ឥតទុក្ខ ឥតសុខ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរលត់ទៅនៃសោមនស្ស និងទោមនស្សអំពីមុនផង ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាសមាធិ**។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ**។

## លក្ខណាទិចតុក្ករបស់សម្មាទិដ្ឋិ

- មានការឃើញត្រូវ ជាលក្ខណៈ
- មានការប្រកាសសេចក្តីពិត ជាកិច្ច
- មានការកម្ចាត់អវិជ្ជា ជាផល។

## លក្ខណាទិចតុក្ករបស់សម្មាសង្កប្បៈ

- មានការលើកចិត្តឡើងត្រូវផ្លូវ ជាលក្ខណៈ

- មានការត្រិះរិះយ៉ាងមាំទាំនៅក្នុងផ្លូវ ជាកិច្ច
- មានការលះបង់នូវមិច្ឆាសង្កប្បៈ ជាផល។

## លក្ខណាទិតិករបស់សម្មាវាចា

- មានការកំណត់កាន់យក ជាលក្ខណៈ
- មានការវៀរចាក ជាកិច្ច
- មានការលះបង់មិច្ឆាវាចា ជាផល។

## លក្ខណាទិតិករបស់សម្មាកម្មន្តៈ

- មានការត្រកង (សម្បយុត្តធម៌) ជាលក្ខណៈ
- មានការវៀរចាក ជាកិច្ច
- មានការលះបង់មិច្ឆាកម្មន្តៈ ជាផល។

## លក្ខណាទិតិករបស់សម្មាអាជីវៈ

- មានការស្អាតនៃអាជីព ជាលក្ខណៈ
- មានការញ៉ាំងអាជីពដោយធម៌ប្រព្រឹត្តទៅ ជាកិច្ច
- មានការលះបង់នូវមិច្ឆាអាជីវៈ ជាផល។

## លក្ខណាទិតិករបស់សម្មាវាយាម

- មានការផ្គងចិត្តឡើង ជាលក្ខណៈ
- មានសម្មប្បធាន ៤ ជាកិច្ច
- មានការលះបង់មិច្ឆាវាយាម ជាផល។

## លក្ខណាទិតិករបស់សម្មាសតិ

- មានការតាំងសតិទុកមាំ ជាលក្ខណៈ

- មានការមិនភ្លេច ជាកិច្ច
- មានការលះបង់មិច្ឆាសតិ ជាផល។

## លក្ខណាទិត្តិករបស់សម្មាសមាធិ

- មានការមិនរាយមាយនៃចិត្ត ជាលក្ខណៈ
- មានការតាំងចិត្តទុកយ៉ាងមាំ ជាកិច្ច
- មានការលះបង់នូវមិច្ឆាសមាធិ ជាផល។

លុះបានរម្ងាប់សេចក្ដីសុខ និងទុក្ខហើយដោយសេចក្ដីសោមនស្ស និងទោមនស្ស បានរលាយបាត់អស់ពីមុនមកដែរ ភិក្ខុចូលទៅកាន់សភាពមួយ ដែលនៅផុតពីសេចក្ដីសុខ និងសេចក្ដីទុក្ខ គឺចតុត្ថជ្ឈាន ដែលមានភាពបរិសុទ្ធិទាំងស្រុង ដោយមានភាពឧបេក្ខា និងសតិដឹងហើយក៏តាំងនៅក្នុងចតុត្ថជ្ឈាននេះ។

(ចប់ធម្មានុបស្សនា)

## អដ្ឋកថា

**សច្ចៈទី ១** ពាក្យថា **ទុក្ខំ** ស័ព្ទថា **ទុ** អត្ថថា គួរស្អប់ បានដល់អាក្រក់ ចំណែក **ខំ** អត្ថថា សូន្យ ទទេ។

**សច្ចៈទី១** នេះគឺគួរស្អប់ ព្រោះជាទីតាំងនៃវត្ថុចោកទាប មានឧបទ្ទវជាដើមដ៏ច្រើន ចាត់ថាសូន្យ ព្រោះវៀរចាកភាពឋិតថេរ ភាពស្អាត សេចក្ដីសុខ និងភាពជាអនត្តា ដែលជនពាលប្រកាន់ហើយ ព្រោះហេតុនោះ ទើបហៅថា ទុក្ខ។

**សច្ចៈទី២** ពាក្យថា **សំ** ប្រកបព្រមចូលគ្នា **ឧ** សំដៅដល់ ការកើត ដូចពាក្យថា **ឧប្បន្ន ឧទិត** កើតឡើង ឧទ័យឡើង **អយ** សំដៅដល់ហេតុ។

**សច្ចៈទី៣** ពាក្យថា **និ** ស័ព្ទសំដៅដល់ការមិនមាន និង **រោធ** ស័ព្ទ សំដៅដល់គុក ការមិនមានទីឃុំឃាំង ដែលហៅថា គុកក្នុងសង្សារសច្ចៈទើបហៅថា ទុក្ខនិរោធ ព្រោះថា ប្រាសចាកគតិទាំងពួង បើព្រះយោគាវចរបានសម្រេចហើយ ក៏មិនមានទីឃុំឃាំងនូវទុក្ខ ដែលហៅថា គុកសង្សារ ព្រោះបដិបក្ខនឹងទុក្ខ។

**សច្ចៈទី៤** (ទុក្ខនិរោធគាមិនីបដិបទា) ដំណើរទៅកាន់ទុក្ខនិរោធ ព្រោះជាធម៌មានមុខឆ្ពោះទៅកាន់ទុក្ខនិរោធនោះ និងមានទុក្ខនិរោធនោះជាអារម្មណ៍ ព្រមទាំងជាបដិបទានៃការសម្រេចទុក្ខនិរោធនោះផងដែរ។

សច្ចៈទាំងឡាយនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា អរិយសច្ចៈព្រោះជាធម៌ដែលព្រះអរិយទាំងឡាយ ទ្រង់សម្រេចហើយ។

ន័យម្យ៉ាងទៀត ហៅថា **អរិយសច្ចៈ** ព្រោះការបានសម្រេចជាព្រះអរិយក៏ដោយសារការបានត្រាស់ដឹងសច្ចៈ ទាំងឡាយនោះក៏បាន ដូចពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ព្រោះការបានត្រាស់ដឹងអរិយសច្ចទាំង ៤ តាមសេចក្ដីពិត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទើបបានព្រះនាមថា អរិយៈ។

## អ្វីជាអត្ថនៃសច្ចៈ?

ឆ្លើយថា សភាវៈណា កាលព្រះយោគាវចរទាំងឡាយ ចូលទៅសម្លឹងមើល ដោយបញ្ញាចក្ខុ ក៏មិនជាសភាវៈដែលវិបរិត (ខុសចាកការពិត) ដោយកលមាយាមិនជាសភាវៈ ដែលបោកបញ្ឆោតដូចថ្ងៃបណ្តើរកូន និងមិនជាសភាវៈដែលនរណាៗរកមិនបាន ដូចជាអត្តារបស់ពួកតិរ្ថិយ តែជាគោចរ (ជាអារម្មណ៍) នៃអរិយញាណជាសភាវៈដែលពិត មិនវិបរិត និងពិតដោយការបៀតបៀន ជាហេតុស្ងប់ និងនាំចេញ ជាសភាវៈដែលពិត មិនវិបរិត ដូចលក្ខណៈរបស់ភ្លើង និងដូចប្រក្រតីរបស់លោក (ដីកាៈ គឺកើត ចាស់ ស្លាប់ ជាធម្មតា)។

## អង្គធម៌សតិប្បដ្ឋាន ៤

**១.កាយានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការពិចារណារឿយៗនូវកាយ អង្គធម៌ បានដល់សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**២.វេទនានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការពិចារណារឿយៗនូវវេទនា អង្គធម៌ បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**៣.ចិត្តានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការពិចារណារឿយៗនូវចិត្ត អង្គធម៌ បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**៤.ធម្មានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការពិចារណារឿយៗ នូវសភាវៈរស់នៅដែលប្រាសចាកតួខ្លួន អង្គធម៌បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

## សតិប្បដ្ឋាន ៤ លះវិបល្លាស ៤ ប្រការ

**១.កាយានុបស្សនា** លះសុភវិបល្លាស (យល់ថាស្អាត)

**២.វេទនានុបស្សនា** លះសុខវិបល្លាស (យល់ថាសុខ)

**៣.ចិត្តានុបស្សនា** លះនិច្ចវិបល្លាស (យល់ថាទៀង)

**៤.ធម្មានុបស្សនា** លះអត្តវិបល្លាស (យល់ថាអត្តា)។

## ហេតុផលសតិតែមួយជាសតិប្បដ្ឋានទាំង ៤

១.អារម្មណ៍ដែលជាទីតាំងនៃការកំណត់ ក៏មាន ៤

២.លក្ខណៈដែលជានិមិត្តប្រាកដ ក៏មាន ៤

៣.ការលះវិបល្លាស ក៏មាន ៤ ។

## សតិកំណត់ដឹងអារម្មណ៍ក្នុងខន្ធ ៥

១.**រូបក្ខន្ធ** ជាអារម្មណ៍របស់សតិ ហៅថា កាយានុបស្សនាសតិប្បដ្ឋាន

២.**វេទនាខន្ធ** ជាអារម្មណ៍របស់សតិ ហៅថា វេទនានុបស្សនាសតិប្បដ្ឋាន

៣.**សញ្ញាខន្ធ និងសង្ខារក្ខន្ធ** ជាអារម្មណ៍របស់សតិ ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន។

៤.**វិញ្ញាណក្ខន្ធ** ជាអារម្មណ៍របស់សតិ ហៅថា ចិត្តានុបស្សនា-សតិប្បដ្ឋាន

**លក្ខណៈ៤ ជានិមិត្តដែលកើតឡើង និងលះវិបល្លាស ៤**

១.ពិចារណាកាយរឿយៗ ជាហេតុកើតអសុភលក្ខណៈរមែងលះនូវសុភវិបល្លាស។

២.ពិចារណាវេទនារឿយៗ ជាហេតុកើតទុក្ខលក្ខណៈ រមែងលះនូវសុខវិបល្លាស។

៣.ពិចារណាចិត្តរឿយៗ ជាហេតុកើតអនិច្ចលក្ខណៈ រមែងលះនូវនិច្ចវិបល្លាស។

៤.ពិចារណាសភាវធម៌រឿយៗ ជាហេតុកើតអនត្តលក្ខណៈ រមែងលះនូវអត្តវិបល្លាស។

## ២.សម្មប្បធាន

**សម្មា បទហន្តិ ឯតេនាតិ** = **សម្មប្បធានំ** សម្បយុត្តធម៌ទាំងឡាយ រមែងព្យាយាមដោយប្រពៃ ដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិនោះទើបឈ្មោះថា **សម្មប្បធាន**។

វីរិយចេតសិកដែលជាសម្មប្បធាននោះ ត្រូវជាវីរិយៈយ៉ាងខ្លាំងក្លា ដែលព្យាយាមលះអកុសល សូម្បីនឹងសល់តែស្បែក សរសៃឆ្អឹង ឬសាច់ និងឈាមរីងស្ងួតក្តី នឹងមិនរាថយដល់ការព្យាយាមនោះឡើយ វីរិយៈធម្មតានៅមិនចាត់ជាសម្មប្បធានទេ។

វិរិយៈដែលជាសម្មប្បធាននោះ ត្រូវជាវិរិយៈដែលប្រាសចាកបមាទធម៌ គឺត្រូវជាវិរិយចេតសិក ដែលប្រកបក្នុងកុសលជវនៈប៉ុណ្ណោះ ចំណែកវិរិយៈដែលនៅក្នុងកិរិយាជវនៈ ឬផលចិត្តរបស់ព្រះអរិយបុគ្គលនោះ រមែងមិនជាសម្មប្បធាន ព្រោះវិរិយៈក្នុងកិរិយាជវ័ននោះ ផុតកិច្ចដែលត្រូវលះអកុសល ឬធ្វើកុសលកើតឡើងហើយ និងជវនក្នុងផលចិត្ត ក៏មិនមានកិច្ចទាក់ទងជាមួយការប្រហារអកុសលដូចគ្នា។

ធម្មតាសត្វដែលនៅវិលវល់កើតស្លាប់ក្នុងវដ្តទុក្ខ រមែងមានអកុសលជាប្រចាំ ២ ប្រការគឺ

១.**ឧប្បន្នអកុសល** អកុសលដែលកើតមកហើយក្នុងសន្តានរបស់ខ្លួន បានទាំងអកុសលអតីត និងបច្ចុប្បន្ន សេចក្តីថា អកុសលធម៌ទាំងឡាយដែលបានធ្វើមកហើយនោះ ប្រភេទខ្លះឱ្យផលទៅហើយក៏មាន និងអកុសលប្រភេទខ្លះមិនទាន់ឱ្យផលក៏មាន ព្រោះនៅមិនទាន់មានឱកាសឱ្យផលក៏មាន អកុសលដែលកើតហើយទាំងនេះ មានសក្កាយទិដ្ឋិ បានដល់ការយល់ឃើញខុស ដែលប្រកាន់មាំក្នុងនាមរូប ខន្ធ ៥ ថា ជាតួខ្លួន មនុស្ស សត្វ យើង គេ ជាដើម ដរាបណាសក្កាយទិដ្ឋិនៅមាន ក៏ដូចជានៅមានបំណុលចាស់ដែលត្រូវសងក្នុងអបាយភូមិ ៤ នៅសល់រកប្រមាណមិនបាន បំណុលចាស់ទាំងនេះហៅថា **ឧប្បន្នអកុសល** កាលណាប្រហារ

សក្កាយទិដ្ឋិបានអកុសលទាំងឡាយ ក៏រមែងអន្តរធានសូន្យបាត់ទៅក្នុងទីបំផុត។

២.**អនុប្បន្នអកុសល** ជាអកុសលដែលនៅមិនទាន់បានកើតឡើងក្នុងសន្តានរបស់ខ្លួន សំដៅដល់អកុសលដែលនៅមិនទាន់បានធ្វើក្នុងអនាគត ពោលគឺសត្វទាំងឡាយតាំងពីនេះជាដើមទៅដរាបណាដែលនៅមិនទាន់ដល់ព្រះនិព្វាន ដរាបនោះអកុសលទាំងឡាយដែលនឹងធ្វើតទៅក៏មានច្រើនទៀតរហូតដល់រកប្រមាណមិនបាន ដល់កាលសក្កាយទិដ្ឋិរលត់កាលណា អកុសលទាំងនោះក៏ត្រូវអន្តរធានបាត់ទៅក្នុងទីបំផុត។

## សម្មប្បធាន ៤ ប្រការ

**១.ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយាមោ** សេចក្តីព្យាយាមដើម្បីលះអកុសលដែលកើតឡើងហើយ អង្គធម៌បានដល់ វីរិយចេតសិកក្នុងកុសលចិត្ត ២១។

**២.អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ វាយាមោ** សេចក្តីព្យាយាមដើម្បីហាមអកុសលធម៌ដែលនៅមិនទាន់កើតឡើងមិនឱ្យកើតឡើង អង្គធម៌បានដល់វីរិយចេតសិកក្នុងកុសលចិត្ត ២១។

**៣.អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ វាយាមោ** សេចក្តីព្យាយាមដើម្បីឱ្យកុសលធម៌ ដែលនៅមិនទាន់

កើតឱ្យកើតឡើង អង្គធម៌បានដល់ វីរិយចេតសិកក្នុងកុសលចិត្ត ២១។

**៤.ឧប្បន្នានំ កុសលានំ ធម្មានំ ភិយ្យោភាវាយ វាយាមោ** សេចក្តីព្យាយាមដើម្បីឱ្យកុសលធម៌ ដែលកើតឡើងហើយ ឱ្យចម្រើនក្រៃលែងឡើង អង្គធម៌បានដល់ វីរិយចេតសិកក្នុងកុសលចិត្ត ២១។

**ហេតុផលវីរិយៈតែមួយបានសម្មប្បធាន ៤**

១.ព្យាយាមដើម្បីលះអកុសលដែលកើតឡើងហើយ

២.ព្យាយាមដើម្បីមិនឱ្យអកុសលថ្មីកើត

៣.ព្យាយាមដើម្បីឱ្យកុសលថ្មីកើត

៤.ព្យាយាមឱ្យកុសលដែលកើតឡើងហើយចម្រើនរុងរឿងឡើង។

**៣.ឥទ្ធិបាទ**

សេចក្តីសម្រេច **ឥជ្ឈនំ = ឥទ្ធិ**

ធម៌សម្រេច **ឥជ្ឈតីតិ = ឥទ្ធិ**

**បជ្ជតិ ឯតេនាតិ = បាទោ** បុគ្គលណាមួយ រមែងចូលដល់ដោយអាស្រ័យធម៌ណា ដូច្នោះឈ្មោះថា **បាទ** បានដល់ អង្គធម៌របស់ឥទ្ធិបាទ ៤។

**ឥទ្ធិយា បាទោ = ឥទ្ធិបាទោ** ធម៌ជាហេតុឱ្យដល់សេចក្តីសម្រេចឈាន អភិញ្ញា មគ្គ ផល ឈ្មោះថា ឥទ្ធិបាទ។

# ឥទ្ធិបាទ ៤ ប្រការ

១.**ឆន្ទិទ្ធិបាទ** សេចក្ដីពេញចិត្តដ៏មានកម្លាំង អង្គធម៌បានដល់ឆន្ទចេតសិកក្នុងកុសលចិត្ត ២១។

២.**វីរិយិទ្ធិបាទ** សេចក្ដីព្យាយាមដ៏មានកម្លាំង អង្គធម៌បានដល់ វីរិយចេតសិកក្នុងកុសលចិត្ត ២១។

៣.**ចិត្តិទ្ធិបាទ** សេចក្ដីតាំងចិត្តដ៏មានកម្លាំង អង្គធម៌បានដល់ កុសលចិត្ត ២១។

៤.**វិមំសិទ្ធិបាទ** បញ្ញាដ៏មានកម្លាំង អង្គធម៌បានដល់បញ្ញាចេតសិក ក្នុងកុសលញាណសម្បយុត្តចិត្ត ១៧។

**ឥទ្ធិបាទ** ដែលជាធម៌ឱ្យសម្រេចលោកុត្តរនោះ មានអធិប្បាយថា **ឥទ្ធិ** គឺឫទ្ធិដែលចូលដល់ការសម្រេចនោះមាន ៥ ប្រការគឺ

១.**អភិញ្ញេយ្យេសុ ធម្មេសុ អភិញ្ញាសិទ្ធិ** បានដល់ ឫទ្ធិ គឺបញ្ញាដែលចូលដល់សេចក្ដីដឹងពិសេសនៃរូបធម៌ និងនាមធម៌ដែលគួរដឹង។

២.**បរិញ្ញេយ្យេសុ ធម្មេសុ បរិញ្ញាសិទ្ធិ** បានដល់ ឫទ្ធិ គឺបញ្ញា ដែលចូលដល់សេចក្ដីដឹងពិតនៃទុក្ខសច្ចដែលគួរដឹង។

៣.**បហាតព្វេសុ ធម្មេសុ បហានសិទ្ធិ** បានដល់ សេចក្ដីសម្រេច ក្នុងការលះសមុទយដែលគួរលះ។

៤.**សច្ចិកាតព្វេសុ ធម្មេសុ សច្ចិកិរិយាសិទ្ធិ** បានដល់សេចក្ដីសម្រេចក្នុងការឃើញច្បាស់ក្នុងនិរោធសច្ចៈ ដែលគួរឃើញច្បាស់។

៥.**ភាវេតព្វេសុ ធម្មេសុ ភាវនាសិទ្ធិ** បានដល់សេចក្ដីសម្រេចក្នុងការចម្រើនមគ្គសច្ចដែលគួរចម្រើន។

## ៤.ឥន្ទ្រិយ ៥

១.**សទ្ធិន្ទ្រិយ** ធម្មជាតិគ្រប់គ្រងក្នុងការជឿ អង្គធម៌បានដល់ សទ្ធាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

២.**វីរិយិន្ទ្រិយ** ធម្មជាតិគ្រប់គ្រងក្នុងការព្យាយាម អង្គធម៌បានដល់ វីរិយចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៣.**សតិន្ទ្រិយ** ធម្មជាតិគ្រប់គ្រងក្នុងការរលឹកឃើញ អង្គធម៌បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៤.**សមាធិន្ទ្រិយ** ធម្មជាតិគ្រប់គ្រងក្នុងការតាំងមាំក្នុងអារម្មណ៍ អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៥.**បញ្ញិន្ទ្រិយ** ធម្មជាតិគ្រប់គ្រងក្នុងសភាវធម៌តាមសេចក្ដីពិត អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណ

សម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អប្បនាជវ័ន ២៦។

គួរសង្កេតថា ឥន្ទ្រិយ ៥ ក្នុងពោធិបក្ខិយធម៌នេះ បញ្ញាដែលជាឥន្ទ្រិយនោះ ចំពោះតែបញ្ញិន្ទ្រិយ តែម្យ៉ាងប៉ុណ្ណោះ មិនរួមដល់បញ្ញាក្នុងឥន្ទ្រិយដទៃៗ គឺអនញ្ញតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយផងទេ ទាំងនោះព្រោះពោធិបក្ខិយធម៌ ជាធម៌ដែលជាហេតុឱ្យចូលដល់ការត្រាស់ដឹង មគ្គ ផល និព្វានប៉ុណ្ណោះ ចំណែកបញ្ញាដែលជាឥន្ទ្រិយទាំង ៣ នោះ ជាបញ្ញារបស់ព្រះអរិយបុគ្គលដែលចូលដល់មគ្គ ផល និព្វានហើយ ទើបមិនចាត់ចូលក្នុងឥន្ទ្រិយ ៥ ជាមួយគ្នា។

## សទ្ធា ២ យ៉ាង

១.**បកតិសទ្ធា** សទ្ធាក្នុងការបរិច្ចាគទាន រក្សាសីល ស្តាប់ធម៌ ជាកុសលសាមញ្ញរបស់មនុស្សទាំងឡាយ ដែលប្រព្រឹត្តទៅដោយប្រក្រតី តែក៏ត្រូវអាស្រ័យសទ្ធាជាអ្នកគ្រប់គ្រងក្នុងការទទួលអារម្មណ៍នោះ បើប្រាសចាកសទ្ធាជាអ្នកគ្រប់គ្រងហើយ ទានកុសល សីលកុសល ក៏មិនអាចនឹងធ្វើបាន ចិត្តនឹងធ្លាក់ចុះទៅក្នុងផ្នែកអកុសល ទាំងអស់ កាលផ្តើមបណ្តុះសទ្ធាឡើងមក ក៏ផ្តើមគិតថានឹងធ្វើកុសល ហើយការធ្វើកុសលខាងដើមនោះ ក៏បានដល់ការវៀរចាកបាបធម៌ គឺតាំងនៅក្នុងកុសលកម្មបថ ១០ ឬធ្វើសេចក្តីល្អ

ក្នុងបុញ្ញកិរិយាវត្ថុ១០ ដូច្នេះទើបពោលថា ទាន សីល ភាវនាខាងដើមរបស់មនុស្សទាំងឡាយរមែងប្រព្រឹត្តទៅដោយបកតិសទ្ធា។

២.**ភាវនាសទ្ធា** បានដល់ សទ្ធាក្នុងការចម្រើនសមថភាវនា និងវិបស្សនាភាវនា បើសទ្ធារបស់បុគ្គលមិនខ្លាំងក្លា ក៏មិនអាចនឹងទៅចម្រើនកម្មដ្ឋានបាន ដូចជាត្រូវគេចចេញចាកពួកគណៈទៅកាន់ស្ថានវិវេក មានគល់ឈើ ផ្ទះស្ងាត់ជាដើម និងកាលចម្រើនកម្មដ្ឋាន សទ្ធាដែលខ្លាំងក្លានេះ នឹងស៊ប់សួនក្នុងចិត្តច្រើន អាចធ្វើចិត្តដែលប្រកបដោយសេចក្ដីសៅហ្មងឱ្យជ្រះថ្លា ដាច់ចិត្តឱ្យខ្វល់ខ្វាយក្នុងការបដិបត្តិដើម្បីទម្លាយសក្កាយទិដ្ឋិឱ្យបាន **ភាវនាសទ្ធា** នេះ រមែងចូលដល់ភាពជាសទ្ធិន្ទ្រិយកាលបដិបត្តិវិបស្សនាកម្មដ្ឋាន ចូលដល់ មគ្គ ផល និព្វាន ជាព្រះអរិយបុគ្គលហើយ អំណាចនៃសទ្ធិន្ទ្រិយ ក៏រមែងប្រាកដច្បាស់ក្រៃលែងឡើង ដូចបាលីក្នុងទដ្ឋព្វសូត្រថា៖

**កត្ថ ច ភិក្ខវេ សទ្ធិន្ទ្រិយំ ទដ្ឋព្វំ។ ចតូសុ សោតាបត្តិយង្គេសុ ឯត្ថ សទ្ធិន្ទ្រិយំ ទដ្ឋព្វំ។** ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្ដេច។ បណ្ដាឥន្ទ្រិយទាំង ៥ នុ៎ះ សទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងអង្គនៃសោតាបត្តិមគ្គទាំង៤។ (ប៊.៣៨ទំ.១៣៦)

## អង្គរបស់សោតាមាន ៤

១.ការធ្វើសេចក្ដីជ្រះថ្លា ក្នុងគុណរបស់ព្រះសម្មាសម្ពុទ្ធយ៉ាងខ្លាំងក្លា។

២.ធ្វើសេចក្តីជ្រះថ្លាក្នុងធម្មគុណ មាន **ស្វាក្ខាតធម៌** ជាដើម យ៉ាងខ្លាំងក្លា។

៣.ធ្វើសេចក្តីជ្រះថ្លាក្នុងសង្ឃគុណ មាន **សុបដិបន្នោ** ជាដើម យ៉ាងខ្លាំងក្លា។

៤.ធ្វើឱ្យបរិបូណ៌ដោយសីលវិសុទ្ធិ ដែលជាបទដ្ឋាននៃលោកុត្តរសមាធិ។

អំណាចនៃសតិន្ទ្រិយ រមែងធ្វើសតិប្បដ្ឋានឱ្យប្រាកដ។

អំណាចនៃសមាធិន្ទ្រិយ រមែងធ្វើឈាន អភិញ្ញាឱ្យប្រាកដ។

អំណាចនៃបញ្ញិន្ទ្រិយ រមែងធ្វើអរិយសច្ចៈ ៤ ឱ្យប្រាកដ។

ឥន្ទ្រិយទាំង ៥ ប្រការនេះ រមែងប្រាប់ប្រយោជន៍ក្នុងការចម្រើន សមថភាវនា និងវិបស្សនាភាវនាឱ្យប្រព្រឹត្តទៅដោយល្អគ្រប់កាលខ្វះឥន្ទ្រិយណាមួយសមថៈ និងវិបស្សនាទាំងឡាយក៏អន្តរាយ។

## ៥.ពលៈមាន ៥

**១.សទ្ធាពលៈ** ធម្មជាតិមិនញាប់ញ័រក្នុងការជឿ អង្គធម៌បានដល់សទ្ធាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

២.**វីរិយពលៈ** ធម្មជាតិមិនញាប់ញ័រក្នុងការព្យាយាម អង្គធម៌បានដល់ វីរិយចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៣.**សតិពលៈ** ធម្មជាតិមិនញាប់ញ័រក្នុងការរលឹកឃើញ អង្គធម៌បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៤.**សមាធិពលៈ** ធម្មជាតិមិនញាប់ញ័រក្នុងការតាំងចិត្តមាំក្នុងអារម្មណ៍ អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៥.**បញ្ញាពលៈ** ធម្មជាតិមិនញាប់ញ័រក្នុងការដឹងធម៌តាមសេចក្តីពិត អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណសម្បយុត្ត ៤ មហាកិរិយាញាណសម្បយុត្ត៤ អប្បនាជវ័ន ២៦។

**ពលៈ** ក្នុងពោធិបក្ខិយសង្គហៈ សំដៅយកកុសលពលៈ ដែលជាកម្លាំងញ៉ាំងសេចក្តីត្រាស់ដឹង មគ្គ ផល និព្វាន ឱ្យកើតឡើង។

## ធម៌បដិបក្ខជាមួយពលៈ ៥ ប្រការ

១.**តណ្ហា** ជាបដិបក្ខធម៌ដល់ សទ្ធាពលៈ

២.**កោសជ្ជៈ** ជាបដិបក្ខធម៌ដល់ វីរិយពលៈ

៣.**មុដ្ឋសតិ** ជាបដិបក្ខធម៌ដល់ សតិពលៈ

៤.**វិក្ខេបៈ** ជាបដិបក្ខធម៌ដល់ សមាធិពលៈ

៥.**សម្មោហៈ** ជាបដិបក្ខធម៌ដល់ បញ្ញាពលៈ។

## ៦.ពោជ្ឈង្គមាន ៧

**សមន្តតោ ពុជ្ឈតីតិ សម្ពោធិ** ញាណត្រាស់ដឹងដោយជុំវិញ។

**សមន្តតោ ពុជ្ឈន្តិ ឯតាយាតិ ពោធិ** បុគ្គលទាំងឡាយ រមែងត្រាស់ដឹងអរិយសច្ចៈ៤ ដោយធម៌ពួកនេះ ដូច្នេះធម៌ពួកនេះ ឈ្មោះថា **ពោធិ**។

**ពោធិយា អង្គោ = ពោជ្ឈង្គោ** ធម៌ដែលជាអង្គប្រកបរបស់ធម៌ដែលជាហេតុឱ្យដឹងអរិយសច្ចៈ ៤ ឈ្មោះថា ពោជ្ឈង្គៈ បានដល់អង្គធម៌របស់ពោជ្ឈង្គៈ៧។

១.**សតិសម្ពោជ្ឈង្គៈ** ការរលឹកបាន ជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

២.**ធម្មវិចយសម្ពោជ្ឈង្គៈ** ពិចារណាធម៌ខាងក្នុងខាងក្រៅ ជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អប្បនាជវ័ន ២៦។

៣.**វីរិយសម្ពោជ្ឈង្គៈ** សេចក្តីព្យាយាមជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ វីរិយចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

៤.**បីតិសម្ពោជ្ឈង្គៈ** ការឆ្អែតចិត្ត ជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ បីតិចេតសិកក្នុងមហាកុសលសោមនស្សចិត្ត ៤ មហាកិរិយាសោមនស្សចិត្ត ៤ រូបកុសលចិត្ត ៣ រូបកិរិយាចិត្ត ៣ លោកុត្តរចិត្ត ៨ ឬសប្បីតិកអប្បនាជវ័ន ៣០។

**៥.បស្សទ្ធិសម្ពោជ្ឈង្គៈ** សេចក្ដីស្ងប់កាយនិងចិត្តជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ កាយបស្សទ្ធិ និងចិត្តបស្សទ្ធិ ចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**៦.សមាធិសម្ពោជ្ឈង្គៈ** ការតម្កល់ចិត្តមាំក្នុងអារម្មណ៍ ជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**៧.ឧបេក្ខាសម្ពោជ្ឈង្គៈ** ការធ្វើឱ្យសម្បយុត្តធម៌មានសភាពស្មើក្នុងនាទីរបស់ខ្លួនជាអង្គនៃការត្រាស់ដឹង អង្គធម៌បានដល់ តត្រមជ្ឈត្តតាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

## អធិប្បាយពោជ្ឈង្គៈ ៧

សតិចេតសិក ដែលហៅថា **សតិប្បដ្ឋាន** កាលចម្រើនឡើងក៏មានភាពជាសតិន្ទ្រិយ **សតិពលៈ** សូម្បីសម្មាសតិ ក៏ហៅថា សតិសម្ពោជ្ឈង្គៈ។

**បញ្ញាចេតសិក** ដែលចម្រើនឡើងជាវិមំសិទ្ធិបាទ បញ្ញិន្ទ្រិយ បញ្ញាពលៈ សម្មាទិដ្ឋិ ហៅថា ធម្មវិចយសម្ពោជ្ឈង្គៈ បានដល់ ការចូលដល់បញ្ញាវិសុទ្ធិ ៥ ប្រការ មានទិដ្ឋិវិសុទ្ធិជាដើម។

**វីរិយចេតសិក** ដែលចម្រើនឡើងជាសម្មប្បធាន វីរិយិទ្ធិបាទ វីរិយពលៈ សម្មាវាយាមៈ ហៅថា វីរិយសម្ពោជ្ឈង្គ។

**បីតិចេតសិក** ដែលចម្រើនឡើងពីការចម្រើនសតិប្បដ្ឋាន ជាដើមហៅថា បីតិសម្ពោជ្ឈង្គៈ។

**បស្សទ្ធិចេតសិក** គឺកាយបស្សទ្ធិ និងចិត្តបស្សទ្ធិ ដែលចម្រើនឡើងពីការចម្រើនសតិប្បដ្ឋាន ហៅថា បស្សទ្ធិសម្ពោជ្ឈង្គៈ។

**ឯកគ្គតាចេតសិក** ដែលចម្រើនឡើងជា សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ក្នុងការចម្រើនសមថភាវនា សម្រេចជាសមាបត្តិ ៨ និងក្នុងវិបស្សនាភាវនា មានសុញ្ញតសមាធិ អនិមិត្តសមាធិ និងអប្បណិហិតសមាធិ គឺសមាធិតាមដែលឃើញត្រៃលក្ខណ៍ រហូតដល់មគ្គ ផល និព្វាន ហៅថា សមាធិសម្ពោជ្ឈង្គៈ។

**តត្រមជ្ឈត្តតាចេតសិក** ដែលកើតពីការចម្រើនកម្មដ្ឋានប្រាសចាកបលិពោធណា ៗ ដាក់ចិត្តស្មើក្នុងកម្មដ្ឋាននោះ ហៅថា ឧបេក្ខាសម្ពោជ្ឈង្គៈ។

## ៧.**មគ្គង្គ** (មគ្គមានអង្គ ៨ )

វចនត្ថៈ **កិលេសេ មារេន្តោ និព្វានំ ឯតេនាតិ** = **មគ្គោ** ព្រះយោគីបុគ្គលទាំងឡាយសម្លាប់កិលេសហើយ រមែងចូលដល់ព្រះនិព្វានដោយធម៌នោះ ដូច្នោះធម៌នោះឈ្មោះថា **មគ្គ**។

**មគ្គស្ស អង្គោ** = **មគ្គង្គោ** ធម៌ជាគ្រឿងប្រកបរបស់ធម៌ដែលជាហេតុនៃ ការសម្លាប់កិលេស ហើយចូលដល់ព្រះនិព្វាន ឈ្មោះថា **មគ្គង្គៈ**។

**១.សម្មាទិដ្ឋិ** សេចក្តីត្រិះរិះត្រូវ អង្គធម៌បានដល់ បញ្ញាចេតសិកក្នុងមហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អប្បនាជវ័ន ២៦។

## សម្មាទិដ្ឋិ មាន ៤ ប្រភេទ

១.ការដឹងក្នុងទុក្ខ ដោយបរិញ្ញាកិច្ច

២.ការដឹងក្នុងហេតុនៃការកើតទុក្ខ ដោយបហានកិច្ច

៣.ការដឹងក្នុងទីរលត់ទុក្ខ ដោយសច្ឆិកិរិយាកិច្ច

៤.ការដឹងក្នុងផ្លូវនៃការរលត់ទុក្ខ ដោយភាវនាកិច្ច។

## សម្មាទិដ្ឋិក្នុងអង្គុត្តរនិកាយឯកធម្មបាលទុតិយវគ្គមាន ៥ ប្រការ

១.**កម្មស្សកតាសម្មាទិដ្ឋិ** បានដល់ បញ្ញាដែលមានការយល់ឃើញត្រូវថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន។

២.**ឈានសម្មាទិដ្ឋិ** ការយល់ឃើញត្រូវក្នុងការធ្វើចិត្តឱ្យស្ងប់តាំងមាំក្នុងអារម្មណ៍តែមួយរមែងអាចគ្រប់សង្កត់កិលេសនីវរណធម៌ទុកមិនឱ្យកើតឡើងក្នុងចិត្តជាការឃើញត្រូវការដឹងឧបាយដែលនឹងចម្រើនសមថភាវនារហូតសម្រេចឈានកុសល នៅក្នុងឈានសមាបត្តិបាន។

៣.**វិបស្សនាសម្មាទិដ្ឋិ** យល់ឃើញត្រូវក្នុងការដែលកើតឡើងខណៈពិចារណានាមរូប ដោយភាពជាត្រៃលក្ខណ៍ គឺ **អនិច្ចំ ទុក្ខំ អនត្តា** ដែលហៅថា វិបស្សនាញាណកើត រហូតដល់អនុលោមញាណមានត្រៃលក្ខណ៍ជាអារម្មណ៍។

៤.**មគ្គសម្មាទិដ្ឋិ** បញ្ញាក្នុងមគ្គញ្ញាណដែលចូលដល់អរិយសច្ចៈ៤ មាននិព្វានជាអារម្មណ៍ ព្រមទាំងប្រហារកិលេសជាសមុច្ឆេទ។

៥.**ផលសម្មាទិដ្ឋិ** បញ្ញាក្នុងផលញាណ ដែលដឹងនិព្វានជាអារម្មណ៍ ដើម្បីសោយវិមុត្តិសុខរបស់ព្រះនិព្វាន កាលមគ្គញ្ញាណប្រហារកិលេសហើយ។

**២.សម្មាសង្កប្បៈ** សេចក្តីត្រិះរិះត្រូវ អង្គធម៌បានដល់វិតក្កចេតសិកក្នុងមហាកុសលចិត្ត៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

## ត្រិះរិះត្រូវ ៣ ប្រការ

១.**នេក្ខម្មសង្កប្បៈ** ត្រិះរិះចេញចាកកាម

២.**អព្យាបាទសង្កប្បៈ** ត្រិះរិះមិនព្យាបាទ

៣.**អវិហិំសាសង្កប្បៈ** ត្រិះរិះមិនបៀតបៀន។

៣.**សម្មាវាចា** សម្តីត្រូវ អង្គធម៌បានដល់ សម្មាវាចាចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨។

ត្រូវវៀរចាកវចីទុច្ចរិត ៤ គឺ ការកុហក និយាយញុះញង់ ពាក្យចាក់ដោត ពាក្យឥតប្រយោជន៍។

៤.**សម្មាកម្មន្តៈ** ការងារត្រូវ អង្គធម៌បានដល់ សម្មាកម្មន្តចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨។

វៀរចាកកាយទុច្ចរិត ៣ ប្រការ គឺមិនសម្លាប់ មិនលួច មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**៥.សម្មាអាជីវៈ** ចិញ្ចឹមជីវិតត្រូវ អង្គធម៌បានដល់សម្មាអាជីវចេតសិក ក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨។ (វៀរចាកកាយទុច្ចរិត និងវចីទុច្ចរិត)។

៦.**សម្មាវាយាមៈ** ព្យាយាមត្រូវ អង្គធម៌បានដល់វីរិយចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា និប្ផន្នសោភិនោ អត្ថា ខន្ត្យា ភិយ្យោ ន វិជ្ជតិ** ធម្មតាមនុស្សដែលមានជាតិជាប្រុស ត្រូវតែព្យាយាមលុះត្រាតែបានសម្រេចប្រយោជន៍ ប្រយោជន៍ដែលនឹងសម្រេចទៅបាន រមែងមិនមានប្រយោជន៍ក្រៃលែងជាងសេចក្តីអត់ទ្រាំបានទេ។

**ឧដ្ឋាតា វិន្ទតេ ធនំ** អ្នកមានព្យាយាមរមែងបាននូវទ្រព្យ។

**ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិធានវា សមំ កប្បេតិ ជីវិតំ សម្ភតំ អនុរក្ខតិ សទ្ធោ សីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ ឥច្ចេតេ អដ្ឋ ធម្មា ច សទ្ធស្ស ឃរមេសិនោ អក្ខាតា សច្ចនាមេន ឧភយត្ថ សុខាវហា ទិដ្ឋធម្មហិតត្ថាយ សម្បរាយសុខាយ ច**

**ឯវមេតំ គហដ្ឋានំ ចាគោ បុញ្ញំ បវឌ្ឍតីតិ។** អ្នកមានព្យាយាមប្រឹងប្រែងក្នុងទីនៃការងារទាំងឡាយ១ មិនប្រហែសធ្វេសក្នុងការចាត់ចែង១ ចិញ្ចឹមជីវិតស្មើ១ ចេះថែរក្សាទ្រព្យដែលរកបានមក១ មានសទ្ធា១ បរិបូណ៌ដោយសីល១ ដឹងនូវពាក្យពេចន៍១ ប្រាសចាកសេចក្តីកំណាញ់ រមែងជំរះនូវផ្លូវមានសួស្តីជាផ្លូវទៅកាន់បរលោកជានិច្ច១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ ដែលព្រះដ៏មានព្រះភាគព្រះអង្គជាសច្ចនាម ទ្រង់សំដែងហើយ ដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្ទះ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគនិងបុណ្យនេះ តែងចម្រើន ដល់គ្រហស្ថទាំងឡាយយ៉ាងនេះឯង។ (បិ.៤៨ ទំ.៥១)

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ។** ជនណាមួយ ខ្ជិលច្រអូស មានព្យាយាមថោកទាប គប្បីរស់នៅអស់រយនៃឆ្នាំពុំប្រសើរ ស្មើនឹងការរស់នៅតែមួយថ្ងៃ ប្រារព្ធសេចក្តីព្យាយាមដ៏មាំមួន។ (បិ.៥២ទំ.៤៥)

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិ-វឌ្ឍតិ ។** យសស័ក្តិតែងចម្រើនដល់បុរសស្រ្តីក្នុងលោក ដោយគុណធម៌ ៧ ប្រការគឺអ្នកមានសេចក្តីព្យាយាម១ អ្នកមានស្មារតី១

អ្នកមានការងារស្អាត១ អ្នកមានពិចារណាទើបធ្វើ១ អ្នកសង្រួម១ អ្នករស់នៅប្រកបដោយធម៌១ អ្នកមិនប្រមាទ១។

**កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ**

ថ្ងៃនិងយប់កន្លងទៅៗ ឥឡូវនេះអាត្មាអញបានធ្វើអ្វីខ្លះហើយ។

**៧.សម្មាសតិ** រលឹកត្រូវ អង្គធម៌បានដល់ សតិចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។ (រលឹកត្រូវ គឺ រលឹកក្នុងសតិប្បដ្ឋាន៤)

**៨.សម្មាសមាធិ** តម្កល់ចិត្តត្រូវ អង្គធម៌បានដល់ ឯកគ្គតាចេតសិកក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវ័ន ២៦។

**វីរិយចេតសិក ជាពោធិបក្ខិយធម៌ ៩ ឋាន**

សម្មប្បធាន ៤ ឋាន វីរិយិទ្ធិបាទ ១ ឋាន វីរិយិន្ទ្រិយ១ ឋាន វីរិយពលៈ១ ឋាន វីរិយសម្ពោជ្ឈង្គៈ១ ឋានសម្មាវាយាមមគ្គ១ ឋាន។

**សតិចេតសិកជាពោធិបក្ខិយធម៌ ៨ ឋាន**

សតិប្បដ្ឋាន ៤ ឋាន សតិន្ទ្រិយ ១ ឋាន សតិពលៈ១ ឋាន សតិសម្ពោជ្ឈង្គៈ ១ ឋាន សម្មាសតិមគ្គ ១ ឋាន។

**ឯកគ្គតាចេតសិកជាពោធិបក្ខិយធម៌ ៤ ឋាន**

សមាធិន្ទ្រិយ ១ ឋាន សមាធិពលៈ ១ ឋាន សមាធិសម្ពោជ្ឈង្គៈ ១ ឋាន សម្មាសមាធិមគ្គ ១ ឋាន។

**បញ្ញាចេតសិកជាពោធិបក្ខិយធម៌ ៥ ឋាន**

វិមំសិទ្ធិបាទ ១ ឋាន បញ្ញិន្ទ្រិយ ១ ឋាន បញ្ញាពលៈ១ ឋាន ធម្មវិចយសម្ពោជ្ឈង្គ ១ ឋាន សម្មាទិដ្ឋិមគ្គ ១ ឋាន។

## សទ្ធាចេតសិកជាពោធិបក្ខិយធម៌ ២ ឋាន

សទ្ធិន្ទ្រិយ ១ ឋាន សទ្ធាពលៈ ១ ឋាន។

## តារាងសរុបអង្គធម៌ពោធិបក្ខិយសង្គហៈ ៧ ក្រុម

| អង្គធម៌ ១៥ | សតិប្បដ្ឋាន ៤ | សម្មប្បធាន ៤ | ឥទ្ធិបាទ ៤ | ឥន្ទ្រិយ ៥ | ពលៈ ៥ | ពោជ្ឈង្គ ៧ | មគ្គ ៨ | សរុបក្រុម |
|---|---|---|---|---|---|---|---|---|
| វីរិយ១ | | ១ | ១ | ១ | ១ | ១ | ១ | ៦ ក្រុម |
| សតិ១ | ១ | | | ១ | ១ | ១ | ១ | ៥ ក្រុម |
| បញ្ញា១ | | | ១ | ១ | ១ | ១ | ១ | ៥ ក្រុម |
| ឯកគ្គតា១ | | | | ១ | ១ | ១ | ១ | ៤ ក្រុម |
| សទ្ធា១ | | | | ១ | ១ | | | ២ ក្រុម |
| ចិត្ត១ឆន្ទ១ | | | ២ | | | | | ១ ក្រុម |
| បីតិ១ បស្សទ្ធិ២ តត្រ-មជ្ឈត្តតា១ | | | | | | ៤ | | ១ ក្រុម |
| វិតក្ក ១ វិរតិ ៣ | | | | | | | ៤ | ១ ក្រុម |
| ចំនួនសរុប | ១ | ១ | ៤ | ៥ | ៥ | ៨ | ៨ | ៧ ក្រុម |

## ចែកអដ្ឋមគ្គ ៨ ជា ៣ យ៉ាង

**-សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ** សង្គ្រោះចូលក្នុងសីលក្ខន្ធ
**-សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ** សង្គ្រោះចូលក្នុងសមាធិក្ខន្ធ
**-សម្មាទិដ្ឋិ សម្មាសង្កប្បៈ** សង្គ្រោះចូលក្នុងបញ្ញាខន្ធ។

(ចប់ពោធិបក្ខិយសង្គហៈ)

## ៤.សព្វសង្គហៈ

**សព្វេសំ បរមត្ថធម្មានំ សព្វសង្គហោតិ** = **សព្វសង្គហោ** ការរួបរួមបរមត្ថធម៌ទាំងអស់ ដូច្នោះ ទើបឈ្មោះថា **សព្វសង្គហៈ**។

មានធម៌ ៣៩ ប្រភេទ សង្គ្រោះបាន ៥ ពួក គឺ ខន្ធ ៥ ឧបាទានក្ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ អរិយសច្ចៈ ៤។

## ១.ខន្ធ

ពាក្យថា **ខន្ធ**, **រាសដ្ឋេន** = **ខន្ធោ** ឈ្មោះថាខន្ធ ដោយអត្ថថា ជាគំនរ ជាក្រុម។

ពាក្យថា **ខន្ធ** ប្រើក្នុងន័យច្រើនយ៉ាង គឺ**ឧទកខន្ធ** = គំនរទឹក **គវក្ខន្ធ** = ពួកគោ **ពលខន្ធ** = កងពល **បុញ្ញខន្ធ** = គំនរបុណ្យ **សីលខន្ធ** = កងនៃសីល ឬគុណគឺសីល ជាដើម។

## ក្រុមនៃធម៌អ្វី?

ក្រុមធម៌ដែលជាអតីត បច្ចុប្បន្ន អនាគត អជ្ឈត្ត ពហិទ្ធ ឱឡារិក សុខុម ហីនធម៌ បណីតធម៌ ដែលនៅក្នុងខន្ធទាំង ៥។

**អនេកធាភេទេហិ ខជ្ជន្តីតិ = ខន្ធា** ធម៌ពួកណាត្រូវទុក្ខផ្សេងៗ ទំពាស៊ី ដូច្នោះធម៌ពួកនុ៎ះឈ្មោះថា **ខន្ធ**។

**សុញ្ញាភាវំ ធារេន្តីតិ = ខន្ធា** ធម៌ពួកណា ដែលទ្រទ្រង់អាការៈទទេចាកអត្តា ដូច្នោះឈ្មោះថា **ខន្ធ** ។

## ក្រុមនៃរូបធម៌

ក្រុមធម៌ដែលជា **អតីត បច្ចុប្បន្ន អនាគត អជ្ឈត្ត (រូបខាងក្នុង) ពហិទ្ធ** (រូបខាងក្រៅ) **ឱឡារិក** (រូបគ្រោតគ្រាត) **សុខុម** (រូបល្អិត) **ហីន (**រូបថោកទាប) **បណីត** (រូបប្រណីត) **ទូរេ** (រូបក្នុងទីឆ្ងាយ) **សន្តិកេ** (រូបក្នុងទីជិត) នេះហៅថា **រូបក្ខន្ធ**។ រូបប្រៀបដូច ភាជន៍ ព្រោះជាទីអាស្រ័យនៃវេទនា។

វចនត្ថៈ **រុប្បតីតិ = រូបំ** ធម្មជាតិណាវមែងបែកធ្លាយ ធម្មជាតិនោះ ឈ្មោះថា **រូប**។

១.**រូបក្ខន្ធ** (Matter Aggregate) អង្គធម៌បានដល់ រូប ២៨។

២.**វេទនាខន្ធ** (Feeling Aggregate) អង្គធម៌បានដល់ វេទនាចេតសិក ក្នុងចិត្ត ៨៩ ឬ១២១។

វចនត្ថៈ **វេទិយតិ អារម្មណរសំ អនុភវតីតិ = វេទនា** ធម្មជាតិណាវមែងដឹងខ្លួន គឺសោយរសនៃ អារម្មណ៍ ព្រោះហេតុនោះ ឈ្មោះថា វេទនា។

វេទនា ប្រៀបដូចភោជន ព្រោះសម្រាប់បរិភោគ (វេទនាមានទំនងដូចរូបខន្ធដែរ)

៣.**សញ្ញាខន្ធ** (Perception aggregate) អង្គធម៌បានដល់ សញ្ញាចេតសិកក្នុងចិត្ត ៨៩ ឬ១២១។

**វចនត្ថៈ នីលាទិភេទារម្មណំ សញ្ជានាតិ សញ្ជានាតីតិ = សញ្ញា** ធម្មជាតិណា រមែងសម្គាល់ចាំ នូវអារម្មណ៍ មានពណ៌ខៀវជាដើម ព្រោះហេតុនោះ ឈ្មោះថា **សញ្ញា**។ (សញ្ញាប្រៀបដូចម្លូបក្រៀម)

៤.**សង្ខារខន្ធ** (Mental formations aggregate) អង្គធម៌ បានដល់ ចេតសិក ៥០ ក្នុងចិត្ត ៨៩ ឬ១២១។

វចនត្ថៈ **សង្ខតំ អភិសង្ខរោន្តីតិ = សង្ខារា** ធម្មជាតិណា តែងប្រជុំតាក់តែងនូវសង្ខតធម៌ ព្រោះហេតុនោះ ឈ្មោះថា **សង្ខារ** (សង្ខារដូចអ្នកដាំស្ល)។ ដូចពុទ្ធវចនៈក្នុងសំយុត្តនិកាយថា៖

ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវធម៌ទាំងឡាយនោះ ហៅថា **សង្ខារ** ។ សភាវៈទាំងឡាយតាក់ តែងនូវសង្ខតធម៌ ដូចម្តេច។ តាក់តែងនូវសង្ខតធម៌ គឺរូប តាមសភាពវិនាស តាក់តែងនូវសង្ខតធម៌គឺវេទនា តាមសភាព សោយនូវអារម្មណ៍ តាក់តែងនូវសង្ខតធម៌ គឺសញ្ញា តាមសភាព ចំណាំនូវអារម្មណ៍ តាក់តែងនូវសង្ខតធម៌ គឺសង្ខារទាំងឡាយ តាម សភាពតាក់តែងនូវសង្ខតធម៌ គឺវិញ្ញាណ តាមសភាពដឹងច្បាស់។

៥.**វិញ្ញាណខន្ធ** (Consciousness aggregate) អង្គធម៌ បានដល់ ចិត្ត ៨៩ ឬ១២១។

វចនត្ថថាៈ **វិជានាតីតិ = វិញ្ញាណំ** ធម្មជាតិណាវមែង ដឹងច្បាស់នូវអារម្មណ៍ ព្រោះហេតុនោះ ឈ្មោះថា **វិញ្ញាណ**។ (វិញ្ញាណប្រៀបដូចជាអ្នកបរិភោគ)។

## និព្វានជាខន្ធវិមុត្តិព្រោះមិនមានប្រភេទផ្សេងគ្នា

១.**និព្វាន** មិនមានប្រភេទនៃបច្ចុប្បន្ន អតីតៈ អនាគត ជាកាលវិមុត្តិ

២.**និព្វាន** ជាអជ្ឈត្តៈមិនមាន ជាពហិទ្ធៈតែម្យ៉ាង

៣.**និព្វាន** ជាឱឡារិកៈមិនមាន ជាសុខុមៈតែម្យ៉ាង

៤.**និព្វាន** ជាហីនៈមិនមាន ជាបណីតៈតែម្យ៉ាង

៥.**និព្វាន** ជាសន្តិកៈមិនមាន ជាទូរៈតែម្យ៉ាង។

## ការបដិបត្តិក្នុងខន្ធ

ការរស់នៅរបស់សត្វ គឺការប្រព្រឹត្តិទៅរបស់ខន្ធ៥ ដែលក្នុងលោកសន្មតលោកនេះថា មានយើង មានគេ ដែលសុទ្ធតែជាអត្តទិដ្ឋិទាំងអស់ តែជាសភាវៈ មិនមែនយើង មិនមែនគេ។ ហើយខន្ធនេះបៀតបៀនសត្វលោកជានិច្ច គឺជាមារ ។ (មារវគ្គ បិ.៣៤)

## ពិចារណាខន្ធ៥ ដូច្នេះ៖

១.ការផ្លាស់ប្តូររបស់រាងកាយមានការចម្រើនលូតលាស់ ចាស់ សក់ស្កូវ ធ្មេញបាក់ជាដើមក្តី ចលនានៃកាយនិងការនិយាយក្តីទាំងនេះជា រូបក្ខន្ធ។

២.ការដឹងថា សុខ ទុក្ខ មិនសុខមិនទុក្ខ ជាវេទនាខន្ធ។

៣.ការចងចាំនូវវត្ថុផ្សេងៗ បាន នេះសញ្ញាខន្ធ។

៤.ការចង់បាន សេចក្តីក្រោធ វង្វេង សេចក្តីជ្រះថ្លា សេចក្តីព្យាយាម ការដឹងតាមសេចក្តីពិតជាដើម ដែលជាការតាក់តែងផ្នែកខាងក្នុងចិត្តសន្តាននេះសង្ខារខន្ធ។

៥.ការដឹងក្នុងអារម្មណ៍ផ្សេង ៗ ហើយរលត់ទៅ ជាវិញ្ញាណខន្ធ។

## ពិចារណាខន្ធដោយការប្រៀបធៀប

ក.**រូប** ដូចកាំបិតមុត ព្រោះនាំឱ្យកើតអន្តរាយ

ខ.**វេទនា** ដូចដែកស្រួច និងលំពែង

គ.**សញ្ញា** ដូចអ្នកជម្ងឺ ព្រោះមានវេទនាដូចលំពែង ឬ **សញ្ញា** ដូចបុចុជ្ជនក្តាប់ដៃទទេ ក៏នាំឱ្យកើតទុក្ខ ឬដូចម្រឹគក្នុងព្រៃ ដែលសម្គាល់ទីងមោងដេញចាបថាជាមនុស្ស។

ឃ.**សង្ខារ** ដូចបុរសអ្នកចាប់មនុស្សដទៃចូលទៅក្នុងរណ្តៅរងើកភ្លើង ព្រោះបោះពពួកសត្វទៅកាន់បដិសន្ធិ។

ង.**មនោវិញ្ញាណធាតុ** ដូចជាស្វាព្រៃ ព្រោះលះអារម្មណ៍ដែលទទួលហើយ កាន់យកអារម្មណ៍ដទៃ ដូចសេះខ្វកព្រោះបង្វឹកបានដោយលំបាក ដូចជាកំណាត់ឈើដែលគេបោះឡើងទៅឰដ៏អាកាស ព្រោះធ្លាក់ទៅក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នានោះៗ និងដូចជាអ្នកសម្តែងក្នុងរោងល្ខោន ព្រោះប្រកបដោយកិលេសច្រើនប្រការមានលោភៈ ទោសៈជាដើម។

## ២.ឧបាទានក្ខន្ធ

### The Five Aggregate of Clinging

**ឧបាទានានំ គោចរា ខន្ធា = ឧបាទានក្ខន្ធា** ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ**។

១.**រូបូបាទានក្ខន្ធ** (Matter Aggregate of Clinging) រូបដែលជាអារម្មណ៍នៃការប្រកាន់មាំ អង្គធម៌បានដល់ រូប ២៨។

២.**វេទនូបាទានក្ខន្ធ** Feeling Aggregate of Cinging វេទនាដែលជាអារម្មណ៍នៃការប្រកាន់មាំ អង្គធម៌បានដល់ វេទនាចេតសិកក្នុងលោកិយចិត្ត ៨១។

៣.**សញ្ញូបាទានក្ខន្ធ** (Perception aggregate of clinging) សញ្ញាដែលជាអារម្មណ៍នៃការប្រកាន់មាំ អង្គធម៌បានដល់ សញ្ញាចេតសិកក្នុងលោកិយចិត្ត ៨១។

៤.**សង្ខារូបាទានក្ខន្ធ** (Mental formation Aggregate of Clinging) សង្ខារដែលជាអារម្មណ៍នៃការប្រកាន់មាំ អង្គធម៌បានដល់ ចេតសិក ៥០ ក្នុង លោកិយចិត្ត ៨១។

៥.**វិញ្ញាណូបាទានក្ខន្ធ** (Consciousness Aggregate of Clinging) វិញ្ញាណដែលជាអារម្មណ៍នៃការប្រកាន់មាំ អង្គធម៌បានដល់ លោកិយចិត្ត ៨១។

## ៣.អាយតនៈ ១២

### The twelve sense-Bases

វចនត្ថថា: **អាយតន្តិ អត្តនោ ផលុប្បត្តិយា ឥទំ ឧស្សាហន្តា វិយ ហោន្តីតិ = អាយតនានិ** ធម៌ពួកណាហាក់

ដូច ជាមានសេចក្តីព្យាយាម ដើម្បីញ៉ាំងផលរបស់ខ្លួនឱ្យកើតឡើង ដូច្នោះ ឈ្មោះថា **អាយតនៈ**។

**ឧស្សាហន្តា វិយ ហោន្តិ** = មានសភាពហាក់ដូចមានសេចក្តីព្យាយាម ដើម្បីឱ្យផលរបស់ខ្លួនកើត។

**អាយសទ្វារេ ចិត្តចេតសិកធម្មេ ឯតានិ តនោន្តិ វិត្ថារេន្តីតិ = អាយតនានិ** ចក្ខុបសាទនិងរូបារម្មណ៍ជាដើម រមែងធ្វើចិត្ត និងចេតសិកធម៌ដែលហៅថា **អាយតនៈ** ឱ្យចម្រើនទូលំទូលាយហៅថា **អាយតនៈ**។

## អាយតនៈមានសេចក្តី ៦ ប្រការ

១.**ធម៌ដែលខ្វល់ខ្វាយក្រៃលែង** បានដល់អាយតនៈ ១២

២.**ដែនកើត** បានដល់ អាយតនៈខាងក្នុង ៦

៣.**ទីនៅ** បានដល់ អាយតនៈខាងក្នុង ៦

៤.**ទីផ្សាយទៅ** បានដល់ អាយតនៈខាងក្នុង ៦

៥.**ទីប្រជុំ** បានដល់ អាយតនៈខាងក្រៅ ៦

៦.**ហេតុ** បានដល់ អាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦។

## អាយតនៈមានអត្ថ ៥ យ៉ាង

១.**សញ្ជាតិទេសដ្ឋ** ជាទីកន្លែងកើត ព្រោះជាកន្លែងកើតឡើងនៃចិត្តរឿយៗ គឺនឹងកើតក្នុងភពណាក៏ដោយ មិនមែនកើតក្នុងទីដទៃទេ គឺត្រូវកើតក្នុងអាយតនៈទាំងឡាយនេះ។

២.**និវាសដ្ឋ** ជាទីនៅ ព្រោះជាទីនៅរបស់វិថីចិត្តការពោលនេះជា ឧបចារន័យ ន័យអម ព្រោះវិថីចិត្តមិនមែនកើតក្នុងភ្នែកជាដើមទេ តែមានហេតុវិថីចិត្តនឹងកើត ដូចខ្សែពិណនិងសំឡេងពិណ រមែងពោលមិនបានថា សំឡេងនោះមានក្នុងពិណឬខ្សែពិណទេ តែបើដេញហើយសំឡេងលាន់ឮឡើង។

៣.**អាករដ្ឋ** ជាហេតុ កើតនៅក្នុងសត្វទូទៅ គឺកើតមិនរើសថ្នាក់ទាប ខ្ពស់ តូច ធំ ឬមនុស្ស ទេវតា សត្វតិរច្ឆានទេ។

៤.**សមោសរណដ្ឋ** ជាទីប្រជុំ ព្រោះជាទីប្រជុំនៃវិថីចិត្តទាំងឡាយ គឺវិថីចិត្តទាំងឡាយកើតឡើងទទួលអារម្មណ៍ជានិច្ច។

៥.**ការណដ្ឋ** ជាហេតុ ព្រោះជាហេតុឱ្យវិថីចិត្តកើតឡើងតាមធម្មតាវិថីចិត្តទាំងឡាយកើតឡើង ត្រូវមានអាយតនៈខាងក្នុងនិងខាងក្រៅ។

## អង្គធម៌អាយតនៈ ១២

១.**ចក្ខាយតនៈ** (Eye-base) ចក្ខុព្រោះជាហេតុឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ ចក្ខុបសាទ។

២.**សោតាយតនៈ** (Ear-base) សោតព្រោះជាហេតុឱ្យចិត្តនិងចេតសិកកើត អង្គធម៌បានដល់ សោតបសាទ។

៣.**ឃានាយតនៈ** (Nose-base) ឃានព្រោះជាហេតុឱ្យចិត្តនិងចេតសិកកើត អង្គធម៌បានដល់ ឃានបសាទ។

៤.**ជិវ្ហាយតនៈ** (Tongue-base) ជិវ្ហាព្រោះជាហេតុឱ្យចិត្ត និង ចេតសិកកើត អង្គធម៌បានដល់ ជិវ្ហាបសាទ។

៥.**កាយាយតនៈ** (Body-base) កាយព្រោះជាហេតុឱ្យចិត្ត និង ចេតសិកកើត អង្គធម៌បានដល់ កាយបសាទ។

៦.**រូបាយតនៈ** (Visible- form -base) រូបារម្មណ៍ព្រោះជាហេតុ ឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ ពណ៌ផ្សេងៗ។

៧.**សទ្ទាយតនៈ** (Sound-base) សទ្ទារម្មណ៍ព្រោះជាហេតុឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ សំឡេងផ្សេងៗ។

៨.**គន្ធាយតនៈ** (Odour-base) គន្ធារម្មណ៍ព្រោះជាហេតុឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ ក្លិនផ្សេងៗ។

៩.**រសាយតនៈ** (Tast-base) រសារម្មណ៍ព្រោះជាហេតុឱ្យចិត្តនិង ចេតសិកកើត អង្គធម៌បានដល់ រសផ្សេងៗ។

១០.**ផោដ្ឋព្វាយតនៈ** (Tangible-base) ផោដ្ឋព្វារម្មណ៍ព្រោះជា ហេតុឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ ផោដ្ឋព្វារម្មណ៍។

១១.**មនាយតនៈ** (Mind-base) ចិត្តព្រោះជាហេតុឱ្យចេតសិក កើត អង្គធម៌បានដល់ ចិត្តទាំងអស់។

១២.**ធម្មាយតនៈ** (Mental-object base) សភាវធម៌ផ្សេងៗ ព្រោះ ជាហេតុឱ្យចិត្ត និងចេតសិកកើត អង្គធម៌បានដល់ ចេតសិក ៥២ សុខុមរូប ១៦ និព្វាន។

# ៤.ធាតុ

## Element

**ធាតុ** គឺជាធម៌ដែលទ្រទ្រង់សភាវៈរបស់ខ្លួន ដែលមិនប្រព្រឹត្តទៅក្នុងអំណាចរបស់អ្នកណាមួយ គឺ បុគ្គល សត្វ មនុស្ស ទេវតា ឬព្រហ្ម។

## ធាតុមានអត្ថ ៣ យ៉ាង

១.**អត្តនោ សភាវំ ធារេន្តីតិ** = **ធាតុយោ** ធម៌ទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ឈ្មោះថា ធាតុ។

២.**យថាសភាវំ ធារីយន្តិ សល្លក្ខីយន្តិ ឧបធារីយន្តីតិ** = **ធាតុយោ** ធម៌ត្រូវកំណត់ទុកតាមសភាវៈ ឈ្មោះថា ធាតុ។

៣.**និស្សត្តនិជ្ជីវដ្ឋេន** = **ធាតុ** ធម៌មិនមែនសត្វ មិនមែនជីវៈ។

## ពាក្យថា ធាតុ មានអត្ថផ្សេងៗទៀត

**វិទហតីតិ** = **ធាតុ** ព្រោះអត្ថថា ចាត់ចែងគឺរមែងចាត់ចែងទុកក្នុងសង្សារវដ្តៈ ជាអនេកប្បការ។

**ធីយតេតិ** = **ធាតុ** ព្រោះអត្ថថា សត្វទាំងឡាយទ្រទ្រង់ទុក គឺសត្វទាំងឡាយទទួលរងទុក្ខដូចរបស់ធ្ងន់។

**វិធានន្តិ** = **ធាតុ** ព្រោះអត្ថថា ជាការចាត់ចែង គឺចាត់ចែងឡើងនៃទុក្ខប៉ុណ្ណោះ។

**វិធីយតេ ឯតាយាតិ** = **ធាតុ** ព្រោះអត្ថថា ជាហេតុទ្រទ្រង់ទុក គឺទ្រទ្រង់សង្សារវដ្តមិនមានទីបំផុត។

ម្យ៉ាងទៀត **ធាតុ** ព្រោះអត្ថថា **ជាចំណែកតូចៗដែលគួរដឹង** គឺ ចំណែកតូចៗ នៃសរីរៈ មានខ្ទុះ ឈាម ជាដើម។

## ធាតុក្នុងព្រះសូត្រមាន ៦ យ៉ាង

១.**បឋវីធាតុ** ធាតុដី

២.**អាបោធាតុ** ធាតុទឹក

៣.**តេជោធាតុ** ធាតុភ្លើង

៤.**វាយោធាតុ** ធាតុខ្យល់

៥.**អាកាសធាតុ** ធាតុ គឺលម្ហទទេ

៦.**វិញ្ញាណធាតុ** ធាតុដឹង។

## ធាតុ ១៨

១.**ចក្ខុធាតុ** (Eye-element) ចក្ខុព្រោះទ្រទ្រង់ភាពថ្លាដែលរូបារម្មណ៍ប៉ះខ្ទប់បាន អង្គធម៌បានដល់ ចក្ខុបសាទ។

២.**សោតធាតុ** (Ear-element) សោតព្រោះទ្រទ្រង់ភាពថ្លាដែលសទ្ទារម្មណ៍ប៉ះខ្ទប់បាន អង្គធម៌បានដល់ សោតបសាទ។

៣.**ឃានធាតុ** (Nose-element) ឃានព្រោះទ្រទ្រង់ភាពថ្លាដែលគន្ធារម្មណ៍ប៉ះខ្ទប់បាន អង្គធម៌បានដល់ ឃានបសាទ។

៤.**ជិវ្ហាធាតុ** (Tongue-element) ជិវ្ហាព្រោះទ្រទ្រង់ភាពថ្លាដែលរសារម្មណ៍ប៉ះខ្ទប់បាន អង្គធម៌បានដល់ ជិវ្ហាបសាទ។

៥.**កាយធាតុ** (Body-element) កាយព្រោះទ្រទ្រង់ភាពថ្លាដែលផោដ្ឋព្វារម្មណ៍ប៉ះខ្ទប់បាន អង្គធម៌បានដល់ កាយបសាទ។

៦.**រូបធាតុ** (Visible- form-element) រូបារម្មណ៍ព្រោះទ្រទ្រង់នូវការប៉ះខ្ទប់ភ្នែក អង្គធម៌បានដល់ ពណ៌ផ្សេងៗ។

៧.**សទ្ទធាតុ** (Sound-element) សទ្ទារម្មណ៍ព្រោះទ្រទ្រង់នូវការប៉ះខ្ទប់ត្រចៀក អង្គធម៌បានដល់ សំឡេងផ្សេងៗ។

៨.**គន្ធធាតុ** (Odour-element) គន្ធារម្មណ៍ព្រោះទ្រទ្រង់នូវការប៉ះខ្ទប់ច្រមុះ អង្គធម៌បានដល់ ក្លិនផ្សេងៗ។

៩.**រសធាតុ** (Taste-element) រសារម្មណ៍ព្រោះទ្រទ្រង់នូវការប៉ះខ្ទប់អណ្តាត អង្គធម៌បានដល់ រសផ្សេងៗ។

១០.**ផោដ្ឋព្វធាតុ** (Tangible-data-element) ផោដ្ឋព្វារម្មណ៍ ព្រោះទ្រទ្រង់នូវការប៉ះខ្ទប់កាយ អង្គធម៌បានដល់ សម្ផស្សផ្សេងៗ។

១១.**ចក្ខុវិញ្ញាណធាតុ** (Eye-consciousness- element) ចក្ខុវិញ្ញាណព្រោះទ្រទ្រង់នូវការឃើញ អង្គធម៌បានដល់ ចក្ខុវិញ្ញាណ ២។

១២.**សោតវិញ្ញាណធាតុ** (Ear-consciousness-element) សោត-វិញ្ញាណព្រោះទ្រទ្រង់នូវការឮ អង្គធម៌បានដល់ សោតវិញ្ញាណ ២។

១៣.**ឃានវិញ្ញាណធាតុ** (Nose-consciousness- element) ឃាន-វិញ្ញាណព្រោះទ្រទ្រង់នូវការដឹងក្លិន អង្គធម៌បានដល់ ឃានវិញ្ញាណ ២។

១៤.**ជិវ្ហាវិញ្ញាណធាតុ** (Tongue-consciousness -element) ជិវ្ហា-វិញ្ញាណព្រោះទ្រទ្រង់នូវការដឹងរស អង្គធម៌បានដល់ ជិវ្ហាវិញ្ញាណ ២។
១៥.**កាយវិញ្ញាណធាតុ** (Body-conciousness-element) កាយ-វិញ្ញាណព្រោះទ្រទ្រង់នូវការដឹងសម្ផស្ស អង្គធម៌បានដល់ កាយ-វិញ្ញាណ ២។
១៦.**មនោធាតុ** (Mind-element) ចិត្ត ៣ ដួង ព្រោះទ្រទ្រង់នូវការដឹងបញ្ចារម្មណ៍ អង្គធម៌បានដល់ មនោធាតុ ៣។
១៧.**មនោវិញ្ញាណធាតុ** (Mind-consciousness-element) ចិត្ត ៧៦ ព្រោះទ្រទ្រង់នូវការដឹងអារម្មណ៍បានច្រើនយ៉ាង អង្គធម៌បានដល់ ចិត្ត ៧៦ ដួង។
១៨.**ធម្មធាតុ** (Mind-data-element) សភាវធម៌ ៦៩ ព្រោះទ្រទ្រង់នូវសភាវលក្ខណៈរបស់ខ្លួនៗ អង្គធម៌បានដល់ ចេតសិក ៥២ សុខុមរូប ១៦ និព្វាន១។

## កិច្ចបដិបត្តិក្នុងធាតុ

ពាក្យថា **ធាតុ** គឺមិនមែនសត្វ មិនមែនជីវៈ នាមរូបត្រឹមជាធាតុប៉ុណ្ណោះ គឺនាមធាតុ រូបធាតុប៉ះខ្ទប់គ្នាយើងក៏សន្មតថាមានអ្នកដឹងអារម្មណ៍តាមពិតវាកើតឡើងព្រោះបច្ច័យរបស់វា ដូចក្នុងអដ្ឋកថាលោកប្រៀបថា ចក្ខុធាតុដូចផ្ទៃស្គរ រូបធាតុដូចអន្លូង ចក្ខុវិញ្ញាណធាតុដូចសំឡេង។ ចក្ខុធាតុដូចផ្ទៃកញ្ចក់ រូបធាតុដូចផ្ទៃមុខ

ចក្ខុវិញ្ញាណធាតុដូចស្រមោលមុខក្នុងកញ្ចក់។ ម្យ៉ាងទៀត ចក្ខុធាតុដូចគ្រឿងយន្តគាបអំពៅ ឬគ្រឿងយន្តកិនល្ង រូបធាតុដូចកំណាត់អំពៅ ឬល្ង ចក្ខុវិញ្ញាណធាតុដូចទឹកអំពៅ ឬប្រេងល្ង។ ចក្ខុធាតុដូចប្រអប់ឈើគូស រូបធាតុ ដូចឈើគូស ចក្ខុវិញ្ញាណធាតុដូចភ្លើង។ សោតវិញ្ញាណជាដើមន័យដូចគ្នា។ ចំណែកមនោវិញ្ញាណធាតុដូចស្វាព្រៃ ព្រោះលះអារម្មណ៍ទទួលហើយកាន់យកអារម្មណ៍ដទៃ ដូចសេះខ្ទក ព្រោះបង្វឹកបានដោយលំបាក ដូចកំណាត់ឈើដែលគេបោះឡើងព្វដ៏អាកាស ព្រោះធ្លាក់ទៅក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នានោះៗ ដូចអ្នកសម្តែងក្នុងរោងល្ខោន ព្រោះប្រកបដោយកិលេសច្រើន។ ដូច្នេះហើយ អ្នកបដិបត្តិគប្បីពិចារណាឃើញត្រឹមធាតុប៉ុណ្ណោះ ចិត្តរមែងនឿយណាយ ប្រាសចាកសេចក្តីប្រកាន់ក្នុងនាមរូបនេះ។

## ៥.អរិយសច្ច ៤

The Four Noble Truths

**អរិយានំ សច្ចានិ = អរិយសច្ចានិ** ធម៌ដែលជាភាពពិតរបស់ព្រះអរិយទាំងឡាយ ឈ្មោះថា អរិយសច្ចៈ។

ដូចទ្រង់ត្រាស់ថា: **ឥមេសំ ខោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ ។បេ។ អរិយោតិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ដែលមនុស្សនិងទេវតាថ្វាយ

ព្រះនាមថា អរិយៈ ព្រោះបានត្រាស់ដឹងក្រៃលែង តាមសេចក្តីពិត នូវអរិយសច្ចៈទាំង ៤ នេះឯង។

បុ.តើដូចម្តេចហៅថា សច្ចៈ?

វិ.ឈ្មោះថា **សច្ចៈ** ព្រោះមានសភាពទៀងទាត់មិនប្រែប្រួលទៅជាប្រការដទៃ។

**ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ ការកោ ន កិរិយាវ វិជ្ជតិ អត្ថិ និព្វុតិ ន និព្វុតោ បុមា មគ្គមត្ថិ គមកោ ន វិជ្ជតិ** ។ សេចក្តីពិតគឺមានតែទុក្ខប៉ុណ្ណោះ បុគ្គលណាជាអ្នកទុក្ខមិនមានឡើយ ការធ្វើមាន តែបុគ្គលអ្នកធ្វើមិនមាន ការរលត់ទុក្ខមាន តែបុគ្គលអ្នករលត់ទុក្ខមិនមាន ផ្លូវមាន តែបុគ្គលអ្នកដើរមិនមាន។ (អដ្ឋកថា សច្ចវិភង្គ)

## ឧបមាអរិយសច្ចៈ ៤

### ឧបមាដូចរបស់ធ្ងន់

- **ទុក្ខសច្ចៈ** ដូចជារបស់ធ្ងន់
- **សមុទយសច្ចៈ** ដូចជាកាន់របស់ធ្ងន់
- **និរោធសច្ចៈ** ដូចជាដាក់របស់ធ្ងន់
- **មគ្គសច្ចៈ** ដូចជាឧបាយជាគ្រឿងដករបស់ធ្ងន់

### ឧបមាដូចរោគ

- **ទុក្ខសច្ចៈ** ដូចជារោគ
- **សមុទយសច្ចៈ** ដូចជាសមុដ្ឋានរបស់រោគ

- ❑និរោធសច្ចៈ ដូចជាសេចក្តីស្ងប់របស់រោគ
- ❑មគ្គសច្ចៈ ដូចជាថ្នាំ

## ឧបមាដូចអ្នកស្រុកអត់បាយ (ទុព្ភិក្ខ)

- ❑ទុក្ខសច្ចៈ ដូចជាភិក្ខារកបានដោយក្រ
- ❑សមុទយសច្ចៈ ដូចជាភ្លៀងមិនល្អ
- ❑និរោធសច្ចៈ ដូចជាភិក្ខារកបានងាយ
- ❑ មគ្គសច្ចៈ ដូចជាភ្លៀងល្អ

## ឧបមាដូចពៀរវេរា

- ❑ទុក្ខសច្ចៈ ដូចជាប្រកបដោយមនុស្សមានពៀរ
- ❑សមុទយសច្ចៈ ដូចជាមូលហេតុនៃពៀរ
- ❑និរោធសច្ចៈ ដូចជាដកឡើងនូវពៀរ
- ❑មគ្គសច្ចៈ ដូចជាឧបាយជាគ្រឿងដកនូវពៀរ

## ឧបមាដូចដើមឈើមានពិស

- ❑ទុក្ខសច្ចៈ ដូចជាដើមឈើមានពិស
- ❑សមុទយសច្ចៈ ដូចជាឫសឈើដែលមានពិស
- ❑និរោធសច្ចៈ ដូចជាកាត់ដើមឈើមានពិស
- ❑មគ្គសច្ចៈ ដូចជាឧបាយកាត់ដើមឈើមានពិស

## ឧបមាដូចការមានភ័យ

- ❑ទុក្ខសច្ចៈ ដូចជាមានភ័យ
- ❑សមុទយសច្ចៈ ដូចជាមូលហេតុនៃភ័យ

❑**និរោធសច្ចៈ** ដូចជាសេចក្តីរំដោះភ័យ

❑**មគ្គសច្ចៈ** ដូចជាឧបាយឱ្យរំដោះភ័យ

**ឧបមាដូចច្រាំងទឹក**

❑**ទុក្ខសច្ចៈ** ដូចជាច្រាំង

❑**សមុទយសច្ចៈ** ដូចជាទឹកស្ទឹងធំរបស់ច្រាំង

❑**និរោធសច្ចៈ** ដូចជាច្រាំងនោះ

❑**មគ្គសច្ចៈ** ដូចជាព្យាយាមឱ្យដល់ច្រាំងនុ៎ះឯង។

## ១.ទុក្ខសច្ចៈ

**The Truth of Suffering**

## អត្ថរបស់ទុក្ខមាន ៤

១.**បីឡនដ្ឋោ** មានអត្ថថា គាបសង្កត់

២.**សង្ខតដ្ឋោ** មានអត្ថថា ដែលបច្ច័យតាក់តែង

៣.**សន្តាបដ្ឋោ** មានអត្ថថា ឱ្យក្តៅក្រហាយ

៤.**វិបរិណាមដ្ឋោ** មានអត្ថថា ប្រែប្រួល។

## ទុក្ខមានប្រការផ្សេងៗ ជាអនេក

❑ **ទុក្ខទុក្ខ** ទុក្ខព្រោះអត់ធន់បានដោយលំបាក

❑ **បរិណាមទុក្ខ** ទុក្ខព្រោះប្រែប្រួល

❑ **សង្ខារទុក្ខ** ទុក្ខរបស់សង្ខារ

❑ **បដិច្ឆន្នទុក្ខ** ទុក្ខបិទបាំង

❑ **អប្បដិច្ឆន្នទុក្ខ** ទុក្ខបើកបង្ហាញ

❑ **បរិយាយ** ទុក្ខអម

- **និប្បរិយាយទុក្ខ** ទុក្ខដោយត្រង់។

## ទុក្ខ ១២ កង

**The Truth of suffering expounded as twelvefold**

១.**ជាតិទុក្ខ** ការកើតជាទុក្ខ (Birth is suffering)

២.**ជរាទុក្ខ** ការចាស់គ្រាំគ្រាជាទុក្ខ (Ageing is suffering)

៣.**ព្យាធិទុក្ខ** ជម្ងឺតម្កាត់ជាទុក្ខ (sickness is suffering)

៤.**មរណទុក្ខ** សេចក្ដីស្លាប់ជាទុក្ខ (Death)

៥.**សោកទុក្ខ** សេចក្ដីសោកជាទុក្ខ (Sorrow)

៦.**បរិទេវទុក្ខ** សេចក្ដីខ្សឹកខ្សួលជាទុក្ខ (Lamentation)

៧.**ទុក្ខ** ការលំបាកកាយជាទុក្ខ (Pain)

៨.**ទោមនស្សទុក្ខ** ការអាក់អន់ចិត្តជាទុក្ខ (Grief)

៩.**ឧបាយាសទុក្ខ** ការតានតឹងចិត្តជាទុក្ខ (Despair)

១០.**អប្បិយេហិ សម្បយោគទុក្ខ** ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ពេញចិត្តជាទុក្ខ (Association with the unloved or unpleasant)

១១.**បិយេហិ វិប្បយោគទុក្ខ** ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ជាទុក្ខ (Separation from those whom you loved)

១២.**យម្បិច្ឆំ ន លភតិ តម្បិទុក្ខ** បុគ្គលកាលចង់បានរបស់ណាតែមិនបានរបស់នោះជាទុក្ខ (Not to get what one wants)

**សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ដោយបំព្រួញឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ។ (In brief the five Aggregates of Clinging)

កាលពោលដោយអភិធម្មន័យ ទុក្ខសច្ច រួមធម៌ ១៦០ (ចិត្ត ៨១ ចេតសិក ៥២ រូប ២៨) ប្រការដោយសង្ខេបបានដល់ នាមរូប។

រួមសេចក្តីមក កាយ និងចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺ កាមភូមិ រូបភូមិ និងអរូបភូមិនោះឯងជាសេចក្តីពិតគឺទុក្ខសច្ចៈ។

ដោយកិច្ច ជាបរិញ្ញាកិច្ច គឺកិច្ចដែលត្រូវកំណត់ដឹង សំដៅដល់ ទុក្ខសច្ចៈនោះនៅមានជាប្រចាំ តែយើងមិនបានកំណត់ទើបគួរកំណត់ដឹង។

## អធិប្បាយតាមអដ្ឋកថា

១.ជាតិទុក្ខនេះជាទីតាំងនៃទុក្ខប្រភេទណា?

១.១.ទុក្ខមានការចុះកាន់គភ៌ជាមូលដូចម្តេច?

១.២.ទុក្ខមានការបរិហារគភ៌ជាមូលដូចម្តេច?

១.៣.ទុក្ខមានវិបត្តិជាមូលដូចម្តេច?

១.៤.ទុក្ខមានការប្រសូតជាមូលដូចម្តេច?

១.៥.ទុក្ខមានការព្យាយាមរបស់ខ្លួន និងអ្នកដទៃជាមូលដូចម្តេច?

## លក្ខណាទិចតុក្ករបស់ជាតិ

១.**តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិ លក្ខណា** មានការកើតមុនក្នុងភពនោះៗ ជាលក្ខណៈ

២.**និយ្យាតនរសា** មានការប្រគល់ឱ្យ ជាកិច្ច

៣.**អតីតភវតោ ឥធ ឧម្មុជ្ជនបច្ចុប្បដ្ឋានា** មានការឃ្លាតចាកភពអតីតមកកើតក្នុងភពនេះ ជាផល

**ផលវសេន ទុក្ខវិចិត្តតា បច្ចុប្បដ្ឋានា វា** ឬមានការវិចិត្ររូបរួមនូវទុក្ខដោយអំណាចនៃផល ជាអាការប្រាកដ។

## លក្ខណាទិតិករបស់ជរា

១.**ខន្ធបរិបាកលក្ខណា** មានការទ្រុឌទ្រោមនៃខន្ធ ជាលក្ខណៈ

២.**មរណូបនយនរសា** មានការចូលទៅរកសេចក្តីស្លាប់ ជាកិច្ច

៣.**យោព្វនវិនាសបច្ចុប្បដ្ឋានា** មានការវិនាសវ័យកំលោះក្រមុំជាអាការប្រាកដ។

## មរណៈមាន ៣ យ៉ាង

១.**ខណិកមរណៈ** ស្លាប់គ្រប់ខណៈ

២.**សម្មុតិមរណៈ** ស្លាប់ដោយសម្មុតិ

៣.**សមុច្ឆេទមរណៈ** ស្លាប់ដោយអស់រលីង។

## មរណៈមាន ២ យ៉ាង

១.**កាលមរណៈ** ស្លាប់តាមកាល

២.**អកាលមរណៈ** ស្លាប់មិនត្រូវតាមកាល ។

## លក្ខណាទិតិករបស់មរណៈ

១.**ចុតិលក្ខណំ** មានការឃ្លាតចាកភពជាលក្ខណៈ

២.**វិយោគរសំ** មានការព្រាត់ប្រាសទៅ ជាកិច្ច

៣.**វិប្បវាសបច្ចុប្បដ្ឋានំ** មានការប្រាសចាកភពចាស់ ជាអាការប្រាកដ។

## ការវិនាស ៥ យ៉ាង

១.**ញាតិព្យសនៈ** ការវិនាសញាតិ

២.**ភោគព្យសនៈ** ការវិនាសភោគៈ

៣.**រោគព្យសនៈ** ការវិនាសព្រោះរោគ

៤.**សីលព្យសនៈ** ការវិនាសសីល

៥.**ទិដ្ឋិព្យសនៈ** ការវិនាសទិដ្ឋិ។

## លក្ខណាទិតិករបស់សោក

១.**អន្តោ និជ្ឈាយនលក្ខណោ** មានការដុតឆេះខាងក្នុង ជាលក្ខណៈ។

២.**ចេតសោ បរិនិជ្ឈាយនរសោ** មានការដុតរោលចិត្ត ជាកិច្ច។

៣.**អនុសោចនបច្ចុប្បដ្ឋានោ** មានការសោកសៅរឿយៗ ជាអាការប្រាកដ។

## បរិទេវៈ

**យំ សោកសល្លវិហតោ បរិទេវមានោ កណ្ឋោដ្ឋតាលុតលសោសជមប្បលយ្ហំភិយ្យោធិមត្តមធិគច្ឆតិយេវ ទុក្ខំ ទុក្ខោតិ តេន ភគវា បរិទេវមាហ។** បុគ្គលអ្នកត្រូវកូនសរ គឺសេចក្តីសោកចាក់ដោតហើយ ការខ្សឹកខ្សួលរមែងប្រសព្វទុក្ខណាដល់ធន់មិនបាន ដែលកើតត្រង់រឹម

បបូរមាត់ផ្ទៃពិតានយ៉ាងក្រៃលែងលើសប្រមាណ ដោយទុក្ខនោះ ទើបព្រះសម្មាសម្ពុទ្ធត្រាស់ បរិទេវៈគឺខ្សឹកខ្សួលថាជាទុក្ខពិត។

## លក្ខណាទិចតុក្កៈរបស់បរិទេវៈ

១.**ទេវលាលប្បនលក្ខណោ** មានការរៀបរាប់ ជាលក្ខណៈ

២.**គុណទោសបរិកិត្តនរសោ** មានការរៀបរាប់គុណ និងទោស ជាកិច្ច

៣.**សម្ភមបច្ចុប្បដ្ឋានោ** មានការត្អូញត្អែរ មិនតាំងនៅមាំ ជាអាការប្រាកដ។

## ទុក្ខ និងទោមនស្សទុក្ខ

**បីឡេតិ កាយិកមិទំ ទុក្ខំ ទុក្ខញ្ច មានសំ ភិយ្យោ ជនយតិ យស្មា តស្មា ទុក្ខន្តិ វិសេសតោ។** ព្រោះទុក្ខផ្លូវកាយនេះរមែងបៀតបៀន និងរមែងឱ្យទុក្ខតាមផ្លូវចិត្តយ៉ាងក្រៃងលែង ព្រោះហេតុដូច្នោះ ពាក្យថា ទុក្ខ ទើបមានដោយសេចក្ដីផ្សេងគ្នា។

**បីឡេតិ យតោ ចិត្តំ កាយស្ស ច បីឡនំ សមាវហតិ ទុក្ខន្តិ ទោមនស្សម្បិ ទោមនស្សំ តតោ អហុ។** ព្រោះទោមនស្សរមែងបៀតបៀននូវចិត្តផង រមែងនាំមកនូវការបៀតបៀនដល់កាយផង ព្រោះហេតុនោះទើបបណ្ឌិតទាំងឡាយពោលនូវទោមនស្សនោះថា ជាទុក្ខព្រោះការអន់ចិត្តនោះឯង។

## ឧបាយាសៈ

**ចិត្តស្ស ច បរិទហនា កាយស្ស វិសាទនា ច អធិមត្តំ យំ ទុក្ខមុប្បាយាសោ ជនេតិ ទុក្ខោ តតោ វុត្តោ។** ឧបាយាសៈ រមែងញុំាងទុក្ខដែលមានប្រមាណដ៏ក្រៃលែងណាឱ្យកើតឡើង ព្រោះការដុតចិត្ត និងធ្វើឱ្យកាយសៅហ្មងព្រះអង្គត្រាស់ហៅ **ឧបាយាសៈ** នោះថា ព្រោះមកពីទុក្ខនោះឯង។

## លក្ខណាទិតិករបស់ឧបាយាសៈ

១.**ព្យាសត្តិលក្ខណោ** មានការជាប់ក្នុងអារម្មណ៍ផ្សេងៗ ជាលក្ខណៈ

២.**និត្ថុននរសោ** មានការបន្ថយចិត្ត ជាកិច្ច

៣.**វិសាទប្បច្ចុប្បដ្ឋានោ** មានការក្រៀមក្រំចិត្ត ជាផល។

## អប្បិយេហិ សម្បយោគទុក្ខ

**តតោ ទុក្ខទ្វយស្សាបិ វត្ថុតោ សោ មហេសិនា ទុក្ខោ វុត្តោតិ វិញ្ញេយ្យោ អប្បិយេហិ សមាគមោ។** ព្រោះឃើញសត្វមិនជាទីស្រឡាញ់ ទើបជាទុក្ខត្រង់ចិត្តមុន និងការកើតទុក្ខដោយសេចក្តីព្យាយាមរបស់សត្វ ដែលមិនជាទីស្រឡាញ់នោះក្នុងកាយ ព្រោះហេតុដូច្នោះ គប្បីជ្រាបការសមាគមជាមួយសត្វដែលមិនជាទីស្រឡាញ់នោះ ព្រះមហាឫស្សីត្រាស់ថា ជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខ សូម្បីទាំង ២ ក្នុងលោកនេះឯង។

## លក្ខណាទិចតុក្កៈរបស់អប្បិយេហិ សម្បយោគទុក្ខ

១.**អនិដ្ឋសមោធានលក្ខណោ** មានការប្រជុំចុះនូវវត្ថុដែលមិនគួរប្រាថ្នា ជាលក្ខណៈ

២.**ចិត្តវិឃាតករណរសោ** មានការធ្វើវិឃាតចិត្ត ជាកិច្ច

៣.**អនត្ថភាវបច្ចុប្បដ្ឋានោ** មានភាវៈដែលឥតប្រយោជន៍ ជាផល។

## បិយេហិ វិប្បយោគទុក្ខ

**ញាតិធនាទិវិយោគា សោកសរសមប្បិតា វិតុជ្ជន្តិ ពាលា យតោ តតោ យំ ទុក្ខោតិ មតោ បិយវិយោគោ។** ព្រោះការព្រាត់ប្រាសចាកញាតិ និងទ្រព្យជាដើមពួកមនុស្សពាលអ្នកឆ្អែតស្កប់ស្កល់ ដោយកូនសរគឺសេចក្តីសោកចាក់មុតហើយ ព្រោះហេតុណា ព្រោះហេតុនោះ ការព្រាត់ប្រាសចាកវត្ថុ ជាទីស្រលាញ់ទើបគេស្គាល់ថា ទុក្ខ។

## លក្ខណាទិចតុក្កៈរបស់បិយេហិ វិប្បយោគទុក្ខ

១.**ឥដ្ឋវត្ថុវិយោគលក្ខណោ** មានការព្រាត់ប្រាសចាកវត្ថុដែលប្រាថ្នា ជាលក្ខណៈ

២.**សោកុប្បាទនរសោ** មានការកើតឡើងនៃសេចក្តីសោកជាកិច្ច

៣.**ព្យសនបច្ចុប្បដ្ឋានោ** មានការវិនាស ជាផល។

## **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខ**

**តំ តំ បដ្ឋយមានានំ តស្ស តស្ស អលាភតោ យំ វិឃាតមយំ ទុក្ខំ សត្តានំ ឥធ ជាយតិ។ អលព្ភនេយ្យ-វត្ថូនំ បដ្ឋនា តស្ស ការណំ យស្មា តស្មា ជិនោ ទុក្ខំ ឥច្ឆិតាលាភមព្រវី។** កាលបើសត្វប្រាថ្នាវត្ថុនោះៗ ហើយព្រោះមិនបានវត្ថុនោះៗ សេចក្តីទុក្ខឯណាដែលកើតពីការពិឃាតរមែងកើតដល់ ពួកសត្វក្នុងលោកនេះ ការប្រាថ្នាវត្ថុដែលមិនគប្បីបានជាហេតុនៃទុក្ខនេះ ព្រោះហេតុដូច្នោះ ទើបព្រះពុទ្ធត្រាស់ថាការមិនបានតាមប្រាថ្នាជាទុក្ខ។

## **លក្ខណាទិតិករបស់យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ**

១.**អលព្ភនេយ្យវត្ថុឥច្ឆនលក្ខណោ** មានការចង់បានក្នុងវត្ថុដែលមិនគប្បីបាន ជាលក្ខណៈ

២.**តប្បរិយេសនរសោ** មានការស្វែងរកវត្ថុនោះ ជាកិច្ច

៣.**តេសំ អប្បត្តិប្បច្ចុប្បដ្ឋានោ** មានការមិនបានសម្រេចនូវវត្ថុទាំងនោះ ជាផល។

## **លក្ខណាទិតិករបស់ទុក្ខសច្ច**

១.**ពាធនលក្ខណំ** មានការបៀតបៀន ជាលក្ខណៈ

២.**សន្តាបនរសំ** មានការធ្វើឱ្យក្តៅ ជាកិច្ច

៣.**បវត្តិប្បច្ចុប្បដ្ឋានំ** មានការប្រព្រឹត្តិទៅ ជាផល។

**ទុក្ខ** ព្រោះអត្ថថា ទ្រាំបានដោយលំបាក។

## កិច្ចបដិបត្តិក្នុងទុក្ខសច្ចៈ

សេចក្តីទុក្ខ មានគ្រប់គ្នាមិនប្រកាន់វណ្ណៈនោះទេ សូម្បីព្រះសម្មាសម្ពុទ្ធកាលទ្រង់មិនទាន់បរិនិព្វាន ក៏ទ្រង់ជួបទុក្ខផ្លូវកាយដែរ គ្រាន់តែព្រះអង្គមិនមានទុក្ខផ្លូវចិត្ត ដូច្នេះសេចក្តីទុក្ខមិនត្រូវលះបង់ទេ ត្រូវកំណត់ដឹង ហៅថា បរិញ្ញាកិច្ច (កិច្ចកំណត់ដឹង) ពេលដឹងថាជីវិតជាទុក្ខយើងនឹងរកផ្លូវចេញហើយ។ ប្រៀបដូចយើងដឹងច្បាស់ថាខ្លួនមានជំងឺ ដឹងខ្លួនថាឈឺទើបត្រូវរកថ្នាំព្យាបាល បើយើងមិនដឹងថាជីវិតជាទុក្ខទេ យើងនឹងសម្គាល់ថាជីវិតជាសុខ ដែលតាមពិតជាទុក្ខ ដែលភ្លើងធ្វើឱ្យយើងក្តៅក្រហាយមាន ១១ កង គឺ

**ចក្ខុំ អាទិត្តំ។ កេន អាទិត្តំ។ រាគគ្គិនា អាទិត្តំ។ ទោសគ្គិនា មោហគ្គិនា ជាតិយា ជរាយ មរណេន សោកេន បរិទេវេន ទុក្ខេន ទោមនស្សេន ឧបាយាសេន អាទិត្តន្តិ វទាមិ។ សោតំ អាទិត្តំ ឃានំ អាទិត្តំ។ ជិវ្ហា អាទិត្តា។ កាយោ អាទិត្តោ។ មនោ អាទិត្តោ។** ចក្ខុជារបស់ក្តៅ។ ក្តៅដោយអ្វី? តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ក្តៅដោយភ្លើងគឺទោសៈ ក្តៅដោយភ្លើងគឺមោហៈ ដោយជាតិ ជរា មរណៈ សោកៈ ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់។ ត្រចៀកជារបស់ក្តៅ។ ច្រមុះជារបស់ក្តៅ។ អណ្តាតជារបស់ក្តៅ។ កាយជារបស់ក្តៅ ចិត្តជារបស់ក្តៅ។

បុ.អរិយមគ្គរមែងបៀតបៀនបុគ្គលក្រៃលែងដោយទុក្ខ គឺការបំពេញបារមីដ៏យូរ និងទុក្ខដែលចម្រើនភាវនាមានភាពបរិសុទ្ធនៃសីលជាដើម ក្នុងជាតិចុងក្រោយ ទាំងមានសភាពប្រែប្រួលរលត់ជានិច្ច ដូច្នោះអរិយមគ្គនោះគួររាប់បញ្ចូលក្នុងទុក្ខសច្ចៈ ព្រោះមានសភាពបៀតបៀនឬ?

វិ.មិនគប្បីពោលយ៉ាងនេះ ព្រោះអរិយមគ្គនាំសេចក្ដីស្ងប់នៃទុក្ខទាំងពួងមកឱ្យ តាមពិតអរិយមគ្គកាលបើកើតឡើងម្ដងម្កាលដល់បុគ្គលអ្នកសោយទុក្ខ ក្នុងការតាក់តែងតាមដែលពោលមកហើយ រមែងកើតឡើងកម្ចាត់កិលេសទាំងអស់បាន ហើយរំលត់ទុក្ខទាំងពួងក្នុងសង្សារវដ្ដដែលមិនប្រាកដខាងដើម និងខាងចុងក្នុងអនាគត ទុក្ខក្នុងអនាគតនឹងស្ងប់ទៅ រមែងឱ្យវិមុត្តិសុខដ៏កំពូលសេចក្ដីសាបសូន្យទើបមិនមានដល់បុគ្គលនោះ ព្រោះការប្រែប្រួលនោះ ព្រោះហេតុនោះ អរិយមគ្គ ទើបមិនរាប់ចូលក្នុងទុក្ខសច្ចៈ។

## ២.សមុទយសច្ចៈ

The Noble Truth of the Origin of Suffering

### សមុទយៈ មានអត្ថ ៣ យ៉ាង

**សមុទេតិ ឯតស្មាតិ សមុទយោ** ដែនកើតនៃទុក្ខ។

**បុនប្បុនំ ឧទយតិ ឧដ្ឋាបេតីតិ សមុទយោ** សភាវៈញ៉ាំងទុក្ខឱ្យកើតឡើង។

**បុនប្បុនំ ឧទយតិ វឌ្ឍេតីតិ** = សភាវៈញ៉ាំងទុក្ខឱ្យចម្រើនរឿយៗ។

## ទុក្ខសមុទយដោយអត្ថ ៤ យ៉ាង

**១.អាយូហនដ្ឋោ** អត្ថថា កៀរគរសេចក្តីទុក្ខឱ្យកើតឡើង

**២.និទានដ្ឋោ** អត្ថថា នាំសេចក្តីទុក្ខមកប្រគល់ឱ្យជាផល

**៣.សំយោគដ្ឋោ** អត្ថថា ប្រកបទាក់ចងសត្វ ដោយសេចក្តីទុក្ខ

**៤.បលិពោធដ្ឋោ** អត្ថថា ធ្វើឱ្យសត្វរវល់រំខានចិត្តស្ទាក់ដំណើរមិនឱ្យបាននូវមគ្គនិងផល។

## តណ្ហាមាន ៣ គឺ

១.**កាមតណ្ហា** ប្រាថ្នាក្នុងកាម

២.**ភវតណ្ហា** ប្រាថ្នាក្នុងភព

៣.**វិភវតណ្ហា** ប្រាថ្នាប្រាសចាកភព។

## ឧបមាកាម ១០ យ៉ាង

១.**អដ្ឋិកង្ខលូបមា កាមា** កាមទាំងឡាយឧបមាដូចរាងឆ្អឹង (ព្រោះអត្ថថា មានរសឆ្ងាញ់(ត្រេកអរ) តិច។

២.**មំសបេសូបមា កាមា** កាមទាំងឡាយឧបមាដូចដុំសាច់ (ព្រោះអត្ថថា ជាទូទៅដល់សត្វច្រើន)។

៣.**តិណុក្កូបមា កាមា** កាមទាំងឡាយឧបមាដូចគប់ភ្លើងធ្វើពីស្មៅ (ព្រោះអត្ថថា តាមដុតរោល)។

៤.**អង្គារកាសូបមា កាមា** កាមទាំងឡាយឧបមាដូចរណ្តៅរងើកភ្លើង ព្រោះអត្ថថា ក្តៅផ្សាក្រៃលែងណាស់)។

៥.**សុបិនកូបមា ភាមា** កាមទាំងឡាយឧបមាដូចយល់សប្តិ (ប្រាកដក្នុងវេលាបន្តិចបន្តួច)។

៦.**យាចិតកូបមា ភាមា** កាមទាំងឡាយឧបមាដូចរបស់ខ្ចីគេ (ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយកាលមួយគ្រា)។

៧.**រុក្ខផលូបមា ភាមា** កាមទាំងឡាយឧបមាដូចផ្លែឈើ (ពុល) (ព្រោះអត្ថថា កាត់បន្ថយអវៈយវទាំងពួង)។

៨.**អសិសូនូបមា ភាមា** កាមទាំងឡាយឧបមាដោយកាំបិត និងជ្រញ់ (ព្រោះអត្ថថា ជាទីទទួលការចិញ្ច្រាំ)។

៩.**សត្តិសូលូបមា ភាមា** កាមទាំងឡាយឧបមាដោយលំពែង និងដែកស្រួច (ព្រោះអត្ថថា ចាក់ដោត)។

១០.**សប្បសិរូបមា ភាមា** កាមទាំងឡាយឧបមាដូចក្បាលពស់ (ព្រោះអត្ថថា គួររង្កៀស និងមានភ័យចំពោះមុខនោះឯង)[១]។

## លក្ខណាទិចតុក្កៈរបស់សមុទយសច្ចៈ

១.**បភវលក្ខណំ** មានហេតុជាដែនកើត ជាលក្ខណៈ

២.**អនុបច្ឆេទករណរសំ** មានការមិនចូលទៅកាត់ផ្តាច់ ជារស

៣.**បលិពោធបច្ចុប្បដ្ឋានំ** មានបលិពោធ ជាបច្ចុប្បដ្ឋាន។

## ៣.និរោធសច្ច

(១) អលគទ្ទូបមសូត្រ ទុតិយភាគ បិដកភាគ ២១ ទំព័រ ២៦ រឿងអរិដ្ឋភិក្ខុ និងអដ្ឋកថាបបញ្ចសូទនី។

(ជាឈ្មោះនៃការអស់តណ្ហា)

**The Noble Truth of the Extinction of Suffering**

**និរុជ្ឈនំ និរោធោ** ការរលត់នូវសេចក្តីទុក្ខក្នុងវដ្តៈ។

## លក្ខណាទិតិករបស់និរោធសច្ច

១.**សន្តិលក្ខណំ** ស្ងប់ចាកកិលេសនិងខន្ធ ជាលក្ខណៈ

២.**អច្ចុតិរសំ** មានសេចក្តីមិនញាប់ញ័រ ជាកិច្ច ឬ **អស្សាសករណរសំ វា** មានភាពស្រោលនៃចិត្ត

៣.**អនិមិត្តបច្ចុប្បដ្ឋានំ** មិនមាននិមិត្ត ជាបច្ចុប្បដ្ឋាន **និស្សរណបច្ចុប្បដ្ឋានំ វា** ឬមានការចេញទៅ ជាផល។

## អត្ថរបស់និរោធសច្ច

១.**និស្សរណត្ថោ** មានអត្ថថា រលាស់ចេញ គឺមានសភាពរួចផុត

២.**វិវេកត្ថោ** មានអត្ថថា ស្ងាត់គឺស្ងាត់ចាកបលិពោធ (ទុក្ខក្នុងវដ្តៈ)

៣.**អសង្ខតត្ថោ** មានអត្ថថា មិនមានបច្ច័យតាក់តែង គឺប្រាសចាកសង្ខារទុក្ខ

៤.**អមតត្ថោ** មានអត្ថថា ជាអមតៈ (មិនស្លាប់)។

អង្គធម៌របស់ **និរោធសច្ចៈ** បានដល់ ព្រះនិព្វាន។ ឈ្មោះរបស់ព្រះនិព្វានមានច្រើនផ្សេងពីសង្ខតធម៌គឺ

១.**អសេសតោ វិរាគោ** អស់រាគៈមិនមានសល់

២.**និរោធោ** ការរលត់

៣.**ចាគោ** ការលះ

៤.**បដិនិស្សគ្គោ** ការលះបង់

៥.**មុត្តិ** ការរួច

៦.**អនាលយោ** ការមិនមានអាល័យ

៧.**រាគក្ខយោ** ការអស់រាគៈ

៨.**ទោសក្ខយោ** ការអស់ទោសៈ

៩.**មោហក្ខយោ** ការអស់មោហៈ

១០.**តណ្ហក្ខយោ** ការអស់តណ្ហា

១១.**អនុប្បាទោ** ការមិនកើតឡើង

១២.**អប្បវត្តំ** ការមិនប្រព្រឹត្តិទៅ

១៣.**អនិមិត្តំ** ការមិនមានគ្រឿងសម្គាល់

១៤.**អប្បណិហិតំ** ការមិនមានទីតាំង

១៥.**អនាយូហនំ** ការមិនព្យាយាម

១៦.**អប្បដិសន្ធិ** ការមិនមានបដិសន្ធិ

១៧.**អប្បដិវត្តិ** ការមិនវិលត្រឡប់

១៨.**អគតិ** ការមិនមានគតិ

១៩.**អជាតំ** ការមិនកើត

២០.**អជរំ** ការមិនចាស់

២១.**អព្យាធិ** ការមិនឈឺ

២២.**អមតំ** ការមិនស្លាប់

២៣.**អសោកំ** ការមិនមានសេចក្ដីសោក

២៤.**អបរិទេវំ** ការមិនមានបរិទេវៈ

២៥.**អនុបាយាសំ** ការមិនចង្អៀតចង្អល់

២៦.**អសង្កិលិដ្ឋំ** មិនមានសេចក្ដីសៅហ្មង។

## ៤.ទុក្ខនិរោធគាមិនីបដិបទា

## (សេចក្ដីប្រតិបត្តិឱ្យដល់ការរលត់ទុក្ខ)

## The Noble Truth of the Path leading to the Cessation of Suffering

### ទុក្ខនិរោធគាមិនីបដិបទាដោយអត្ថមាន ៤ យ៉ាង

**១.និយ្យានដ្ឋោ** អត្ថថា ដឹកជញ្ជូនសត្វចេញចាកពីវដ្ដសង្សារ

**២.ហេត្វដ្ឋោ** អត្ថថា ជាហេតុញុំាងសត្វឱ្យដល់ព្រះនិព្វាន

**៣.ទស្សនដ្ឋោ** អត្ថថា ឃើញនូវព្រះនិព្វាន ដែលជាធម៌ល្អិតសុខុមយ៉ាងក្រៃលែង

**៤.អធិបតេយ្យដ្ឋោ** អត្ថថា ជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន។

### មគ្គអង្គ ៨

១.**សម្មាទិដ្ឋិ យល់ត្រូវ** បានដល់ បញ្ញាចេតសិកក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ៧៩។

២.**សម្មាសង្កប្បោ ត្រិះរិះត្រូវ** បានដល់ វិតក្កចេតសិកក្នុងកាមាវចរចិត្ត ២៤ បឋមជ្ឈានចិត្ត ១១។

៣.**សម្មាវាចា សម្តីត្រូវ** បានដល់ សម្មាវាចាចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៤០។

៤.**សម្មាកម្មន្តោ ការងារត្រូវ** បានដល់ សម្មាកម្មន្ត-ចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៤០។

៥.**សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ** បានដល់ សម្មាអាជីវ-ចេតសិកក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត៤០។

៦.**សម្មាវាយាមោ ព្យាយាមត្រូវ** បានដល់ វីរិយចេតសិកក្នុងសោភណចិត្ត ៩១។

៧.**សម្មាសតិ ការរលឹកត្រូវ** បានដល់ សតិចេតសិកក្នុងសោភណចិត្ត ៩១។

៨.**សម្មាសមាធិ ការតម្កល់ចិត្តត្រូវ** បានដល់ ឯកគ្គតា-ចេតសិកក្នុងសោភណចិត្ត ៩១។

## អង្គធម៌របស់អរិយសច្ចៈ ៤

១.**ទុក្ខសច្ចៈ** បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥១ (វៀរលោភចេតសិក) រូប ២៨។

២.**សមុទយសច្ចៈ** បានដល់ លោភចេតសិក។

៣.**និរោធសច្ចៈ** បានដល់ ព្រះនិព្វាន។

៤.**មគ្គសច្ចៈ** បានដល់ អង្គមគ្គ ៨ ក្នុងមគ្គចិត្ត ៤។

## ហេតុ និងផលជាដើមរបស់សច្ចៈ ៤

## ក.ចែកដោយហេតុ និងផល

- **ទុក្ខសច្ចៈ** ជាផល **សមុទយសច្ចៈ** ជាហេតុ
- **និរោធសច្ចៈ** ជាផល **មគ្គសច្ចៈ** ជាហេតុ

## ខ.ដោយលោកិយ និងលោកុត្តរ

- **សច្ចៈ២ ខាងដើម** ជាលោកិយធម៌ និងលោកិយសច្ចៈ
- **សច្ចៈ២ ខាងចុង** ជាលោកុត្តរធម៌ និងលោកុត្តរសច្ចៈ។

## គ.ចែកដោយវដ្តៈ

- **រូបនាមទាំង ២** កើតក្នុងសង្សារវដ្តសុទ្ធតែជាទុក្ខ ឈ្មោះថា **បវត្តិសច្ចៈ** ជាសច្ចៈដែលមិនល្អ។
- **សមុទយសច្ចៈ** ជាសច្ចៈដែលជាហេតុឱ្យទុក្ខសច្ចកើតឡើងប្រព្រឹត្តទៅក្នុងវដ្តសំសារៈ ឈ្មោះថា **បវត្តិហេតុសច្ចៈ** ជាសច្ចៈដែលមិនល្អ។
- **និរោធសច្ចៈ** ជាសច្ចៈដែលថយក្រោយចេញចាកវដ្តទុក្ខ ឈ្មោះថា **និវត្តិសច្ចៈ** ជាសច្ចៈដែលល្អ។
- **មគ្គសច្ចៈ** ជាសច្ចៈដែលជាហេតុឱ្យដល់ការថយចេញចាកវដ្តទុក្ខ ឈ្មោះថា **និវត្តិហេតុសច្ចៈ** ជាសច្ចៈដែលល្អ។

## ដើម្បីស្វែងរកបដិវេធញ្ញាណ ២ ប្រការ

១.**លោកិយបដិវេធញ្ញាណ** បានដល់ ការសិក្សាបរិយត្តិសាសនា ឱ្យយល់ទុក្ខ និងសមុទយរហូតដល់ខន្ធ អាយតនៈ ធាតុ

ត្រូវសិក្សាឱ្យដល់និរោធ និងមគ្គសច្ចៈ ថាព្រះនិព្វានមានសភាព យ៉ាងណាដោយបដិបទាត្រឹមត្រូវ។

២.**លោកុត្តរបដិវេធញ្ញាណ** ជាបញ្ញាកើតព្រមជាមួយអរិយមគ្គ ធ្វើកិច្ចប្រហារកិលេស និងឱ្យយល់ដឹងអរិយសច្ចៈទាំង ៤ ប្រការ បានចំពោះបដិវេធញ្ញាណប៉ុណ្ណោះ តែតាមវោហារសង្គ្រោះ លោកិយបដិវេធ កាលសិក្សាឱ្យយល់ច្បាស់ល្អជាមុនហើយ ជួយឧបការៈដល់ការបដិបត្តិស្វែងរកបដិវេធញ្ញាណ បានស្រួលក្រៃលែងឡើង។

## សុញ្ញតាក្នុងសច្ចៈ

១.សច្ចៈទាំង ៤ គប្បីជ្រាបនូវសច្ចៈ ២ ខាងដើមថា សូន្យចាកភាពទៀង ភាពស្អាត ភាពសុខ និងភាពជាអត្តា។ អមតបទសូន្យចាកអត្តា។ ចំណែកមគ្គសច្ចៈ សូន្យចាកភាពទៀង ភាពសុខ និងភាពជាអនត្តា។

២.សច្ចៈ ៣ សូន្យចាកនិរោធ ឬនិរោធសច្ចសូន្យចាកសច្ចៈ ៣។

៣.សច្ចៈដែលជាហេតុ សូន្យចាកសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផលនោះក៏សូន្យចាកសច្ចៈដែលជាហេតុដែរ។

## សច្ចញាណ ២ យ៉ាង

១.**អនុពោធញ្ញាណ** ញាណដែលដឹងដោយលំដាប់

២.**បដិវេធញ្ញាណ** ញាណដែលចាក់ធ្លុះ។

បណ្តាញាណទាំងពីរនោះ អនុពោធញ្ញាណ គឺជាលោកិយ រមែងប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គ ដោយអំណាចនៃការស្តាប់ជាដើម។ បដិវេធញ្ញាណ គឺជាលោកុត្តរ ធ្វើនិរោធឱ្យជាអារម្មណ៍ ហើយចាក់ធ្លុះសច្ចៈទាំង ៤ ដោយកិច្ចដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះរមែងឃើញទុក្ខសមុទយផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង។

ម្យ៉ាងទៀត សច្ចញ្ញាណដែលជាលោកិយនេះ **ទុក្ខញ្ញាណ** រមែងហាមនូវសក្កាយទិដ្ឋិ ដែលកំពុងប្រព្រឹត្តទៅជាបរិយុដ្ឋាននោះ ដោយអំណាចនៃការគ្របសង្កត់។ **សមុទយញ្ញាណ** រមែងហាមនូវឧច្ឆេទទិដ្ឋិ។ **និរោធញ្ញាណ** រមែងហាមនូវសស្សតទិដ្ឋិ។ មគ្គញ្ញាណ រមែងហាមនូវអកិរិយទិដ្ឋិ។

ម្យ៉ាងទៀត ទុក្ខញ្ញាណ រមែងហាមការបដិបត្តិខុសក្នុងផល គឺការដែលបានសម្គាល់ខុសក្នុងបញ្ចក្ខន្ធថាទៀង ថាស្អាត ថាសុខ និងថាមានអត្តាតួខ្លួន។ សមុទយញ្ញាណ ហាមការបដិបត្តិខុសក្នុង

ហេតុ គឺការដែលប្រព្រឹត្តទៅក្នុងការរាប់អានចំពោះអ្វីដែលមិនមែនជាហេតុថាជាហេតុ ដូចជាយល់ថា លោកនេះ រមែងប្រព្រឹត្តទៅដោយព្រះជាម្ចាស់ ព្រះព្រហ្ម ព្រះសិវៈ និងអ្វីដទៃទៀត ឬប្រព្រឹត្តទៅដោយខ្លួនឯងជាដើម។ និរោធញ្ញាណ ហាមការបដិបត្តិខុសក្នុងនិរោធ គឺប្រកាន់ក្នុងអរូបលោក ឬក្នុងភូមិដែលជាកំពូលនៃភពជាដើមថាជាព្រះនិព្វាន។ មគ្គញ្ញាណ រមែងហាមការបដិបត្តិខុសក្នុងអបាយ គឺមានការប្រកាន់ក្នុងផ្លូវដែលមិនបរិសុទ្ធិ ដូចជាកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគជាដើម ថាជាមគ្គដ៏បរិសុទ្ធ។ ដូចព្រះបាលីថា៖

**លោកេ លោកប្បភវេ លោកត្ថគមេ សិវេ ច តទុបាយេ សម្មុយ្ហតិ តាវ នរោ ន វិជានាតិ យាវ សច្ចានិ។** នរជនមិនទាន់បានត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដរាបណាគេរមែងវង្វេងក្នុងលោក ក្នុងហេតុដែលនាំឱ្យឱ្យកើតលោក ក្នុងព្រះនិព្វានដែលជាការរលត់ទៅនៃលោក និងក្នុងឧបាយនៃការរលត់លោនោះដរាបនោះឯង។

## ដោយសភាគ និងវិសភាគ

១.សច្ចៈទាំង ៤ ជាសភាគ គឺមានចំណែកស្មើគ្នា ដោយជារបស់ពិត ដោយជារបស់សូន្យចាកខ្លួន និងដោយជារបស់ចាក់ធ្លុះ

បានដោយលំបាក។ ជាវិសភាគ គឺមានចំណែកមិនស្មើគ្នាដោយកំណត់លក្ខណៈរបស់ខ្លួន។

២.សច្ចៈពីរដំបូងគឺ ទុក្ខសច្ចនិងសមុទយសច្ច ជាសភាគ ព្រោះជាធម៌ជ្រៅ ដោយអត្ថថា ចូលដល់បានដោយក្រ និងជាលោកិយ ឬជាសាសវធម៌ បានដល់ធម៌ជាអារម្មណ៍របស់អាសវៈ។ ជាវិសភាគ ព្រោះចែកជាផលនិងហេតុ ម្យ៉ាងទៀត ព្រោះជាធម៌គួរកំណត់ដឹង និងជាធម៌គួរលះ។ សច្ចៈ២ ខាងក្រោយគឺ និរោធសច្ច និងមគ្គសច្ច ជាសភាគ ព្រោះជាធម៌ជ្រៅ និងព្រោះជាលោកុត្តរ ឬជាអនាសវធម៌ បានដល់ធម៌មិនមែនជាអារម្មណ៍នៃអាសវៈ។ ជាវិសភាគ ព្រោះជាវិសយ និងវិសយី (និរោធជាវិសយ ព្រោះជាអារម្មណ៍របស់មគ្គ ឯចំណែកមគ្គ ជាវិសយី ព្រោះមាននិរោធ គឺព្រះនិព្វានជាអារម្មណ៍។ ម្យ៉ាងទៀត ព្រោះជាធម៌គួរធ្វើឱ្យជាក់ច្បាស់ និងជាធម៌គួរចម្រើន។

៣.សច្ចៈទី ១ និងសច្ចៈទី ៣ ជាសភាគ ព្រោះជាផល ជាវិសភាគ ព្រោះជាសង្ខតៈ និងអសង្ខតៈ។ សច្ចៈទី២ និងសច្ចៈទី៤ ជាសភាគ ព្រោះជាហេតុ ជាវិសភាគ ព្រោះជាអកុសល និងកុសល។

៤.សច្ចៈទី ១ និងទី ៤ ជាសភាគ ព្រោះជាសង្ខតៈ ជាវិសភាគ ព្រោះជាលោកិយនិងលោកុត្តរ។ សច្ចៈទី ២ និងសច្ចៈទី៣

ជាសភាគ ព្រោះជានេវសេក្ខានាសេក្ខា ជាវិសភាគ ព្រោះជា សារម្មណ និងអនារម្មណៈ។

## អរិយសច្ចដោយចតុក្កៈ

១.ក្នុងចតុក្កៈនេះ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ដោយព្រះបាលីថា យទនិច្ចំ តំ ទុក្ខំ របស់ណាមិនទៀងរបស់នោះជាទុក្ខ ប៉ុន្តែទុក្ខនេះមិនមែនអរិយសច្ចៈ (សច្ចវិមុត្តិ)។

និរោធជាអរិយសច្ច តែមិនមែនជាទុក្ខ។

អរិយសច្ចៈ ២ គឺសមុទយសច្ច និងមគ្គសច្ច គឺជាទុក្ខ ព្រោះការមិនទៀង តែមិនមែនទុក្ខអរិយសច្ច ដែលកុលបុត្រអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ គប្បីកំណត់ដឹងនោះបាន។

ចំណែកឧបាទានក្ខន្ធ ៥ វៀរតណ្ហាចេញហើយ គឺទាំងជាទុក្ខ ព្រោះមិនទៀង ទាំងជាទុក្ខអរិយសច្ច។

ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនមែនជាទុក្ខ ដែលកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគជាម្ចាស់ គប្បីកំណត់ដឹងនោះឡើយ ទាំងមិនមែនជាទុក្ខអរិយសច្ច។

២.កិលេសដែលជាសមុទយ ក្រៅពីតណ្ហា ជាសមុទយៈ ព្រោះអត្ថថា ធ្វើឱ្យកើតទុក្ខ តែមិនមែនសមុទយសច្ច។

និរោធជាអរិយសច្ច តែមិនមែនជាសមុទយសច្ច។

ទុក្ខសច្ច និងមគ្គសច្ច ជាសមុទយៈក៏បាន ព្រោះជាហេតុជាបច្ច័យនៃផលរបស់ខ្លួន តែមិនមែនជាសមុទយសច្ចដែលជាសច្ចៈត្រូវលះបង់នោះឡើយ។

តណ្ហា គឺទាំងជាសមុទយ ទាំងជាអរិយសច្ចដែលជាសច្ចត្រូវលះបង់។

ធម៌ដែលត្រូវសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនមែនជាសមុទយៈដែលគប្បីលះបង់ផង ទាំងមិនមែនជាអរិយសច្ចផង (ព្រោះជាសច្ចវិមុត្តិ)។

៣.សង្ខារនិរោធ និងនិរោធសមាបត្តិជានិរោធ តែមិនមែនជានិរោធអរិយសច្ច។

សមុទយៈជាអរិយសច្ច តែមិនមែនជានិរោធសច្ច។

ទុក្ខសច្ច និងមគ្គសច្ចជានិរោធសច្ចក៏បានដែរ គឺខណៈនិរោធ (ភង្គៈបែកធ្លាយ)។

អសង្ខតធាតុទាំងជានិរោធ ទាំងជាអរិយសច្ច។

ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនមែនជានិរោធដែលគប្បីជាក់ច្បាស់ ទាំងមិនមែនជាអរិយសច្ច។

៤.អង្គមគ្គដទៃក្រៅអំពីអរិយមគ្គ ជាមគ្គ តែមិនមែនជាមគ្គអរិយសច្ច។

និរោធជាអរិយសច្ច តែមិនមែនជាមគ្គ។

ទុក្ខ និងសមុទយៈ ជាមគ្គក៏បានដែរ ព្រោះជាផ្លូវទៅកាន់ភព តែមិនមែនជាអរិយមគ្គ ដែលគួរចម្រើនដើម្បីនិរោធឡើយ។

និរោធគាមិនីបដិបទា ទាំងជាមគ្គទាំងជាអរិយសច្ចដោយប្រការទាំងពួង។

ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនមែនជាមគ្គដែលគប្បីចម្រើន និងមិនមែនជាអរិយសច្ច។

## អរិយសច្ចដោយអត្ថ

ប្រសិនបើមានពាក្យសួរថា អ្វីដែលជាអត្ថរបស់សច្ចៈនោះ នឹងមានពាក្យតបយ៉ាងពិស្តារថា ភាវៈណា កាលបើបុគ្គលសម្លឹងមើលដោយបញ្ញាចក្ខុ ភាវៈនោះរមែងមិនវិបរិតដូចជាកលមាយា មិនបញ្ឆោតភ្នែកដូចជាថ្ងៃបណ្ដើរកូន និងមិនជាសភាវៈដែលអ្នកណាៗរកមិនបានដូចអត្តារបស់អន្យតិរ្ថិយឡើយ។ ដោយពិតសច្ចៈគឺជាគោចរ (អារម្មណ៍) នៃអរិយញ្ញាណ ជារបស់ពិតប្រាកដ មិនវិបរិត

ដូចជាលក្ខណៈភ្លើង និងដូចជាធម្មតារបស់សត្វលោក (សត្វលោកធម្មតាត្រូវកើតចាស់ឈឺស្លាប់ជាធម្មតា)។ ដូចព្រះមានព្រះភាគត្រាស់ទុក្ខថា **ឥទំ ទុក្ខន្តិ ខោ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ** ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ នោះឯង គឺជារបស់ពិត នោះឯង គឺជារបស់មិនខុស នោះឯង គឺជារបស់ដែលមិនទៅជាប្រការដទៃឡើយ។

## អរិយសច្ចដោយធម៌តែម្យ៉ាងជាដើម

១.ទុក្ខសច្ចទាំងអស់ ឈ្មោះថា តែម្យ៉ាង ព្រោះជាបវត្តិ គឺជាធម៌ប្រព្រឹត្តទៅក្នុងវដ្តៈ។ ជាពីរយ៉ាងគឺនាម១ រូប១ ។ ជាបីយ៉ាង គឺកាមភព១ រូបភព ១ អរូបភព១។ ជាបួនយ៉ាងគឺអាហារ ៤។ ជា ៥ យ៉ាងគឺឧបាទានក្ខន្ធ ៥។

២.សមុទយសច្ចតែម្យ៉ាង ព្រោះជាសភាវៈញុំាងវដ្តៈឱ្យប្រព្រឹត្តទៅ។ ជាពីរយ៉ាង គឺជាធម៌សម្បយុត្តដោយទិដ្ឋិ និងមិនមែនសម្បយុត្តដោយទិដ្ឋិ។ ជាបីយ៉ាងដោយចែកជា កាមតណ្ហា ភវតណ្ហា និងភវតណ្ហា។ ជាបួនយ៉ាង គឺជាទោសដែលមគ្គ ៤ គប្បីលះ។ ជាប្រាំយ៉ាង ដោយចែកតាមអារម្មណ៍ មានសេចក្តីត្រេកអរក្រៃលែងក្នុងរូបជាដើម។ ជាប្រាំមួយយ៉ាង គឺដោយប្រភេទនៃកងតណ្ហា ៦។

៣.និរោធសច្ចតែម្យ៉ាង ព្រោះជាសង្ខតធាតុ។ តែដោយបរិយាយគឺអម និរោធមាន ២ យ៉ាង បានដល់ សឧបាទិសេសនិព្វាន

និងអនុបាទិសេសនិព្វាន។ ជា ៣ យ៉ាងព្រោះស្ងប់នូវភពទាំង ៣។ ជា ៤ យ៉ាងព្រោះជាអារម្មណ៍ឱ្យសម្រេចមគ្គ ៤។ ជាប្រាំយ៉ាង ព្រោះស្ងប់សេចក្តីត្រេកអរក្នុងរូបជាដើម។ ជាប្រាំមួយយ៉ាង គឺដោយប្រភេទនៃការអស់កងតណ្ហា ៦។

៤.មគ្គសច្ចតែម្យ៉ាង ព្រោះជាធម៌គួរចម្រើន។ ជា ២ យ៉ាង ដោយចែកជា សមថៈ និងវិបស្សនា ឬម្យ៉ាងទៀតជាពីរយ៉ាងដោយប្រភេទនៃទស្សននិងភាវនា។ ជា ៣ យ៉ាងដោយប្រភេទនៃខន្ធ ៣ មានសីលខន្ធ សមាធិខន្ធ បញ្ញាខន្ធ។ ជា ៤ យ៉ាងដោយអំណាចនៃមគ្គ ៤។

បិដកលេខ ២១,ទំព័រ ១៩៣ ព្រះសារីបុត្តសម្តែងថា នៃអ្នកមានអាយុទាំងឡាយ ស្នាមជើងទាំងឡាយណាមួយរបស់ពួកសត្វដែលបិតនៅលើផែនដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីប្រាកដជាវិសេសជាងស្នាមជើងនៃសត្វអម្បាលនោះ ព្រោះស្នាមជើងដំរីនោះ ជាស្នាមជើងធំ ដូចម្តេចមិញ ម្នាលអ្នកដ៏មានអាយុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ចទាំង ៤ ដូច្នោះឯង។

បិដកលេខ ១៦,ទំព័រ ១៩៣ ពេលដែលព្រះអង្គជិតនឹងបរិនិព្វានទ្រង់គង់នៅកោដិគ្រាម បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាល

ភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តៈ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចៈទាំង ៤។

## តារាងសព្វសង្គហៈ

| អង្គធម៌ | ខន្ធ ៥ | ឧបាទានក្ខន្ធ ៥ | អាយតន ១២ | ធាតុ ១៨ | អរិយសច្ច ៤ | សរុបអង្គធម៌ក្នុងក្រុម |
|---|---|---|---|---|---|---|
| រូប ២៨ | ១ | ១ | ១ | ១ | ១ | ៥ |
| ចេតសិក៥២ | ១ | ១ | ១ | ១ | ១ | ៥ |
| លោកិយ៨១ | ១ | ១ | ១ | ១ | ១ | ៥ |
| លោកុត្តរ៨ | ១ | | ១ | ១ | | ៣ |
| និព្វាន | | | ១ | ១ | ១ | ៣ |
| សរុប | ៤ | ៣ | ៥ | ៥ | ៤ | ៥ ក្រុម |

**(ចប់ បរិច្ឆេទទី ៧)**

## អ្នករចនាក្រប

-ភិក្ខុជោតិវីរិយោ **យ៉ាវ ឡង់ឌី**

## អ្នកពិនិត្យ

១.ភិក្ខុបធានជ្ជោតោ **ម៉ាន់ សុភាព**

២.ភិក្ខុសាសនរក្ខិតោ **សុខ ចន្ថា**

៣.ភិក្ខុវីរិយបណ្ឌិតោ **ភឿន វ៉ាន់ឌី**

៤.ភិក្ខុ កល្យាណធម្មោ **ម៉ិច វណ្ណនុច**

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង។

## សិក្សាបន្ថែមតាមរយៈ

**YouTube:** YON YI OFFICIAL

**Facebook:** Ven Yon Yi

**Page:** Yon Yi page

# ឯកសារពិគ្រោះ

១.បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ (ជាភាសាខ្មែរ និងអង់គ្លេស)
២.វចនានុក្រមសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន ណាត**
៣.សទ្ទានុក្រមព្រះពុទ្ធសាសនា
៤.អភិធម្មត្ថវិភាវិនីដីកា
៥.ធម្មាវតារបូរាណដីកា
៦.ព្រះត្រៃបិដកជាភាសាខ្មែរ ព្រមទាំងអដ្ឋកថា
៧.បរមត្ថជោតិកៈ
៨.បរមត្ថទីបនី
៩.អានាបានទីបនី
១០. A Manual of Abhidhamma By Narada Maha Thera, 1979
១១.A Comprehensive Manual of Abhidhamma by Bhikkhu Bodhi, Reprinted 2010